DE CIVILISATION
INDIENNE
N° D. 2624

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ៧

ខែ ១, ២, ៣, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER
933

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព. ស. ២៤៧៩
គ. ស. ១៩៣៥

1935

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

# បញ្ជីរឿង

ទំព័រ


១— បុណ្យដង្ហែព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធ និងព្រះអរហន្តធាតុ ទៅដំកល់ក្នុងទីវត្តប្រាង្គណ៍ (ខង្គុំ) កំពង់ស្ពឺ . . . . . . . . . . . . . . ១

២ — រឿងបារ៉ឡាអាមនឹងយ៉ូសាហ្វាត់ ឬរឿងព្រះពុទ្ធក្នុងគម្ពីររបស់ សាសនាគ្រិស្ទៀង ក្រម្ការផុំ-ម៉ៅ ប្រែពីភាសាបារាំងមកជាភាសាខ្មែរ តាមសេចក្ដីកត់សំគាល់របស់លោក ឯដ.ហ៊ុក្ល . . . . . . . . . . . . . . . . . . ៩

៣— ដំណឹងខ្លះអំពីលោក ត.ហ.ម៉ូណូទ៍ កាលនៅធ្វើជារេស៊ីដង់ក្នុងស្រុកខ្មែរ និងរឿងពេញដែលលោករៀបរៀង . . . . . . . . . . . . . . . . . ២៤

៤— សាសនប្រវត្តិ ព្រះមហាពិទូរក្រសេមគន្ធរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ រៀបរៀង (តពីឆ្នាំទី ៦) . . . . . . . . . . . . . . . . . ៣៩

៥— រឿងទំនៀមទំលាប់ខ្មែរ — ១ ពិធីបន់សុំកូន. . . . . . . . . . . . . . . . . ៥៦

៦— ពាក្យព្រេងប្រដៅ ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះហរិរក្សរាមាឥស្សរាធិបតីព្រះអង្គដួង ដែលទ្រង់ត្រាស់បង្គាប់ឲ្យអ្នកប្រាជ្ញរាជបណ្ឌិតចារិកទុក ក្រម្ការ កង-ជា នៅកំពង់ធំផ្ញើមក. . . . . . . . . . . . . . . . . . . . . ៦៨

៧— រឿងព្រេងខ្មែរ ដែលមិនទាន់បោះពុម្ពផ្សាយៈ

១ រឿងប្រាជ្ញាសំណាងនិងផលទាំង ៣ អ្នកឲ្យទ្រព្យតែសព្វខ្លួន. . . . . . . . . . ៧១

២ រឿងស្រីភ្ញោកមាស. . . . . . . . . . . . . . . . . . . . . ៧៩


## រូបចំលាក់


ក្នុងវត្តព្រែកប្រណាក—វេលាដែលក្បួនដង្ហែរដល់ទៅមុខវត្តព្រែកប្រណាក គេនិមន្តព្រះកោដ្ឋ ទៅក្នុងព្រះវិហារ ដើម្បីឲ្យព្រះសង្ឃនិងគ្រហស្ថ នមស្សការ.. ២

រូបក្រៅរឿង ព្រះចេតិយ៍ធំ បញ្ចុះព្រះបរមសារីរិកធាតុព្រះសម្មាសម្ពុទ្ធ នៅពោធគយា (ឥណ្ឌា) . . . . . . . . . . . . . . . . . . . . ៥៦

# TABLE DES MATIÈRES


I. Cérémonie du transfert de Reliques Bouddhiques à la pagode Prang (Oudong), Kompong Speu, le 22 Avril 1934. 1

II. Barlaam et Josaphat ou l'histoire du Bouddha d'après une version chrétienne, traduit du Français en Cambodgien par Krommokar Choum-Mau, d'après la note de M. Ed. Foucaux. . . . . . . . . . . . . . . . . . . 9

III. Sasanapravatti ou l'Histoire des Religions, par Préas Maha Pitou Krasém pandit à la Bibliothèque Royale (suite) . . . . . . . . . . . . . . . . . . . . . . . 24

IV. Histoire d'une Vache racontée par M. G. Monod ancien Résident de France, précédée de quelques souvenirs relatifs à son séjour au Cambodge . . . . . 39

V. Coutumes Cambodgiennes. Cérémonie d'accomplissement de vœux pour avoir des enfants . . . . . . . . . . . . 56

VI. Conseils des Anciens, poème composé sur l'ordre de S. M. Ang-Duong et recueilli par Krommokar Kâng-Chéa, suivi d'un poème qu'il composa pour inviter ses compatriotes à se conformer aux conseils des anciens . . . . . . . . . . . . . . . . . . . . . . . 68

VII. Contes populaires cambodgiens inédits:

I° L'intelligence, le bonheur et le mérite d'une existence antérieure se vantent respectivement de leur vertu . . 71

II° Ruong Srey Kangok Méas ou l'histoire de la femme dénommée "Paon d'or" . . . . . . . . . . . . . . . . . 79


## ILLUSTRATIONS


Dans la pagode de Prek Pranak — au moment où le cortège arrive devant la pagode, l'urne contenant des Reliques Bouddhiques est transportée dans la pagode pour recevoir les hommages des fidèles . . . . . . . . . . . 2

Hors texte représentant le grand temple Bouddhique à Boudhagaya Indes . . . . . . . . . . . . . . . . . . . . 56

# អំពីការបុណ្យដង្ហែរ

ព្រះបរមសារីរិកធាតុនៃព្រះសម្ពុទ្ធជាម្ចាស់ នឹងព្រះអរហន្តធាតុទៅដំកល់ក្នុងទីវត្តប្រាង្គណ៌ (ឧដុង្គ) ខែត្រកំពង់ស្ពឺ ពីថ្ងៃ៩កើតខែពិសាខ ឆ្នាំចសំរឹទ្ធិស័ក ព. ស. ២៤៧៦ ត្រូវនឹងថ្ងៃ២២អាព្រីល ១៩៣៤ ។

# អំពីហេតុដែលបានព្រះបរមសារីរិកធាតុ

ព្រះបរមសារីរិកធាតុ ១ ព្រះអង្គ ព្រះឧត្តមមុនី អ៊ុំ-ស៊ូ បានប្រគេនមកលោកព្រះវិសុទ្ធិវង្ស ពាត ជាយូរហើយ ដើម្បីនឹងនិមន្តទៅដំកល់ទុកក្នុងទីវត្តប្រាង្គណ៌ ។

ម៉ាដឺម្វ័អាហ្វៀល ការប៉ឺឡែស ជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ទើបនឹងបានព្រះអរហន្តធាតុជាច្រើនអង្គពីស្រុកភូមាក្នុងឆ្នាំ ១៩៣៤ នេះដោយលោកអ្នកប្រាជ្ញ ១ អង្គឈ្មោះឧសុរិយអគ្គមហាបណ្ឌិត បានសុំអំពីសំណាក់ឧបាសិកាម្នាក់ឈ្មោះអហ្មាឡាយហើយបានជូនមកលោកអគ្គលេខាធិការដើម្បីឲ្យយកមកផ្សាយក្នុងកម្ពុជរដ្ឋនេះ ទុកជាបូជនីយវត្ថុជាភស្តុតាងនៃអ្នកកាន់ព្រះពុទ្ធសាសនា លោកអគ្គលេខាធិការក៏បានប្រគេន ព្រះអរហន្តធាតុ ៥ អង្គមកលោកព្រះវិសុទ្ធិវង្ស ពាត ដើម្បីឲ្យយកទៅដំកល់ទុកជាបូជនីយស្ថានក្នុងទីវត្តប្រាង្គណ៌(ឧដុង្គ) ។

# អំពីគ្រឿងដំកល់ព្រះសារីរិកធាតុ

ក្នុងវេលាមុននឹងដង្ហែរទៅនោះ ឋីប៉ូល-ប៉ោយ-និខ ជាឧបាសកធ្វើរាជការក្នុងក្រសួងរេស៊ីដង់ខ្មែរ ព្រមទាំងភរិយាជាឧបាសិកាឈ្មោះស៊ីសាក់ បានមកថ្វាយបង្គំព្រះបរមសារីរិកធាតុនឹងព្រះអរហន្តធាតុក៏កើតមានសេចក្ដីជ្រះថ្លាក្រៃពេក ហើយបានបរិច្ចាគទ្រព្យកសាងកោដ្ឋប្រាក់ ១ ។ កោដ្ឋប្រាក់នោះឆ្លាក់រម្ចេចជាក្បាច់យ៉ាងល្អះដិតបញ្ចុះដោយថ្នាំពណ៌ រាងសមល្អគួរឲ្យជាទីជ្រះថ្លាដល់ភ្នែកអ្នកមើលគ្រប់គ្នា ខាងក្នុងកោដ្ឋនោះ រចនាធ្វើជាត្របកផ្កាឈូកមានទងទ្រពីក្រោមធ្វើដោយមាសសុទ្ធ ត្រង់កណ្ដាលផ្កាឈូកដំកល់ព្រះបរមសារីរិកធាតុព្រះពុទ្ធ នៅប្របទងផ្កាឈូកដំកល់ព្រះអរហន្តធាតុទាំង ៥ ព្រះអង្គ ។ មិនតែប៉ុណ្ណោះ បានពាក់តែងធ្វើជាមញ្ជូសន៍ ៣ ថ្នាក់ប៊ិទរម្ចេចដោយក្បាច់ឆ្លាក់នឹងស្នាន់មានពណ៌ផ្សេង ៗ គ្នា ត្រង់លើថ្នាក់ទី ៣ មានធ្វើជារំភាយគ្របពីលើ វិចិត្ររចនាដោយសំពត់យ៉ាងស្ដើងមានសាច់ដិតស្និទ្ធយ៉ាងល្អ មានពណ៌ផ្សេងៗគ្នាត្រង់ជាយសំពត់នោះសុទ្ធតែប្រក់បដោយក្បាច់ផរធ្វើដោយប្រាក់ ត្រង់ជ្រុងទាំង៤សុទ្ធ

តែចងដោយរំយោលដែលធ្វើដោយសរសៃប្រាក់ ។ កន្លែងដែលដំកល់ព្រះកោដ្ឋនោះ ត្រង់កណ្ដាលថ្នាក់ទី ៣ មានគោតចម្រមាសដាក់ពញ្ញក់ទ្រពីខាងក្រោម ។

ឌី ប៊ូល-ហោយ-និន ឧិងឧបាសិកា ស៊ី សាក់ ជាអ្នកដើមគំនិតក្នុងការបុណ្យនេះ ។

# អំពីរបៀបបុណ្យ

នៅថ្ងៃ ៨ កើតខែពិសាខឆ្នាំចសំរឹទ្ធិស័ក ព.ស. ២៤៧៦ គឺថ្ងៃ ២១ អាព្រិល ១៩៣៤ វេលាម៉ោងពីយប់ និមន្តព្រះសង្ឃចំរើនព្រះបរិត្តនៅទីកុដិព្រះឧត្តមមុនី អ៊ុំ-ស៊ូ វត្តឧណ្ណាលោមភ្នំពេញ រួចនិមន្តព្រះធម្មកថិក ២ អង្គទេសនាបុប្ផាវិសជ្ជនា ។

ថ្ងៃ ៩ កើតខែឆ្នាំដាមួយគ្នា ត្រូវនឹងថ្ងៃ ២២ អាព្រិល ១៩៣៤ វេលាម៉ោង ២ រសៀល រៀបរថយន្ត ជាក្បួនហែរនៅមុខវត្តឧណ្ណាលោមក្រុងភ្នំពេញ រថយន្តនីមួយ ៗ សុទ្ធតែប្រដាប់ដោយទង់ជ័យនឹងផ្កាភ្ញីផ្សេង ៗ :

រថយន្តមុខបំផុត ពួកទាហានក្រុមរក្សាស្រុកចំនួន ៣០ នាក់លេងភ្លេងនូបានឹងភ្លេងខ្សែ
រថយន្តបន្ទាប់ ដំកល់ព្រះសារីរិកធាតុព្រះពុទ្ធនឹងព្រះអរហន្តធាតុ
រថយន្តទី ៣ ពួកភ្លេងបារាំង នឹងពួកឧបាសកខ្លះ
រថយន្តជាលំដាប់មក ភិក្ខុសាមណេរគង់
រថយន្តជាលំដាប់ពីនោះមកទៀតមានចំនួនជាច្រើន សុទ្ធតែពួកឧបាសកឧបាសិកា

កាលដែលដង្ហែរចេញពីភ្នំពេញទៅនៅវេលារសៀលម៉ោង ២ នឹង ១៥ មីនុតទៅតាមផ្លូវបាត់ដំបង កំពង់ហ្លួង កាលដែលដល់ទៅវត្តព្រែកបារាំង នៅកំពង់ហ្លួងដែលពួកអ្នកស្រុកដើងវត្តរង់ចាំទទួល សូមនិមន្តព្រះសារីរិកធាតុនេះទៅដំកល់ក្នុងវិហារ ហើយព្រះភិក្ខុសង្ឃនឹងឧបាសកឧបាសិកាមានចំនួនច្រើននាំគ្នាធ្វើសក្ការបូជាដោយសេចក្ដីជ្រះថ្លា ទើបដង្ហែរចេញពីនោះទៅទៀត ដល់ទៅវត្តព្រែកប្រណាក កំពង់ហ្លួងឈប់ចង្អុលនៅទីមុខវត្ត ព្រោះក្នុងទីវត្តនោះ ព្រះភិក្ខុសង្ឃមានលោកគ្រូសូត្រស៊ុំ ជាដើមនឹងឧបាសកឧបាសិកា បានដឹងដំណឹងពីថ្ងៃមុន ក៏បានរៀបចំតាមផ្លូវនៅមុខវត្តរហូតដល់ក្នុងវិហារ ប្រដាប់តាក់តែងដោយទង់ជ័យនឹងផ្កាឈើ រង់ចាំទទួលវេលាដែលក្បួនហែរដល់ទៅមុខវត្តភ្លាម ព្រះសង្ឃនឹងឧបាសកឧបាសិកានៅស្រុកនោះខ្លះ មកពីស្រុកឆ្ងាយ ៗ ខ្លះ ក៏និមន្តព្រះបរមសារីរិកធាតុដង្ហែរចូលទៅដំកល់ក្នុងវិហារ ថ្វាយទៀនធូបនឹងផ្កាភ្ញី ហើយធ្វើសក្ការបូជាទាំងអស់គ្នា ។

[illegible]

[illegible]



[illegible]

[illegible]

លុះរួចកិច្ចក្នុងទីវត្តព្រៃកប្រិណាកហើយ ទើបរៀបជាក្បួនហែរដង្ហែរចេញពីនោះបំពោះទៅវត្តប្រាង្គណ៌ ក្នុងវេលាដែលដង្ហែរទៅនោះ ព្រះសង្ឃនឹងមនុស្សប្រុសស្រីដែលដង្ហែរទៅ មានចំនួនច្រើនក្រៃពេក គិតតែត្រឹមរថយន្តចំនួន ៤១ រថយន្តអ្នកដែលជិះរទេះសេះជិះរ៉ឺម៉ក នឹងអ្នកដែលដើរដោយជើង ពុំអាចគណនាឲ្យសព្វគ្រប់បានឡើយ ក្នុងរវាងផ្លូវពីកំពង់ហ្លួងដល់ វត្តប្រាង្គណ៌ (ឧដុង្គ) ចំនួន ៦ គីឡូម៉ែត្រសឹងតែជាសពាសដោយរថយន្ត រទេះសេះ រ៉ឺម៉កប៊ីស៊ីក្លែត នឹងមនុស្សដើរ ។

ក្នុងពេលនោះក៏កើតជាអស្ចារ្យ អាកាសនឹងមេឃដែលកំពុងតែក្ដៅ ក៏ក្លាយទៅជាត្រជាក់ បណ្ដាលឲ្យមានពពកបិទបាំងព្រះអាទិត្យជាច្រើនស្រទាប់ មានអាការដូចជាមេឃនឹងធ្លាក់ចុះមកសង្កត់លើក្បួនហែរ ។

លុះដង្ហែរដល់ទៅទីវត្តប្រាង្គណ៌នៅវេលារសៀលម៉ោង៤ នឹង១៥ មីនុត កាលដែលដល់ទៅភ្លាម មេឃក៏បណ្ដាលឲ្យធ្លាក់ទឹកភ្លៀងយ៉ាងល្មមបំព្រំឲ្យជោកដី អាកាសក៏ត្រជាក់ល្អ គួរជាទីជ្រះថ្លាដល់អ្នកដង្ហែរគ្រប់គ្នា លុះស្ងាតភ្លៀងហើយ ទើបនិមន្តព្រះសារីរិកធាតុដង្ហែរប្រទក្សិណវិហារ៣ជុំរួចចូលទៅដំកល់ក្នុងកណ្ដាលវិហារ ព្រះសង្ឃគង់ម្ខាង ឧបាសកឧបាសិកាអង្គុយម្ខាងពេញណែនក្នុងវិហារ អ្នកដែលចូលទៅក្នុងវិហារមិនចុះ ក៏នៅសាយភាយជាសពាសខាងក្រៅជាច្រើន ចំនួនមនុស្សទាំងអស់នោះ បើរួបរួមដោយស្មានប្រមាណជាជាង ២១០០ នាក់ ចំណែកអស់លោកមន្ត្រីបារាំងក៏អញ្ជើញទៅជួយទទួលអំណរជាច្រើន គឺលោកសាំងមីរេស៊ីដង់កំពង់ស្ពឺ ម៉ាដឹម្ទំអាហ្វៀល ការប៊ីឡែលជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ លោកគូឡូណែល (លោកស័ក្តិ ៥) លោកកម្មង់ដង់ (លោកស័ក្តិ ៤) លោកអាំងស្ប៉ិកទ័រជានាយកលើពួកទាហានក្រុមរក្សាស្រុក ព្រមទាំងម៉ាដាម លោកឡឺសែហ្វជាចាងហ្វាងក្រុមសមាគមខាងដំឡូញ ព្រមទាំងម៉ាដាម លោកសង់ដាមនៅកំពង់ហ្លួង ព្រមទាំងម៉ាដាម នឹងបារាំងឯទៀតប្រុសខ្លះស្រីខ្លះ ។ លោកមន្ត្រីបារាំងទាំងនោះបានកាន់ផ្កាគ្រប់គ្នា ចូលទៅបូជាព្រះបរមធាតុ ហើយអញ្ជើញចេញមករង់ចាំនៅខាងក្រៅ លុះព្រះសង្ឃ នឹងឧបាសកឧបាសិកាធ្វើមស្សការបូជារួចស្រេច អស់លោកមន្ត្រីបារាំងទាំងអស់អញ្ជើញចូលទៅក្នុងវិហារម្ដងទៀតក្នុងទីចំពោះមុខព្រះបរមធាតុ នឹងជាកណ្ដាលនៃពពួកព្រះភិក្ខុសង្ឃនឹងឧបាសកឧបាសិកា ។ ក្នុងពេលនោះ ថៃ ប៉ុល-ហោយ-និន ក្រោកឈរឡើងថ្លែងសុន្ទរកថាថា :

សូមពិតព្រះករុណាគ្រប់អង្គ

សូមជំរាបលោកប្រេស៊ីដង់ លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ និងអស់លោកអ្នកទាំងឡាយ ។

យើងខ្ញុំទាំងពីរនាក់ប្ដីប្រពន្ធមានសេចក្ដីត្រេកអរជាពន្លឹក ចំពោះអស់លោក-អ្នក ដែលបានអញ្ជើញមកក្នុងទីសន្និបាតនេះហើយបានគោរពដល់ព្រះបរមសារីរិកធាតុ ព្រះសម្ពុទ្ធព្រមទាំងអរហន្តធាតុ ដែលដំកល់នៅលើមញ្ជូសដ៏ប្រកបដោយក្បាច់រចនាមានពណ៌ដ៏ឧភាសរុងរឿង ។

ឱកាសនេះខ្ញុំសូមថ្លែងសុន្ទរកថារបស់ខ្ញុំ ជំរាបជូនអស់លោកអ្នកទាំងឡាយ ។

រីព្រះបរមសារីរិកធាតុព្រះសម្ពុទ្ធនិងព្រះអរហន្តធាតុនេះ កាលដើមឡើយព្រះតេជព្រះគុណ ព្រះវិសុទ្ធិវង្ស ពាត តាំងផ្ដួចផ្ដើមឡើង គិតបំរុងនឹងដង្ហែរមកដំកល់ក្នុងវត្តប្រាង្គណ៍នេះដោយស្ងាត់ៗតែបន្តិចបន្តួចទេ ពុំបានគិតដោយមាំមួនជាឧឡារិកអធិកអធំដូច្នេះឡើយ ប៉ុន្តែជាកុសលរបស់ខ្ញុំ និងភរិយាព្រមទាំងបុត្រាបុត្រីរបស់ខ្ញុំ បណ្ដាលឲ្យយើងខ្ញុំជូនដំណឹងដល់អស់លោកអ្នកទាំងឡាយឲ្យកើតមានសទ្ធាជ្រះថ្លាឡើង ដោយយើងខ្ញុំយល់ថា ធម្មតាព្រះបរមសារីរិកធាតុព្រះពុទ្ធនិងព្រះអរហន្តធាតុពិតមែននោះ មិនសមគួរនឹងដង្ហែរមកដោយលបលាក់ស្ងាត់កំបាំងឡើយ គួរតែធ្វើឲ្យលាន់ឮផ្សាយដំណឹងទូទៅដល់អស់លោកអ្នកដែលកាន់ព្រះពុទ្ធសាសនាជាហេតុនឹងឲ្យបានថ្កុំថ្កើងរុងរឿងឡើងទើបសមគួរ ។

សេចក្ដីនេះខ្ញុំនិងភរិយាខ្ញុំទាំងពីរនាក់ គិតព្រមព្រៀងគ្នាបរិច្ចាគទ្រព្យកសាងព្រះកោដ្ឋនិងគ្រឿងមញ្ជូសព្រមទាំងចាត់ចែងការបុណ្យនេះឲ្យសមគួរដល់គុណសម្បត្តិនៃព្រះបរមសារីរិក-ធាតុនិងព្រះអរហន្តធាតុ ឥឡូវនេះយើងខ្ញុំសូមឧទ្ទិសចំណែកបុណ្យជូនដល់លោកអ្នកដែលអញ្ជើញមកប្រជុំនៅទីនេះ សូមទទួលអនុមោទនាយកផលានិសង្ស ហើយសូមជូនដល់លោកអ្នកដ៏មានគុណគឺមាតាបិតានៃយើងទាំងអស់គ្នាដែលអញ្ជើញទៅកាន់បរលោកនាយក្ដី នៅរស់ក្ដីសូមឲ្យបានសំរេចដូចសេចក្ដីប្រាថ្នា កាលបើបានអនុមោទនារួចហើយសូមបញ្ចេញវាចាថាសាធុៗ ឲ្យព្រមគ្នា ។

ឯចំណែកបុណ្យដែលចែកជូនដល់លោកអ្នកទាំងអស់គ្នានេះ សូមឲ្យឃើញច្បាស់ក្នុងបច្ចុប្បន្ននេះផង ទោះឯអនាគតសូមឲ្យបានសំរេចសម្បត្តិសួគ៌ សម្បត្តិព្រះនិព្វាន ។

ម្យ៉ាងទៀត ដោយអំណាចកុសលផលបុណ្យនេះ យើងសូមឲ្យបានព្រះពុទ្ធសាសនារុងរឿង សូមព្រះករុណាជាម្ចាស់ជីវិតលើត្បូង និងអស់លោកកុម្ម៉ង់យសេនាបតីព្រមទាំងរាជការ

ប្រតិកត្តភគ៌បាភាំងសែស បានដំកល់នៅក្នុងសិរីសួស្តីមង្គលតទៅ ។ ម្យ៉ាងទៀតយើងសូមឲ្យលោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ នឹងអស់លោកអ្នកប្រាជ្ញគ្រប់អង្គ មានលោកគ្រូបាងហ្វាងសាលាបាឡីជាន់ខ្ពស់ជាដើម បានសេចក្ដីសុខចំរើនអស់កាលជាអង្វែងតទៅ ។

ទីបំផុតនេះខ្ញុំនឹងភរិយាព្រមទាំងបុត្ររបស់ខ្ញុំដែលមានសទ្ធាជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាខំប្រឹងកសាងកុសលផ្សេង ៗ នឹងប្រព្រឹត្តនូវធម៌ដ៏ប្រសើរ តាំងប្រឹងធ្វើកាយវាចាចិត្ត ឲ្យឃ្លាតចេញពីធម៌ជាអកុសល យើងខ្ញុំសូមតាំងប្រាថ្នា ចំពោះមុខព្រះបរមសារីរិកធាតុ ក្នុងកណ្ដាលនៃព្រះភិក្ខុសង្ឃ នឹងឧបាសកឧបាសិកា បើខ្ញុំអន្ទោលទៅកើតក្នុងជាតិណា ៗ សូមកុំប៉ះពាល់ជិតជាប់ទៅដោយបាបធម៌ឡើយ សូមឲ្យបានជាអ្នកបរិសុទ្ធល្អប្រពៃ លុះដល់ព្រះពុទ្ធទ្រង់ព្រះនាមអរិយមេត្រៃយ ត្រាស់ឡើងក្នុងកាលជាអនាគត យើងខ្ញុំសូមឲ្យបានសម្រេចមគ្គផលដល់និព្វានបានជាអគ្គសាវកដ៏ប្រសើរ នៃព្រះអរិយមេត្រៃយអង្គនោះកុំបីឃ្លាតឡើយ ។

គ្រាកាលដែល ជី ប៉ូល-ប៉ោយ-និន ប្រកាសសេចក្ដីនេះចប់ហើយព្រះសង្ឃនឹងឧបាសកឧបាសិកាទាំងអស់ជួយឲ្យពរសព្ទសាធុការថា សាធុ ៗ ព្រមគ្នា ។

លំដាប់ពីនោះមក ម៉ាជីម៉ូអាហ្វៃល ការប៉ុឡែស បានថ្លែងសេចក្ដីយ៉ាងសង្ខេបថា ខ្ញុំមានសេចក្ដីត្រេកអរនឹងសេចក្ដីពេញចិត្តជាទីបំផុត ចំពោះអស់លោកអ្នករាល់គ្នា ដែលបានជួបជុំគ្នាធ្វើការកុសលក្នុងពេលនេះ ដោយខ្ញុំឃើញច្បាស់ថា ជនអ្នកកាន់ព្រះពុទ្ធសាសនា ក្នុងស្រុកខ្មែរនេះ កាលពីដើមពុំសូវមានកេរ្តិ៍ឈ្មោះផ្សាយទូទៅដល់ប្រទេសធំ ៗ ដែលកាន់ព្រះពុទ្ធសាសនាដូចគ្នានោះឡើយ ក៏សម័យនេះមានកេរ្តិ៍ឈ្មោះផ្សាយទូទៅដល់ប្រទេសធំ ៗ ដូចជាស្រុកភូមាជាស្រុកគេកាន់ព្រះពុទ្ធសាសនាយ៉ាងមាំមួនណាស់ កាលពីដើមគេពុំដឹងជាស្រុកខ្មែរនេះមានអ្នកកាន់ព្រះពុទ្ធសាសនាមាំមួនចេះដឹងច្រើនទេ ទើបតែក្នុងសម័យនេះគេដឹងប្រាកដថាស្រុកខ្មែរមានអ្នកចេះដឹងច្រើនទាំងអ្នកដែលប្រព្រឹត្តប្រតិបត្តិតាមពុទ្ធឱវាទក៏មាំមួន ដោយហេតុនេះហើយបានជាព្រះសារីរិកធាតុព្រះពុទ្ធនឹងព្រះអរហន្តធាតុដែលមានខ្លះក្នុងស្រុកភូមា ក៏ត្រឡប់ផ្សាយនឹងអណ្ដែតចូលមកប្រតិស្ឋានក្នុងស្រុកខ្មែរ នេះហើយដែលនាំឲ្យឃើញច្បាស់នឹងភ្នែកជាភស្តុតាងរបស់អ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងមាំមួន ។ ខ្ញុំសូមឲ្យអ្នករាល់គ្នាទាំងអស់បាន សេចក្ដីសុខនឹងចំរើនឥតអាក់តរៀងទៅ ។ លុះចប់ហើយ លោកឡឺរេស៊ីដង់កំពង់ស្ពឺ បានមានប្រសាសន៍ថា ព្រះករុណាគ្រប់អង្គ នឹងអស់លោកអ្នកទាំងឡាយក្នុងវេលាបួន-ប្រាំថ្ងៃមុននេះ លោកព្រះវិសុទ្ធិវង្សបាត បានទៅឲ្យដំណឹងខ្ញុំអំពីការបុណ្យដង្ហែព្រះបរមសារីរិកធាតុនេះ ខ្ញុំក៏មានចិត្តត្រេកអរណាស់

ទើបខ្ញុំបានមកជួយក្នុងការបុណ្យនេះដោយសេចក្តីពេញចិត្ត ខ្ញុំសូមជួយសំបូងសង្រ្គង សូមឲ្យទេវតាទាំង ១ ហ្នឹងលោកធាតុជួយថែរក្សាលោកអ្នកទាំងអស់គ្នា ឲ្យបានសេចក្តីសុខតាំងពីក្នុងបច្ចុប្បន្ននេះទៅ ។

ម្យ៉ាងទៀតខ្ញុំមានសេចក្តីសង្ឃឹមថា អស់លោកអ្នកទាំងអស់គ្នានឹងបានប្រព្រឹត្តត្រឹមត្រូវតាមគន្លងធម៌ក្នុងព្រះពុទ្ធសាសនាដោយពិត កាលបើដូច្នេះព្រះធម៌ដែលអស់លោកអ្នករាល់គ្នាប្រព្រឹត្តកាន់ត្រឹមត្រូវហើយ នឹងបានជួយថែរក្សាលោកអ្នករាល់គ្នាឲ្យបានសេចក្តីសុខចំរើនតរៀងទៅ ។ លុះហើយកិច្ចប៉ុណ្ណេះហើយ អស់លោកមន្រ្តីបារាំងព្រមទាំងព្រះសង្ឃ នឹងឧបាសកឧបាសិកាខ្លះដែលមកពីទីដ៏ឆ្ងាយ ៗ ក៏ថយចេញអំពីវិហារត្រឡប់ទៅកាន់និវេសនស្ថានរបស់ខ្លួនជាការស្រេច ១ លើកប៉ុណ្ណេះ ។

ក្នុងឱកាសបុណ្យនោះ ឃុនព្រះម្ចាស់ បុប្ផារលក្ខណ៍(តាត)នឹងលោកអ្នកឧកញ៉ាភជសម្បត្តិ យិន នឹងអ្នកស្រី ប៊ុក ជាបិតា មាតា បានអញ្ជើញទៅដែរ ដើម្បីជួយឧបត្ថម្ភក្នុងកិច្ចបុណ្យនោះដរាបដល់ហើយស្រេច ។ កាលពីល្ងាចម៉ោង ៦ កន្លះឃុនព្រះម្ចាស់បានតាំងស្ត្រីល្ខោនទៅរាំថ្វាយ ព្រះបរមសារីរិកធាតុក្នុងវិហារជាការបួងសួងតាមទំនុកដែលបាននិពន្ធក្នុងខាងក្រោយសុំឲ្យបានសេចក្តីសុខចំរើន ចំនួន ២៤ មីនុតក៏ហើយស្រេច ។ ដល់វេលាយប់ម៉ោង ៧ កន្លះនិមន្តព្រះសង្ឃចំរើនព្រះបរិត្ត លុះចប់ព្រះបរិត្តហើយ ក៏អុចកញ្ជ្រូចពោហ៍ជាការរុងរឿង ដល់ម៉ោង៩ យប់ និមន្តលោកគ្រូព្រះសិរីសម្មតិវង្សបានឡើងសាលាបាឡីជាន់ខ្ពស់ សំដែងធម៌ទេសនាក្នុងវិហាររហូតដល់ម៉ោង ១២ យប់ចប់ ។

ចំណែកឃុនព្រះម្ចាស់ ក៏បានបាត់ចែងពួកស្ត្រីល្ខោនឲ្យរាំក្នុងវេលាយប់នោះក្នុងទីសាលាធំ ជាការសម្ពោធបុណ្យនោះតាំងពីម៉ោង ៨ យប់ ដរាបដល់ម៉ោង ២ យប់ សង្ខេប ។ ក្នុងឱកាសបុណ្យនោះតាំងពីពេលថ្ងៃដរាបដល់យប់ទល់នឹងពេលជិតភ្លឺ មានមនុស្សប្រុសស្រីដើរដាសពាសពេញក្នុងទីវត្ត ពុំមានថយចេញទៅកាន់ទីណាឡើយ ដោយសេចក្តីជ្រះថ្លា នឹងព្រះបរមសារីរិកធាតុផង នឹងការស្តាប់ធម៌ទេសនាផង នឹងការបុណ្យនោះដែលមានគ្រឿងតាក់តែងសំរាប់ធ្វើចិត្តឲ្យជ្រះថ្លា ឲ្យរីករាយសប្បាយផង លុះពេលភ្លឺស្វាងឡើង បុណ្យនោះក៏ហើយស្រេចប៉ុណ្ណេះ ។

# ទំនុកបង្ស្លង(ពាក្យ៧)

យើងខ្ញុំបង្គំគុណត្រៃរតន៍ គឺគុណព្រះពុទ្ធនឹងព្រះធម៌ ព្រមទាំងព្រះសង្ឃសីលបវរ នឹងទេពនិករស្ថានសួគ៌ ។ ថ្ងៃនេះជាថ្ងៃមានសួស្តី មហាជនប្រុសស្រីមកជួបជុំ ហែរអង្គព្រះធាតុដ៏ឧត្តម នៃព្រះបរមទសពល នឹងអង្គព្រះធាតុនៃអរហន្ត ប្រសើរលោកល្អនិរមល ដោយពួករថយន្តច្រើនសោភសល់ មកតាំងដំកល់ក្នុងវត្តប្រាង្គណ៍ ដោយតេជះគុណដែលយើងខ្ញុំ បានមកជួបជុំធ្វើកសាង កុសលសីលទានជាច្រើនយ៉ាង សូមឲ្យសំណាងនិងថ្លៃថ្លា មកជួយឧបត្ថម្ភយ៉ាងជាប់ផុត សូមឲ្យព្រះពុទ្ធសាសនា ចំរើនរុងរឿងដូចសុរិយា កណ្តាលមេឃាភ្លឺសព្វឋាន សូមតេជះគុណព្រះត្រៃរតន៍ ចូរជួយកំចាត់កុំឲ្យមាន រោគាព្យាធិឲ្យក្សេមក្សាន្ត កើតសុខសម្រាន្តយើងរាល់គ្នា យើងខ្ញុំបួងសួងបុណ្យកុសល ដែលបានដំកល់រាល់វេលា សូមជួយជ្រោមជ្រែងជនទានា កើតសុខរាល់គ្នាសព្វកាលហោង ។ះ៚—

### រឿងបាវឡាអាមនិងយ៉ូសាហ្វាត់ ឬរឿងព្រះពុទ្ធ ១៤
### ដែលមានក្នុងគម្ពីរពួកគ្រេស្ទៀន ៗ

ក្រមការ ជុំ-ម៉ៅ ប្រែចេញពីភាសាបារាំងសែសមកជាភាសាខ្មែរ ។

គឺក្នុងខាងដើមនៃបរិច្ឆេទនេះហើយ ដែលមានប្រទះឃើញក្នុងសៀវភៅ ដែលមានចំណងជើងថា បាវឡាអាមនិង យ៉ូសា-ហ្វាត់ នោះមានភាពទំនងដូចគ្នាយ៉ាងច្រើន នឹងរឿងលលិតវិស្តារ សេចក្តីនេះនាំឲ្យបញ្ជាក់បាន អ្នកតែងសៀវភៅជាភាសាក្រិក ក្នុងរវាងឆ្នាំ៧០១ នោះបានដឹងរឿងរបស់ព្រះសម្មាសម្ពុទ្ធសក្យមុនី ដោយសេចក្តីប្រែជាភាសាអារ៉ាប ឬជាភាសាប៉ែរ្ស ឬក៏បានដឹងដោយរឿងដំណាលនិយាយនៃអ្នកដំណើរ ។ សាំងសង់នៅស្រុកជាម៉ាស់ ក៏អាចបានស្គាល់គម្ពីរលលិតវិស្តារនេះ ដោយដំណាលនិយាយនៃពួកអ្នកដំណើរជាតិក្លិង្គផង នឹងដោយក្បួនខ្នាតព្រះពុទ្ធសាសនាដែលខ្ចាត់ភ្លាត់ទៅប្រទេសក្រៅ ៗ ផង ដោយអំណាចសេចក្តីបៀតបៀននៃសាសនាឯទៀតដល់ព្រះពុទ្ធសាសនា ហើយអ្នកដែលគេបចេញពីស្រុកនេះ នាំយកគម្ពីរ

លលិតវិស្តារនេះទៀងផង ។ សេចក្ដីប្រៀបធៀបពាក្យក្រិកក្នុងសៀវភៅបារ៍ឡាអាម និងយ៉ូសាហ្វាត់ ជាមួយនឹងពាក្យសំស្ក្រឹតក្នុងគម្ពីរក្លឹង នាំឲ្យលោកម៉ាក់ម្យុល្លែរពោលថា គេស្មើរតែនឹងជឿថា សាំងសង់នៅស្រុកជាម៉ាស់ មានគម្ពីរលលិតវិស្តារនៅចំពោះមុខលោក ក្នុងស្ថាននេះអ្នកតែងរឿងបារ៍ឡាអាមនឹងយ៉ូសាហ្វាត់ ទំនងជាបានមើលគម្ពីរសំស្ក្រឹតយ៉ាងវត់មាត់ សេចក្ដីនេះនាំឲ្យមានសង្ស័យណាស់ ។

ប៉ុន្តែយើងត្រូវបណ្ដោយឲ្យសាស្ត្រាចារ្យ ម៉ាក់ម្យុល្លែរនិយាយប៉ុះ ។

មានមនុស្សតិចណាស់ ដែលមានសេចក្ដីសង្ស័យនឹងសង្ស្ប-វាជមៅវត្តកុត្តលិក ថាជាអ្នកនាំយករឿងវ៉ារ ពីបូព៌ាប្រទេសទៅក្នុងបច្ចិមប្រទេស ។ ប៉ុន្តែរឿងនេះវាជួប្ចេះមែន ។

នៅក្នុងព្រះបរមរាជវាំង ខាលីហ្វ អ័លម៉ងស្ល ដែលអ័បជាល្ងះអ៊ិប្ន អ័លមោកាហ្វា កំពុងប្រែរឿង កាលីឡានឹងឌិម្នា ពីភាសាប៉ែហ្សានមកជាភាសាអារ៉ាប ក្នុងកាលនោះមានអ្នកកាន់សាសនាគ្រិស្តៀងម្នាក់ឈ្មោះសែរ៍ស៊ីយុស ដែលមកនៅធ្វើជានាយ

ឃ្លាំងស្តេចជាច្រើនឆ្នាំហើយ ។ តាយឃ្លាំងនេះមានកូនប្រុស១ ហើយបានបង្ហាត់បង្រៀនចំណេះវិជ្ជាយ៉ាងស្ទាត់ជំនាញតាមជំ-នាន់ក្នុងសម័យនោះ អាចារ្យធំរបស់កុមារនេះ គឺជាអ្នកបួសជាតិអ៊ីតាលៀន ឈ្មោះកុស្មាសដែលពួក សារ៉ាស៊ិន ចាប់យកទៅដាក់គុក ហើយលក់ទៅឲ្យធ្វើខ្ញុំកញ្ជះគេនៅស្រុកប៉តដាទ ។

ជាក្រោយដែលសែរស៊ុយុសមរណភាពទៅ កុមារកូននោះបានធ្វើការជំនួសអាពុក ហើយឡើងជាអធិបតីក្រុមប្រឹក្សាការរបស់ស្តេច អ័លម័នសួ ។ ប៉ុន្តែមិនបាននៅយូរប៉ុន្មានក្នុងព្រះបរមរាជវាំងឡើយ ព្រោះអំណាចគំនិតអ្នកបួសអ៊ីតាលៀនជាអាចារ្យនោះចាប់ជាប់ដល់ស្មារតីរបស់សិស្ស លុះត្រាតែនាំឲ្យបោះបង់ភោគយសវាសហោល បេញទៅផ្លូងវេរនឹងការសិក្សានឹងការបំរើនមេត្តាភាវនា ហើយនឹងការដែលជាកុសលផ្សេងៗ បានទៅតាំងក្នុងអារាម ១ ឈ្មោះសាំង-សាបា នៅជិតយេរុយសាឡិម ហើយបានផ្សាយការប្រាជ្ញរបស់លោកយ៉ាងសំខាន់ក្នុងផ្លូវសាសនា មានសម្តែងនូវជំនឿរបស់លោកជាដើម ។ អ្នកបួសនេះក៏ល្បីល្បាញមានអំណាចជាសំឡាក់សំខាន់ក្នុងផ្លូវ

សាសនា ក្នុងអារាមក័ត្តលិកនៅប្ញពាំប្រទេស មិនតែប៉ុណ្ណោះ លោកមានកន្លែងនៅក្នុងបំណោមពួកព្រះអរហន្តក័ត្តលិក ក្នុងអារាមក្នុងប្ញពាំប្រទេសនឹងបច្ចិមប្រទេសថែមទៀតផង ។ លោកតាំងឈ្មោះលោកថា "សង់" ហើយដោយលោកមានកំណើតកើតជានៅស្រុកដាម៉ាស់ ដែលជាទីក្រុងសម្រាប់ស្តេចតៗមក នោះឈ្មោះរបស់លោកបានស្គាល់ក្នុងពង្សាវតារថា សង់នៅដាម៉ាស់ ។ អ្នកបួសនេះទំនងជាភាសាអារ៉ាប ហើយប្រហែលជាបេះប៉ៃរ្យានផង ឯបំណោះខាងភាសាក្រិកយ៉ាងសំខាន់របស់លោកនោះ នាំឲ្យលោកបានបញ្ញត្តនាម ជាភាសាក្រិកថា "គ្រីសរ៉ូអាសប្រែថាដែលបណ្តោយឲ្យហូរមាស(បេញពីមាត់)។ លោកបានជាអ្នកមាននាមយ៉ាងល្បីល្បាញឡើងក្នុងការការពាររូបសំរាប់គោរពផ្សេងៗ នឹងក្នុងការដែលជាខ្មាំងសត្រូវយ៉ាងក្លាហាននឹងព្រះចៅរាជាធិរាជ ឡេអុងលីសូរៀន កាលពីក្នុង គ.ស.៧២៦ឆ្នាំ ។ ក្នុង១ជាតិរបស់អ្នកបួសនេះ លំបាកនឹងបញ្ជាក់រឿងរ៉ាវនឹងពង្សាវតារឲ្យជាដាប់ខាតណាស់ ប៉ុន្តែកាលក្នុងរជ្ជកាល ខាលីហ្វ៍អ័លម័នសួ នោះលោកកាន់កាប់ដំណែង

ក្រសួងយ៉ាងប្រសើរក្នុងព្រះបរមរាជវាំង ហើយដែលលោកតាំង ទទឹងនូវរបៀបរដ្ឋប្រសាសន៍នូបាយ នៃព្រះចៅរាជាធិរាជ ឡើងអំង ដែលជាប្រសាសន៍នូបាយ កំចាត់ចេញនូវរូបសំរាប់គោរពបូជា ទាំងអស់ ហើយក្នុងសម័យនោះហើយដែលលោកតាំងសរ សេររឿងខាងផ្លូវប្រាជ្ញក្នុងការសាសនា ដែលយើងមិនបាច់ត្រូវ សង្ស័យក្នុងរឿងនេះ ។

ក្នុងសៀវភៅឬការដែលគេទុកជាក់ជាស្នាដៃអ្នកបួសនេះគឺរឿង បារ៍ឡាអាមនឹងយ៉ូសាហ្វាត់ ។ មានការជជែកជេញដោលគ្នា ជាច្រើន ដើម្បីនឹងសម្រេចបញ្ជាក់ថាសៀវភៅនេះ ជាអ្នកនេះ សរសេរមែនឬមិនមែន ។ ឯកិច្ចធុរៈរបស់យើងក្នុងវេលានេះ ទោះបីរឿងនេះជាស្នាដៃរបស់លោកសង់នៅដាម៉ាស៍ក្តី ឬក៏ជា ស្នាដៃរបស់អ្នកបួសក្រៅចៀងឯទៀតក្តី ក៏ទំនងដែលនាំឲ្យរិះគន់ ដល់អ្នកសរសេរនោះ ហាក់ដូចជាមានស្លូបស្ងើងណាស់ ។

"....រឿង បារ៍ឡាអាម នឹងយ៉ូអាសាហ្វ៍ ឬ យ៉ូ-សាហ្វាត់ (តាមដែលហៅធម្មតា) រួមសេចក្តីយ៉ាងខ្លីទៅថា ដូច្នេះ ។ ស្តេច ១ អង្គក្នុងស្រុកឥណ្ឌា ដែលជាសត្រូវនឹងជា

អ្នកបៀតបៀនពួកគ្រិស្ទៀង មានព្រះរាជបុត្រា ១ អង្គ ។ ពួកហោរា ថ្វាយទំនាយថា ព្រះរាជបុត្រានោះនឹងបានជាអ្នកជឿសាសនា ១ ថ្មី ។ ក្នុងវេលានោះព្រះវររាជបិតាទ្រង់តាំងបាត់ការប្រយ័ត្នគ្រប់បែបយ៉ាង ដើម្បីបង្ខាំងព្រះរាជកុមារកុំឲ្យប្រទះឃើញនូវហេតុភេទជាទុក្ខវេទនា ហើយធ្វើឲ្យឃើញតែកិច្ចការជាទីនាំឲ្យមានសេចក្ដីតម្រេកត្រេកត្រអាលរីករាយ ។ ប៉ុន្តែមានតាបសគ្រិស្ទៀងមួយបានចូលទៅជិតព្រះរាជកុមារ ហើយបានបង្ហាត់បង្រៀននូវធម៌អាថ៌ខាងសាសនាកាតូលិក ។ ព្រះរាជកុមារមិនគ្រាន់តែចូលកាន់សាសនានេះឡើយ គឺថែមទាំងបោះបង់ទ្រព្យសម្បត្តិទាំងអស់របស់ព្រះអង្គ ហើយនូវវេលាដែលបាននាំព្រះវររាជបិតា នឹងអាណាប្រជានុរាស្ត្រជាច្រើនឲ្យចូលកាន់សាសនាកាតូលិកជាស្រេចហើយ ទ្រង់ក៏យាងតាមតាបសជាអាចារ្យចេញទៅកាន់ទីព្រៃទៅ ។

.... ដែលជាការនាំឲ្យបង់ដឹងនោះ គឺថា អ្នកតែងរឿងបារ៉ឡាអាមនឹងយ៉ូសាហ្វាត់ បានរើសយកជាតួឯកក្នុងរឿងនេះព្រះអង្គម្ចាស់ក្លិង្គ ១ អង្គទ្រង់នាមថា យ៉ូសាហ្វាត់ ដែលស្រង់

យកពីក្នុងរឿងរបស់ក្លិគ្គណាមួយមក ។ ក្នុងគម្ពីរលលិតវិស្តារ ដែលជាពុទ្ធបរិវត្តន៍នោះព្រះពុទ្ធបិតាជាមហាក្សត្រ ១ អង្គ ។ វេលាដែលព្រះមហាសត្តប្រសូតិមក អសីតព្រាហ្មណ៍បានថ្វាយទំនាយថា ព្រះរាជកុមារនឹងបានជាមហាក្សត្រយ៉ាងធំ ១ ព្រះអង្គដែលមានឫទ្ធានុភាពយ៉ាងខ្លាំងឬនឹងបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ១ ព្រះអង្គ នូវវេលាដែលបោះបង់រាជសម្បត្តិហើយចេញទៅកាន់ភេទតាបសវិញ ។ ឯកិច្ចយ៉ាងធំបំផុតរបស់ព្រះវររាជបិតាគឺត្រូវការពារកុំឲ្យចេញទៅទ្រង់ព្រះផ្នួសបាន ។ ដើម្បីនឹងធ្វើឲ្យបានសម្រេចតាម ព្រះយោបល់របស់ព្រះអង្គនោះទ្រង់បង្ខាំងព្រះអយ្យបុត្រឲ្យនៅតែក្នុងព្រះបរមរាជវាំង លុះបំរើនព្រះវ័យឡើងជាលំដាប់ ៗ ទ្រង់ចាត់ឲ្យមានសុទ្ធតែការកំសាន្តត្រេកត្រអាល ដើម្បីបង្វែរនូវគំនិតព្រះរាជកុមារចេញអំពីផ្លូវរំពឹងពិចារណា ហើយឲ្យជាប់ជំពាក់ដោយផ្លូវសប្បាយរីករាយវិញ ។ ការបង្ខាំងយ៉ាងមធ្យមនោះ គឺកុំឲ្យដឹងអំពីរោគាព្យាធិជរានឹងមរណៈ ព្រោះតែដឹងការទាំងនេះ នឹងនាំឲ្យឃើញនូវទុក្ខវេទនារបស់សត្វ នឹងសេចក្ដីសោះសូន្យនៃរូបកាយ ។

លុះនៅយូរមកព្រះរាជកុមារបានទទួលព្រះរាជានុញ្ញាតយាងចេញទៅក្រសាលក្នុងទីខាងក្រៅព្រះបរមរាជវាំង ត្រង់នេះហើយដែលដល់ត្រង់រឿងព្រះមហាសត្វទ្រង់ប្រទះនិមិត្តទាំង ៤ . ក្នុងវេលាដែលទ្រង់យាងចេញទតសួនច្បារ ៤ ដង ។ នៅត្រង់កន្លែងដែលទ្រង់យាងព្រះពាតសួនច្បារនោះ គេបានសាងជាព្រះស្តូបចេតិយ៍ ដើម្បីជាទីរឭកគ្រប់កន្លែងដែលព្រះពាត ហើយព្រះស្តូបចេតិយ៍នោះ កាលដែលអ្នកដំណើរចិន ឈ្មោះ ហ្វា-ហៀន បានចូលទៅក្នុងស្រុកឥណ្ឌា កាលពីក្នុងជាប់ឆ្នាំ គ.ស. ៤០០ នោះ គាត់បានប្រទះឃើញនៅឡើយ ក្នុងសម័យដែលហ្វួនត្សាំងបានចូលទៅក្នុងស្រុកឥណ្ឌាក្នុង គ . ស . ៧០០ ក៏នៅបានឃើញនៅឡើយដែរ ។

“ . . . ក្នុងវេលានេះបើយើងយករឿងរបស់សង្ឃរាជសង់នៅស្រុកជាម៉ាស៍ មកផ្ទៀបមើល នោះយើងឃើញថារឿងរ៉ាវខាងដើមក្នុងបរិវត្តន៍របស់ យ៉ូសាហ្វាត់ នោះដូចគ្នាសុទ្ធនឹងពុទ្ធ-បរិវត្តន៍ខាងដើម ។ គឺព្រះវររាជបិតាជាមហាក្សត្រ វេលាដែលព្រះអយ្យបុត្រប្រសូតមក ហោរាបានថ្វាយទំនាយថាព្រះកុមារនឹង

បានដល់នូវទីជាមង្គលខ្ពង់ខ្ពស់ប្រសើរ ប៉ុន្តែមិនមែនបានក្នុងនគរនេះទេ គឺនឹងបានក្នុងទីដ៏ទៃផ្សេងដែលខ្ពង់ខ្ពស់ហើយប្រសើរថ្លៃថ្លាផង តាមពិតនោះគឺដែលទ្រង់ចូលកាន់សាសនាថ្មី គឺសាសនាក្រៅបៀងនេះឯង ។ ព្រះវររាជបិតាបានចាត់ការគ្រប់យ៉ាងដើម្បីការពារកុំឲ្យបេញបោលព្រះបរមរាជវាំង គឺទ្រង់ចាត់បង្ខាំងព្រះកុមារក្នុងព្រះដំណាក់ ១ យ៉ាងល្អ ហើយដែលមានគ្រឿងកំសាន្តសម្រាប់ត្រេកត្រអាលរីករាយគ្រប់បែបយ៉ាងហើយបង្ការណ៍យ៉ាងមធ្យ័ត កុំឲ្យព្រះកុមារជ្រាបរឿងរោគាព្យាធិជរានឹងមរណ ។ លុះនៅយូរមក ព្រះវររាជបិតាទ្រង់ប្រោសព្រះរាជានុញ្ញាតឲ្យយាងបេញទៅក្រសាលក្រៅព្រះបរមរាជវាំង ។ វេលាដែលយាងបេញទៅម្ដងដំបូងទ្រង់ព្រះឃើញមនុស្សពីរនាក់ម្នាក់ខ្វិនម្នាក់ខ្វាក់ ។ ក្នុងវេលានោះព្រះកុមារទ្រង់ត្រាស់ដណ្ដឹងសួរថា មនុស្សទាំងពីរនាក់នេះជាមនុស្សអ្វី ក្នុងវេលានោះគេក្រាបទូលថាជាមនុស្សជំងឺ ។ ទើបព្រះរាជកុមារត្រាស់សួរទៀតថា មនុស្សទាំងអស់សុទ្ធតែត្រូវឈឺដូចគ្នា ឬក៏គេមានដឹងជាមុនថា អ្នកនេះត្រូវឈឺ ហើយអ្នកនោះត្រូវរួចដូច្នេះឬអ្វី លុះ

ទ្រង់បានជ្រាបការពិតជាស្រេចហើយ ទ្រង់ក៏យាងត្រឡប់ទៅក្នុងព្រះបរមរាជវាំងវិញ ដោយមានសេចក្ដីក្រៀមក្រំក្នុងព្រះហឫទ័យ ។ ក្នុងគ្រាក្រោយ វេលាដែលព្រះរាជកុមារទ្រង់យាងចេញទៅក្រសាលក្រៅព្រះបរមរាជវាំងទ្រង់ប្រទះឃើញមនុស្សជរាម្នាក់មុខជ្រីវជ្រួញ ជើងញ័រទទ្រើក ខ្នងកោង សក់ស មាត់គ្របុបសំឡេងខ្សាវខ្សោប ។ ព្រះរាជកុមារក៏ត្រាស់សួរអំពីហេតុភេទដែលឃើញនេះទៀតជាយ៉ាងដូចមេច ក្នុងវេលានោះគេក៏ក្រាបទូលថា ហេតុភេទនេះនឹងបានដល់គ្រប់រូបមនុស្សទាំងអស់គ្មានអ្នកឯណាមួយចៀសផុតពីចាស់ជរា ហើយក្នុងទីបំផុតមនុស្សទាំងអស់ត្រូវតែស្លាប់គ្រប់ៗគ្នា ។ លុះទ្រង់ជ្រាបដូច្នេះហើយ ក៏យាងវិលត្រឡប់ចូលទៅក្នុងព្រះដំណាក់វិញ ដើម្បីទ្រង់រំពឹងពិចារណាអំពីសេចក្ដីស្លាប់ លុះដល់លេចតាបសមួយទៅដល់បំពោះព្រះភក្ត្រហើយសម្ដែងឲ្យឃើញនូវរសជាតិយ៉ាងស្ដែងរបស់សាសនាក្រៅៗ ដូចមានសម្ដែងក្នុងព្រះគម្ពីររបស់ព្រះគ្រិស្ដទាំងអស់ ។

ខ្ញុំស្មានថា អ្នកឯណាមួយដែលបានមើលរឿងទាំងពីរនេះហើយមិនយល់ឃើញថាជារឿងដែលមួយខ្ចីត្រាប់យកពីមួយទៅ ។ ហើយបើហ្វាហៀន កាលពី ៣០០ ឆ្នាំមុនសង្ក្រាជសង់នៅជាម៉ាស៍ បានប្រទះឃើញព្រះស្តូបចេតិយ៍ដែលគេសាងដើម្បីទុកជាទីរឭកដល់កន្លែងដែលព្រះមហាសត្វទ្រង់ព្រះពាតសួនច្បារនៅល្អទាំងអស់នៅឡើយ កណ្តាលទីក្រុងកបិលវត្ថុដែលបាក់បែកហើយគេបោះបង់ចោល នោះត្រូវយល់ថាអ្នកបួសជាតិក្រិកនេះបានខ្ចីរឿងរបស់ព្រះពុទ្ធសាសនាទៅធ្វើត្រាប់តាម ។ ប្រសិនបើជាមានប្រយោជន៍ ត្រូវតែពោលបញ្ជាក់ឲ្យឃើញនូវកន្លែងនិមួយ ៗ ដែលមានទំនងដូចគ្នាក្នុងបរិវត្តន៍របស់ យ៉ូសាហ្វាត់ នឹងពុទ្ធបរិវត្តន៍ ។ ក្នុងទីបំផុតរបស់រឿងទាំងពីរនេះ គឺសុទ្ធតែបានញាំងនូវព្រះវររាជបិតាឲ្យចូលកាន់សាសនាដូចគ្នា សុទ្ធតែបានផ្ចាញ់បង់នូវកិលេសមារនឹងបាបមារដូចគ្នា ហើយសុទ្ធតែគេទុកជាព្រះអរហន្តដូចគ្នាជាក្រោយដែលលះបង់រូបកាយនូវទៅ ។ ម្យ៉ាងវិញទៀត ឯចំណែកអសាធារណ៍នាមក្នុងសៀវភៅភាសាក្រិកនោះដូចស្រង់យកមក

ពីក្នុងគម្ពីររបស់ព្រះពុទ្ធសាសនា ។ ឯនាយសារថីដែលជូនព្រះមហាសត្វចេញទៅទ្រង់ព្រះផ្នួសក្នុងវេលាយប់ដែលទ្រង់លះបង់រាជវាំងប្រាសាទ អគ្គទេវីនឹងអគ្គរាជបុត្រ ព្រមទាំងទ្រព្យសម្បត្តិ នោះមានឈ្មោះថា ឆន្នក ដែលអ្នកស្រុកភូមាគេហៅ សន្ន ។ បំណែកមិត្រដែលជាប់ជាមួយនឹងបារ់ឡាអាមទៅនោះ ឈ្មោះថាសារ់ជីន(១) ។ លោកវេណូទ៍អធិប្បាយក្នុងសេចក្ដីយល់ឃើញរបស់លោក អំពីស្រុកក្លិង្គបានកត់សំគាល់ថា យូដាស៍ ដែលលោកម៉ាស្ប៊ឺឌីសំគាល់ថាជាអ្នកបង្កើតសាសនា សាបេយែន នឹងយូអាសាហ្វ៍ ដែលអ្នកសរសេររឿងកិតបអ័លហ្វិប្រ៊ាស្ដ៍សំគាល់ថាអ្នកបង្កើតព្រះពុទ្ធសាសនា

---

(១)ក្នុងកន្លែងខ្លះឯទៀត គេស្មើរតែនឹងយល់ថា សង់នៅជាម៉ាស មិនមែនគ្រាន់តែបានឮគេនិយាយរឿងព្រះពុទ្ធឲ្យស្ដាប់ ផ្ទាល់មាត់នឹងអ្នកដែលនាំរឿង ពីស្រុកឥណ្ឌាទៅដូចជាលោកពោលនោះទេ គឺលោកមានចំពោះមុខលោក គម្ពីរលលិតវិស្ដារ ។ ក្នុងរឿងព្រះពាតស្វូនប្បារទាំង៣ជីននោះចំណែកគម្ពីររបស់ព្រះពុទ្ធសាសនាសម្ដែងថាព្រះមហាសត្វ បានឃើញមនុស្សចាស់ជរាក្នុងលើកដំបូង លើកក្រោយឃើញមនុស្សឈឺ ហើយលើកក្រោយបំផុតឃើញមនុស្សស្លាប់ ចំណែករឿងរបស់លោកសង់វិញនោះ គឺក្នុងលើកដំបូង យ៉ូសាហ្វ៍ បានប្រទះឃើញមនុស្សពីរនាក់ ម្នាក់ខ្វិនម្នាក់ខ្វាក់ ហើយក្នុងលើកទី ២ ឃើញមនុស្សជរាទៀបនឹងស្លាប់ ។ ក្នុងស្ថានត្រង់នេះឃើញមានខុសគ្នាធំ ហើយគួរឲ្យជឿដល់សេចក្ដីដែលសង់នៅជាម៉ាស់បានពោល គឺថារឿងរ៉ាវនេះគេនាំយកពីស្រុកក្លិង្គទៅហើយមនុស្សដែលជាទីទុកចិត្តបាននិយាយឲ្យលោកស្ដាប់ ។

នោះ ពាក្យទាំងពីរនេះឯង ប្រើជំនួសពាក្យសំស្រ្កឹតថា ពោធិ-សត្វគឺជាសេចក្តីផ្លាស់ផ្ទេរងាយយល់ ដោយអំណាចប្រើបែបផ្ទេរអក្សរ ដោយអក្សរ ប៉ែរ្សន ។ សាស្ត្រាចារ្យបេនហ្វី បាទដំរូវថា បេអូដាស់ដែលជាមេរើទមន្តក្នុងរឿង បារ៌ឡា-អាមនឹងយ៉ូសាប្ហាត់ គឺជាទេវទត្ត ក្នុងគម្ពីរព្រះពុទ្ធសាសនា នោះឯង ។

ឯរឿងរ៉ាវទាំង ២ ដែលដូចគ្នានេះ ពួកអ្នកប្រាជ្ញក្នុងប្រ-ទេសផ្សេងៗមានប្រទេសបារាំងសែសអាឡឺម៉ាញនឹងអ័ងក្លេតែរជាដើម បានពោលដោយឡែក ៗ ដោយឥតដឹងគ្នាអំពីសេចក្តីដែលដូចគ្នានេះ ។ ខ្ញុំដាក់ប្រទេសបារាំងសែសជាមុន ព្រោះបើសង្កេតតាមពេលវេលា ឃើញថាលោកឯអ៊ារ្វូឡាប៊ូឡាយ បានប្រារព្ធជាដំបូង អំពីសេចក្តីដែលដូចគ្នានេះ គឺលោកបានពោលក្នុងស្សូរណាល់ដេដេបាត់ (បូតហ្មាយហេតុរឿងជជែកដេញដោល) ចុះថ្ងៃ ២១ នឹង ២៦ សូយេត៍ ឆ្នាំ១៨៥៩ ។

លោកដុកទ័រ លីអឹប្រែស្ត៍ បានធ្វើសេចក្តីប្រៀបធៀបយ៉ាងពិស្តារ ហើយក្នុងខាងក្រោយ លោក ន.ប៉ាល បាន

ប្រារព្ធពោលរឿងនេះក្នុងសេចក្ដីប្រែរឿង ដំណើររបស់ហ្វាហាំន គឺថា រឿងយ៉ូសាហ្វាត់ ជារឿងខ្ចីយកមកអំពីពុទ្ធបរិវត្តន៍ ។ ខ្ញុំអាចនឹងជូនឈ្មោះអ្នកប្រាជ្ញខ្លះទៀត ដែលបានមើលរឿងទាំងពីរនេះ ហើយមិនបានខានយល់ឃើញថា សង់នៅជាម៉ាស៍ បានយកតួបុគ្គលពីក្នុងរឿងលលិតវិស្តារដែលជាគម្ពីររបស់ព្រះពុទ្ធសាសនា មកធ្វើជាតួបុគ្គលក្នុងរឿងរបស់ខ្លួន ។ ប៉ុន្តែដែលត្រូវបានទីជាអ្នកបានពោលប្រារព្ធជាដំបូងនោះ គឺលោកអេអារ្ន៍ឡាប៊ូឡាយ ។

រឿងនេះជារឿងគួរឲ្យចង់ដឹងចង់មើលបំផុតក្នុងរឿងរ៉ាវជាពួកអក្សរសាស្ត្រ ប៉ុន្តែនៅមានរឿងមួយទៀតដែលគួរឲ្យចង់ដឹងចង់មើលជាងនេះទៅទៀត ដែលជាប់ទាក់ទងក្នុងរឿងនេះដែរ ហើយខ្ញុំមានសេចក្ដីងឿងឆ្ងល់ណាស់អំពីដែលគេមិនដែលបានប្រារព្ធអំពីរឿងនេះសោះ ។ គេបានដឹងជាប្រាកដថា កាលពីក្នុងសម័យកណ្ដាលអាយុ រឿងបាវឡាអាមនឹងយ៉ូសាហ្វាត់ ជារឿងដែលបានស្គាល់ទូទៅគ្រប់ស្រុក ។ ក្នុងបូពាប្រទេស

រឿងនេះគេបានប្រែមកជាភាសាស៊ីរីយ៉ក ជាភាសាអារ៉ាប ជាភាសាអេស្ប៉ាញ៉ុល អារមេនៀននឹងជាភាសាហេប្រឺ ។ ក្នុងបស្ចិមប្រទេស រឿងនេះប្រែជាភាសាឡាតាំង ជាភាសាបារាំងសែស អ៊ីតាលៀន អាឡឺម៉ង់ អ៊ែងក្លេស អេស្ប៉ាញ៉ុល បូហេមៀន និងប៉ូឡូណែស ។ កាលពី គ.ស.១២០៤ ព្រះចៅក្រុង នរវ៉ែស៍ បានប្រែជាភាសា ឥស្លង់ដេស៍ ហើយខាងក្រោយបំផុតនេះ មានអ្នកបួសក្នុងសាសនាគ្រិស្ទ ១ អង្គបានប្រែចេញជាភាសាតគ៍លៈ គឺជាភាសាសម្រាប់កោះហ្វីលិព្ពីនគឺស្រុកម៉ានិលសព្វថ្ងៃនេះ ។ ប៉ុន្តែរឿងនៅមិនទាន់ផុតនៅឡើយ ឯបាឡាអាមនឹងយ៉ូសាហ្វាត៍ បានឡើងជាព្រះអរហន្តទាំងក្នុងអារាមខាងបូព៌ាប្រទេស ទាំងក្នុងអារាមខាងបស្ចិម-ប្រទេស ។ បំណែកខាងអារាមក្នុងបូព៌ាប្រទេស នោះថ្ងៃ ២៦ អ៊ូតជាថ្ងៃព្រះអរហន្ត បាឡាអាមនឹងយ៉ូសាហ្វាត៍ ក្នុងបញ្ជីកត់អ្នកបុណ្យរ៉ូមាំង នោះថ្ងៃ ២៧ អ៊ូតវិញជាថ្ងៃព្រះអរហន្តបាឡាអាមនឹងយ៉ូសាហ្វាត៍នេះ ។

ដំណើរខ្លះ អំពីលោក គៈហៈ. ម៉ូណូទ៍

## កាលនៅធ្វើជារេស៊ីដង់ត៍ ក្នុងស្រុកខ្មែរ នឹងរឿងគោញីដែលលោករៀបរៀង

យើងបានបាត់ការស៊ើបសួរដណឹង ដល់ខែត្រទាំងប៉ុន្មានដែលលោក គ. ម៉ូណូទ៍ ធ្វើជារេស៊ីដង់ត៍ អំពីសេចក្ដីខ្វះខ្វែងរបស់លោក ។

### អំពីខែត្រពោធិសត្វយើងបានដំណើរដូច្នេះ

លោក គ.ម៉ូណូទ៍ លោកយកចិត្តទុកដាក់ នឹងអ្នកស្រុកដែលជាមនុស្សអភ័ព្វនៅក្នុងភ្នំ គឺពួកព័រដែលជាអ្នកបេះក្រវាញលក់ ។ លោកបានស៊ើបសួរបញ្ជាក់ហេតុភេទយ៉ាងច្បាស់លាស់ ហើយក៏ដំរូវបែបដែលលក់ក្រវាញ គឺថាត្រូវរាជការបាត់ការលក់ឲ្យ ហើយបែបនៅជាប់ប្រើជាសណ្ដាប់មកលុះដល់សព្វថ្ងៃនេះ គឺដើម្បីការពារកុំឲ្យពួកអ្នកស្រុកព្រៃនេះ ត្រូវគេបំបាត់ប្រវិញ្ញូទ៍ដែលនាំឲ្យខាតយ៉ាងធំដល់ការបំណេញដែលកើតមានដោយផលដំណាំប្រសើរនេះ ។

គឺក្នុងសម័យដែលលោក គ. ម៉ូណូទ៍ នៅធ្វើជារេស៊ីដង់ត៍នៅពោធិសត្វ ដែលលោក ម៉ារកេត៍ ក្រុមក្នុងរាជការស៊ីវិល បានធ្វើរឿងខេត្តពោធិសត្វ ដែលចេញបោះពុម្ពក្នុងសេចក្ដីឧបត្ថម្ភនៃក្រុមសមាគម សិក្សាការក្នុងប្រទេសឥណ្ឌូចិន ។

អំពីខេត្តកំពង់ធំ យើងមានដំណឹងដូច្នេះ

១— លោក គ. ម៉ូណូទ៍ បានធ្វើរេស៊ីដង់ត៍នៅកំពង់ធំពីថ្ងៃ ១០ ខែសេបតម ឆ្នាំ ១៩១០ ដល់ថ្ងៃ ១១ ខែយ៉ាំងវីយេរ ឆ្នាំ ១៩១២ ។

២ — ក្នុងវេលាដែលលោកធ្វើជារេស៊ីដង់ត៍នោះ លោកបានចេញជាអធិបតីក្នុងពិធីបុណ្យគ្រប់រង្វង់ក្នុងវត្តទាំងអស់ក្នុងទីខេត្តនេះ ។

៣— លោកនិយាយនឹងសរសេរខ្មែរបាន ។

៤ — លោកបានតយុទ្ធនឹងខ្លាំងហើយត្រូវរបួសដៃខាងស្ដាំ ។

៥ — ខ្សែត្រៃបិុលដែលធ្វើរាជការនៅកំពង់ធំសព្វថ្ងៃជាមនុស្សរាប់អានទុកចិត្តរបស់លោក កាលពី ៧ ឬ ៨ ឆ្នាំមុននេះ

វេលាដែលលោកអញ្ជើញទៅនៅក្នុងខេត្ត ឯក្សអង់ប្រែវង្ស នោះ ឡែត្រែបិលបានទទួលសំបុត្រ១ច្បាប់ក្រោយបំផុតអំពីលោក ។

ក្រុងភ្នំពេញ នៅថ្ងៃ ១៩ ខែអាវរិល ឆ្នាំ ១៩៣៤

ខ្ញុំឈ្មោះរស់-ខៀវ ចៅហ្វាយខេត្តលេខ ១ រើត្រៃសីរ៉ាលឺ-យេជីឡាឡេស៊ីយុងដូណើរ ខ្ញុំបានទទួលប្រសាស្ន៍ពីលោកចាងហ្វាងគ្រប់គ្រងព្រះរាជបណ្ណាល័យក្រុងកម្ពុជា សួរអំពីរឿងលោកឡឺរេស៊ីដង់ត៍.គ.ហ.ម៉ូណូទ៍នោះ កាលនោះខ្ញុំនៅធ្វើជាចៅហ្វាយខេត្តពោធិសត្វ នៅក្នុងបង្គាប់លោកឡឺរេស៊ីដង់ត៍រួមខេត្តជាប្រើនរូប លុះក្រោយមកប្រមាណជា ឆ្នាំ ១៩០៦-៧-លោកម៉ូណូទ៍នេះ បានទៅធ្វើជារេស៊ីដង់ត៍ពោធិសត្វ លោកនេះជាក្មួយឡឺរេស៊ីដង់ត៍សុប៉េរិយើមោនសៀរប៉ូលលូស លោកមានម៉ា-ដាមជាភរិយាត្រឹមត្រូវ ហើយលោកចេះភាសាខ្មែរច្បាស់ទើបឯកិរិយាដែលធ្វើការនោះជាអ្នកឧស្សាហ៍គួរផែន្ទឹក្នុងខេត្តទាំងអស់ ទើបឯរាស្ត្រខ្មែរដែលបានដឹងថា លោកម៉ូណូទ៍ ចេះភាសាខ្មែរច្បាស់ចេះអក្សរខ្មែរសរសេរបានច្បាស់ ហើយរួសរាយរាប់អានខ្មែរណាស់ រាស្ត្រមានការសុខទុក្ខអ្វីក៏សឹងតែប្ដឹងដល់

លោកៗនិយាយការផ្ទាល់នឹងរាស្ត្រ តែបើទុកជាលោកនិយាយ
បានយ៉ាងណា លោកឱ្យអ៊ាំងតែរប្រែតឈរស្ដាប់តាមច្បាប់មិន
មែនធ្វើឫកថាអញចេះខ្មែរហើយ មិនរវល់នឹងអាំងតែរប្រែតនោះ
ទេ បើកាលណាលោកដើរត្រួតក្នុងខេត្តម្ដងៗឧស្សាហ៍មើលគ្រប់
ស្រុកភូមិ អិនឱ្យសល់ភូមិណា បើភូមិតូចនៅក្នុងព្រៃភ្នំឆ្ងាយក៏គង់
កត់យកមកដាក់ក្នុងផែនទីដែរខ្ញុំសូមអធិប្បាយពីរឿងរាស្ត្រភ្នំក្រ-
វ៉ាញក្នុងខេត្តពោធិសត្វ ជាតិបែបខ្មែរដែលគេហៅសាស្ត្រព័រ ភា-
សានិយាយរដឹនៗ លោកម៉ូណូទ៍ នាំម៉ាដាមទៅត្រួតខេត្តនៅភ្នំ
ក្រវ៉ាញរាល់ឆ្នាំ លោកឧស្សាហ៍សាកសួរពីរាស្ត្រភ្នំក្រវ៉ាញ លោក
ដឹងថារាស្ត្រស្រុកនោះស្រឡាញ់របស់អ្វីលោកក៏ទិញយកទៅឱ្យ
ស្រីចាស់ក្រមុំក្មេង-តាមរាស្ត្រស្រីៗរាប់អាន លោកទិញកាំម៉ាព-
ណ៌ក្រហម-លឿង ស្វាយ-ស-ខៀវ-នឹងជញ្ជៀនស្ពាន់ហៅជញ្ជៀន
ដៃរគៀម ធ្វើពីជ័រពណ៌ក្រហម អង្កាំកែវ ដាក់ផ្លុកដំរី២-៣ទើប
ឯរាស្ត្រភ្នំក្រវ៉ាញឮថា លោកម៉ូណូទ៍ ឡើងទៅមានម៉ាដាមទៅ
ផងវាអរណាស់ ព្រោះរាស្ត្រស្រី ១ ឬប្រុសខ្លះមិនដែលឃើញម៉ា-
ដាមស្រីបារាំងសោះ កាលមុនលោកទៅដល់មេស្រុកបានប្ដឹងខ្ញុំ

ថារាស្ត្រស្រីៗចង់ឃើញលោកនឹងម៉ាដាម តើលោកអនុញ្ញាតឲ្យរាស្ត្រស្រីៗចាស់-ក្មេង ទទួលលោកបានឬទេ ខ្ញុំបានប្តឹងលោកម៉ូណូទ៍នឹងម៉ាដាមតាមដំណើរ លោកមានប្រសាសន៍ថាបានល្អណាស់ហើយ លុះលោកនឹងខ្ញុំបាទទៅ ដល់ឃើញរាស្ត្រប្រុស-ស្រីឈរចាំទទួលលោកនឹងម៉ាដាមជាច្រើនខ្នាន់ខ្នាប់រាស្ត្រស្រីៗ ឈរមើលលោក វាថាយើងមិនដែលស្គាល់លោកស្រីម៉ាដាមនោះ ឥឡូវយើងបានឃើញល្អណាស់ បួងសក់ល្អអីម៉្លេះម៉្លោះ ហើយរាស្ត្រស្រីៗ ឈរមើលលោកភ្លេចខ្លួនខ្លះៗ លោកពីសាបាយរូបលោកឲ្យរបស់ជាសំពត់កាំម៉ាជញ្ជៀន-ឲ្យរើស ១ ម្នាក់តាមចិត្តស្រឡាញ់ ទើបឯស្រីស្រុកនោះទាំងចាស់ក្មេងស្រឡាញ់តែរបស់ពណ៌ក្រហមៗ ស្រឡាញ់ជញ្ជៀនស្ពាន់នឹងអង្កាំកែវអរណាស់ប្រហែលដូចជាខ្មែរស្រុកក្រុងស្រឡាញ់មាស កាលលោកកំពុងពីសាបាយ រាស្ត្រឈរមើលខ្លះថា លោកពីសាសាប់មាន់ដូចយើងដែរ ហេតុអ្វីមានគេនិយាយថាបារាំងស៊ីសាប់មនុស្សបានជាយើងខ្លាច ខ្ញុំជំរាបលោក រស៊ីដងត៍ ម៉ូណូទ៍នឹងម៉ាដាមលោកសើចហើយប្រាប់ថាបារាំងគេខ្ពើមសាប់មនុស្ស

ណាស់ មនុស្សក្រហកទេ រាស្ត្រស្រីៗចាស់ក្មេងថាយើងលែងជឿ ហើយយើងឃើញច្បាស់នឹងភ្នែកយើង លោកបារាំងស្អាតពុម ក្លិនក្រអូបសុទ្ធតែទឹកអប់ រាស្ត្រនាំគ្នាសើចថាយើងជឿតែមនុស្ស ផ្ដេះផ្ដាសក្រហកយើង ហើយយើងអរណាស់ បានលោកម៉ូណូទ៍ នឹងម៉ាដាមមកឲ្យយើងស្គាល់ តាំងពីដើមមកយើងមិនដែល ស្គាល់សោះ គ្មានលោកបារាំងណានាំប្រពន្ធមកឲ្យយើងឃើញ សោះ រាស្ត្រស្រុកភ្នំក្រវាញមានសេចក្ដីស្រឡាញ់លោកម៉ូណូទ៍ នឹងម៉ាដាមជាអស់ពីចិត្ត មកជំរាបសួរលោក រកពេលណា ១ ឲ្យលោកសំរាកគ្មាន លោកម៉ូណូទ៍ក៏រាប់អានជាតិខ្មែរទាំងអស់ ក្នុងខែត្រមិនរើសមុខ វេលាយប់សំរាក ស្រីចាស់ៗនាំក្មេង ក្រមុំៗមកលេងភ្លេងអង្គុបធ្វើពីដែក ឈ្មោះអន្ទោតៈធ្វើពីឫស្សី ខ្សែឫស្សីមានផ្លែឃ្លោក ខ្សែដៀវរ៉ៃឮសូររងំមិនប្លង់ទេ គួរឲ្យស្រណោះរងំណាស់ បើដល់កន្លែងដាក់និមួយៗ រាស្ត្រក៏សឹងតែ មកជួបជុំទាំងប្រុសទាំងស្រីរាប់អាន លោកម៉ូណូទ៍នឹងម៉ាដាម ហាក់ដូចអាពុកម្ដាយវា ហើយវាមើលម៉ាដាមមិនឈប់សោះ ពីព្រោះរាស្ត្រខាងស្រុកភ្នំនោះស្រីទាំងអស់មិនដែលស្គាល់ផ្សារ

ពោធិសត្វឬប៉ុស្តលោករេស៊ីដង់សោះ ទាល់តែបាស់ស្លាប់ក៏មាន លោកម៉ូណូទ័ដើរត្រួតខែត្រជិត ១ ខែទើបមកដល់ទីរេស៊ីដង់វិញ មានរាស្ត្រខ្មែរធ្វើបុណ្យឡើងអ្នកតាអន្សាស្រុកវា ៗ អញ្ជើញលោកទៅ វាយកបាយ១ផ្តិលជូនលោកឲ្យដាក់បាត្រលោកសង្ឃឲ្យវាបានសុខសប្បាយ លោកក៏ទទួលដាក់បំពេញអំណររាស្ត្រ ៗ ជាតិខ្មែរមានពាក្យសរសើរថា យើងបានសុខដោយសារបារាំងសែសជាអាពុកម្តាយយើង បើកុំអីបារាំងកើតទ័ពជាញឹកញាយ ខ្ញុំរំឭកពីលោកម៉ូណូទ័និងម៉ាដាមឡើងទៅភ្នំក្រវាញជាមួយនឹងខ្ញុំជាទេសកាលខ្លាំងណាស់ វេលាម៉ោង ៤ រសៀល លោកឲ្យដំរីបរទៅមុនទៅ ពីកំពង់លួងឃុំលាជ ពោធិសត្វនឹងទៅដាក់នៅវាលនិគ្រោះបំនួន ២០ គីឡូម៉ែត្រ លោកទៅក្រោយដំរីកន្លះម៉ោង ជិះសេះមានប្រដាប់គួរផែនទី គួរដល់ម៉ោង ៥ រសៀល ដល់កណ្តាលព្រៃធំម្នាស់ប្លើយើយ ស្រាប់តែខ្យល់ព្យុះពីងត្បូងងងឹតមើលគ្នាមិនឃើញ ភ្លៀងក៏ធ្លាក់ខ្លាំងណាស់ រកទីឈប់គ្មាន កណ្តាលព្រៃដើមឈើធំ ៗ បាក់ជុំវិញ ខ្ញុំនឹងលោកម៉ូណូទ័នឹងម៉ាដាម

តែបីនាក់ ខ្ញុំគិតថាមុខជាស្លាប់ទាំងអស់គ្នា ទីនោះសុទ្ធតែព្រៃគ្មានវាលសោះ ក៏ខំជិះសេះបន្តិច ៗ ទៅបំនួន ១ ម៉ោងទើបរាំងភ្លៀង ទើបឃើញបាឡាត់ត្រួតក្រវាញយកដំរី ៣ មកទទួលកណ្តាលផ្លូវ កន្លះម៉ោងទើបដល់វាលនិគ្រោធ ឃុំតាំងល្អប បំណែកភ្នំក្រវាញខែត្រពោធិសត្វសំរាន ១ យប់នោះ ព្រឹកឡើងលើកទៅទៀត បំនួន ១ ខែ ទើបមកដល់ប៉ុស្តពោធិសត្វវិញ តាំងពីខ្ញុំធ្វើរាជការឈរនៅពោធិសត្វ ១៥ ឆ្នាំ និងខែត្រឯទៀតផងជិត ៣០ ឆ្នាំ ខ្ញុំមិនដែលឃើញអស់លោកបារាំងណាបាននិយាយស្និទ្ធស្នាលនឹងខ្មែរដូចលោកម៉ូណូទ៍នេះគ្មានទេ បាននិយាយតែអ្នកមានការទើបបានចឹបកប្រែរួចក៏ហើយទៅ ដូចមោនស្យេរអើទ្រីសដែលបេះខ្មែរនោះ ក៏មិនបានប្រាស្រ័យស្និតស្នាលនឹងខ្មែរដូចលោករេស៊ីដង់ម៉ូណូទ៍នេះទេ ជាតិខ្មែរសព្វថ្ងៃតែជួបនឹងខ្ញុំក៏សួរពួកលោកម៉ូណូទ៍ថា លោកវិលមកស្រុកខ្មែរវិញហើយឬយ៉ាងណា បើឮថាលោកពុំបានមកវិញ ក៏នាំគ្នាស្តាយពេកណាស់ ។

១ ទៀតលោកម៉ូណូទ៍មកឈរស្រុកខ្មែរច្រើនដងផ្លាស់ទៅស្រុកបារាំងវិញ របស់ឥឡូវក្រុម្ការនឹងរាស្ត្រទេ មិនលក់របស់អ្វីសោះ កាលខ្ញុំទៅក្រុងបារីសពីឆ្នាំ ១៩០៩-១០ នោះខ្ញុំបានឃើញញាតិលោកម៉ូណូទ៍ម៉ាដាម សុទ្ធតែមានសម្បត្តិទាំងអស់ មាតាលោកម៉ូណូទ៍ អាយុ ៨០ ឆ្នាំហើយ ហើយនៅមាំមួនណាស់ ។

## រឿងគោញី

លោក គ.ហ.ម៉ូណូទ៍ ជារេស៊ីដង់ចាស់ក្នុងស្រុកខ្មែររៀបរៀង

មាននិយាយថា កាលណោះមានស្ដេច ១ អង្គមានគោញី ១ ដែលទ្រង់ស្រឡាញ់អស់ពីព្រះរាជហឫទ័យ នោះព្រះករុណាទ្រង់ជ្រាបថា នឹងបិញ្ចឹមគោញីនោះឲ្យបានល្អ គួរផ្ញើនឹងអ្នកស្រែស្រុកក្រៅ នៅទីណាដែលមានស្មៅច្រើនល្អ ឲ្យគោនោះវាបានស៊ីឲ្យឆ្អែតផង ទ្រង់ព្រះបិន្តាដូច្នេះហើយ ទ្រង់ត្រាស់បង្គាប់ឲ្យចៅហ្វាយស្រុក ១ នាក់ ឈ្មោះអ៊ុក មានងារនៅខេត្ត ១ ដែលមានវាលធំល្អ មកទទួលគោញីនោះ នាំទៅឃ្វាលឯស្រុកស្រែ ចៅហ្វាយស្រុកនោះចូលមកហើយ ទ្រង់មានព្រះ

បន្ទូលថា ដ្បិតអញផ្ញើមេគោអញ ១ នេះឲ្យរាស្ត្រខេត្រចៅហ្វាយស្រុកឯងឃ្វាលរក្សា តែសត្វនេះយ៉ាងល្អបំផុតប្លែក ហើយអញស្រឡាញ់ណាស់ផង ដូច្នេះឲ្យគេបំពេញមើលថែទាំឲ្យល្អ តែប្រយ័ត្ន បើតែមានឈ្មោះណា ១ មកប្រាប់ថាមេគោអញនោះវាស្លាប់ អញនឹងឲ្យកាប់ក្បាលអានោះឥតប្រណីឡើយ ។ ដូច្នេះហើយចៅហ្វាយស្រុកក្រាបទូលទទួលថា ព្រះករុណាវិសេស ហើយនាំគោញីនោះចេញទៅខេត្រវិញ មកដល់ហើយចៅហ្វាយស្រុកប្រមូលអស់ តាហ្មឺន មេស្រុក ជំទប់ រាស្ត្រ ទាំងអស់ផ្ដាំថាគោញី ១ នេះ របស់លួងជាអំម្ចាស់ ទ្រង់បានផ្ញើឲ្យយើងឃ្វាលរក្សាថែទាំឲ្យស្រួលសប្បាយតទៅមុខ សេចក្ដីនេះឲ្យតាហ្មឺនក្រុមការ រាស្ត្រ យកចិត្តទុកដាក់ជួយទាំងអស់គ្នា ឲ្យមេគោនេះបំរើនកុំខានឡើយ តែបើមិនឃើញឃ្វាលរក្សាទេឲ្យទៅជាស្លាប់ នោះព្រះករុណានឹងឲ្យកាប់ក្បាលយើងទាំងអស់គ្មានប្រណីឡើយ ។

នោះតាហ្មឺនក៏រករើសភូមិណាដែរមានស្មៅច្រើនល្អយ៉ាងឯកឲ្យរាស្ត្រភូមិនោះ យកមេគោរបស់លួងទៅឃ្វាលឲ្យសុំខាន់ឯរាស្ត្រក៏ចេះ តែខំប្រឹងយកចំណីឲ្យមេគោនោះស៊ីតែរាល់គ្នាសព្វ

ថ្ងៃសព្វវេលា នោះមេគោនោះវាឡើងជាធាត់ណាស់ ពុំបេះដើររកស្មៅស៊ីទេ បាំតែក្នុងរោងឲ្យរាស្ត្រយកអ្វីឲ្យវាស៊ី ក៏រាស្ត្របេះតែយកបំណីជាច្រើនពេញ កញ្ជើការុង ជារាល់វេលា យកស្មៅខ្លះ សំណាបខ្លះ ទំពាំងឫស្សីខ្លះ ស្រូវខ្លះ ក្លពោតទ្វីៗខ្លះ ឯគោទោះវាស៊ីក្រៃពេក ទាល់តែស្លាប់ទៅដោយតែវាស៊ីហួស ឃើញដូច្នេះរាស្ត្រតូចចិត្ត ទៅប្តឹងជំទព់ៗរត់ទាំងខ្លាចទៅប្តឹងមេស្រុកៗភ័យណាស់ពុំហ៊ានទៅជំរាបលោកចៅហ្វាយ ទៅប្តឹងត្រឹមស្មៀនៗភ័យពន្លឹកទៅជំរាបបាឡាត់ ៗ ឮតាមសេចក្តីក៏ញ័រទាំងដៃទាំងជើង ចូលទៅឯលោកចៅហ្វាយ ៗ ឃើញបាឡាត់ដូច្នេះក៏សួរថាកើតគ្រោះអ្វីក៏លោកបាឡាត់ញ័រទាំងដៃទាំងជើងយ៉ាងម៉្លេះ នោះបាឡាត់ឆ្លើយទៅវិញថាខ្ញុំប្របាទពុំហ៊ាននិយាយទេ ឯចៅហ្វាយស្រុកប្រាប់ថាមិនឥទេ ឲ្យលោកបាឡាត់និយាយចុះនោះបាឡាត់និយាយថា សូមមេត្តាប្រោស ដ្បិតមេគោព្រះករុណាវាស្លាប់ទៅហើយ ឮដូច្នេះចៅហ្វាយស្រុកក៏ស្លុតញ័រសព្វសាប់ ស្រែកថាខ្ញុំមើយម្តងនេះឃើញជាផុតជីវិតហើយ ដ្បិតល្ហងជាម្ចាស់ជីវិតមានព្រះបន្ទូលផ្តាំថា បើនរណាទៅទូលថាមេគោនោះស្លាប់ នឹង

ឲ្យកាប់ក្បាលឥតប្រណី យើខ្ញុំពុំព្រមទៅថ្វាយបង្គំក្រាបទូលតាមដំណើរទេ ឲ្យលោកបាឡាត់ទៅបុះ ឯបាឡាត់ប្រកែក ឯការដែលចូលទៅក្រាបទូលព្រះករុណាក្នុងវេលានេះ ជាក្រសួងរបស់ចៅហ្វាយស្រុក ពុំគួរប្រើនាហ្មឺនណាទៅជួសឡើយ ប្រកែកគ្នាទៅវិញទៅមកជាយូរខ្លាំងណាស់ ។

កាលណោះជួនជាកូនក្រមុំចៅហ្វាយស្រុកដើរលេងក្នុងច្បារជិតខាងសាលាខែត្រ ឮចៅហ្វាយស្រុកជាអាពុកក្បកក្បួលដូច្នេះ ក៏នាងឡើងទៅលើសាលាសួរថា ឪរើយមានការអ្វីឲ្យបារមណ៍បិត្តម្ល៉េះ នោះចៅហ្វាយស្រុកប្រាប់មកវិញថា កូនអើយអាពុកមានសេចក្ដីវេទនាណាស់ ដ្បិតគោញីរបស់ហ្លួងវាស្លាប់ទៅហើយ ឯព្រះករុណាបានផ្ដាំថា បើអ្នកណាចូលទៅក្រាបទូលថាមេគោនោះស្លាប់ ព្រះករុណានឹងឲ្យកាប់ក្បាលអ្នកនោះឥតប្រណី ហេតុនេះបានជាអាពុកមានធុរៈជាខ្លាំងណាស់ ពុំព្រមចូលទៅក្រាបទូលតាមសេចក្ដីទេ ឮដូច្នេះហើយនាងឆ្លើយមកវិញថា កុំឲ្យអាពុកព្រួយបិត្ត បើឪពុំហ៊ានទៅមិនឥតទេ ខ្ញុំសូមទៅជួស ចៅហ្វាយស្រុកឃាត់ ពុំព្រមឲ្យនាងទៅ ក្រែងស្ដេចឲ្យកាប់ក្បាល

នាងតាមព្រះបន្ទូល ឯចៅហ្វាយស្រុកឃាត់យ៉ាងណាក៏នាងពុំព្រមស្តាប់ បេះតែអង្វរឲ្យអាពុកបើកច្បាប់ឲ្យទៅ ដល់ចៅហ្វាយស្រុកទាល់គំនិតបើកឲ្យកូនទៅតាមប្រាថ្នាចិត្តទៅ នោះនាងរៀបដំណើរស្លៀកសំពតហូលល្អ បង់កកាំម៉ាព្រៃយ៉ាងល្អ ចូលទៅគាល់នៅអង្គុយស្ងៀមនឹងគេ នោះស្តេចទតឃើញនាងក្រមុំនោះរូបល្អណាស់មានព្រះបន្ទូលសួរថា នាងមកពីណាអញពុំដែលស្គាល់មុខសោះ នោះនាងក្រាបទូលថា ពរម្ចាស់ខ្ញុំម្ចាស់មិនមែននៅៗក្រុងទេ ខ្ញុំម្ចាស់នៅស្រុកក្រៀ ខ្ញុំម្ចាស់ជាកូនចៅហ្វាយស្រុកឈ្មោះ អ៊ុក នោះស្តេចមានព្រះបន្ទូលសួរថាចៅហ្វាយស្រុកអ៊ុកដែលចិញ្ចឹមមេគោអញនោះឬត នាងក៏ក្រាបទូលថាពរម្ចាស់ ខ្ញុំម្ចាស់ជាកូនចៅហ្វាយស្រុកនេះឯង នោះព្រះករុណាក៏ទ្រង់ព្រះសោមនស្សណាស់ សួរថាឯមេគោអញសព្វថ្ងៃវាយ៉ាងម៉េចទៅ នោះនាងក្រាបទូលថាសព្វថ្ងៃនេះ មេគោព្រះករុណាវាពុំបេះផឹកទឹកទេ ស្តេចឮដូច្នេះឆ្ងល់ណាស់សួរទៀតថាវាស៊ីស្មៅស្រួលទេ នោះនាងឆ្លើយឡើងវិញថា វាពុំបេះស៊ីស្មៅទេ ស្តេចសួរថា បើដូច្នេះមេគោអញវាធ្វើអ្វី នាងទូលថា វាពុំ

បេះបន្ទោរមូត្រទេ នោះស្តេចក៏ឆ្ងល់រឹតតែខ្លាំងឡើង សួរថាអ្វីទៀត ឯនាងក្រាបទូលថា មេគោនោះវាលែងបន្ទោរល្អក់ផង ស្តេចក៏ស្រែកថា ល្ហើយបុះមេគោអញវាពុំបេះផឹកទឹក ពុំបេះស៊ីស្មៅ លែងនោមលែងជុសអាចម៍ នោះដូចជាមេគោអញវាស្លាប់ទៅហើយ នាងក៏ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាមានព្រះបន្ទូលថា មេគោនោះវាស្លាប់ហើយ ឯខ្ញុំម្ចាស់មិនបានក្រាបទូលថាដូច្នេះសោះ ហេតុនេះមិនមែនជាក្បាលខ្ញុំម្ចាស់ទេដែលគួរកាប់នោះ លុះឮដូច្នេះហើយស្តេចក៏ទ្រង់ព្រះសំរួលពុំមានខ្ញាល់ឡើយ ទ្រង់ព្រះរាជទានរង្វាន់ទៅនាងវិញផង ហើយមានព្រះបន្ទូលត្រាស់បង្គាប់ឲ្យទឹមព្រះរាជរថ ១ នាំនាងវិលទៅផ្ទះវិញ ទ្រង់អភ័យទោសទាំងអស់ ។

រឿងគោញីចប់តែប៉ុណ្ណេះឯង ។

# រឿងពុទ្ធប្រវត្តិ បរិច្ឆេទទី ៧

# ព្រះរាជពង្សាវតារក្រុងកម្ពុជា (ត)

ព្រះមហាពិទូរក្រសេមគន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យរៀបរៀង

# ផ្លាស់ព្រះវង្សថ្មី

### រដ្ឋកាលព្រះថាងកោណ្ឌញ្ញភាគ៨

លុះមកដល់ពុទ្ធសករាជប្រមាណជាង ៩០០ (គឺក្នុងចុងគ្រិស្តសករាជ ៤០០) មានព្រាហ្មណ៍ម្នាក់ឈ្មោះ កោណ្ឌញ្ញ គឺខ្មែរដើមបុះមកអំពីប្រទេសឥណ្ឌៀ ត្រូវនឹងពេលដែលប្រទេសកម្ពុជាខ្វះព្រះមហាក្សត្រិយ៍ដ៏ទ្រង់គុណវុឌ្ឍិសមគួរនឹងគ្រងពិភព ព្រោះក្នុងសម័យនោះកើតក្បត់ខ្លាំងជាច្រើនលើក ពួកព្រះរាជវង្សដែលមានសតិបញ្ញាសមគួរ ក៏ត្រូវពួកក្បត់រំលាយបាត់បង់ទៅ អ្នកនគរព្រមគ្នាអញ្ជើញលោកកោណ្ឌញ្ញឡើងគ្រងពិភពកម្ពុជា ព្រោះលោកជាអ្នកមានក្រិត្យាភិនិហារព្រមដោយសិប្បវិជ្ជានឹងតេជានុភាពសមគួរជាម្ចាស់នៃលោក មានព្រះអគ្គមហេសីទ្រង់ព្រះនាមសោមាទេវី ។ កាលព្រះអង្គបានសោយរាជសម្បត្តិឡើងហើយទ្រង់យកព្រះហឫទ័យទុកដាក់បង្ហាត់បង្រៀនរាស្ត្រឲ្យបេះធ្វើការរកស៊ីក្នុងផ្លូវហត្ថកម្ម កសិកម្ម ពាណិជកម្ម នឹងសិល្បសាស្ត្រទាំងពួងដែលជាប្រយោជន៍នឹងលំអរក្នុងព្រះនគរតាមបែបឥណ្ឌៀ ដូចយ៉ាងជីកស្រះ ជីកគូ

និងសិតរូបភាពផ្សេង ៗ ដែលជាទីគោរពនឹងជាគ្រឿងលំអរជាដើម ។ ព្រះអង្គមានព្រះរាជបុត្រាព្រះរាជធីតាដែលប្រាកដព្រះនាម ២ អង្គគឺព្រះពាលាទិត្យនឹងនាងសរស្វតី ។ ព្រះពាលា-ទិត្យទ្រង់ឲ្យទៅនៅឯអនិន្ទិតបុរ នាងសរស្វតីបានជាភរិយាព្រាហ្មណ៍ឈ្មោះ វិស្វរូប ។ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិលុះអស់ព្រះជន្មាយុខ័យ ព្រះជន្មប៉ុន្មានមិនប្រាកដ ។

## រាជវង្សវរម័ន

### រដ្ឋកាលព្រះបាទសម្ដេចព្រះជយវរ្ម័ន

កាលព្រះបាទកោណ្ឌញ្ញរាជទិវង្គតហើយ ព្រះរាជវង្សរបស់ព្រះអង្គ ព្រះនាម ជយវរ្ម័ន បានសោយរាជ្យគ្រងពិភពក្រុងនគរបុរីតមក ព្រះរាជាអង្គនេះជាអ្នកក្លាហានក្នុងរាជសង្គ្រាមខ្លាំងណាស់ គឺទ្រង់ធ្វើព្រះរាជសង្គ្រាមនឹងក្សត្រិយ៍ ចាម ក្រុងចម្ប៉ាមានជ័យជំនះមានព្រះតេជានុភាពជាទីស្ញប់ស្ញែងនៃពួកបច្ចាមិត្រជិតខាងទូទៅ ទ្រង់នូវព្រះកិត្តិយសជា មហារាជា ទ្រង់បង

សម្ពន្ធមិត្តមេត្រីនឹងក្សត្រិយ៍ក្រុងរាជគ្រឹះហ (១) ក្សត្រិយ៍ប្រទេសនោះថ្វាយព្រះកិត្តិយសយ៉ាងខ្ពស់ថាជា "ក្សត្រិយ៍កំពូលសឹកក្នុងប្រទេសរវាងដែនឥណ្ឌានឹងចិន" (ការដែលតាំងព្រះមហាក្សត្រិយ៍តាងប្រទេសឲ្យមានយសសក្តិជាព្រះកិត្តិយសដូច្នេះ សូម្បីក្នុងសម័យបច្ចុប្បន្នក៏មានដែរ ដូចយ៉ាងសម្តេចព្រះចៅក្រុងអង់គ្លេសតាំងសម្តេចព្រះចៅមហាជិរាវុធ (ស្យាម) ជា "នាយពលត្រី" ព្រមទាំងគ្រឿងយសទាហាន ជាមេទ័ពជើងគោករបស់កងទ័ពអង់គ្លេស) (ន័យ ១ ទៀតប្រាកដក្នុងរាជពង្សាវតារលាវថា ក្នុងកាល ព.ស. ៩០០ ក្សត្រិយ៍ខ្មែរ (មិនចេញព្រះនាម) លើកទ័ពទៅកំចាត់ក្សត្រិយ៍លាវ ព្រះនាម ហ្វាំង ដែលរុករានចូលមកក្នុងស្រុកជៀងសែន ដ៏ជាអាណាខេត្តរបស់ខ្មែរ ចាប់ព្រះចៅហ្វាំងបានព្រមទាំងអគ្គមហេសី ត្រាស់ឲ្យនិរទេសទៅស្រុកវៀងស៊ុផ្លូង គិតមើលតាម

(១) ក្រុងរាជគ្រឹះហដែលថា មិនច្បាស់ជាប្រទេសណា តាមដែរធ្លាប់ចូលចិត្តមកក្នុងសម័យពុទ្ធកាល ព្រះបាទពិម្ពិសារ រួចព្រះបាទអជាតសត្រូវសោយរាជ្យនៅក្រុងរាជគ្រឹះហប្រទេសមគធគឺនៅក្នុងឥណ្ឌាកណ្ដាល តែមកវេលាក្រោយមានខ្មែរលាវសៀមខ្លះចូលចិត្តថា ក្រុងរាជគ្រឹះហ គឺប្រទេសចិន តែដោយអនុមានមើលគួរថា រាជគ្រឹះហក្នុងឥណ្ឌា ព្រោះក្សត្រិយ៍អង្គនេះមានព្រះវង្សទាក់ទិនមកអំពីឥណ្ឌា ។

បំនួនពុទ្ធសករាជប៉ុណ្ណោះឃើញថាប្រហែលជាត្រូវនឹងរជ្ជកាលនេះ ។ ព្រះបាទសម្តេចព្រះជយវរម័ន មហារាជ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់ព្រះជន្មាយុ៧៥ ។

### រដ្ឋកាលព្រះបាទសម្តេចព្រះឥទ្រវរម័ន

កាលព្រះបាទសម្តេចព្រះជយវរម័នទិវង្គតទៅហើយ ព្រះរាជបុត្រអង្គទី ២ ទទួលរាជសម្បត្តិតមក ទ្រង់ព្រះនាមក្នុងសុវណ្ណបត្រថា ឥទ្រវរម័ន ។

សម័យនោះ ប្រទេសខ្មែរមានអាណាខេត្តធំទូលាយ គឺរួមទាំងស្រុកកុសង់ស៊ុីនទាំងស្រុកសៀមសព្វថ្ងៃនេះទាំងមូលជាអាណាខេត្តនៃប្រទេសកម្ពុជា ។ លុះមកដល់ ព.ស. ១០០០ ប្លាយ (មុនគ្រិស្ត ៥០០) មានរាស្ត្រនៅទន្លេធំក្បែតផែនដី តាំងឥស្សរភាពជាក្សត្រិយ៍នៅស្រុកមួយអន្លើហៅតាមសំដីបិនថា "បិន្លា" តែអ្នកដែលសាងក្រុងបិន្លាគោនោះមិនប្រាកដនាម សម័យនោះប្រហែលជាប្រជួបវេលាដែលព្រះបាទសម្តេចព្រះឥទ្រវរម័នប្រឈួនធ្ងន់ ហើយមិនយូរប៉ុន្មានក៏ស្តេចទិវង្គតទៅ វេលាទិវង្គតទៅហើយ ស្រុកឯទៀត ៗ ឃើញ

បានឱកាសក្នុងពេលរាជការរវល់ធំ ទាំងឃើញអ្នកស្រុកទន្លេធំតាំងខ្លួនបានឡើងហើយជាតួយ៉ាង ក៏នាំគ្នាប្រកាសតាំងឥស្សរភាពឡើងដោយសព្វខ្លួនជាច្រើនស្រុក ។

ក្នុងកាល ព.ស. ១០០២ ប្រាកដក្នុងរាជពង្សាវតារលាវថា ក្សត្រិយ៍ខ្មែរទ្រង់នាម "កាឡវណ្ណតិស្ស" ជារាជបុត្រព្រះបាទកាកពត្រទ្រង់សាងក្រុង "លវបុរ" ដែលយើងហៅថានគរស្រីលវោ សឹងនៅក្នុងដែនសៀមសព្វថ្ងៃនេះ ទីក្រុងនោះមានបុរាណវត្ថុដ៏ជាដំណែលសល់នៅដល់វេលានេះ គឺប្រាសាទថ្ម កំផែងថ្ម ព្រះពុទ្ធរូបស្នាដៃខ្មែរ និងសិលាចារិកអក្សរខ្មែរ ។ កន្លងអំពីនោះមក១៨ឆ្នាំ គឺក្នុង ព.ស. ១២០០ ប.ស. ២៥ ក្សត្រិយ៍ខ្មែរនៅក្រុងលវបុរ ទ្រង់តាំងព្រះរាជធីតាព្រះនាម ចាមទេវី(១)ទៅគ្រងនគរហរិភុញ្ជយ គឺមណ្ឌលពាយព្យរបស់សៀមសព្វថ្ងៃនេះ តែក្សត្រិយ៍ក្រុងលវបុរនេះមើលទៅមិនមែនជាពួកដែលក្បត់តាំងឥស្សរភាពក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះរុទ្រវរម័ននោះទេ ។

---

(១) ចូរមើលក្នុងរឿងចាមទេវីវង្ស ។

### រជ្ជកាលព្រះបាទសម្ដេចព្រះភវវរម័ន

កាលសម្ដេចព្រះរុទ្រវរម័នទិវង្គតហើយ ព្រះភវវរម័ន ជារជ្ជទាយាទទទួលរាជសម្បត្តិ តែមុននឹងរាជាភិសេកពេញទី បានស្ដេចលើកទ័ពហ្លួងទៅកម្រាបពួកក្បត់នៅទន្លេធំ និងពួកឯទៀតទាំងប៉ុន្មានស្រុកឲ្យរាបទាប ឱនាំទោសមកសូមជ្រកក្រោមម្លប់ព្រះពោធិសម្ភារបារមីដូចអំពីដើម ស្រេចហើយស្ដេចប្រាព្ធាភិសេកឡើងសោយរាជសម្បត្តិក្នុងកាល ព.ស. ១១៤៣ ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់អស់ព្រះជន្មាយុខ័យ ។ វេលាសុគតហើយគេថ្វាយព្រះនាមព្រះបរមសពជា "សិវបទ" ។

### រជ្ជកាលព្រះបាទសម្ដេចព្រះមហិន្ទ្រវរម័ន

កាលព្រះបាទសម្ដេចព្រះភវវរម័នទិវង្គតទៅហើយ ព្រះអនុជាធិរាជរបស់ព្រះអង្គ ព្រះនាមដើម ចិត្រសេនកុមារ បានទទួលរាជសម្បត្តិជំណាងសម្ដេចព្រះជេដ្ឋាធិរាជ ព្រះនាមក្នុងសុវណ្ណបត្រថា មហិន្ទ្រវរម័ន ។ កាលទ្រង់បានសោយរាជ្យឡើងហើយ ទ្រង់ភាតវង់ព្រះរាជអាណាខេត្តចេញទៅទិសខាងជើងដល់ទៅស្រុកខេមរដ្ឋ នៅក្នុងរវាងដែនលាវសព្វថ្ងៃនេះ

ទ្រង់នូវព្រះតេជានុភាពជា មហារាជ ដូចសម្តេចព្រះជេដ្ឋាធិរាជ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់ព្រះជន្មាយុក្ស័យ គឺទិវង្គត ក្នុងកាល ព.ស. ១១៦០ ។

### រជ្ជកាលព្រះបាទសម្តេចព្រះឥសាណវរ្ម័ន

កាលព្រះបាទសម្តេចព្រះមហេន្ទ្រវរម័នទិវង្គតទៅហើយព្រះឥសាណវរម័នបានទទួលរាជសម្បត្តិស្នងព្រះរាជបិតាតមក ក្នុងកាល ព.ស. ១១៦០ ដល់ ១២០៨ (គ.ស.៦១៧-៦៦៥) ក្នុងរជ្ជកាលនេះទ្រង់ចាត់គ្រឿងរាជបណ្ណាការឲ្យរាជទូតនាំទៅថ្វាយព្រះចៅក្រុងរាជគ្រឹះហ(ឥណ្ឌៀឬចិន) សូមចងស្ពានមេត្រីតាមប្រវេណីក្សត្រិយ៍អំពីបូរាណ ដើម្បីឋាវរនៃវឌ្ឍសាសនកិច្ច ស្តេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់អស់ព្រះជន្មាយុក្ស័យ ។

### រជ្ជកាលព្រះបាទសម្តេចព្រះជយវរ្ម័នទី១

កាលសម្តេចព្រះឥសាណវរម័នទិវង្គតទៅហើយ ព្រះជយ-វរម័នបានទទួលរាជសម្បត្តិតមក (ដើម្បីកុំឲ្យច្រឡំនឹងរជ្ជកាលព្រះជយវរម័នខាងដើម ទើបរាប់រជ្ជកាលនេះជាទី១) ក្នុងកាល ព.ស. ១២០៨ ។ តាមសេចក្តីកត់ហេតុរបស់ចិនថា ក្នុង

ចុងរជ្ជកាលនេះ ប្រទេសកម្ពុជាបែកជា ២ អាណាចក្រមានព្រះរាជាគ្រងផ្សេងគ្នា គឺអាណាចក្រវ្យាធបុរៈដែលជាស្រុកដើម ១ អាណាចក្រសម្ភុបុរ នៅក្នុងខណ្ឌឆ្លូង ខេត្តកំពង់ធំ ១ តែមិនយូរប៉ុន្មាន កាលព្រះជ័យវរម័ន ព្រះបាទក្រុងវ្យាធបុរទិវង្គតទៅហើយ ព្រះភាគទាំងពីរនោះត្រឡប់រួមជាអាណាចក្រតែមួយទៅវិញដោយអានុភាពនៃព្រះរាជេន្ទ្រវរម័ន ។

### រជ្ជកាលព្រះអាធសម្តេចព្រះរាជេន្ទ្រវរម័នទី ១

កាលសម្តេចព្រះជ័យវរម័នទី ១ ទិវង្គតទៅហើយ ព្រះរាជបុត្រព្រះនាម. រាជេន្ទ្រវរម័ន ជារជ្ជទាយាទបានទទួលរាជ-សម្បត្តិតមកកាលរាជាភិសេករួចហើយ ស្តេចលើកកងទ័ពហ្លួងទៅកម្រាបក្រុងសម្ភុបុរបានសម្រេច រួមជាអាណាចក្រតែ ១ មកវិញដូចអំពីដើម ។

អាស្រ័យហេតុដែលប្រទេសកម្ពុជាកំពុងចលាចលខាងក្នុងដូច្នេះ ជាធម្មតាអ្នកប្រទេសក្រៅតោងបើកភ្នែកមើលមកតែរាល់គ្នា កាលឃើញឱកាសស្រួលក៏ម្នីម្នាមកនឹងក្រសោបយក

គ្រានោះពួកថាមលើកទ័ពជើងទឹកចូលមកលុកលុយប្លន់យកទ្រព្យសម្បត្តិពេញពាសទាំងប្រទេសកម្ពុជា ខ្មែរស៊ូថាមមិនបានក៏ចោងព្រមចំណុះថាម តែមិនយូរប៉ុន្មានប្រហែលជា ១ ឆ្នាំ ខ្មែរក៏កែខ្លួនឡើងវិញបានក្នុងរជ្ជកាលព្រះជ័យវរ្ម័នទី ២ ។

### រជ្ជកាលព្រះបាទសម្តេចព្រះជ័យវរ្ម័នទី ២

កាលថាមសង្កត់ខ្មែរបានដូច្នោះហើយ មានព្រះអង្គម្ចាស ១ អង្គដែលប្រាកដព្រះនាមក្នុងវេលារាជាភិសេកហើយជា ជ័យវរ្ម័ន ស្តេចរួបរួមកងទ័ពខ្មែរបានល្មមសមគួរហើយ ក៏បេញច្បាំងកំចាត់ពួកថាមឲ្យអបរាជ័យទៅ ទាំងតាមទៅវាយបានប្រទេសថាមមកជាស្រុកចំណុះវិញផង ។ កាលស្រេចការព្រះរាជសង្គ្រាមហើយ ត្រាស់ឲ្យផ្លាស់រាជធានីចេញអំពីនគរបុរីទៅតាំងនៅស្រុកសម្បូរបុរ (សម្បូរព្រៃគុក) នៅក្នុងខណ្ឌដែបខេត្តកំពង់ធំសព្វថ្ងៃនេះ ទឹងត្រាស់ឲ្យធ្វើពិធីប្រាប្តាភិសេកសោយរាជសម្បត្តិនៅក្រុងថ្មីនោះ ក្នុងកាល ព. ស. ១៣៤៥ ប្រាកដព្រះកិត្តិយសជា មហារាជ ឬរាជាធិរាជ មានព្រះរាជ

អាណាខេត្តធំទូលាយ គឺខាងលើទៅទល់ត្រឹមប្រទេសភូមា ខាងក្រោមរួមទាំងប្រទេសចាម (គឺប្រទេសយួនសព្វថ្ងៃនេះ) ទាំងមូលមកផង ។ ព្រះមហាក្សត្រិយ៍អង្គនេះមានព្រះក្រិត្យាភិនិហារនឹងតេជានុភាពរឹងប្ញទ្ធិមោះហ៊ាមាផុតវិស័យ និងពណ៌នាឲ្យសព្វគ្រប់ ព្រះអង្គបានសាងប្រាសាទវត្តទុកព្រះកេរ្តិ៍ទុកដល់សព្វថ្ងៃនេះជាមហាអស្ចារ្យពន់ប្រមាណ ដែលនាំឲ្យអ្នកខ្លះមមើរទៅថា ទេពនិមិត្ត តាមដែលដឹងបានដោយអក្សរចារិកក្នុងវេលានេះ គឺទ្រង់សាងក្រុងសម្បូរបុរ ១ ប្រាសាទបេងមាលានៅក្នុងខណ្ឌជីក្រែង ខេត្តកំពង់ធំ ១ ប្រាសាទបន្ទាយឆ្មារនៅក្នុងខណ្ឌស្វាយចេក ខេត្តបាត់ដំបង ១ ប្រាសាទព្រះខាន់នៅជាខាងឥសាណក្រុងនគរធំក្នុងខេត្តសៀមរាប ១ ក្រុងមហិន្ទ្របុរ នៅក្នុងខេត្តសៀមរាប ១ ។ល។ ក្នុងបុរាណវត្ថុទាំង ៤ យ៉ាងនេះ ៣ ខាងដើមសូមលើកទុក នឹងពណ៌នាបំពោះរឿងរ៉ាវក្រុងមហិន្ទ្របុរឲ្យពិស្តារបន្តិចតទៅទៀត គឺកាលព្រះបាទសម្តេចព្រះជ័យវរ្ម័នមហារាជទី ២ រាជាភិសេករួចហើយ ទ្រង់ឃើញទី ១ កន្លែងនៅជាខាងជើងទន្លេសាប ជាទីជ័យភូមិល្អ

សមគួរជាទីតាំងព្រះរាជនិវេស ទើបត្រាស់ឲ្យសាងរាជធានីទីក្រុងនៅទីនោះដ៏ហើយដោយសិលា ឲ្យឈ្មោះជា "មហិន្ទ្រ-បុរ" ដែលយើងហៅថានគរធំក្នុងកាលឥឡូវនេះ របស់ដែលសាងក្នុងរជ្ជកាលរបស់ព្រះអង្គ គឺកំផែងថ្មរជុំវិញ នឹងជីកគូពីខាងក្រៅកំផែងជុំវិញ នឹងសាងប្រាសាទបាយននៅត្រង់រយៈពាក់កណ្ដាលព្រះរាជវាំង ឧទ្ទិសថ្វាយក្នុងព្រះពុទ្ធសាសនាលទ្ធិមហាយាន ហើយឆ្លាក់រូបភាពរឿងព្រះរាជពង្សាវតារត្រង់ដែលព្រះអង្គច្បាំងនឹងក្សត្រិយ៍ចាមនៅព្រះរបៀងទី ១ នៅព្រះរបៀងទី ២ ឆ្លាក់រឿងរ៉ាវផ្សេង ៗ ក្នុងសាសនាព្រាហ្មណ៍ខ្លះរឿងរ៉ាវក្នុងព្រះពុទ្ធសាសនាប៉ែកមហាយានខ្លះ នឹងសាងព្រះរាជនិ-វេសនៅក្នុងកំផែងជាន់ទី ២ គឺត្រង់បរិវេណប្រាសាទវិមានអា-កាស ។ ទីព្រះរាជវាំងនោះជា ៤ ជ្រុងចតុរសហើយធំទូលាយណាស់ បណ្ដោយពីកំផែងខាងកើតទៅកំផែងខាងលិចចម្ងាយ ៣០០០ ម៉ែត្រ គឺ ៣ គីឡូម៉ែត្រ ទទឹងពីកំផែងខាងត្បូងទៅកំផែងខាងជើង ៣០០០ ម៉ែត្រដូចគ្នា ប្រាសាទពិធូរនឹងឃ្លាំងទាំងពីរក៏ប្រហែលជាសាងក្នុងរជ្ជកាលនេះដែរ បំណែក

ឯប្រាសាទក្រៅពីនេះ ជារបស់សាងក្នុងរជ្ជកាលក្រោយ ៗ មក មិនតែប៉ុណ្ណោះ បានទ្រង់ឲ្យសាងសាលារៀនវិជ្ជាការផ្សេង ៗ ជាច្រើន តាំងព្រាហ្មណ៍ម្នាក់ជាអាចារ្យធំជាអ្នកបង្រៀនក្នុងផ្លូវព្រហ្មញ្ញសាសនា និងសិល្បវិជ្ជាក្នុងផ្លូវលោកដែលជាគ្រឿងឲ្យបំរើនរុងរឿងក្នុងព្រះនគរ ។

ស្តេចស្ថិតនៅក្នុងរាជសម្បត្តិមកដល់ ព.ស. ១៤១២ ទើបទិវង្គត រួមព្រះជន្មដែលនៅក្នុងរាជសម្បត្តិបាន ៦៧ ឆ្នាំ កាលទិវង្គតទៅហើយ គេថ្វាយព្រះនាមជាព្រះកិត្តិយសសម្រាប់ហៅព្រះបរមសពក្នុងព្រះកោដ្ឋនោះថា "បរមេស្វរ" ហេតុនោះ ទើបជាប់ជាប្រវេណីដរាបដល់សព្វថ្ងៃនេះ ។

### រជ្ជកាលព្រះបាទសម្តេចព្រះជយវរ្ម័ន ទី ៣

កាលព្រះបាទសម្តេចព្រះជយវរ្ម័ន បរមេស្វរ ទិវង្គតទៅហើយ ព្រះរាជបុត្ររបស់ព្រះអង្គទទួលរាជសម្បត្តិតមក ទ្រង់ព្រះនាមជា ជយវរ្ម័ន ដូចព្រះរាជបិតា តែរាប់ជាទី ៣ ក្នុងកាល ព.ស.១៤១២ ដល់ ១៤២០ ត្រូវនឹង គ.ស. ៨៦៩-

៨៧៧ រួមព្រះជន្មនៅក្នុងរាជសម្បត្តិបាន ១៨ឆ្នាំ ទើបសុគត ហើយគេថ្វាយព្រះនាមព្រះបរមសពថា "វិស្ណុលោក" ។

## រជ្ជកាលព្រះបាទសម្ដេចព្រះរាជេន្ទ្រវរ្ម័នទី ១

រជ្ជកាលព្រះជយវរ្ម័នទី ៣ ទិវង្គតទៅហើយព្រះរាជេន្ទ្រ-វរ្ម័នហៅដោយក្ដី ឥន្ទ្រវរ្ម័ន ត្រូវជារាជភាគិនេយ្យនៃសម្ដេចព្រះជយវរ្ម័នទី ២ បានឡើងសោយរាជសម្បត្តិតមកក្នុងកាល ព.ស. ១៤២០ ដល់ ១៤៣១ គ្រានោះពួករាជវង្សព្រះជ័យវរ្ម័នទី ៣ មិនព្រមឱនលំទោនជ្រកម្លប់ព្រះពោធិសម្ភារបារមី ក៏បង្ករហេតុបាស់បោររឹងទទឹងផ្សេង ៗ តែក៏មិនជាផលសម្រេច ក៏គោងស្ងប់ទៅឯង ។ ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិបាន ១១ ឆ្នាំ ទើបទិវង្គត ទើបសុគតហើយគេថ្វាយព្រះនាមព្រះបរមសពថា ឥស្វរលោក ។

## រជ្ជកាលព្រះបាទសម្ដេចព្រះយសោវរ្ម័នទី ២

កាលសម្ដេចព្រះឥន្ទ្រវរ្ម័នទី ១ ទិវង្គតទៅ ព្រះយសោវ-រ្ម័នរាជឱរសបានទទួលគ្រងពិភពតមក ក្នុងកាល ព.ស.

១៤៣២ ដល់ ១៤៥៣ (គ.ស.៨៨៩–៩០៨) គ្រានោះ ពួកព្រះរាជវង្សព្រះជយវរម័នទី៣ សំដែងអាការទោមនស្សនឹងបង្ករហេតុចលាចលឡើងម្តងទៀត តែក៏មិនផុតអំពីព្រះតេជានុភាពនៃសម្តេចព្រះយសោវរម័នទៅបាន ។ ព្រះមហាក្សត្រិយ៍អង្គនេះប្រាកដក្នុងសិលាចារឹកថា មានព្រះអភិនិហារនឹងព្រះតេជានុភាពនឹងស្ទាត់ក្នុងផ្លូវយុទ្ធវិធីជាយ៉ាងក្រៃពេក កាលទ្រង់បានរាជាភិសេកឡើងហើយ ក៏ទ្រង់កម្រាបពួករាជវង្សព្រះជយវរម័នទី ៣ ឲ្យបាក់បបខ្លបខ្លាចព្រះបារមី នឹងទ្រង់ធ្វើព្រះរាជសង្គ្រាមនឹងប្រទេសចាមជាច្រើនលើកទាំងផ្លូវគោកទាំងផ្លូវទឹក ចាប់បានទូកចម្បាំងចាមរាប់ដោយកោដិ ៗ ធ្វើឲ្យពួកចាមរញមព្រមចុះចូលជាស្រុកចំណុះ មិនតែខ្លាំងពូកែក្នុងផ្លូវយុទ្ធវិធីប៉ុណ្ណោះ សូម្បីក្នុងផ្លូវវិជ្ជាសាស្ត្រ នឹងផ្លូវរដ្ឋបសាសនកិច្ចទាំងពួងក៏ទ្រង់ចេះនឹងប្រសប់គ្រប់យ៉ាង បានរៀបចំទំនុកបំរុងព្រះនគរឲ្យរុងរឿងឡើងជាអស្ចារ្យ មានទាំងសាលារៀនបំណេះវិជ្ជានឹងសាលាព្យាបាលរោគសម្រាប់អ្នកនគរ ទ្រង់កំចាត់ពួកចោរលួចប្លន់ឲ្យរាបទាបសាបសូន្យអំពីព្រះនគរ ទ្រង់

ធ្វើសេចក្ដីសង្គ្រោះដល់អាណាប្រជារាស្ត្រ ឲ្យយកពន្ធស្ងួយសារអាករតាមព្រះរាជកំណត់ដែលល្មមសមគួរ ប្រទេសសម្បូណ៌ដោយធនសម្បត្តិភោគទ្រព្យនឹងរាប់នឹងប្រមាណពុំបាន ប្រជារាស្ត្រនៅជាសុខក្សេមក្សាន្តសព្វទិវារាត្រី មានប្រទេសរាជរាល់បូរីនាំស្ងួយសារអាករមកបង្គំគាល់ថ្វាយល្អងធុលីព្រះបាទជាអាបិណ្ឌ ។

បូរាណវត្ថុដែលទ្រង់សាងទុកដែលអាចដឹងបានក្នុងវេលានេះ គឺទ្រង់សាងប្រាសាទបាយនបែមឋយឡើងទៀត ហើយឲ្យឈ្មោះជាថ្មី "ប្រាសាទយសោធរគិរី" នឹងផ្លាស់ឈ្មោះក្រុងមហិន្ទ្របុរ ជាក្រុងយសោធរបុរ ទ្រង់សាងប្រាសាទ ១ ពួកនៅលើកំពូលភ្នំបាខែងឲ្យឈ្មោះថា "យសោធរេស្វរ" នឹងទ្រង់សាងវត្តសុគតអាស្រមដែរហៅថា ទេពប្រណម្យ នៅខាងជើងព្រះរាជមណ្ឌីរ នឹងសាងប្រាសាទវិមានអាកាសនៅកណ្ដាលព្រះរាជមណ្ឌីរ តែមិនទាន់ហើយស្រេច ក៏ទទួលដល់ពេលទិវង្គត នៅក្នុងរាជសម្បត្តិបាន ២៥ ឆ្នាំ វេលាគង់ព្រះជន្មនៅប្រាកដព្រះកិត្តិយសជា មហារាជា ឬរាជាធិរាជ វេលាសុគតទៅហើយគេថ្វាយព្រះនាមជា ព្រះបរមសិវលោក ។

## រជ្ជកាលព្រះបាទសម្តេចព្រះហស៌វរម័នទី ១

កាលព្រះបាទសម្តេចព្រះយសោវរម័ន បរមសិវលោក ទិវង្គតទៅហើយ ព្រះបរមឱរសាធិរាជ ព្រះនាមហស៌វរម័នបាន ទទួលរាជសម្បត្តិតមក អំពី ព.ស. ១៤៥៣ ដល់ ១៤៧៣ ក្នុងរជ្ជកាលនេះទ្រង់សាងរបស់ដែលដឹងបានក្នុងវេលានេះ គឺ ប្រាសាទវិមានអាកាសដែលព្រះរាជបិតាសាងមិនទាន់ហើយ បង្ហើយឡើង ហើយយកព្រះបរមអដ្ឋិធាតុសម្តេចព្រះរាជបិតា ទៅប្រតិស្ឋានទុកនៅទីនោះ ព្រះរាជាអង្គនេះមានព្រះតេជះបារមី ប្រហែលនឹងព្រះរាជបិតា មានសិលាចារិកនៅប្រាសាទបន្ទាយ-ក្តីជាពាក្យសរសើរព្រះបារមីសម្តេចព្រះឥន្ទ្រវរម័នទី ១ ជាព្រះរាជបិតាសម្តេចព្រះយសោវរម័នជាព្រះរាជបុត្រ សម្តេចព្រះហស៌វរម័នជាព្រះរាជនត្តាដោយប្រការផ្សេងៗមានដើមថា សុទ្ធតែទេពបុត្តិបុះមកកើត ។ វេលាទិវង្គតហើយគេថ្វាយព្រះនាមជាព្រះរុទ្រលោក ។

## ពិធីបន់សុំកូន

ប្រទេសកម្ពុជានេះមានប្រពៃណីមួយយ៉ាងហៅថា "ពិធីបន់សុំកូន" ជាកិច្ចដែលអ្នកគ្មានកូនខ្លះ តែងធ្វើមកជារឿយ ៗ តែបើនឹងស្រាវរកទៅទៀត ក៏នឹងឃើញប្រទេសឯទៀត ដូចយ៉ាងប្រទេសឥណ្ឌៀជាដើមធ្លាប់ធ្វើមកហើយដែរ តាំងអំពីសម័យមុនពុទ្ធកាល ដរាបមកដល់ពុទ្ធកាល និងក្រោយពុទ្ធ-កាលមកទៀត ។

ក្នុងសម័យទ្វាបរយុគ (មុនពុទ្ធកាល) នោះ គឺរឿងរា-មាយណ ដែលខ្មែរយើងហៅថា រាមកេរ្តិ៍ សឹងមានសេចក្ដីថា គ្រានោះព្រះបាទទសរថ ព្រះរាជាក្រុងស្រីអយុធ្យា ប្រ-ទេសកោសលគ្មានព្រះរាជបុត្រជាដំណាសន្តតិវង្ស ទើបត្រាស់ឲ្យអញ្ជើញព្រះវសិដ្ឋមុនី អធិបតីបរោហិត ១ ព្រះវាមទេពមុនីភូឈួយបរោហិត ១ ព្រះសុយញ្ញមុនី ១ ព្រះជ្វាលីមុនី ១ ព្រះកាស្យបមុនី ១ និងឥសីជីព្រាហ្មណ៍ឯទៀតជាច្រើន មកប្រឹក្សាការដើម្បីនឹងធ្វើពិធីបូជាយញ្ញដល់ទេវតា សូមព្រះរាជបុត្រ



ទីប្រឹក្សាយល់ព្រមតាមព្រះអធ្យាស្រ័យ ។ វេលាកំពុងបូជាយញ្ញ ប្រាកដឃើញអមនុស្ស ១ នាក់ រូបរាងខ្មៅដ៏បង តែមុខក្រហម ស្លៀកពាក់ពណ៌ក្រហម ខ្លួនពេញទៅដោយរោមបីដូចជារាជសីហ៍ កាន់យកថោបាយាសដុសឡើងមកអំពីកណ្ដាលគំនរភ្លើងពិធីនោះ ប្រកាសប្រាប់ថា ខ្លួនជាទូតរបស់ព្រះប្រជាបតិ នាំបាយាសនេះមកថ្វាយ ដើម្បីឲ្យព្រះមហេសីសោយ គង់នឹងបានព្រះរាជឱរសដូចប្រាថ្នា ។ ព្រះបាទទសរថទ្រង់ទទួលៈថាបាយាសមកហើយ ទេវទូតនោះក៏អន្តរធានបាត់ទៅ ។ ទ្រង់យកបាយាសនោះមកបែងជា ៤ ភាគ ព្រះរាជទានដល់ព្រះអគ្គមហេសីទាំង ៣ នាង គឺប្រទាននាងកោសល្យា នឹងនាងកៃកេយី មួយអង្គ ១ ភាគ នាងសុមិត្រា ២ ភាគតែ ១ អង្គឯង ។ ព្រះនាងទាំងនោះក៏ទ្រង់គភ៌ប្រសូតិព្រះរាជឱរសរៀងខ្លួន នាងកោសល្យា បានព្រះរាជឱរស ១ អង្គ ព្រះនាមជា “រាម”, នាងកៃកេយី បាន ១ អង្គដែរ ព្រះនាមជា ភរត, នាងសុមិត្រាបាន ២ អង្គ ព្រះនាមជា លក្ស្មណ៍ ១ សត្រុឃ្នៈ ១ ។ វេលាក្រោយមកព្រះរាម

នឹងព្រះលក្ខណ៍ បានច្បាំងកម្ចាត់ស្តេចយក្សឈ្មោះ រាពណ (រាវណា) នៅលង្កាទ្វីប ។

ក្នុងសម័យពុទ្ធកាល មានរឿងសេដ្ឋីម្នាក់នៅក្នុងប្រទេសឥណ្ឌា គ្មានកូន បានធ្វើពិធីបន់សុំកូននឹងនាក់តាព្រះជ្រៃ ក៏កើតបានជាកូនប្រុសពីរនាក់ កូនបងឈ្មោះមហាកាល កូនប្អូនឈ្មោះចុល្លកាល ។ វេលាក្រោយមក មហាកាលបានបួសជាភិក្ខុក្នុងព្រះពុទ្ធសាសនា បានសម្រេចព្រះអរហត្តជាព្រះអរហន្ត ហើយប្រាកដនាមតាមដែលសហធម្មិក គឺអ្នកបួសផងគ្នាហៅថា បក្កុបាល ។ រឿងនេះមានមកក្នុងគម្ពីរធម្មបទដ្ឋកថា ។

នឹងរឿងនាងសុជាតា ជាធីតាសេដ្ឋីម្នាក់នៅស្រុកឧរុវេលសេនានិគម មានប្ដីហើយគ្មានកូន នាងបានបន់សុំកូននឹងអារុក្ខទេវតា ដែលអាស្រ័យនៅដើមពោធិព្រឹក្ស (គឺដើមពោធិដែលព្រះអង្គត្រាស់) នោះសម័យក្រោយមកនាងក៏មានកូនដូចដែលសុំ ។ ថ្ងៃ ១ នោះនាងធ្វើមធុបាយាសនឹងយកទៅថ្វាយអារុក្ខទេវតាដែលនាងបន់នោះ ទទួលជួបនឹងព្រះពុទ្ធអង្គស្តេចគង់

នៅក្រោមដើមពោធិនោះ នាងស្មានថាជាទេវតាដំណែងកាយឲ្យប្រាកដចុះមកទទួលគ្រឿងដង្វាយរបស់ខ្លួន ក៏លើកថាសមធុបាយាសបង្អោនថ្វាយទៅថ្វាយ ក្នុងថ្ងៃដែលព្រះអង្គបានត្រាស់នោះឯង ។ រឿងនេះមានមកក្នុងគម្ពីរបឋមសម្ពោធិកថា ។

ប្រជាជនជាតិខ្មែរក្តី ជាតិដទៃក្តី បណ្តាដែលធ្វើពិធីបន់ស្រន់ ប្រហែលជាបានជ្រាបនឹងជឿរឿងទាំងឡាយដែលពណ៌នាមកហើយខាងលើនេះទេដឹង ទើបបាននាំគ្នាធ្វើត ៗ មកដរាបដល់សព្វថ្ងៃនេះ ។

របៀបបន់តាមដែលពួកខ្មែរយើងធ្វើមកដូច្នេះ

មានបុរសស្ត្រីខ្លះ ដែលបាននៅជាស្វាមីភរិយាផងគ្នាមកអស់កាលជ័យូរហើយ ៗ គ្មានកូន តែមិនអាចដឹងបានជាប្រាកដថា "ខ្លួនជាអាឬមិនជាអា" កាលមានសេចក្តីប្រាថ្នាចង់បានកូនខ្លាំងក្លាឡើងក៏នាំប្តីប្រពន្ធទៅបន់ស្រន់កូន បំពោះព្រះពុទ្ធរូបវត្តនេះវត្តនោះ តាមដែលខ្លួនដឹងឮថា មានព្រះបារមីស្ថិតពូកែសក្តិសិទ្ធិ អាចប្រសិទ្ធិឲ្យសម្រេចតាមដែលសុំ អ្នកខ្លះក៏ទៅបន់ស្រន់នឹងទេវរូប ១ យ៉ាងដែលហៅថា "យាយទេព" អ្នកខ្លះ

ក៏ទៅបន់សុំនឹងអ្នកតា តែវត្ថុពីរខាងក្រោយ ក្នុងសម័យនេះមិនសូវមានអ្នកបន់ទេ ប្រើនបន់តែនឹងព្រះពុទ្ធរូប ៗ ដែលគេនិយមរាប់អានថា ពូកែសក្តិសិទ្ធិនោះមាននៅគ្រប់ខេត្តក្នុងប្រទេសកម្ពុជា ។

វេលានឹងទៅបន់ គេរមែងនាំយកគ្រឿងសក្ការៈទៅថ្វាយផង គ្រឿងសក្ការៈនោះមានផ្សេង ៗ គ្នា ខ្លះតិច ខ្លះច្រើន ខ្លះល្អ ខ្លះអន់បន្តិចមក ខ្លះថ្វាយវត្ថុនេះ ខ្លះថ្វាយវត្ថុនោះ តែកំណត់ដោយច្រើន គេច្រើនធ្វើជាស្លាធម៌ ១ គូ (គឺជាស្លាធម៌ដែលធ្វើអំពីដើមបេកក៏មាន ដែលធ្វើអំពីផ្លែដូងក៏មាន) នឹងទៀនធូបភ្ញីផ្កា ។ ដល់វេលាហើយគេក៏តាក់តែងកាយឲ្យស្អាតប្រដាប់ប្រដាដោយគ្រឿងសំលៀកបំពាក់ថ្មី ៗ អ្នកខ្លះក៏បានទាំងសមាទានសីលអំពីភិក្ខុសង្ឃជាមុនហើយ ទើបនាំគ្នាយកគ្រឿងដង្វាយអំបាលនោះទៅកាន់ទីព្រះពុទ្ធរូប ។ ដល់ហើយយកទៀនធូបអុជ ដោតនៅស្លាធម៌លើកថ្វាយទៅ ចយមកក្រាបថ្វាយបង្គំ ៣ ដង ហើយលើកដៃប្រណម្យតាំងសច្ចាប្រណិធានសុំទាំងពីរនាក់ ដោយបន្លឺវាចាឲ្យឮឡើង ល្មមត្រចៀកខ្លួនស្តាប់

ឮច្បាស់ថា "ខ្ញុំព្រះអង្គទាំងពីរនាក់នេះបានគ្នាជាស្វាមីភរិយាមក ជាយូរឆ្នាំហើយ តែមិនមានកូនដល់ ១ នាក់សោះ ឥឡូវខ្ញុំព្រះអង្គមានប្រាថ្នាចង់បានកូនជាយ៉ាងក្រៃពេក ទើបបបួលគ្នានាំយកគ្រឿងសក្ការៈបូជាអំបាលនេះមកថ្វាយ ដោយអំណាចព្រះបារមីរបស់ព្រះអង្គ សូមឲ្យខ្ញុំមានកូន (ចង់បានកូន ១ ឬ ២ ប្រុសឬស្រីក៏ថាទៅតាមត្រិវការ ហើយមានពាក្យប្តេជ្ញាទុកនឹងព្រះពុទ្ធរូបនោះថា) បើបានកូនពិតតាមដែលសុំហើយនឹងថ្វាយ......" គឺនឹងថ្វាយរបស់នេះរបស់នោះ តាមដែលខ្លួនអាចនឹងថ្វាយបាន របស់ដែលនឹងថ្វាយបូជាគុណបុណ្យបារមីក្នុងលើកក្រោយនេះ ក៏មិនមានបទកំណត់បំពោះវត្ថុនេះវត្ថុនោះដែរ ស្រេចហើយតែនឹងអាច គេបន់ថ្វាយទង់ក៏មាន ថ្វាយសំពត់ពិតានក៏មាន ថ្វាយអង្រឹះព្រៃក៏មាន ប្រគំភ្លេងថ្វាយក៏មាន បន់ជួសជុលវិហារដោយឯកទេស ឬទាំងមូលក៏មាន បន់បិទមាសអង្គព្រះពុទ្ធរូបនោះក៏មាន ។ បើជារូបយាយទេពនឹងតាគេច្រើនបន់ប្រគំភ្លេងថ្វាយ នឹងថ្វាយមាន់ស្ងោរ ទាស្ងោរ ក្បាលជ្រូកស្ងោរជាដើម ។ កាលបានកូនសមដូចដែលសុំ

ហើយ គេក៏ចាត់ចែងភ័ស្តុភាតាមដែលបានប្តេជ្ញាទុកប្រុង ឬច្រើនជាងនោះនាំយកទៅថ្វាយ បើមិនមានកូនទេ ក៏វាហើទៅមិនបាច់ធ្វើការលាបំណន់ ។

នៅមាន ១ បែបទៀត គេធ្វើជាកបាក្លូនសង្កត់ ឬខ្សែបង្កេះឯណានិមួយយកមកក្រវាត់ ក៏ថាអាចនឹងបណ្តាលឲ្យមានកូនដែរ ។ ឯលក្ខណៈកបា កូនសង្កត់ នឹងខ្សែបង្កេះ នឹងមានអធិប្បាយទៅខាងមុខ ក្នុងបទដែលនិយាយពីវិធីរក្សាគ៌ភ៌ ។

បុណ្ណោះសន្មតថាចប់ពិធីបន់សុំកូនហើយ ។

អំពីនេះនឹងបានអធិប្បាយសេចក្តីខ្លះ ដែលនៅមិនទាន់ត្រូវបះ ឲ្យត្រូវបះឡើង ដើម្បីប្រយោជន៍ដល់អ្នកត្រូវការដឹង នឹងបានដឹងតទៅ .—

ការដែលបន់ ៗ ដូច្នេះ សូមឲ្យជ្រាបថាជាលទ្ធិនៃសៃយ-សាស្ត្រដោយត្រង់ ព្រោះក្នុងលទ្ធិនោះគេកាន់ការបន់ ការបួងសួង ការបូជាយញ្ញៈ ដើម្បីឲ្យព្រះជាម្ចាស់ ឬអ្នកនេះអ្នកនោះប្រសិទ្ធិពរឲ្យតាមដែលត្រូវការ ។ គតិនៃពុទ្ធសាសនាសុទ្ធមិនមានការបន់ស្រន់-បួងសួងដូច្នេះ ខ្មែរយើងសម័យនេះដែលរាប់

ថាជា អ្នកកាន់ព្រះពុទ្ធសាសនាហើយ ៗ ទៅធ្វើការបន់ស្រន់ទៅលើព្រះពុទ្ធរូបក្ដី ទេវរូបក្ដី ឬរូបអ្វី ៗ ក្ដី ក៏ដោយជាប់គតិមកអំពីសាសនាព្រាហ្មណ៍នោះឯង ព្រោះក្នុងសម័យនោះខ្មែរយើងកាន់សាសនាព្រាហ្មណ៍យ៉ាងពេញទី ។

ការបន់ស្រន់ក្នុងខ្លួះ តាមដែលបានសង្កេតមើលឃើញថាមិនមែនសុទ្ធតែបានទាំងអស់គ្នាទេ អ្នកខ្លះក៏បានមែន អ្នកខ្លះក៏មិនបាន ។ ដែលបាននោះ បានដោយការបន់ ឬបានដោយហេតុដទៃ គួរប្រាជ្ញនឹងគប្បីពិចារណាមើលដែរ ។ មានរឿងដែលគួរនាំមកប្រកបនឹងរឿងដែលពោលមកហើយខាងដើម ២ រឿង ។

រឿងទី ១ ថា ព្រះពោធិរាជកុមារ គ្មានព្រះរាជបុត្រ ទ្រង់ប្រាថ្នាចង់បានព្រះរាជបុត្រ ។ ថ្ងៃមួយនោះ ទ្រង់ឲ្យតាក់តែងភត្តាហារនឹងថ្វាយព្រះពុទ្ធអង្គ នៅក្នុងព្រះរាជនិវេស មុនដែលព្រះសាស្ដានឹងស្ដេចយាងទៅដល់ ត្រាស់ឲ្យយកសំពត់សមកក្រាលតាំងអំពីកន្លែងពុទ្ធាសនៈ រហូតដល់មាត់ជណ្ដើរខាងក្រោម ហើយទ្រង់ផ្សងថា បើទ្រង់មានព្រះរាជបុត្រ សូមឲ្យ

ព្រះពុទ្ធអង្គស្ដេចយាងជាន់លើសំពត់កម្រាលនេះ បើមុកជាគ្មានព្រះរាជបុត្រ សូមកុំឲ្យព្រះអង្គទ្រង់ជាន់ឡើយ ដល់ព្រះអង្គយាងមក មិនទ្រង់ជាន់ ទ្រង់យាងបៀស ។ ព្រះពោធិរាជ-កុមារក៏ទ្រង់ជ្រាបថា ព្រះអង្គមុកជាមិនមានព្រះរាជបុត្រ ហើយក៏គ្មានមែនរហូតអស់ព្រះជន្ម ។

រឿងទី ២ ថា នាងមល្លិកា ជាជាយារបស់ពន្ធុលសេនាបតីបាននៅជាមួយគ្នាមកអស់កាលដ៏យូរហើយ មិនមានបុត្រធីតា ពន្ធុលទើបប្រាប់នាងទៅថា ចូរនាងត្រឡប់ទៅនៅនឹងមាតាបិតារបស់នាងវិញចុះ ព្រោះនាងគ្មានបុត្រនឹងតវង្ស ។ នាងមល្លិកាគិតថា ថ្ងៃនេះហើយនឹងដាច់អំពីប្ដី ដូច្នេះគួរអញទៅថ្វាយបង្គំលាព្រះសាស្ដាសិនហើយសិមទៅ ។ គាតោះនាងលាស្វាមីហើយក៏ទៅថ្វាយបង្គំព្រះសាស្ដា ។ ត្រាស់សួរថា នាងមានកិច្ចទៅណាមកណា នាងក៏ក្រាបទូលតាមរឿង ។ ព្រះសាស្ដាត្រាសថា ចូរនាងត្រឡប់ទៅនៅនឹងស្វាមីវិញទៅ ។ នាងក៏ធ្វើតាមព្រះពុទ្ធដម្រាស់នោះ ។ ពន្ធុល ឃើញនាងត្រ-ឡប់មកវិញក៏សួរ នាងក៏រាយរឿងប្រាប់តាមព្រះពុទ្ធដីកាដែល

ព្រះអង្គត្រាស់មក ។ ពន្ធុលកាលបានស្ដាប់ពាក្យនាងហើយក៏ពិចារណាថា ធម្មតាព្រះពុទ្ធជាអ្នកឃើញវែង ដូច្នេះគួរអញឲ្យនាងនៅវិញចុះ ។ លុះនៅជាមួយគ្នាមកក៏មានបុត្រជាច្រើននាក់ ៕

រឿងទាំងពីរនេះមានមកក្នុងគម្ពីរធម្មបទដ្ឋកថា ជារឿងដែលសរសេរសេចក្ដីថា ព្រះពុទ្ធមិនមែនជាអ្នកទទួលបំណន់ក្នុងរឿងឲ្យមានកូនឬឲ្យគ្មានកូន បទដែលត្រូវគ្មានកូន វាក៏គ្មានឯង ដូចព្រះពោធិរាជកុមារ ៗ បទដែលត្រូវមានកូនក៏មានមកឯង ដូចនាងមល្លិកា ។ តែសង្កេតមើលរឿងខ្លះក្នុងពួកគម្ពីរជាតកឃើញថា ការបន់សុំកូន អាចនឹងបានតាមសុំខ្លះ តែអ្នកសុំត្រូវប្រកបដោយគុណធម៌យ៉ាងខ្ពស់ ហើយមានចិត្តប្រកបដោយចតុព្រហ្ម-វិហារ ប្រាថ្នាសេចក្ដីសុខ សេចក្ដីចំរើន ប្រាថ្នាធ្វើប្រយោជន៍ដល់ប្រជុំជនជាច្រើន ខនេះអាចនឹងមានបានខ្លះ ដូចមានរឿងក្នុងជាតកថា ព្រះមហាក្សត្រិយ៍អំពីបូរាណអង្គខ្លះ គ្មានព្រះរាជបុត្រនឹងដំណាលសន្តតិវង្ស ពួករាស្ត្រនាំគ្នាឡើងក្រាបទូលឲ្យទ្រង់គិតធ្វើឧបាយម្ដេច ដ៏ជាហេតុឲ្យមានព្រះរាជបុត្រ ។ ព្រះ

មហាក្សត្រិយ៍អង្គនោះ ត្រាស់ឲ្យធ្វើពលីកម្មបួងសួងដល់ទេវតា សុំឲ្យទេពបុត្រមកកើត នឹងបានគ្រប់គ្រងផែនដី រក្សាអាណាប្រជារាស្ត្រឲ្យនៅជាសុខតទៅ ឯអង្គព្រះមហាក្សត្រិយ៍នោះ នឹងព្រះអគ្គមហេសី ឬព្រះស្នំ ក៏ទ្រង់សមាទានសីលបរិសុទ្ធស្អាតជានិច្ចទៅ ។ ដោយហេតុនេះ រមែងបណ្ដាលក្ដៅដល់ព្រះឥន្ទ្រ ៗ ក៏អញ្ជើញទេវតាឯណាមួយឲ្យចុះមកកើត បានព្រះរាជបុត្រឡើងមែន ។ បើអ្នកធ្វើទ្រង់នូវគុណធម៌ ហើយធ្វើពិធីសុំតាមរបៀបដែលពោលមកនេះ គួរជឿថាអាចនឹងមានបានខ្លះ ។

ឯទេវរូប ១ យ៉ាងជារូបស្រី ដែលខ្មែរយើងហៅថាយាយទេព ឬយាយទេព នោះ គឺជារូបនាងឧមា មហេសីរបស់ព្រះឥសូរ ។ ន័យថា នាងមាននាមដល់ទៅ ១០០០ យ៉ាងដូចយ៉ាងនាមថា ភគវតី ភវានី គិរីជា បាតិតី ទុរគា កាឡីជាដើម នាមអំពាលនេះជាគ្រឿងសំដែងគុណសម្បត្តិខ្លះ ជាគ្រឿងសរជាតិ សត្រកូលខ្លះ ជាគ្រឿងសំដែងសេចក្ដីករុណា គឺសេចក្ដីកាចខ្លះ ។ នាមឧមា ភគវតី ភវានី អំពាលនេះ

សំដែងគុណសម្បត្តិ ព្រោះនាងជាអ្នកភ្លឺ-ត្រចះត្រចង់-ជាអ្នកមានជោគជ័យ-ជាដែនកើតនៃប្រជាជន គឺជាមាតារបស់សត្វលោក ។ នាមគិរីជា បាព៌តី ពីរនេះសរជាតិ ព្រោះនាងកើតអំពីភ្នំ ។ នាម ហេមវតី នេះសរត្រកូល ព្រោះនាងជាធីតាព្រះហេមវត គឺព្រៃហេមពាន្ត និងនាងមេនកា ។ នាម ទុគ៌ា កាឡី ពីរនេះជាគ្រឿងសរសន្តានខាងឯអាក្រក់ ខាងឯខ្មៅ កាឡិកណី ព្រោះនាងមានឫទ្ធិ អាចធ្វើឲ្យល្អក៏បាន ធ្វើឲ្យអាក្រក់ក៏បាន ធ្វើឲ្យបំរើនក៏បាន ធ្វើឲ្យវិនាសក៏បាន ។ កាលជាប្រក្រតី ឬកាលណាត្រូវការធ្វើអ្វីជាប៉ែកខាងល្អ រូបនាងក៏ប្រាកដឃើញល្អ កាលណាត្រូវការធ្វើអ្វីជាប៉ែកខាងអាក្រក់ រូបនាងក៏ប្រាកដឃើញអាក្រក់មុខក្រញូវក្រញូវដូចជាយក្ស ហេតុនោះពួកអ្នកកាន់សាសនាព្រាហ្មណ៍គេទើបសាងរូបនាងជាពីរបែបគឺបែបល្អ ១ យ៉ាង បែបអាក្រក់ ១ យ៉ាង ។ រូបល្អនោះគេតែងធ្វើពលីកម្មបួងសួង បន់ស្រន់សុំក្នុងរឿងដែលល្អបាន ន័យថា នាងសព្វព្រះហឫទ័យ សោយតែឈាមមនុស្ស ឬឈាមសត្វ បើអ្នកណាចង់បានពរអំពីនាង គប្បីបំពេញតបះឲ្យមាំមួន ហើយយកមនុស្សឬ

សត្វរស់នៅអារកសម្លាប់យកឈាមថ្វាយ នឹងប្រទានពរជាឆាប់ ។ រូបអាក្រក់នោះគេកាន់ថា មិនត្រូវបន់សុំអ្វីខាងល្អ ព្រោះក្នុងវេលាដែលនាងមានរូបអាក្រក់ដូច្នេះ ជាពេលដែលនាងត្រូវតែបំផ្លិចបំផ្លាញឲ្យហិនហោចទៅ ប្រៀបដូចមនុស្សយើងកំពុងខឹងខ្លាំង កំពុងមុខអាក្រក់ បើជាមានអ្នកណាមកសុំអ្វីក៏មិនបានសម្រេចតាមសុំ មានតែឲ្យទោសមកវិញ បើបន់សុំឲ្យជួយបំផ្លិចបំផ្លាញបាន ។

ដែលពួកខ្មែរយើងហៅថាយាយទេព ជាឈ្មោះដែលកើតឡើងក្នុងជាន់ក្រោយ ដែលអស់អ្នកបេះដឹងរឿងនោះហើយមិនដឹងជាឈ្មោះអ្វី មានរឿងរ៉ាវមកដូចម្ដេច ក៏នាំគ្នាហៅយាយទេពទៅ តាមលក្ខណៈនៃរូបនោះជាស្រី ។

## ពាក្យពេចន៍ប្រដៅ

### កាព្យពាក្យ ៧

នេះពាក្យទំនៀមបូរាណមុន ទូន្មានមហាជនតទៅមុខ ឲ្យអស់កូនចៅផងចាំទុក ទើបបានទីសុខមកដល់ខ្លួន កុំឲ្យលួចគេវាផ្លាប់ដៃ កុំឲ្យដេកថ្ងៃវាផ្លាប់ខ្លួន កុំឲ្យស្ដីញាប់វាផ្លាប់ស្លួន

កុំឲ្យប្ញឹមខ្លួនវាធ្លាប់ខ្ជិល កុំឲ្យស្មោកគ្រោកវាហោកការ កុំឲ្យផឹកស្រាវាដាច់សីល កុំឲ្យស៊ីច្រើនវាច្រើនខ្ជិល កុំឲ្យកកិលវាធ្លាប់រឹក កុំឲ្យស្មៀមដៃវាធ្លាប់លួង កុំឱបជង្គង់វាធ្លាប់ស្ទឹក កុំឲ្យផ្ញួរវាទ្រមឹក កុំឲ្យផ្ទើងរឹកគេស្អប់ខ្លួន កុំឲ្យរួសពេកវាបែកបាក់ កុំឲ្យប្ញឹមថ្នាក់វាបាត់ស្ងួន កុំឲ្យផ្ញួដោកវាហោកខ្លួន កុំឲ្យវេះព្លូនវាបាត់មុខ កុំឲ្យម្នះពេកវាបែកមិត្រ កុំឲ្យទ្រស្តស្និទ្ធវាបាត់សុខ កុំឲ្យលើកខ្លួនវាស្ងួនទុក្ខ កុំឲ្យស្ដីបាក់រុកវាអប្រិយ៍ កុំឲ្យធ្វើស្នេហាវាបែរឃ្លាត កុំឲ្យទ្រស្តញាតិវាបង់ក្តី កុំឲ្យហ៊ានហួសអាយុខ្លី កុំឲ្យជេរស្រីវាបង់ទ្រព្យ កុំឲ្យស៊ីពេកវាបែកពោះ កុំឲ្យទ្លេះទ្លោះវាខានគាប់ កុំឲ្យខុសរឿយវាអភ័ព្វ កុំឲ្យលេលាប់វាធ្លាប់ចិត្ត បើម៉្យែនឹងបេះឲ្យគេកោត បើម៉្យែនឹងដោតឲ្យគេអាណិត បើម៉្យែនឹងហ៊ានឲ្យមានចិត្ត បើម៉្យែនឹងគិតឲ្យបានការ បើម៉្យែនឹងកាបឲ្យពេញវង់ បើម៉្យែនឹងលួងឲ្យផុតហា បើម៉្យែនឹងប្រាជ្ញឲ្យបានការ បើម៉្យែនឹងគេហាឲ្យបានខ្នាត ។ ឲ្យរៀនអត់ឪនពាក្យជូនតា ឲ្យរៀនវិជ្ជាការសិល្បសាស្ត្រ ឲ្យរៀនចិត្តធ្ងន់កុំប្រមាទ ឲ្យខំសង្វាតរកទ្រព្យធន ឲ្យរៀនជិះសណ្តាប់ធី

ឲ្យខំរកស៊ីកុំលួចប្លន់ ឲ្យសង្គ្រោះញាតិមានអាសន្ន ឲ្យបេះអត់ធន់កុំក្រេវក្រោធ ឲ្យបេះត្រង់ណាឲ្យមាំមួន ឲ្យចាំច្បាប់ក្បួនជម្រាសោត ឲ្យពេញជាប្រាជ្ញលោកីយកោត រកសោតឲ្យសមជាប្រាជ្ញប្រាយ ឲ្យបងឲ្យចាំទំនៀមព្រេង ឲ្យបេះចាំបែងបទបរិយាយ ឲ្យរាប់ព្រេងលាននាញាតិជិតឆ្ងាយ ឲ្យផ្សាយមេត្តានឹងផលផង ឲ្យស្គាល់ទាបខ្ពស់ជរាបទៅ ឲ្យស្គាល់ប្រាជ្ញខ្លៅនូវរៀមច្បង ឲ្យបងចាំចិត្តគិតខ្លាបហ្មង ឲ្យត្រង់ឲ្យត្រាប់ច្បាប់ធម្មតា ឲ្យមានមេត្តាប្រយ័ត្នទោស ឲ្យខំសន្តោសលោះរើរាឲ្យមានមេត្រីប្រណីគ្នា ឲ្យជាប់ឲ្យជាធម៌ខន្តី ។

### បទកាកគតិ គតិសេចក្ដីខាងលើ

បណ្ដាំព្រេងព្រឹធ បំណាននៃមនពិត តែអស់អ្នកផងមើលហើយប្ដូរពិ ចារណាត្រាប់ត្រង់ ប្រាណលោកបងជាបរិស្ថាន ។

ន័យមួយលោកហោម កុំឲ្យធ្វើតាម អំពើសាមាន្យ ត្រូវប្រឹងប្រយ័ត្ន ប៉ៀសវៀងឲ្យបាន នោះទើបសន្និដ្ឋាន ថាជាអ្នកល្អ ។

ន័យពីររំលឹក មនោត្រិះនឹក សព្វកាលនិរន្តរ ប្ដូរហំបង
ទុក ជាផ្លូវគោចរ ន័យនេះកម្រ អ្នកផងធ្វើបាន ។

ន័យបីប្រើធ្វើ កិច្ចការសារពើ ឲ្យតាមលំអាន ជាបែប
ជាបទ បំណកប់បំណាន ជាផ្លូវនាំប្រាណ ជាប្រសើរអើយ ។

សំគាល់ពាក្យបណ្ដាំព្រេងជាបទពាក្យ ៧ ខាងលើនេះកើតឡើងក្នុងរាជព្រះករុណាព្រះបរមកោដ្ឋ គឺព្រះបាទសម្ដេចព្រះហរិរក្សរាមា ឥស្សរាធិបតី ព្រះអង្គ (ដួង) ទ្រង់ត្រាស់បង្គាប់ឲ្យអ្នកប្រាជ្ញរាជបណ្ឌិតចារិកទុក ឯពាក្យបទកាកគតិខាងក្រោមគឺ ក្រម្ការ (កង-ជា) បានរិះគិតបញ្ចូលជាមួយដោយសេចក្ដីពេញចិត្តនឹងទំនៀមព្រេងខាងលើនេះ ទុកជាផ្លូវពិចារណា ។

### រឿងប្រាជ្ញា-សំណាង-ផលទាំង ៣ អួតរិទ្ធិតែសព្វខ្លួន

១ មានពេល ១ ប្រាជ្ញា-សំណាង-ផល-ទាំង ៣ នាក់បានមកប្រជុំគ្នា ប្រាជ្ញាអាងអួតឡើងថា ប្រាជ្ញាមានរិទ្ធិពូកែជាងសំណាងនឹងផល សំណាងអាងអួតឡើងថា សំណាងមានរិទ្ធិធំពូកែជាងប្រាជ្ញានឹងផល ផលអាងអួតឡើងថា ផលមាន

វិទ្ធិជាងប្រាជ្ញានឹងសំណាង នោះអ្នកទាំង ៣ នាក់អាងអួតតែសព្វរៀងខ្លួនមិនដឹងជាអ្នកខាងណាមានវិទ្ធិអានុភាពជាងខាងណា មានសេចក្ដីអំនួតតែសព្វរៀងខ្លួន នោះអ្នកទាំង ៣ នាក់ថាបើចង់ដឹងឲ្យល្បងវិទ្ធិគ្នាមើល ឲ្យដឹងជាអ្នកណាពូកែជាងអ្នកណា នោះប្រាជ្ញា-សំណាង-ផលទាំង ៣ នាក់ជំនុំព្រមតាំងល្បងវិទ្ធិទាំង ៣ នាក់បណ្ដើរគ្នាទៅ ក៏មើលទៅឃើញមានមនុស្ស ១ នាក់ជាអ្នកក្រកំសត់នៅខំសេដ្ឋី ៗ ឲ្យបុរសនោះឃ្វាលគោក្របីរកតែសំពត់អាវនឹងស្លៀកពាក់គ្មាន មនុស្សនោះល្ងង់មិនស្គាល់ខុសត្រូវ ចេះដឹងតែឃ្វាលក្របី នោះប្រាជ្ញា-សំណាងទាំងពីរនាក់ថាៈបើផលអាងអួតថាខ្លួនគ្រាន់បើឲ្យផលទៅជួយមនុស្សនៅខំសេដ្ឋីនោះតើបានគ្រាន់បើយ៉ាងដូចម្ដេចឡើង នោះផលក៏បានទៅជួយមនុស្សនោះៗ តាំងពីថ្ងៃដែលផលទៅជួយនោះ ក៏អ្នកទាំងពួងចេះតែនឹកអាណិតមនុស្សនោះ ក៏យកបំណាំទៅឲ្យមនុស្សនៅខំសេដ្ឋីនោះស៊ីពុំមានខ្វះបំណាំអ្វីសោះឡើយ តែផលជួយក៏ឡាំងដល់បានតែត្រឹមស៊ីពុំមានខ្វះឡើយ ផលនឹងគិតជួយមនុស្សនោះអ្វីតទៅមិនបាន នោះប្រាជ្ញា-សំណាង-បានសួរ

ទៅផលថា ផលជួយមនុស្សបានយ៉ាងណាតទៅទៀត ផល ឆ្លើយប្រាប់ទៅសំណាងប្រាជ្ញវិញថា អំណាចផលជួយមនុស្ស នេះបានតែប៉ុណ្ណឹងទេ នោះសំណាងបានទៅជួយមនុស្សនោះ ទៀត ឯមនុស្សនោះលុះសំណាងបានទៅជួយទៀត ក៏ក្របី ដែលឃ្វាលទាំងប៉ុន្មាន ផុសអាចម៍មកដាក់ក្នុងក្រោលនោះ ក៏ តទូតែជុំពេជ្រទាំងអស់ភ្លឺពេញក្រោល តែបុរសដែលឃ្វាល ក្របីនោះមិនស្គាល់ជាជុំពេជ្រសោះ រើសបានអាចម៍ក្របីនោះ ១ ដុំយកមកចងនឹងចុងខ្សែក្របីគ្រវីលេងភ្លឺព្រោងព្រាតដេញក្របី ទៅឃ្វាលជារាល់ថ្ងៃ ដល់ដេញក្របីឲ្យទៅផឹកទឹកនៅបាងស-មុទ្រ ក៏គ្រវីខ្សែក្របីនោះលេងជាធម្មតា និយាយពីនាយសំពៅ ដែលបើកសំពៅក្នុងសមុទ្រភាត្រូវភ្នែកនឹងអំណាចរស្មីពេជ្រដែល បុរសនោះគ្រវីលេង ក៏ក្រឡេកដេញតាមអំណាចពេជ្រដែល ភ្លឺនោះមកឃើញបុរសនោះគ្រវីលេង នាយសំពៅក៏បើកសំពៅ ចូលមកក៏សួរទៅបុរសនោះថា បុរសឯងបានរបស់នេះពីណា មក បុរសនោះក៏ប្រាប់ទៅនាយសំពៅវិញថា របស់នេះជាអាចម៍ ក្របីដែលខ្ញុំឃ្វាលនេះ នាយសំពៅក៏គិតថា មនុស្សនេះល្ងង់

មិនស្គាល់ជុំពេជ្រ នាយសំពៅក៏បានសួរទៅបុរសនោះទៀតថា បុរសឯងដែលឃ្វាលក្របីនោះក្របីបុរសឯង ឬក្របីរបស់អ្នកឯណា បុរសនោះបានឆ្លើយប្រាប់ទៅនាយសំពៅថា ខ្ញុំនៅជាខ្ញុំសេដ្ឋីតាំងពីជីដូនជីតារហូតដល់មកអាពុកម្តាយដល់មកខ្ញុំជាកូនទៀត នោះនាយសំពៅបានសួរទៅបុរសនោះថា ជំពាក់សេដ្ឋីប្រាក់ប៉ុន្មានរៀល បុរសនោះបានប្រាប់ទៅនាយសំពៅវិញថាខ្ញុំឮអាពុកម្តាយខ្ញុំនិយាយប្រាប់ខ្ញុំថា ជីដូនជីតាខ្ញុំគាត់ជំពាក់លោកសេដ្ឋីប្រាក់ដើម ១០០០៛០០ នាយសំពៅក៏បានសួរទៅបុ-រសនោះវិញទៀតថា បុះក្របីដែលជុសអាចម៍នៅក្នុងក្រោលអ្នកឯងនោះមានប៉ុន្មានដែលមានពន្លឺដូចរបស់អ្នកឯងកាន់លេងនេះ បុរសនោះបានប្រាប់ទៅនាយសំពៅវិញថា អាចម៍ក្របីដែលដូចជាដុំដែលខ្ញុំកាន់មកនេះ គឺពេញតែក្រោលក្របីដែលខ្ញុំឃ្វាលនោះ នាយសំពៅគិតថា បុរសនេះជាមនុស្សមានសំណាង តែមិនស្គាល់ជាពេជ្រព្រោះដោយល្ងង់ នាយសំពៅបានសួរទៅបុរសនោះថា អ្នកឯងព្រមធ្វើជាកូនយើង ៗ នឹងយកអ្នកឯងទៅថែរក្សាធ្វើកូន នោះបុរសនោះបានប្រាប់ទៅនាយសំពៅវិញថា

ខ្ញុំទៅនៅនឹងលោកនាយមិនបានទេ ព្រោះខ្ញុំនៅជំពាក់ប្រាក់លោកសេដ្ឋី នាយសំពៅថា មិនអីទេឲ្យតែបុរសឯងព្រមទៅនៅធ្វើកូនយើងចុះយើងយកប្រាក់ ១០០០៛ ០០ ទៅលោះពីលោកសេដ្ឋី ឯអាចម៍ក្របីដែលផុសមកក្នុងក្រោលទាំងប៉ុន្មានយើងត្រូវយកដាក់ក្នុងសំពៅយើងទៅ បុរសនោះក៏ព្រមតាមនាយសំពៅ ៗ ក៏បានយកប្រាក់ ១០០០៛ ១០ ទៅលោះពីសេដ្ឋីរួច ក៏បានទៅកើបពេជ្រយកពីក្នុងក្រោលក្របីផ្ទុកដាក់សំ-ពៅពេញបើកទៅដល់ទីលំនៅផ្ទះនាយសំពៅ ៗ គិតពិចារ-ណាប្ដីប្រពន្ធថា កូនយើងនេះជាមនុស្សល្ងង់ម្ល៉េះ ឥឡូវយើងចាត់ទៅធ្វើជំនួញគិតគូររបស់អ្វីៗ មិនកើត បើដូច្នេះគួរយើងទៅដណ្ដឹងកូនស្ដេចឲ្យ ធម្មតាស្ដេចគឺនៅតែស្ងៀមគ្មានគិតគូរអ្វី បើកូនយើងធ្វើស្ដេចនឹងធ្វើបាន ជំនុំព្រមប្ដីប្រពន្ធក៏នាំគ្នាទៅដណ្ដឹងកូនស្ដេច ៗ ក៏ព្រមព្រៀងឲ្យកូនក្រមុំមកកូននាយសំពៅក៏គិតគូរគ្នាការងារហើយជាស្រេច នាយសំពៅក៏វិលទៅផ្ទះវិញនៅតែបុរសជាកូននាយសំពៅ ដល់ពេលយប់កូនក្រមុំស្ដេចតាំងរៀបពូកកន្ទេលខ្នល់ខ្នើយដំណេកបង្គុយប្ដីខ្លួន នឹងរួមរំណើ

ជាមួយដូចធម្មតាអ្នកទាំងពួង ឯបុរសនោះជាមនុស្សល្ងង់ខ្លៅ ក៏មិនគិតទៅដេកនឹងកូនក្រមុំស្ដេច ទៅដេកឯជើងកំផែងវាំង ស្ដេចនោះវិញ លុះព្រឹកឡើងដើរលេងទូ្ល លេងឈ្លូងជាមួយនឹង កូនក្មេង ៗ គ្មានកាន់គំនិតសុណ្ដាប់ជាកូនស្ដេច ល្ងង់មួយថ្ងៃជា ២ ថ្ងៃ នាងនោះក៏បេះតែរៀបកន្ទេលខ្នើយជារាល់ថ្ងៃពុំឃើញប្ដី ទៅដេកជាមួយសោះ ហើយនាងឲ្យបម្រើទៅពិនិត្យមើល ឃើញ បុរសនោះដើរទៅដេកដោយជើងកំផែងវាំង ហើយនាងកូនក្រមុំ ស្ដេចគិតទៅខឹងនឹងស្ដេចអាពុក ឲ្យមានប្ដីកិរិយាមិនប្រិទ្បឹងគេ ក៏ទៅទូលស្ដេចអាពុកតាមដំណើរ ស្ដេចអាពុកកាលណាបើ បានស្ដាប់ពាក្យកូនទូលសព្វគ្រប់ហើយ ក៏ខ្ញាល់ណាស់គិតថា បុរសនេះដែលប្រដិបត្តិកិរិយាយ៉ាងហ្នឹង ជាមិនមែនពូជត្រកូល អ្នកខ្ពស់ គឺនាយសំពៅអាងតែខ្លួនមានសម្បត្តិទៅយកមនុស្សខ្ញុំ គេមកដណ្ដឹងកូនអញដើម្បីនឹងមើលងាយអញ បើដូច្នេះនឹងត្រូវ ឲ្យទៅហៅយកកូនប្រសានោះមកមើល រីឯផ្ទះនាយសំពៅទៀត ត្រូវបាត់ឲ្យទាហានទៅព័ទ្ធរឹបយកទ្រព្យសម្បត្តិទាំងអស់ ស្ដេច រកទៅឃើញថាមិនមែនជាកូននាយសំពៅទេ នឹងយកកូនប្រសា

នឹងតាយសំពៅទាំងប្ដីប្រពន្ធទៅសម្លាប់ចោលទាំងអស់ ឯទ្រព្យសម្បត្តិត្រូវរិបអូសដាក់ព្រះរាជទ្រព្យទាំងអស់ ។

នោះសំណាងនឹងផលបានដឹងថា ស្ដេចមុកជាយកទៅធ្វើទោសបុរសនេះ ឥឡូវនេះ ក៏គិតភិតភ័យនឹងគិតជួយបទណាឲ្យបុរសនេះបានរួចពីជីវិត ឯអំណាចផលគឺរួចបានតែត្រឹមស៊ី ឯសំណាងជួយបានដល់ត្រឹមសោយរាជ្យ តែត្រង់ដោះខ្លួនឲ្យរួចពីជីវិតតទៀតពុំបាន នោះសំណាងនឹងផលទាំងពីរនាក់បានជំនុំគ្នាថា យើងត្រូវរត់ទៅពឹងប្រាជ្ញានិយាយប្រាប់ប្រាជ្ញាថា បុរសគង្វាលក្របីយើងទាំងពីរនាក់ជួយបានសោយរាជ្យទៅហើយ តែឥឡូវស្ដេចអាពុកគិតយកទៅសម្លាប់ សុំឲ្យប្រាជ្ញាទៅជួយឲ្យរួចពីស្លាប់ ប្រាជ្ញាកាលណាបើបានឮសំណាងនឹងផលមកពឹងខ្លួនយ៉ាងដូច្នេះ ហើយថាទេបើប្រាជ្ញាទៅជួយលុះតែសំណាងនឹងផលចុះចាញ់ ទុកប្រាជ្ញាជាច្បង សំណាងជាកណ្ដាលផលជាប្អូន ប្រាជ្ញាបានទៅដល់ជួយបុរសនោះ ៗ បានភ្ញាក់ស្មារតីដឹងខ្លួនថា អញបានធ្វើជាស្ដេចសោយរាជ្យមិនត្រូវដើរមកលេង ត្រូវតែកាន់សណ្ដាប់ខ្លួនជាស្ដេច បុរសនោះក៏ដើរទៅ

រកនាង រំពេច ប្រាជ្ញាវៃវៀងដើរទៅទ្រូតត្រាលើមនុស្ស បារព្រាវទាំងប៉ុន្មាន ក៏នាងកូនស្ដេចនឹកឆ្ងល់ថា ប្ដីអញពីមុន តាំងពីថ្ងៃការរួបមកដើរដេកដោយជើងកំផែងភាំង បែបជាមនុស្សមិនដឹងខុសត្រូវឥឡូវដល់ពេលនេះ ក៏មើលទៅឃើញមានប្រាជ្ញាឆ្លុះឆ្លាតរកអ្នកឯណាស្មើគ្មាន នាងក៏សួរទៅប្ដីសូមទូលព្រះអង្គ ពីថ្ងៃដែលការរួបមក ហេតុអ្វីក៏ព្រះអង្គទៅដើរផ្តុំដោយជើងកំផែងភាំងមិនមកទីកន្លែងក្រឡាព្រះបន្ទំ តើយ៉ាងដូចម្ដេច ក៏ស្ដេចបុរសនោះបានប្រាប់ទៅនាងវិញថា គ្រូបងផ្ដាំបងថា បើរៀបការប្រពន្ធថ្មី ឲ្យសង្កេតមើលកិរិយាស្រីសិន ថាបើត្រឹមត្រូវសឹមយកធ្វើជាប្រពន្ធ បើមិនបានត្រឹមត្រូវទេយកធ្វើជាប្រពន្ធមិនបាន ហេតុនេះបានជាបងសង្កេតមើលប្អូនឯងសិន កិរិយាប្អូនឯងឃើញត្រឹមត្រូវទើបបងបានមករកនាងនេះ នាងក៏បានទៅទូលស្ដេចអាពុក ៗ ក៏បានពិនិត្យមើលឃើញថាមនុស្សនេះមានដំរេះប្រាជ្ញានឹងរកអ្នកឯណាស្មើគ្មាន ក៏លើករាជ្យឲ្យហោយទៅ ។

## រឿងក្អែកមាស

ដើមឡើយមានបុរសម្នាក់បានទទួលពាក្យបណ្ដាំពីអាពុកប្រដៅថាកុំឲ្យយកប្រពន្ធស្រីប្ដីលែងនឹងស្រីសៅកែ ឲ្យយកស្រីក្រមុំព្រហ្មចារីនឹងមេម៉ាយប្ដីស្លាប់ធ្វើជាប្រពន្ធ ហើយកុំឲ្យយកក្មេងនឹងមនុស្សគ្របី ហើយស្ដេចឥតធម៌កុំឲ្យនៅក្នុងនគរនោះ បុរសនោះបានយកប្រពន្ធស្រីទាំង ៤ នាក់នោះ នឹងយកក្មេងមនុស្សគ្របីល្បងមើល មានថ្ងៃ ១ នោះក្អែកមាសរបស់ស្ដេចវាទៅរកស៊ីក្បែរផ្ទះបុរសនោះ ហើយបុរសនោះគិតពីសោតមើល បានចាប់សត្វក្អែកមាសនោះយកទៅបង់លាក់ក្នុងទ្រុង ១ ហើយដាក់បំណីបាយទឹកឲ្យសត្វនោះអាស្រ័យ រួចបុរសនោះបានយកមាន់គក ១ ទៅកាប់បោចស្រេច យកទៅធ្វើជាម្ហូបអាស្រ័យពេលនឹងអាស្រ័យបុរសនោះបានយកប្រពន្ធទាំង ៤ ហើយនឹងក្មេងនោះទៅអាស្រ័យសាច់មាន់គកនោះទាំងអស់គ្នា ហើយបុរសនោះនិយាយថា សាច់នេះគឺក្អែកមាសរបស់ស្ដេច អញលួចកាប់យកសាច់មកស៊ីនេះ ។

ក្រោយនោះដល់បាត់សត្វក្ងោក ស្ដេចឲ្យប៉ារិគង់សួររកសត្វក្ងោកនោះ ទើបនាងស្រីប្ដីលែងនឹងស្រីសៅកែនិយាយនឹងនាងក្រមុំ-នាងប្ដីស្លាប់ថា ប្រាប់ពួកអ្នកប៉ារិគង់ទៅថា ប្ដីយើងវាលួចកាប់សត្វក្ងោករបស់ស្ដេចយកសាច់ស៊ី ព្រោះវាធ្វើបាបវាយជេរយើងខ្លាំងណាស់ ទើបស្រីក្រមុំនឹងស្រីប្ដីស្លាប់អង្វរទៅវិញថា កុំធ្វើបាបប្ដីរបស់ខ្លួនដូច្នោះមិនល្អទេ នោះស្រីសៅកែនឹងស្រីប្ដីលែងថា បើនាងឯងមិនចូលគំនិតនឹងយើង មុកជាយើងប្ដឹងអ្នកប៉ារិគង់ហើយ ស្រាប់តែស្រីទាំងពីរអ្នកនោះប្ដឹងអ្នកប៉ារិគង់តាមដំ-ណើរដែលប្ដីប្រាប់ថា លួចកាប់សត្វក្ងោកស្ដេចយកសាច់ស៊ីនោះ រួចពួកអ្នកប៉ារិគង់បានចាប់យកបុរសនោះទៅថ្វាយស្ដេច ហើយទូលតាមដំណើរ ស្ដេចឲ្យនាំបុរសនោះទៅពិឃាដ លុះនាំទៅដល់មាត់ទ្វាររាំងអ្នកចាំទ្វារសួរថា អ្នកនាំមនុស្សទោសមកនេះស្ដេចបានជំនុំជំរះហើយឬនៅ អ្នកនាំថានៅទេ អ្នកចាំទ្វារពុំព្រមបើកទ្វារហើយបាននិយាយរឿងប្រាប់អ្នកនាំថា មានរឿង១នោះសេដ្ឋីចិញ្ចឹមក្អែក៥០០ លុះយប់អាចោរជីកអុងម៉ុងចូលទៅលួចយកទ្រព្យសម្បត្តិរបស់សេដ្ឋីនោះចូលទៅក្នុងអុងម៉ុងនោះទាំង

អស់ ផ្ដែសេដ្ឋីដឹង បានទៅខាំអាហោរស្លាប់ក្នុងអុងម៉ង្គនោះស្លាប់ទាំងអស់ លុះព្រឹកឡើងមហាសេដ្ឋីឃើញបាត់ទ្រព្យសម្បត្តិដូច្នោះនឹកខឹងនឹងផ្ដែហាមិនបេះបាំរបស់ ក៏សម្លាប់ផ្ដែនោះទៅ លុះខ្មោចហោរធុំអសោចឡើងទៅ មើលឃើញហោរស្លាប់ដូច្នោះក៏នឹកស្ដាយផ្ដែក្រោយ កំពុងតែនិយាយបន្ដិច ឃើញបម្រើស្ដេចឲ្យទៅហៅយកបុរសនោះជំនុំជំរះវិញ លុះស្ដេចសួរបុរសនោះពីសម្លាប់សត្វក្ងោកមាស បុរសទូលស្ដេចថា ក្ងោកនោះមិនបានសម្លាប់ទេ មានកន្លែងទុកដោយល្អ ឯសម្លាប់នោះគឺមាន់គកទេ ស្ដេចបានឲ្យទៅយកសត្វក្ងោកនោះវិញ ស្ដេចបានលើកទោសបុរសនោះលែង ហើយបុរសនោះបានលាស្ដេចលែងនៅក្នុងនគរនោះព្រោះស្ដេចឥតធម៌ ឯស្រីទាំងពីរដែលប្ដឹងពីបុរសនោះថាកាប់ក្ងោកនោះ ក៏បុរសនោះលែងចោលចេញ ។

រឿងនេះចប់តែប៉ុណ្ណេះ

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាឡីនិងប្រែ) ១ ចប់ចំនួន ១១០ សៀវភៅ. . . . | ថ្លៃ | ២៥០០?,១០ |
| ទស្សនាវដ្ដីឆ្នាំទី. . . . . . . . . . . . . . . . . . . . | — | ៤, ០០ |
| ដំណាលពុទ្ធចេតិយ. . . . . . . . . . . . . . . . . . | ១ សៀវភៅ ថ្លៃ | ១, ៨០ |
| អំពីព្រះពុទ្ធសាសនា. . . . . . . . . . . . . . . . . | — | ១, ៥០ |
| កថាយនូបត្ថម្ភកវគ្គ ១. . . . . . . . . . . . . . . . | — | ១, ៣០ |
| " " វគ្គ ២. . . . . . . . . . . . . . . . . . | — | ១, ៤០ |
| អភិធម្មត្ថសង្គហ. . . . . . . . . . . . . . . . . | — | ១, ២០ |
| មិលិន្ទបញ្ហាវគ្គ ១. . . . . . . . . . . . . . . . | — | ១, ០០ |
| " " វគ្គ ២. . . . . . . . . . . . . . . . . . | — | ០, ៧០ |
| សាសនកិច្ចានុក្រម. . . . . . . . . . . . . . . . | — | ០, ៨១ |
| អរិយសច្ចកថា. . . . . . . . . . . . . . . . . . | — | ០. ៧០ |
| វុឌ្ឍោទយ. . . . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| ធម្មបទដ្ឋកថា. . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| សុរិយាត្រឡើងស័ក. . . . . . . . . . . . . . . . | — | ០, ៦០ |
| សតិបដ្ឋានសុត្ត. . . . . . . . . . . . . . . . . | — | ០, ៥០ |
| មរណានុស្សតិ. . . . . . . . . . . . . . . . . . | — | ០, ៤០ |
| បញ្ញាសជាតក. . . . . . . . . . . . . . . . . . | — | ០, ៥០ |
| គិហិបដិបត្តិ. . . . . . . . . . . . . . . . . . | — | ០, ៤៥ |
| អំពីប្រាសាទនគរវត្ត. . . . . . . . . . . . . . | — | ០, ៣៥ |
| មាតាបិតុឧបដ្ឋាន. . . . . . . . . . . . . . . . | — | ០, ៣៥ |
| សិង្គាលោវាទសុត្ត. . . . . . . . . . . . . . . | — | ០, ៣០ |
| ទសបារមីកថា. . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សាមណេរវិន័យ. . . . . . . . . . . . . . . . . | — | ០, ៣០ |
| បាដិមោក្ខសង្ខេប. . . . . . . . . . . . . . . . | — | ០, ៣០ |
| សេកសោមបណ្ឌិត. . . . . . . . . . . . . . . . | — | ០, ៣០ |
| អំពីព្រះនិព្វាន. . . . . . . . . . . . . . . . . . | — | ០, ៦០ |

| | | |
|---|---|---|
| ១០០ គាថា | ១ សៀវភៅថ្លៃ | ០រ ២០ |
| មនោបុព្វកថា | — | ០, ១៥ |
| ពុទ្ធាភិធានុស្សតិ | — | ០, ១៦ |
| កាលាមសូត្រនឹងបរាភវសូត្រ | — | ០, ១៥ |
| គតិលោកខ្មែរ | — | ០, ១៥ |
| ច្បាប់ថ្មី | — | ០, ១៥ |
| ពាក្យសម្រាក ទី ១ | — | ០, ១៥ |
| " " ២ | — | ០, ១៥ |
| " " ៣ | — | ០, ១៥ |
| ញាណកថា | — | ០, ១២ |
| សំវេជនីយធម៌ | — | ០, ១២ |
| សីមាវិនិច្ឆ័យ | — | ០, ១០ |
| អនត្តលក្ខណសូត្រ | — | ០, ១០ |
| ធាតោបមាទិកថា | — | ០, ០៨ |
| សេចក្តីជាសំនៀន | — | ០, ០៦ |
| សុភទោសកថា | — | ០, ០៥ |
| អក្ខទោសកថា | — | ០, ០៥ |
| ព្រះចង្កូមកែវ | — | ០, ១០ |
| ពុទ្ធបវត្តិ | — | ០, ១៥ |
| រឿង ៤ ពាន់ ១ យប់ | — | ០, ០៤ |
| បាយាសិរាជញ្ញសូត្រ | — | ០, ០៤ |
| គិរិមានន្ទសូត្រ | — | ០, ០៧ |
| ពាក្យកាព្យក្រមង៉ុយ | — | ០, ០៥ |
| សប្បុរិសធម៌ | — | ០, ០៥ |
| សារទេសនា | — | ០, ០៣ |
| អនុត្តរិយសូត្រ | — | ០, ០២ |
| បុណ្ណោវាទសូត្រ | — | ០, ០២ |
| សត្តបរិត្តនឹងទ្វាទសបរិត្ត | — | ០, ៣០ |
| ធម្មបទីប | — | ០, ១៥ |

| | | |
|---|---|---|
| ល្បើកទូន្មានក្មេងចៅចិន . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ជយវរ្ម័ន ទី ៧ . . . . . . . . . . . . . . . . . . . . . . | — | ០, ២៥ |
| អត្ថានុសាសនី . . . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| ជយវរ្ម័ន ទី ៧ (អក្សរបារាំង) . . . . . . . . . . . . . . | — | ០, ៤៥ |

## រូបថតពុម្ពផ្សេងៗ

| | | |
|---|---|---|
| រូបព្រះបាទសម្ដេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . . . . | ថ្លៃ | ០រ ២៥ |
| " " ក្រដាសទន់ . . . . . . . | — | ០, ០៦ |
| " ព្រះស៊ីសុវត្ថិ . . . . . . . . . . . . . . . . . | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . . . . | — | ០, ១០ |
| រូបសម្ដេចព្រះវររាជជននី . . . . . . . . . . . . . . . . . . . | — | ០, ០២ |
| ព្រះពុទ្ធរូបមានអគ្គសាវកអម (រចនាពណ៌) . . . . . . . . . . . | — | ០, ០៥ |
| ព្រះពុទ្ធរូប និព្វាន . . . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ៣ ព្រះអង្គ . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ១ ព្រះអង្គ . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក ១ សន្លឹក . . . . . . . . . . . . . | -- | ០, ០៦ |
| រូបព្រះពុទ្ធបាទ ១ សន្លឹក . . . . . . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបព្រះឥន្ទ្រលាសំពត់រឿងពុទ្ធបរិវត្តន៍ . . . . . . . . . . . . | — | ០, ០៣ |
| ព្រះរូបសម្ដេចព្រះមហាសង្ឃរាជ (ទៀង) . . . . . . . . . . . . | — | ០, ០៣ |
| ព្រះពុទ្ធរូបបាយ័ន ១៣ សន្លឹក ១ សន្លឹក . . . . . . . . . . . | — | ០, ០២ |
| រូបគំនូរ តេមិយជាតក ១៣ សន្លឹក . . . . . . . . . . . . . . | -- | ០, ១៥ |
| " មហាជនកជាតក ១៣ សន្លឹក . . . . . . . . . . . . | -- | ០, ១៥ |
| " សុវណ្ណសាមជាតក ១៣ " . . . . . . . . . . . . . | — | ០, ១៥ |
| ប្រតិទិនឆ្នាំថ្មី . . . . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ព្រះពុទ្ធរូបមានព្រះឥន្ទ្រនឹងព្រះព្រហ្មឈរអម . . . . . . . . | | ០, ០៥ |

ÉCOLE FRANÇAISE
BIBLIOTHÈQUE

1935

ពេល



៧-៨

## សូមជូនដំណឹងដល់អ្នកមើលទស្សនាវដ្ដីកម្ពុជសុរិយា

ក្នុងឆ្នាំទី ៣ នេះ សៀវភៅទស្សនាវដ្ដីទាំង ១២ ខែ រួមមកដេរជាប់គ្នាជា ៤ ក្បាលវិញ គឺក្នុងមួយក្បាលមាន ៣ ខែ។ ដែលយើងធ្វើដូច្នេះនេះ គឺប្រយោជន៍ដើម្បីឲ្យបានរហ័សឆាប់ផងនឹងឲ្យបានធូរសោហ៊ុយក្នុងការផ្ញើលបោះពុម្ពនោះផង ព្រោះសៀវភៅទស្សនាវដ្ដីក្នុងឆ្នាំនេះបន្ថយថ្លៃចុះមកត្រឹម ៤ រៀលក្នុង ១ ឆ្នាំ ហើយចំនួនទំព័រនៅដដែល ថែមមានរឿងរ៉ាវកាន់តែច្រើនជាងឆ្នាំមុន ៗ ។

យើងមានសេចក្ដីសង្ឃឹមថាអ្នកមើលទស្សនាវដ្ដីទាំងអស់គ្នា នឹងមានសេចក្ដីសង្ឃឹមទុកចិត្តលើយើងតទៅ ហើយនឹងចុះឈ្មោះជាវជាថ្មីឡើងទៀតមិនខាន ៚

ព្រះរាជបណ្ណាល័យកម្ពុជា

INSTITUT
DE CIVILISATION
INDIENNE
N° 10 2625

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ៧

ខ្សែ ១, ២, រួមគ្នា

កុង្សីយសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER.
933

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៨

គ. ស. ១៩៣៥

1935

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

# បញ្ជីរឿង


ទំព័រ

១ — អំពីព្រះពុទ្ធរូបថ្មភក់១អង្គដែលទើបនឹងរកឃើញក្នុងដីនៅទីប្រាសាទបាយ័ន .. ១

២ — អំពីរបៀបកាន់ព្រះពុទ្ធសាសនាគ្រប់ប្រទេស ដែលអ្នកដំណើរជាតិអង់គ្លេស ម្នាក់បានអធិប្បាយក្នុងទស្សនាវដ្ដី ''មហាពោធិ'' . . . . . . . . . . ២

៣ — សាសនប្រវត្តិ ព្រះមហាពិទូរក្រសេមគន្ធវង្សបណ្ឌិតនៅព្រះរាជបណ្ណាល័យ រៀបរៀង(ត) . . . . . . . . . . . . . . . . . . . . . ៩

៤ — នីតិសាស្ត្រ ពាក្យកាព្យ អាចារ្យហ៊ឹមក្រុមជំនុំព្រះត្រៃបិដករៀបរៀង . . . . ២៣

៥ — វិជ្ជាគុណកថា កាព្យពាក្យ ពី ភិក្ខុ ឈិម-ស៊ុម (សទ្ធម្មបញ្ញា) ក្រុមជំនុំព្រះត្រៃបិដកតែង . . . . . . . . . . . . . . . . . . . . . . . ៣៧

៦ — រឿងទំនៀមទំលាប់ខ្មែរ— វិធីរក្សាគភ៌ . . . . . . . . . . . . . . . ៥៨

៧ — រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយៈ

១ — រឿងសត្វឱក្កូវនឹងសត្វក្អែកដោះប្រស្នាគ្នា . . . . . . . . . . . . ៦៣

២ — រឿងតាបពួកប្រឈ្មោះនឹងតាបក្បាលទំពែក. . . . . . . . . . . ៦៧

៣ — រឿងបុរសបាក់ស្មុគ្រ. . . . . . . . . . . . . . . . . . . ៦៩


## រូបថតៈ


ព្រះពុទ្ធរូបនាគប្រក់ នៅប្រាសាទបាយ័ន. . . . . . . . . . . . . . . ១

រូបក្រៅរឿង-ព្រះស្តូបចេតិយ នៅសារនាថ ជាកន្លែងដែលព្រះសម្មាសម្ពុទ្ធទ្រង់ សម្ដែងព្រះធម្មចក្កប្បវត្តនសូត្រ. . . . . . . . . . . . . . . . . . ២១

# TABLE DES MATIÈRES


I. Notice sur une statue de Bouddha en grès trouvé récemment au Bayon.............................................. 1

II. Le Bouddhisme dans divers pays: observations d'un voyageur anglais — Extrait de la Revue " Maha Bodhi "........................................................................ 2

III. Sasanapravatti ou l'histoire des religions par Préas Maha Pitou Krasém, pandit à la Bibliothèque Royale (suite)........................................................................ 9

IV. Nitisastra, mis en vers par l'Achar Him, membre de la Commision du Tripitaka.......................................... 23

V. Vijja Guna Katha ou les vertus de la science — Poème composé par Bhikkhu Chhim-Soum (Saddhamma Panna), membre de la Commision du Tripitaka.................. 37

VI. Les Coutumes Cambodgiennes — II. Mesures préservatrices à l'égard de la femme enceinte........................ 58

VII. Contes populaires cambodgiens inédits:

I. Dialogues entre le corbeau et la chenille.................. 63

II. Histoire de la dispute entre les oiselets Chap Pouk et les oiselets Chap Kbal Tumpèk.................................. 67

III. Conte d'un homme qui tresse une malle en feuilles de palmier à sucre.................................................. 69


## ILLUSTRATIONS


Le Bouddha sur Naga trouvé au Bayon.............................. 1

Hors-texte représentant les Ruines de cloître et stûpa de Dhamekh à Sarnath.................................................. 21



ព្រះពុទ្ធរូបនាគប្រក់ នៅប្រាសាទបាយ័ន

## អំពីព្រះពុទ្ធរូបថ្ម ១ អង្គដែលទើបនឹងរកឃើញ
## ក្នុងដី ក្នុងទីប្រាសាទបាយ័ន

ជាតិខ្មែរយើងទាំងអស់គ្នានឹងបានពេញមុខមាត់ដោយទើបនឹងបានរកឃើញព្រះពុទ្ធរូបសាងដោយថ្ម ១ អង្គ ព្រះពុទ្ធរូបនេះបើតាមក្បួនខ្នាតខាងព្រះពុទ្ធសាសនា ឃើញថាមានលក្ខណៈត្រឹមត្រូវហ្មត់ចត់ល្អណាស់ បើតាមដោយការរចនាវិជ្ជ ឃើញជាប្រកបដោយក្បួនរចនាឥតមានល្អៀងឡើយ ព្រះពុទ្ធរូបនេះគឺជីដូនជីតា ដែលជាបុព្វបុរសរបស់យើងបានកសាងក្នុងរវាងព្រះពុទ្ធសករាជ ១៧៥០ ហើយកប់នៅក្នុងដីជំរៅ ១៣ ម៉ែត្រក្នុងផ្ទៃក្រោមអាសនៈប្រាសាទបាយ័ន ដែលជាប្រាសាទយ៉ាងធើត ១ ក្នុងដំបន់មហានគរ បែបភាពលក្ខណៈក្បាច់រចនាខ្មែរទាំងប៉ុន្មានត្រឹមត្រូវគប់យ៉ាងក្នុងព្រះពុទ្ធរូបនេះ គឺព្រះភ្រូមោរាងទ្រនូយកោងស្រួល តបកព្រះនេត្រខាងលើជ្រៀលសម្រួលមកលើព្រះនេត្រ ព្រះឱស្ឋទ្រង់ញញឹមប៉ប្រឹម ហើយរាងព្រះភក្ត្រក៏ស្អាតឥតមន្ទិល ។ ព្រះពុទ្ធរូបនេះជាយ៉ាងឯកលេខ ១ រកគូរ

ផ្ទឹមគ្មានទាំងទំហំនឹងទាំងលំអក្នុងភាពរបនា គឺសមព្រមទាំងទំហំទាំងកំពស់ទាំងភាពទំនងក៏ប្រសើរ ហើយរាងពៅព្រះភក្ត្រក៏សមឥតទាស់អ្វីសោះ ។

រឿងព្រះពុទ្ធសាសនាក្នុងប្រទេសវៀន ។

មានអាំងក្លេសម្នាក់ ដែលជាអ្នកកាន់ព្រះពុទ្ធសាសនា ហើយបានដើរក្នុងស្រុក ដែលកាន់ព្រះពុទ្ធសាសនាទាំងអស់ បានសរសេរអំពីព្រះពុទ្ធសាសនាដាក់ក្នុងទស្សនាវដ្ដី "មហាពោធិ„ជាអក្សរអាំងក្លេសដែលបោះពុម្ពនៅស្រុកឥណ្ឌា ដូចខាងក្រោយនេះ ។

ខ្ញុំបានដើរគ្រប់ស្រុកដែលកាន់ព្រះពុទ្ធសាសនា ទាំងមហាយាន (រទេះធំ) នឹងហីនយាន (រទេះតូច) — ឃើញថាព្រះវិញ្ញាណរបស់ព្រះសម្មាសម្ពុទ្ធគ្មានទីផុតឡើយ ។ អ្នកឯណាដែលមិនបានសិក្សាជ្រៅជ្រះ នឹងយល់បានតែដោយអន្លើខ្លះ យើងមានទំនើងនឹងរើសយកធម៌ដែលពេញចិត្តរបស់យើង ។ អ្នកកាន់ព្រះពុទ្ធសាសនា មានបែបដែលទៅកាន់ព្រះនិព្វានផ្សេងពីគ្នា ។

ដែលហៅថា ហីនយាននោះតើដូចម្ដេច គឺគ្រាន់តែជាសេចក្ដីប្រាថ្នាខុសគ្នាបន្ដិចប៉ុណ្ណោះ ។ អ្នកចង់ទៅនិព្វានឬទេ បើខ្លួនអ្នកជាអ្នកកាន់ព្រះពុទ្ធសាសនាដោយត្រឹមត្រូវ ហ្មត់ចត់ នោះសេចក្ដីប្រាថ្នារបស់អ្នកគឺឆ្ពោះទៅរកព្រះនិព្វាន តែបើអ្នកប្រាថ្នានឹងទៅតែម្នាក់ឯង នោះខ្លួនអ្នកជាពួកហីនយាន ព្រោះអ្នកជិះយន្ដដែលបុះមនុស្សបានតែ ១ នាក់ ឥតលើសបានឡើយ ។ បើអ្នកចង់ឲ្យយឺតដំណើរក្នុងផ្លូវទៅនិព្វាននោះគឺបង្អង់ចាំឲ្យបានត្រាស់ដឹងទាំងអស់ជាមួយគ្នានោះ ខ្លួនអ្នកជាពួកមហាយាន ព្រោះអ្នកនឹងនាំអ្នកដំណើរទៅច្រើនទៅជាមួយនឹងអ្នកផង ។ ព្រោះហេតុនេះបានជាមានប្រទះឃើញព្រះពោធិសត្វ ឬព្រះពុទ្ធក្នុងអនាគតកាល ដែលពួកខាងមហាយានគោរពរាប់អានលើកដំកើង ពិតមែនជារឿងព្រះពោធិសត្វនេះអ្នកកាន់ព្រះពុទ្ធសាសនាបានស្គាល់ទូទៅទាំងអស់គ្នា ហើយបានសម្ដែងពន្យល់យ៉ាងច្បាស់លាស់ក្នុងគម្ពីរបាឡី ។

ឯព្រះបច្ចេកពុទ្ធវិញនោះ ជាបែបគំរូរបស់ហីនយាន ព្រោះព្រះបច្ចេកពុទ្ធលោកត្រាស់ដឹងតែ ១ អង្គលោក លោកបាទដល់

នូវព្រះនិព្វាន ប៉ុន្តែលោកមិនអាចនឹងនាំអ្នកឯទៀតឲ្យទៅនិព្វានបានឡើយ ។ លោកប្បាស់ក្នុងឈានរបស់លោកហើយបំពោះកាន់ខ្ជាប់តែក្នុងឈានរបស់លោក ។ ព្រះបច្ចេកពុទ្ធមិននៅលាយឡំនឹងជនសាមញ្ញឡើយ គឺក្នុង ១ ជាតិលោក ៗ នៅតែម្នាក់លោកដើម្បីភាវនាក្នុងគោហានន្ទមូល ឬនៅលើភ្នំគន្ធមាទន៍ជាកណ្ដាលជួរភ្នំហិមាលយា ក្នុងស្រុកឥណ្ឌៀ ។

លុះយូរ ៗ និមន្តបុះមកក្នុងស្រុកភូមិម្ដង ដើម្បីឲ្យបានទាយកទាយិកាថ្វាយទានដើម្បីយកផលានិសង្ស ។ ព្រះបច្ចេកពុទ្ធនឹងសម្ដែងធម៌ទេសនាមិនបានឡើយ ។ ដោយហេតុនេះហើយបានជា ក្នុងគម្ពីរផ្សេង ៗ របស់ព្រះពុទ្ធសាសនា តែងតែទុកដាក់ព្រះបច្ចេកពុទ្ធក្នុងថ្នាក់ទាបជាងព្រះពោធិសត្វ ដូចមាននិទានមហាមោរជាតកជាសំអាងស្រាប់ ។

### សេចក្ដីអធិប្បាយរួមៈយាបល់

ខ្ញុំបានដើរកាត់ក្នុងស្រុកដំបន់ទិសបូព៌ា ជាច្រើនស្រុក ហើយខ្ញុំបានឃើញច្បាស់ថាព្រះពុទ្ធសាសនា មានកំឡាំងអានុ-

ភាពពេញសំនួនក្នុងសម័យនេះ ។ ពួកអ្នកបួសក្នុងព្រះពុទ្ធ-សាសនា មានសេចក្ដីសប្បាយនឹងមានសេចក្ដីប្រព្រឹត្តិខ្ពស់ជាងពួកអ្នកបួសក្នុងសាសនាឯទៀតទាំងអស់ ។..........

..............................

កាលពីរវាង ៥០ ឆ្នាំមុននេះ នៅស្រុកលង្កា អ្នកស្រុកមានសេចក្ដីអៀនខ្មាសណាស់ដែលប្រាប់គេថា ខ្លួនជាអ្នកកាន់ព្រះពុទ្ធសាសនាហើយ ក្នុងជាន់នោះវត្តអារាមដែលកសាងឡើងនោះតូច ៗ ហើយអាក្រក់ ។ ក្នុងវេលានេះឃើញប្រែប្រួលអស់រលីង ហើយមានសាងវត្តអារាមដែលធំ ៗ ល្អ ៗ ក្ដីជាច្រើន ។ ក្នុងពួកមនុស្សសម័យខាងក្រោយ មានកើតសេចក្ដីចំរើនក្នុងចំ-ណោះវិជ្ជាជាច្រើន មានភិក្ខុដែលចេះដឹងត្រឹមត្រូវក្នុងពពួកសង្ឃជាងកាលពី ៦០ ឆ្នាំមុន ប៉ុន្តែពួកភិក្ខុក្នុងស្រុកលង្កាសុទ្ធតែថយខ្លួនចេញពីសាធារណជនស្រីឡះពេកណាស់ គឺពួកភិក្ខុទាំងនេះហើយដែលត្រូវដឹកនាំនូវឧបាសកឧបាសិកា ។ ក្នុងទីបំផុតភិក្ខុទាំងនេះត្រូវសម្ដែងសិក្ខាបទទាំង ៨ ដែលមានបារិក

ក្នុងមហាបរិនិព្វានសុត្ត . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

នៅស្រុកភូមាព្រះពុទ្ធសាសនាជាកំឡាំងជីវិត ១ ក្នុងបណ្ដាអ្នកស្រុក ហើយវិធីបរមត្ថរបស់ព្រះពុទ្ធសាសនាជាទីរាប់អានយ៉ាងសំខាន់របស់អ្នកស្រុកនេះ គឺមានមនុស្សជាច្រើនដែលរៀនព្រះអភិធម្ម (ដែលខ្ញុំរៀនមិនដល់) សេចក្ដីនេះធ្វើឲ្យឃើញថាអ្នកកាន់ព្រះពុទ្ធសាសនាក្នុងស្រុកភូមានេះ មិនមែនជាអ្នកទន្ទេញសូត្រតាមគំរូឲ្យចាំមាត់ គឺជាសេចក្ដីយល់ច្បាស់ដោយពិត ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ក្នុងប្រទេសឥណ្ឌូស៊ីន ខ្ញុំមិនអាចនឹងវិនិច្ឆ័យសេចក្ដីបានឡើយ ព្រោះបំណែកភាសាមានជារបងខាន់ មិនឲ្យស្ដាប់គ្នាបានដោយងាយ ។

បំណែកស្រុកសៀម ដោយឃើញវត្តអារាមសុទ្ធតែបិទទ្វារនោះខ្ញុំនឹកក្រែងថា គេមិនសូវរាប់អានព្រះពុទ្ធសាសនាប៉ុន្មានកាលក្នុងរជ្ជកាលព្រះបាទមង្កុដ នោះមានការផ្លាស់ប្រែជាច្រើន

ក្នុងព្រះពុទ្ធសាសនាស្រុកសៀម វត្តអារាមទាំងឡាយគេបើកតែក្នុងថ្ងៃឧបោសថ ហើយក្នុងថ្ងៃឧបោសថនោះ អ្នកគោរពព្រះពុទ្ធសាសនាឃើញសុទ្ធតែស្រីចាស់ ៗ ឃើញថាជាខុសគ្នាអំពីស្រុកភូមាណាស់ ព្រោះក្នុងស្រុកភូមាមនុស្សទាំង ប្រុស ស្រី ចាស់ ក្មេងគោរពព្រះធម៌ពេកណាស់ ។

បំណែកខាងលោកសង្ឃស្រុកសៀម ឃើញមានវត្តខ្លះនៅក្រុងបាងកក បានធ្វើការយ៉ាងល្អ ៗ ក្នុងផ្លូវព្រះពុទ្ធសាសនា។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .
. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

បំណែកស្រុកខ្មែរ ខ្ញុំមិនមានសេចក្ដីសង្ស័យឡើយ អំពីសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធសាសនា នៅក្រុងភ្នំពេញមានវត្តជាច្រើន ហើយវត្តទាំងនេះមិនមែនបិទទ្វារដូចជាវត្តក្នុងស្រុកសៀមទេ ។ ក្នុងពេលរសៀល ១ ខ្ញុំបានចូលទៅមើលវត្តបទុមវតី ដែលជាវត្តចាស់ជាងគេក្នុងក្រុងភ្នំពេញ មានលោកសង្ឃជាច្រើនមកចោមរោមខ្ញុំដោយសេចក្ដីសាទរ មានភិក្ខុ ១ អង្គក្មេង

បេះភាសាបារាំងសែសល្អបានសួរខ្ញុំជាច្រើន អំពីដំណើរដែលខ្ញុំបានធ្វើគ្រប់ស្រុក នឹងអំពីការដែលក្រុមសមាគមរបស់ខ្ញុំ ហៅមហាពោធិបានធ្វើ ។

ខ្ញុំបានចូលទៅថ្វាយបង្គំសម្តេចព្រះសង្ឃនាយកខ្មែរ ព្រមទាំងបានប្រាស្រ័យនឹងមហាថេរឯទៀតជាច្រើន ។

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

# សាសនប្រវត្តិ

## បរិច្ឆេទទី ៧

# ព្រះរាជពង្សាវតារកម្ពុជា

**ជាន់ដើមដោយសង្ខេប**

ព្រះមហាពិទូរក្រសេមគន្ធរបទបណ្ឌិត នៅព្រះរាជបណ្ណាល័យ

**រៀបរៀង**

## បរិច្ឆេទទី

### បឋមភាគពង្សាវតារកម្ពុជា ដោយសង្ខេប.

### រជ្ជកាលទី ១

ប្រទេសកម្ពុជាធិបតី ធ្លាប់ទទួលរាប់អានលទ្ធិសាសនាផ្សេង ៗ មកហើយតាំងអំពីសម័យព្រេងនាយ តែមុននឹងពណ៌នាអំពីប្រវត្តិនៃសាសនាអំពាលនោះ សូមនាំយកមូលប្រវត្តិនៃជនខេមរជាតិមកថ្លែងទុកក្នុងរវាងនេះ ដើម្បីឲ្យជ្រាបដើមទងជាមុនសិន ហើយសឹមពណ៌នាអំពីប្រវត្តិសាសនាតទៅជាខាងក្រោយដូច្នេះៈ-

តាំងអំពីសម័យពុទ្ធកាលរៀងមក មានជនជាតិផ្សេង ៗ មកតាំងភូមិលំនៅ នៅក្នុងដែនសុវណ្ណភូមិរវាងប្រទេសឥណ្ឌៀនឹងចិនជាច្រើនហើយ ៗ លុះមកដល់សមយព.ស. ៥០០ ដល់ ៦០០ មានពណ៌ដ៏មានប្រាកដក្នុងសេចក្ដីកត់ហេតុរបស់ចិននឹងពង្សាវតារលាវផៀងជាដើម ពោលដល់ឈ្មោះមនុស្សជាតិជាច្រើនជាតិ គឺ ភូមា, មន, មិឡក្ខ, ភ្នង, គួយ, សំរែ, រដែ, ស្មៀង, លាវ ឬ លាវបក, នាគ, ខ្មែរ, ចាម ជាដើម តាំងភូមិលំនៅនៅក្នុង

ដែនដីនេះ ញែកជាអាណាចក្រតូចៗជាច្រើនអាណាចក្រ ជាតិខ្លះមានក្សត្រិយ៍គ្រប់គ្រង ជាតិខ្លះគ្មានក្សត្រិយ៍ តោងរួមនៅក្នុងអំណាចអាណាព្យាបាលនៃប្រទេសដែលមានក្សត្រិយ៍គ្រប់គ្រង ។

ក៏ជនជាតិខ្មែរនេះ មិនមែនជាមនុស្សក្នុងស្រុកអាយនេះ ស្រុកដើមរបស់ខ្មែរនៅក្នុងដែនមជ្ឈិមប្រទេស(ឥណ្ឌៀ)ភាគខាងត្បូង គឺនៅក្នុងដែនកលិង្គរដ្ឋដែរហៅដូច្នេះ ដោយអាស្រ័យតឹកតាងគឺ អក្សរ នឹងភាពបម្លាក់ដែលចារិក នឹងឆ្លាក់ទុកក្នុងប្រទេសកម្ពុជានេះក្នុងជាន់ដំបូងបំផុត ឃើញសុទ្ធតែអក្សរនឹងភាពបម្លាក់របស់ប្រទេសដែលពោលមកហើយទាំងអស់ សូម្បីអ្នកប្រាជ្ញបុរាណគតិដូចយ៉ាង សម្តេចក្រុមព្រះយ៉ា ដំរុងរាជានុភាពនឹងសាស្ត្រាចារ្យ សេដេស ដែលបានពិនិត្យបុរាណស្ថានក្នុងប្រទេសនេះហើយ ក៏យល់ឃើញដូច្នេះ ។ អាការដែលខ្មែរចុះមកនៅក្នុងប្រទេសនេះ ២ យ៉ាងគឺពួកខ្លះមកដោយផ្លូវពាណិជកម្ម,ពួកខ្លះមកដោយរត់សឹក ។ ពួកដែលមកដោយផ្លូវពាណិជកម្មនោះមានមកហូរហែតាំងអំពីសម័យរួមពុទ្ធកាល ឬមុននេះក៏ថាបាន, ពួកដែលមកដោយរត់សឹកសង្គ្រាមនោះ មានពណ៌ដំមាន

ថា ក្នុងរជ្ជកាលព្រះបាទអសោកមហារាជ ប្រទេសឥណ្ឌា កើតសង្គ្រាមយ៉ាងធំ ដោយហេតុព្រះបាទអសោករាជស្ដេចលើកទ័ពទៅកម្រាបប្រទេសជិតខាងបាននៅក្នុងអំណាចជាច្រើនប្រទេសក្នុងជាន់ក្រោយបំផុតទ្រង់លើកទ័ពហ្លួងមកកម្រាបប្រទេសកលិង្គសម្លាប់មនុស្សអស់ជាច្រើនហ្មឺននាក់ ដូចមានប្រាកដក្នុងសិលាចារិករបស់ព្រះអង្គ ឬក្នុងរឿងអសោកាវទានថា អ្នកស្រុកកលិង្គបានសេចក្ដីក្ដៅក្រហាយ នឹងភិតភ័យខ្លាចសង្គ្រាមក៏នាំគ្នាដោះដៃចុះមកអាស្រ័យនៅក្នុងដែនសុវណ្ណភូមិ តាំងអំពីប្រទេសមនរហូតមកដល់ប្រទេសកម្ពុជា ។ដែលថា ខ្មែរមកអំពីឥណ្ឌានោះសមដោយសេចក្ដីចូលចិត្តរបស់ខ្មែរយើងក្នុងសម័យនេះ គឺកាលគេឃើញកលិង្គឥណ្ឌា រមែងពោលថា “នេះខ្មែរដើម” ទាំងត្រូវតាមព្រះរាជពង្សាវតារផង ។ កាលខ្មែរមកនៅយូរទៅក៏បានជាធំលើជនជាតិស្រុកអាយ ព្រោះជាតិខ្មែរជាមនុស្សដែលចំរើនដោយបំណេះវិជ្ជា ទំនៀមទម្លាប់នឹងអារ្យធម៌ ប្រសើរជាជាងជាតិឯទៀត ៗ ក្នុងបំណោមនេះ ។

ដំបូងដែលខ្មែរបានជាធំក្នុងប្រទេសកម្ពុជា ប្រាកដក្នុងសេចក្ដីកត់ហេតុរបស់ចិនថា ក្នុងរវាងសម័យព. ស. ៥០១ ដល់ ៦០០ ជនជាតិនាគ (មិនមែនសត្វនាគ) មានក្សត្រិយ៍គ្រប់គ្រងប្រទេស ១ គឺ ប្រទេសកម្ពុជានេះ តាំងរាជធានីនៅក្នុងខណ្ឌព្រៃក្របាស ហៅថា វ្យធបុរ ឬ វ្យធភាភ ដែលយើងហៅថា នគរប្ញុរី សព្វថ្ងៃនេះ ក្សត្រិយ៍ដែលប្រាកដនាមក្នុងសម័យនេះជាក្សត្រី ដែលហៅតាមសំដីចិនថា លិវយី សឹងប្រែថា នាងនាគ។ នាងក្សត្រិយ៍នេះជាមេម៉ាយសោយរាជ្យជំណាងព្រះរាជស្វាមីឬជាក្រមុំព្រហ្មចារិណី កាលឥតអំពីព្រះរាជមាតាបិតាទៅហើយគ្មានព្រះរាជវង្សនឹងទទួលរាជសម្បត្តិតទៅ ព្រះនាងទើបទទួលរាជសម្បត្តិដោយព្រះអង្គឯង ដូច្នេះឬយ៉ាងណាមិនប្រាកដក្នុងពង្សាវតារនោះ ។

គ្រានោះមានជនជាតិខេមរបុះសំពៅមកអំពីប្រទេសឥណ្ឌៀ ឈ្មោះនាយសំពៅហៅតាមសំដីចិនថា "ហ្វូនទៀង" ប្រហែលជាដែលហៅក្នុងព្រះរាជពង្សាវតារ "ព្រះថោង" នោះឯង មកអាស្រ័យនៅក្នុងក្រុងវ្យធបុរ ឈ្មោះនេះក្នុងសេចក្ដីកត់ហេតុរបស់ចិន

ថាជា ព្រាហ្មណ៍ តែប្រទះឃើញក្នុងទីដទៃថាជា ក្សត្រិយ៍ ។ ដោយហេតុហ្វូនទៀងជាបុគ្គលមានអភិនិហារនឹងមានសតិបញ្ញាឆ្លៀវឆ្លាស កាលបានមកនៅក្នុងប្រទេសនេះហើយក៏តាំងខ្លួនក្បត់នឹងព្រះនាងលិវយី ដល់ទៅច្បាំងគ្នាយ៉ាងមាំមួន តែព្រះនាងលិវយីស៊ូមិនបានក៏តោងព្រមចុះចាញ់ ហ្វូនទៀងក៏បានជាក្សត្រិយ៍គ្រប់គ្រងប្រទេសកម្ពុជា ព្រមទាំងបានព្រះនាងលិវយីជាអគ្គមហេសី ។ ដោយហេតុព្រះនាងមានព្រះរូបព្រះឆោមល្អណាស់ ស្មើហាក់ព្រះចន្ទ្រពេញវង់ ព្រះបាទហ្វូនទៀងទើបប្រទាននាមជាថ្មីថា "សោមាទេវី" ឲ្យសមនឹងព្រះឆោមនោះ តាមក្នុងដំណាលនេះឃើញថាព្រះបាទហ្វូនទៀងជាបឋមក្សត្រិយ៍របស់ខ្មែរយើងដែលមកនៅក្នុងប្រទេសនេះ ហេតុនេះអ្នកសិក្សាព្រះរាជពង្សាវតារគប្បីចូលចិត្តថា ព្រះបាទហ្វូនទៀង និងព្រះនាងសោមាទេវីនេះ(១) ជាបឋមខត្តិយរាជវង្សរបស់ខ្មែរយើងដែលមកបានជាធំគ្រប់គ្រងប្រទេសនេះ តាំងអំពី ព.ស.៥០០ ប្លាយជាដើមមក ។ កាលព្រះបាទហ្វូនទៀងមកបានជាធំក្នុងទីនេះហើយ មានជនជាតិខេមរនាំគ្នាចុះ

(១) ប្រហែលដែលក្នុងព្រះរាជពង្សាវតារថា នាម ណាគវតី ។

មកអាស្រ័យនៅនឹងមកជួញសម្បត្តិក្នុងប្រទេសនេះច្រើនឡើង ដោយលំដាប់ ជាតិខ្មែរជាមនុស្សដែលចំរើនដោយចំណេះ វិជ្ជានឹងអារ្យធម៌ប្រសើរជាជាងជនជាតិឯទៀត ៗ ដែលនៅក្នុង ស្រុកអាយនេះ ទាំងបានជាធំលើស្រុកអាយនេះផង បានដឹក នាំស្រុកអាយឲ្យបេះប្រកបការរកស៊ី នឹងធ្វើសំពត់ស្លៀកដណ្ដប់ តាក់តែងកាយឲ្យល្អឡើងជាងសម័យមុន នឹងអាស្រ័យសេចក្ដី សេពគប់នឹងការរួមប្រវេណីក្នុងរវាងជាតិទាំងពីរ ទើបទៅជា ជាតិ ១ ដែលរុងរឿងនៅដែនសុវណ្ណភូមិ តែនៅមានមនុស្សជាតិ បំពួកខ្លះ មិនត្រូវការដោយសេចក្ដីរុងរឿងដូចម្ដេចទៅទៀតក៏ ស៊ូតែនាំគ្នាជាពួក ៗ ទៅពឹងពាក់អាស្រ័យនៅដោយព្រៃភ្នំក្រិឬ គឺ ភ្នង គួយ សំរែ រដែ ស្ទៀង ជង តែម្លឹងជនជាតិអំបាលនេះ ដែលអាស្រ័យនៅក្នុងដែនខ្មែរ សព្វថ្ងៃនេះក៏រលាយជាតិជិត អស់ទៅហើយ ដូចយ៉ាងសំរែនៅក្នុងខេត្តសៀមរាប ឃើញទៅ ជាខ្មែរអស់ហើយ ។

ព្រះបាទហ្លួនទៀងមានព្រះរាជបុត្រនឹងព្រះនាងសោមាទេវី ដែលប្រាកដតាមតែ ១ អង្គហៅតាមសំដីចិនថា «ហ្លួនប៉ាន់ហ្វាង»

ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់ព្រះជន្មាយុ៥យ តែទិវង្គត ក្នុងរវាងព្រះជន្មប៉ុន្មាន ក្នុងពុទ្ធសករាជប៉ុន្មាន មិនប្រាកដ ។

## រជ្ជកាលព្រះចាន់បញ្ញាចាន់ហ្វាន ទី ២

កាលព្រះបាទហ្វូនទៀងសុគតហើយ ព្រះអង្គហ្វូនប៉ាន់-ហ្វាងរាជឱរសបានទទួលសម្បត្តិតមក ក្នុងរជ្ជកាលនេះ ទ្រង់ច្បាំងកម្រាបប្រទេសជិតខាងឲ្យនៅក្នុងអំណាចបាន ៧ នគរ រួមជាអាណាខេត្តប្រទេសកម្ពុជា គ្រានោះទ្រង់តាំងព្រះរាជបុត្រ ១ អង្គជាឧបរាជទៅឈររក្សាស្រុក ១ (តែមិនដឹងជាទៅឈរនៅស្រុកណាជាប្រាកដ ដោយប្រមាណមើលប្រហែលជាទៅប្រ-ទេសប៉ែកខាងលើ) ស្ថិតនៅក្នុងរាជសម្បត្តិដរាបដល់ព្រះជន្ម ៩០ ឆ្នាំ ទើបស្ដេចទិវង្គត ។ ឆ្នាំដែលសោយរាជ្យនឹងឆ្នាំដែលទិវង្គតបានស្រាវជ្រាវរកទៅមិនទាន់ប្រទះជាប្រាកដ សុំចំហរទុកសិន ។

## រជ្ជកាលព្រះចានប៉ាន់ចាន់ ទី ៣

កាលព្រះបាទហ្វូនប៉ាន់ហ្វាងទិវង្គតហើយ ព្រះរាជបុត្របន្ទាប់ព្រះនាមប៉ាន់ប៉ាន់បានទទួលរាជសម្បត្តិដំណវង្សមក

ទៀត (ព្រះរាជបុត្រច្បង ហេតុម្ដេចក៏មិនទទួលរាជសម្បត្តិ មិនប្រាកដហេតុក្នុងរឿងនោះ) ព្រះបាទប៉ាន់ប៉ាន់បានសោយរាជ្យឡើងគ្រាន់តែឈរព្រះនាមជាគោលក្នុងប្រទេស បំណែកឯរាជកិច្ចទាំងពួងទ្រង់ដាក់ធុរឲ្យអគ្គមហាសេនាធិបតី ឈ្មោះហ្វាន់ម៉ន ដែលជាអ្នកប៉ិនប្រសប់ក្នុងផ្លូវរដ្ឋបសាសនោបាយនឹងយុទ្ធសាស្ត្រ ឲ្យជាអ្នកសម្រេចរាជការទាំងមូលជំនួសព្រះអង្គ ហេតុប្ញីបានជាព្រះរាជាអង្គនេះដាក់ឲ្យអគ្គមហាសេនាសម្រេចរាជការជំនួសអង្គ ដោយអនុមានមើលប្រហែលជា ទ្រង់មានព្រះរោគច្រើន មិនអាចនឹងចាត់ការបានដោយស្រួល ហេតុនោះទើបប្រាកដថា ស្ដេចនៅក្នុងរាជសម្បត្តិបាន ៣ ឆ្នាំ ក៏ទិវង្គត ។

## រជ្ជកាលព្រះបាទហ្វាន់ម៉ន

កាលព្រះបាទប៉ាន់ប៉ាន់សុគតហើយ បណ្ដារាស្ត្រនឹងមន្ត្រីទាំងឡាយព្រមគ្នាលើករាជសម្បត្តិឲ្យលោកអគ្គមហាសេនាធិបតី ហ្វាន់ម៉ន ទទួលជាជំណាងឡើង ។ ព្រះបាទហ្វាន់ម៉នជាក្សត្រិយ៍សឹកមានព្រះតេជានុភាពដ៏មោះមាំ កាលទ្រង់បានគ្រងពិភពឡើងហើយ ក៏ស្ដេចលើកកងទ័ពទៅក្រោបប្រទេសជិត

ខាងឲ្យនៅក្នុងព្រះរាជអាណា វាតរីងព្រះរាជអាណាខែត្របេញ ទៅទៀតបានជាង១០ខេត្ត មានព្រះកិត្តិយសជា "មហារាជា" ជាទីស្ញប់ស្ញែងនៃអរិរាជសត្រូវ ពួកនានាប្រទេសដែលជាស្រុកបំណុះទាំងប៉ុន្មាន តែងនាំគ្រឿងរាជបណ្ណាការមកបង្គំគាល់ថ្វាយល្អងធុលីព្រះបាទជានិច្ចរាល់ឆ្នាំ ស្តេចសោយរាជរម្យនៅក្នុងក្រុងវិយធារបុរជាសុខរៀងមក លុះដល់ ព.ស. ៧៦៨ ត្រូវនឹង គ.ស. ២២៥ ក៏ស្តេចទិវង្គត ព្រះជន្មប៉ុន្មានមិនប្រាកដ ។

## រជ្ជកាលព្រះបាទហ្វាន់ចាន់

កាលព្រះបាទហ្វាន់ម័នទិវង្គតហើយ ព្រះភាគិនេយ្យ (ក្មួយ) នាមហ្វាន់ប៉ាន់ដណ្តើមរាជសម្បត្តិបាន ឡើងសោយរាជ្យតមកក្នុងរជ្ជកាលនេះទ្រង់បងសម្ពន្ធមិត្រនឹងប្រទេសឥណ្ឌា ប្រទេសចិនដើម្បីរក្សាផលវឌ្ឍនៈបសាសនោបាយ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិបានជាង ១០ ឆ្នាំ គេនោះព្រះអង្គហ្វាន់ចាងជារាជឱរសព្រះបាទហ្វាន់ម័ន សម្រេចព្រះជន្មព្រះអង្គបង់ហើយឡើងសោយរាជ្យតមក តែមិនយូរប៉ុន្មានមានមន្ត្រីធំម្នាក់ជាមេទ័ព

ដំណែងអគ្គមហាសេនាធិបតី ឈ្មោះហ្វាន់ស៊ិន ដាក់ព្រះជន្មព្រះបាទហ្វាន់ចាងបង់ទៅទៀត ។

## រជ្ជកាលព្រះបាទហ្វាន់ស៊ិន

កាលពញាមហាក្សត្រិយ៍សឹក ហ្វាន់ស៊ិន កំចាត់ព្រះបាទហ្វាន់ចាងបានសម្រេចហើយ ក៏ប្រាប្តាភិសេកសោយរាជសម្បត្តិតមកជាយូរឆ្នាំ ។ ក្នុងរជ្ជកាលនេះ ទ្រង់យកព្រះហឫទ័យទុកដាក់ទំនុកបំរុងប្រជារាស្ត្រឲ្យបេះធ្វើរបររកស៊ី នឹងធ្វើគ្រឿងសំលៀកបំពាក់ ពាក់តែងកាយល្អរៀបរយប្លែកអំពីសម័យបូរាណកាល ព្រះនគរឈ្មោះហ៊ាបានខត់ឡើងទៅកាន់សេចក្តីរុងរឿង ១ កាំទៅទៀត ។ ស្តេចស្ថិតនៅក្នុងរាជសម្បត្តិប៉ុន្មានឆ្នាំ សុគតកាល ព.ស.ប៉ុន្មានមិនប្រាកដ ។



ព្រះស្តូបចេតីយ៍ នៅសារនាថ

# ជីតិសាស្ត្រ

អាចារ្យ ហិម

ក្រុមជំនុំប្រែព្រះត្រៃបិដករៀបរៀង

# អារម្ភកថា

ខ្ញុំផ្គុំម្រាមទាំងដប់ បរិបូណ៌គ្រប់នូវក្របក បីដូចកល់ត្របក កេសរង្កាឈូកក្រពុំ ។ ដោមដាក់ដល់លើភ្នែក ត្រង់លង្វែកនាប្រជុំ បំព្រើមថ្វាយបង្គំ ឆ្ពោះព្រះពុទ្ធមង្គលលោក ។ ហើយក្រាបអភិវាទ ព្រះធម៌ស្អាតឥតស្មោកគ្រោក ដែលព្រះពុទ្ធមានជោគ ទ្រង់សំដែងប្រដៅជន ។ ហើយក្រាបថ្វាយបង្គំ ព្រះសង្ឃសមប្រសើរលន់ សាវកព្រះមានគុណ ជាស្រែបុណ្យដល់សព្វសត្វ ។ សូមគុណរតនត្រ័យ ប្រសើរក្រៃជួយកំចាត់ ទុក្ខសោករោគឲ្យបាត់ ដោយអំណាចក្រាបបង្គំ ។ ខ្ញុំជាវង្សបណ្ឌិតនាមឈ្មោះពិតប្រសើរសម អាចារ្យហិមឧត្តម អ្នកសន្សំសីលភាវនា ។ សូមតែងសេចក្ដីពិត ដោយសង្ខិតពាក្យកាព្យប្រែមកពីគាថា លោកនីតិបាឡី ។ ដោយមានចិត្តប្រាថ្នាសង្គ្រោះមហាជនប្រុសស្រី ឲ្យឆ្លាសការលោកីយ៍ ដូចសេចក្ដីតនេះទៅ ។

## នីតិសាស្ត្រ

### បទព្រហ្មគីត

ជាតិខ្ជិលឥតសិល្បសាស្ត្រ ទ្រព្យវិនាសព្រោះល្ងង់ខ្លៅ ខ្សត់ទ្រព្យឥតញាតិនៅ រករាប់អានហោមរោមច្រើន ។ គ្មានញាតិមិត្តទំនុក ពុំបានសុខបានចំរើន វាស្នាក់ពុំកើន កប់ជាប់ក្នុងសង្សារ ។ មានទ្រព្យគាប់គ្រាន់បើ តែពុំស្មើនឹងវិជ្ជា ចេះចាំកិច្ចវិទ្យា ចោរលបលួចយកពុំបាន ។ វិជ្ជាទុកដូចមិត្ត លោកីយ៍ពិតពេញថ្កើងថ្កាន បរលោកក៏ក្សេមក្សាន្ត សុខសម្រានបានជាពូជ ។ កុំមកងាយបញ្ញា ដោយគិតថាមានតិចតួច មិនសម្រេចប្រយោជន៍ ដោយចំណេះចេះប្រាជ្ញព្រោក ។ ដូចផ្ទាំងបើកមាត់បើ លើកដាក់លើក្បាលដំបូក ដំណក់ភ្លៀងជោរជោក យូរ ៗ ទៅគង់ពេញបាន ។ កុំមើលងាយចំណេះ ដែលខ្លួនចេះតិចប៉ុន្មាន ឲ្យតែចាំចំណាន គង់នឹងបានមានកេរ្តិ៍ឈ្មោះ ។ គេពឹងក្នុងលោកីយ៍ ដោយមានល្បីឈ្មោះពីរោះ ការគេពឹងពរនោះ ជាប្រយោជន៍ដ៏ស្តុកស្តម្ភ ។ ជាតិកែវមណីល្អផើត មិនដែលកើតសព្វថ្មភ្នំ គជមានថ្លៃឧត្តម មិនមានសព្វគជេន្ទ្រជ័យ ។

ខ្លឹមចន្ទន៍ក្រអូបអប់ មិនមានសព្វដំបន់ព្រៃ អ្នកប្រាជ្ញព្រិល្សប្រពៃ
មិនដែលកើតមានសព្វស្ថាន ។ ប្រសិនបើឮថា អ្នកប្រាជ្ញណា
ចេះចំណាន មកថ្លែងសំដែងអាន ធម៌អាថ៌អត្ថក្នុងទីណា ។
ត្រូវខំគិតខ្នះខ្នែង ដោយខ្លួនឯងមានឧស្សាហ៍ សង្វាតចរយាត្រា
ទៅស្តាប់រៀនក្នុងទីនោះ ។ រៀនសិល្បកុំរួសរាន់ ញាប់ចន្ទាន់ចិត្ត
ដូច្នោះ រកទ្រព្យសន្សំចុះ គំនិតថ្នមដូចឡើងភ្នំ ។ សេពគាមគួរ
បន្ថយ សេពញយ ៗ គួរតែធុំ ធ្វើការកុំបង្ខំ ឲ្យសន្សំតាមធម្មតា ។
សិល្បសាស្ត្រក្នុងលោកីយ៍ ដប់ប្រាំបីតាមមាត្រា ១ ចេះស្តាប់
ភាសា ២ ចេះឆន្ទសាស្ត្រជាក់ ។ ៣ ចេះលេខនព្វន្ត
៤ អត់ធន់ចេះបាំងឆ្លាក់ ៥ ចេះទាយលក្ខណ ៦ ចេះទាយជោគ
ជ័យ ។ ៧ ចេះច្រៀងរាំស្អាត ៨ ផ្ទាត់គ្រួសត្រង់ក្រៃ ៩ ចេះផ្ទួ
សិល្បសៃយ ១០ ចេះលៃលកវិចា ។ ១១ ចេះក្បួនពេទ្យ
១២ ហេតុចេះកាព្យ ១៣ ត្រៃវិទ្យា ១៤ ចេះព្យូហ៍សត្រូវ ។
១៥ ចេះនីតិសាស្ត្រ ១៦ ឆ្លាសគ្នេគ្នាន់ត្រូវ ១៧ ចេះខាបហៅ
១៨ ចេះចិត្តជឿជាក់ ។ បណ្ឌិតពិតពេញគួរ គ្មានគេសួរសាក
ប្រត្យក្ខ ស្ងៀមស្ងាត់មិនហើបហាក់ ដូចស្គរធំឥតគេវាយ ។

បើគេសួរកាលណា មានវាចាចេញរោះរាយ ហួរហែតាមបរិ-យាយ មានគួរគាដូចភ្លៀងធ្លាក់ ។ ជាតិពាលមិនដឹងគួរ គ្មានគេសួរសាកបង់ជាក់ ឆ្លើយឆ្លងផងរាក់ទាក់ ក្បួនហិនលក្ខណ៍ធ្លាក់លើខ្លួន ។ សិល្បសាស្ត្រមិនចាំមាត់ មានប្រាកដនៅក្នុងក្បួន ដល់ពេលដែលជួបជួន គេសួរសាកពិបាកគេច ។ ទ្រព្យធនផងខ្លួនក្ដី ឲ្យគេខ្ចីទោះច្រើនតិច ដល់ត្រូវការធ្វើម្ដេច នឹងបានចាយឈ្មោះថាគ្មាន ។ ទ្រព្យលើកឲ្យគេខ្ចី ចេះដឹងអ្វីឆ្លើយមិនបាន ភរិយានៅឆ្ងាយប្រាណ ឈ្មោះថាគ្មាន ៗ ដូចគ្នា ។ ប្រមាណទឹកពិនិត្យ ដកព្រលឹតវាស់វែងវា ប្រមាណមនុស្សកាចជា មើលកិរិយាអាការចេញ ។ ប្រមាណអ្នកប្រាជ្ញប្រាយស្ដាប់បរិយាយពោលមកមិញ ប្រមាណដីជីដេញ មើលស្មៅខៀវទើបដឹងបាន ។ ធ្វើស្រែឲ្យមើលស្មៅ រៀបកូនចៅមើលសន្ដាន ទីនៅមើលភូមិស្ថាន ស៊ីប្រមាណមើលអាហារ ។ ខ្លៅរៀនសូត្រតិចតួច គិតថាស្រួចគ្រប់កិច្ចការ មិនដឹងរសធម៌អាថ៌ ដូចកង្កែបបែបកំឡៅ ។ នៅក្នុងអណ្ដូងទាល់ មិនដែលស្គាល់សមុទ្រជ្រៅ សំគាល់ទីដែលនៅ ថាធំជ្រៅប៉ុណ្ណោះឯង ។ វ័យទី១ គឺថា គ្រប់អាត្មាកាលនៅក្មេង កុំខ្ជិលកុំដើរលេង

កុំកាន់ល្បែងផងនានា ។ ប្រឹងប្រែងឧស្សាហ៍រៀន ខំប្រឹត
ប្រៀនគួរអក្ខរា បឋមវិជ្ជា ឲ្យបេះចាំស្ទាត់បំណាន ។ វ័យទី ២
ក្នុងកាល ខ្លួនកណ្ដាលត្រូវឲ្យមាន ខ្វល់ខ្វាយរកធនធាន ទ្រព្យ
បរលោកទ្រព្យលោកីយ៍ ។ កុំបីមានប្រមាទ ប្រឹងឧហាតចិត្ត
មេត្រី ក្នុងធម៌សុចរិតបី ជាវិន័យគ្រប់រូប ។ នាវ័យទី ៣
នោះ កាលខ្លួនចុះចាស់ជរា សោមនស្សក្នុងភាវនា ចោះចិត្ត
ភ្ជាប់ក្នុងត្រ័យលក្ខណ៍ ។ ឲ្យដឹងថាមិនទៀង ព្រួយរៀង ៗ
ទៅតាមថ្នាក់ ឥតខ្លឹមឥតសារធ្លាក់ ចុះក្នុងសូណ្យគ្រប់អាត្មា ។
ហៃបាបុត្តឧត្តម ចូរបាខំរៀនសិក្សា បើខ្ជិលរៀនវិជ្ជា ចុះចំ-
រើគេមិនខាន ។ បើបាខំរៀនបេះ ក្នុងលោកនេះគេរាប់អាន
មានយសស័ក្តិថ្កើងថ្កាន ចូរខំហាត់ឲ្យស្ទាត់ទៅ ។ មាតានឹង
បិតា ជាវរាឬសត្រូវ ណែនាំកូនខុសផ្លូវ មិនបង្ខំឲ្យរៀនសូត្រ ។
លុះកូនធំកាលណា ចូលពាលាខុសរហូត ដឹកនាំដោយក្រេវ
ក្រោធ ឬលោមល្អងពត់មិនឡើង ។ អាប់មុខក្នុងជំនុំ មន្ទិល
រុំមិនឲ្យថ្កើង ដូចកុកលោតចរចើង ចូលក្នុងហ្វូងរាជហង្ស ។
ភ្នំបត្លាស្រូបឯង គ្មានបាត់បែងតាមចិត្តចង់ ភ្នែកម្រឹគខ្មៅថ្លាយយង់

តាមធម្មតាគ្មានថ្នាំផប់ ។ ផ្កាឧប្បលក្រអូបឯង គ្មានបាត់បែង បាក់ទឹកអប់ កុលបុត្តបេះដឹងសព្វ កុំបាំបាច់គេតឿនក្រើន ។ កូនណាឧស្សាហ៍ត្រាប់ ប្រឹងរៀនស្តាប់បេះដឹងច្រើន កូននោះនឹងចំរើន ផលប្រយោជន៍ក្តីសុខា ។ ១ សុខក្នុងមនុស្សលោក គ្មានទុក្ខសោកនឹងរោគា, ២សុខក្នុងទេវតា, ៣សុខបាននិព្វានពិត ។ ទ្រព្យពុំស្មើវិជ្ជា ពាលពាធាដេញប្រកិត ពុំស្មើរោគរោមរិត កាយិន្ទ្រីយ៍យើងគេះសោះ ។ ស្រឡាញ់អ្វីពុំស្មើបាន នឹងខ្លួនប្រាណនៃយើងនោះ កំឡាំងអ្វីប្រជុំបុះ ក៏ពុំស្មើកំឡាំងកម្ម ។ ហង្សនៅក្នុងហ្វូងក្អែក រាជសីហ៍សែកនៅដំរាំ ក្នុងហ្វូងគោក៏ទ្រាំ ក្តីខ្វាននៃរាល់គ្រា ។ អាជានេយ្យនៅប្រទ្បូ ស្មុគ្រស្មាគមដោយហ្វូងលា អ្នកប្រាជ្ញព្រិត្តប្រជា នៅក្នុងពួកពាលសាមាន្យ ។ លំនៅ ៗ ប្អូននេះ ទាស់ដំរេះហៅខុសស្ថាន ពុំសុខពុំក្សេមក្សាន្តបានហោកទាបភាពប្លែក ៗ ។ ពាលនៅផងបណ្ឌិត អស់ជីវិតលង់អនេក មិនដឹងធម៌អាថ៌ឯក ប្រៀបដួចវែកមិនដឹងរស ។ ប្រាជ្ញនៅផងអ្នកប្រាជ្ញ រំពេចអាចដឹងធម៌អស់ ដូចអណ្តាតដឹងរស សាបប្រៃស្រស់ល្វៀមដឹងបាន ។ អ្នកប្រាជ្ញមិនប្រកាស

ក្ដីវិនាសអន្តរធានមិនឲ្យក្ដៅក្នុងប្រាណ នឹងសន្តានបុត្រភរិយា ។ គ្មានឆបោកបញ្ឆោត គ្មានក្រេវក្រោធក្រៅធម្មា គ្មានមើលងាយគ្នីគ្នា ក្នុងគ្រិហាឬញាតិមិត្ត ។ ជនណាដឹងគួរសម ដឹងភិរម្យពាក្យពោលពិត មិនខឹងក្រោធក្រៅកិត្យ ជននោះពិតជាអ្នកប្រាជ្ញ ។ មនុស្សខ្ជត់អត់ធនធាន ឡើងជោរមានចិត្តល្ហល្ហាប កើតបង់រសអង់អាច លក់បញ្ចាំឲ្យតែឆ្ងាញ់ ។ មនុស្សខ្សោយខ្សត់កំឡាំង ឡើងជោរតាំងលេងឈ្នះចាញ់ ក្អេងក្អាងអួតថាអញពេញជាមនុស្សខ្លាំងពូកែ ។ មនុស្សអាប់ឥតប្រាជ្ញា គ្មានវិជ្ជាបេះអត្ថប្រែ និយាយខុសហួរហែ ណាស់តែពាក្យពោលអាងអួត ។ មនុស្ស ៣ ពួកនេះឯង លោកសំដែងថាស្មើឆ្កួត ព្រោះជោរឡើងអំនួត ល្មោភល្មើសលើសហួសប្រមាណ ។ មនុស្សណាឆ្លេឆ្លាចិត្ត ទៅមកឥតគេរាប់អាន ឡើងផ្ទះគេហៅហាន កើតរំខានដល់គេឯង ។ ឬឥតគេសាកសួរ មិនដឹងគួរឡើងថាថ្លែង ឆ្លើយឆ្លងឥតមានក្រែង កាត់គេឯងថ្លែងបំពាន ។ ឬឥតគេសរសើរតាមដំណើរចិត្តឃ្លានពាន អួតសរសើរធនធាន ឬអ្វី ៗ ហួសដំណាក់ ។ មនុស្ស ៣ ពួកនេះឯង លោកសំដែងថាហិន

លក្ខណ៍ បុះទាបភាពយសស័ក្តិ ជាមនុស្សធ្លាក់បាកក្តិក្តើង ។
មនុស្សហោកសំដីខ្ពស់ ឥតឥស្សរិយយសរឹកបរើង ប្រាជ្ញា
តិចស្តួចស្តើង ប្រឹងដំឡើងអំនួតចេញ ។ ដូចទឹកកន្លះក្អម
ទោះលើកឬមយ៉ាងណាមិញ ឃ្លេងឃ្លោងក្រឡុកចេញ ក្រនឹង
ទប់ឲ្យនឹងបាន ។ ឬដូចមេគោតិច ទឹកដោះគេចគាយផ្ទោះក្រាន
ធាក់ប្រិបន្លំដាន មិនឲ្យកូនបៅអាត្មា ។ ក់ង្កេបប្រហោងស្រែក
អាងសម្រែកស្មើសីហា អួតទាល់អោយបង្កា ដូចពាលាឡើង
អំណាច ។ អួតចេះដឹងជ្រៅជ្រះ ចោទឆ្លើយឈ្នះលោកអ្នកប្រាជ្ញ
ពោលខុសក៏មិនខ្លាច បន្លំកាចបន្លប់ថា ។ កុលបុត្រកបរូបទ្រង់
កើតក្នុងវង្សមានសក្តា មិនចេះសិល្បសាស្ត្រា ដូចផ្កាបារឥតក្លិន
ភ្ញី ។ ស្រស់តែពណ៌សម្បុរ ប្រាលសន្ធោរដូចអគ្គី កុលបុត្រ
មិនចេះអ្វី កើតហោកទាបសាបអំណាច ។ អ្នកទាបជាអ-
មាត្យ កូនពាលឆ្លាតជាអ្នកប្រាជ្ញ កូនអ្នកក្រជាប់ជាច ឡើង
ជាអ្នកមានធនធាន ។ ប្រុសអើយបូរអ្នកស្តាប់ យើងថ្លែង
ប្រាប់ឲ្យអ្នកមាន គំនិតកុំបំពាន ពាក្យប្រមាទមើលងាយគេ ។
ស្ទូនផ្ទាំងដំសំពង ក្អមផ្ទាំងប៉ងឲ្យល្អទេ គ្រូហាត់ទោះវាយដេរ

ចង់នាំសិស្សចេះសិល្បសាស្ត្រ ។ អ្នករៀបរុំក្រស្នា ស្លឹកធម្ម-តាឬក្រដាស ពីដោរផ្សាយផ្សប់ពាស ក្រអូបអប់អ្នករៀបនោះ ។ ស្លឹកឈើឬក្រដាស ជាប់ក្លិនពាសពេញចំពោះ គប់ប្រាជ្ញអាចភ្លឺផ្លុះ មានដូច្នោះគួរឲ្យត្រេក ។ អ្នកសេពគប់សប្បុរស មានសោមនស្សប្រសើរពេក ចេះដឹងធម៌អនេក ដឹងបាបបុណ្យគុណទោសនោ ។ ហៃចៅជាតិពិសី ចូរលះក្ដីប្រទ្បំទៅ ដោយផនពាលឃោរឃៅ ចូរគប់នៅពួកសប្បុរស ។ ចូរធ្វើបុណ្យប្រក្រតី សព្វរាត្រីថ្ងៃទាំងអស់ ឲ្យមានចិត្តសោមនស្ស នឹកត្រៃលក្ខណ៍ជាគ្រឿងទ្រង់ ។ ផ្លែឧទុម្ពរចាស់ទុំ សម្បុករុំក្រៅរលង់ គ្រាប់សោតសឹងមមង់ ក្រៅនឹងក្នុងមិនត្រូវគ្នា ។ ចិត្តពាលដូចទេវទត្ត ល្អតែមាត់ដូចទេវតា ឧទុម្ពរយ៉ាងណា ពួកពាលយ៉ាងនោះឯង ។ ខ្នុរណាំងទុំបន្លា ច្រូងច្រាងមហាស្រួចជាក់ស្ដែង ក្លិនក្លែបពីដោរឈ្ងុង ឱជារសផ្អែមពីសា ។ ប្រៀបដូចពួកសប្បុរស ក្រៅមិនស្រស់ប៉ុន្តែថា ខាងក្នុងគួរស្នេ-ហា ព្រោះសុចរិតឥតត្មះបាន ។ ខ្លឹមចន្ទន៍ក្រៀមក្រញង់ មិនលះបង់ក្លិនកល្យាណ ដំរីសឹកក្លាហាន ចូលសង្គ្រាមដោយ

ឱបាយ ។ មិនលះដំណើរល្អ ទោះតាំងតស្គាយល្គងក្រាយ អំពៅផងទាំងឡាយ ទោះនៅក្នុងឃ្នាបគាបរឹត ។ មិនលះបង់សភាព ផ្អែមដរាបរសល្អពិត អ្នកប្រាជ្ញដែលប្រព្រឹត្ត ទោះមានទោសទុក្ខយ៉ាងណា ។ មិនលះធម៌សុចរិត នៅប្រព្រឹត្តតាមធម្មតា សិស្សហាត់រៀនសិក្សា ចូរយាត្រាផ្លូវនេះចុះ ។ រាជសីហ៍ស្តេចម្រឹគ ខ្លាំងពន្លឹកអធិកទោះ អត់ឃ្លានយ៉ាងណានោះ មិនបរិភោគស្លឹកឈើស្មៅ ។ រាជសីហ៍ទោះស្គាំងស្គមធុះទ្រមម្លូហ្មងសៅ អត់ធន់ស៊ូទ្រាំនៅ មិនបរិភោគសាច់ដំរី ។ កុលបុត្រមានពូជពង្ស រក្សាវង្សស្រីសួស្តី ក្រខ្សត់យ៉ាងណាក្តី មិនប្រព្រឹត្តការទាបពេក ។ កន្លង់ប៉ង់ត្របង្កា ប្រាជ្ញប្រាជ្ញាប៉ងត្របត្រែក រសធម៌អាប់អនេក មិនជិនឆ្អន់រសធម៌ឡើយ ។ រុយប៉ង់រោមលាមក ពាលឥតគ្នក់កាន់កៀកកើយ ធម៌បាបជាអស់ហើយ ស្រឡាញ់បាបមិនងាកមុខ ។ ពាលស្វែងបាបអកុសល មិនស្កប់ស្កល់ដូចជ្រូកស្រុក ស្វែងរកជ្រាំមូត្រល្មក់ជាអាហារនឹងខ្នាបខ្លួន ។ ប្រាជ្ញស្វែងបុណ្យកុសល មិនស្កប់ស្កល់មិនល្មមធួន ដូចហង្សហើរស្វែងកូន ស្រះបុះបឹកក្បេរ

ឆ្កែ ។ ឆ្កែឃើញឆ្កែគ្នាឯង តាំងសំដែងប៉ងពាធា ជនផ្សួរ ជួបគ្នាវា រករឿងហេតុឈ្លោះប្រកាន ។ បាបមិនទាន់ឲ្យផល ពាលគិតយល់ថាបាបគ្មាន ឃើញបុណ្យពីបូរាណ រឹងរឹត ហានធ្វើបាបទៀត ។ កាលណាអស់បុណ្យនោះ បាបក៏ស្ទុះ មកប្រៀតបៀត ឲ្យផលខ្វល់បង្អៀត ពាលរងទុក្ខធំកាលណោះ ។ ពាលណាដឹងខ្លួនឯង ថាបែបលេងមិនល្អព្រោះ ទទួលទុកបំ-ពោះ ហើយលើកចិត្តឡើងប្រព្រឹត្ត ។ ធ្វើទានសីលភាវនា មានមេត្តាកាន់សុចរិត ពួកពាលនោះឯងពិត ជាអ្នកប្រាជ្ញ ស្ដែងក្នុងលោក ។ ប្រាជ្ញណាតាំងខ្លួនឯង ឡើងថ្លាថ្លែងថា ប្រាជ្ញព្រោក អស្មិមានះដោក ម្លូស្រឹងក្នុងលោភា ។ ប្រាជ្ញ នោះលោកកំណត់ ថាប្រាកដជាពាលា មិនមែនប្រាជ្ញប្រិជា ព្រោះទុច្ចរិតចិត្តវៀចវរ ។ ខ្ញុំតែងច្បាប់នេះទុក ដោយទំនុក បម្រុងត សាសនាឲ្យបានល្អ ជាសង្ខេបប៉ុណ្ណោះហោង ។៚—

វិដ្ឋាកុណាកថា

កាព្យពាក្យ ៧

# ភិក្ខុ (សទ្ធម្មបញ្ញា) ឈិម-ស៊ុម

ក្រុមជំនុំប្រែព្រះត្រៃបិដកក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ព. ស. ២៤៧៨

គ.ស. ១៩៣៥

ពាក្យ ៨

អហិរីទុំអក្សរសិ ស្រឧខ្យល់មប្រកបមុខ នាមនេះពិត ពីម្តាយឪពុក លោកបានដាក់ទុកជាសញ្ញា ។ រីនាមទីពីរ លោកកំណត់ ហៅតាមដោយបទបាឡីថា ភិក្ខុសទ្ធម្មបញ្ញា តាមកម្មវាចានឹងឧបជ្ឈាយ៍ ។ សូមថ្លែងតាមដោយពិនិត្យយល់ នៅលើសកលផែនពសុធា ជនផងដែលកើតមកគ្រប់គ្នា មិនមាននរណាទំនេមួយ ។ សុទ្ធសឹងមានកិច្ចការរវល់ រដើបរបល់កង្វល់ព្រួយ ព្រោះតែចិញ្ចឹមជីវិតមួយ ជាហេតុឲ្យព្រួយខានមិនបាន ។ ខ្លះមានអាហារដោយសព្វគ្រប់ តែមិនទាន់ស្កប់ក្នុងសន្តាន ខំប្រឹងរកគ្រឿងដំកើងប្រាណ ខ្លះបង់ឲ្យបានគេកោតខ្លាច ។ បំណងប៉ុណ្ណោះជាដើមទង ធ្វើឲ្យអ្នកផងព្រឹងប្រសាច អ្នកណាប្រសប់ទើបអង់អាច គឺជាអ្នកប្រាជ្ញទើបបានព្រម ។ អ្នកមានប្រាជ្ញាមានគំនិត បេះអ្វីបេះពិតប្រព្រឹត្តល្មម មិនល្មោភលោភល្មើសលើសទាំងព្រម បេះហ្នក់បេះថ្នមរក្សាខ្លួន ។ ទើបពេញបំណងប៉ងប្រាថ្នា ត្រូវការអ្វីបានគ្រប់ចំនួន

តាមដោយបំណោះបេះរាល់ខ្លួន បេះបីបេះបួនគង់បំពើន ។

រីឯបំណោះក្នុងលោកីយ៍ បើនឹងស្រដីឃើញមានច្រើន សុទ្ធតែវិជ្ជាត្រូវក្រវើន ជាហេតុបំរើនដល់អាត្មា ។ មានដប់ប្រាំបីបាឡើយឡើង ដូចនឹងសំដែងតែងមាតិកា ១- គឺបេះស្តាប់សព្ទភាសា ២- បេះសាស្ត្រាធមិអាចិជាក់ ។ ៣- បេះលេខបូកលេខគុណហារ ៤- មានប្រាជ្ញាបេះគួរឆ្លាក់ ៥- បេះដម្រាទាយលក្ខណៈ ៦- បេះដាក់ឫក្សជោគជ័យ ។ ៧- បេះបាំច្រៀងរាំស្អាត ៨- បេះផ្ចាត់ដោយម្រាមដៃ ៩- បេះមន្តធ្នូសិល្បសៃយ ១០- គឺបេះសៃលករាចា ។ ១១- បេះពេទ្យរក្សារោគ ១២- បេះយោគយោងកាព្យា ១៣- បេះភេទត្រៃវេទ្យា ១៤- មាយាព្យហ៍សត្រូវ ។ ១៥- បេះធន្ធតិសាស្ត្រ ១៦- បេះគាតគ្នេក្នុងក្រៅ ១៧- បេះមន្តសែកហាហៅ ១៨- បេះផរសត្វខ្លាប់ ។ សិប្បៈទាំងដប់ប្រាំបីនេះ អ្នកប្រាជ្ញត្រិះរិះជាប្រដាប់ ឲ្យអស់អ្នកផងបានត្រងត្រាប់ តាំងទុកជាច្បាប់ក្នុងលោកីយ៍ ។

ហៃសាធុជនផងទាំងឡាយ គួរខំខ្វល់ខ្វាយទាំងប្រុសស្រី កុំធ្វេសប្រហែសភ្លេចស្មារតី សង្វាតឃ្មាតខ្មីរៀនវិជ្ជា ។ ត្រូវ

តែយើងខំប្រកបកិច្ច ឲ្យបានសម្រេចតាមវេលា បឋមវ័យ
ត្រូវយើងរៀនវិទ្យា អក្ខរវិជ្ជាលេខភាសា ។ ឲ្យបានបេះបាំ
ជាប្រធាន រូបទើបគិតអានពិចារណា រើសរកវិជ្ជាដែលថ្លៃ
ថ្លា គេរាប់ត្រង់ណាចាប់ត្រង់នោះ ។ វិជ្ជាទាំងអស់ដូចបាន
ថ្លែង រាប់រៀបសំដែងរៀងរាល់ឈ្មោះ មិនមែនសក្តិ៍សិទ្ធិ៍សព្វ
សាយសុះ មានត្រូវមានខុសតាមសម័យ ។ ស្រេចហើយនឹង
យើងប្រឹងសង្កេត មើលបែបផែនអោទសុីវីឡៃ កុំធ្មេងធិត
ទាំងយប់ថ្ងៃ វិជ្ជាណាថ្លៃត្រូវយើងរក ។ ដូចជារបស់ភស្តុ
សម្ភាយ ជនផងទាំងឡាយគេចង់យក ចង់ទិញចង់ដូរត្រូវ
យើងរក ហើយគិតលៃលកលក់យកថ្លៃ ។ បំណេះមិន
មែនបេះតែគេ បើយើងរិះរេគង់រៀងរៃ ស្រេចនឹងសន្សំសព្វ ៗ
ថ្ងៃ គង់បានកម្រៃមិនសូវខ្វះ ។ ប្រៀបដូចអុងអាងពាងក្រឡ
បើកមាត់បំហរឲ្យស្រឡះ ដាក់ត្រងទឹកភ្លៀងគង់ពេញខ្លះ
យូរទៅប្រទះពេញមិនខាន ។ កំណើតវិជ្ជាដូចឫស្សី ដាំមួយ
ដុះបីបួនក៏មាន វិជ្ជាបេះបាំក្នុងសន្តាន សង្វាតហាត់អាន
គង់បេះច្រើន ។ វិជ្ជាជាទ្រព្យវិសេសថ្លៃ មិនបាច់សំបៃគង់

បំរើន ហាយណាស់កើតណាស់រឹតតែច្រើន អ្នកណាក្រវើន អ្នកនោះបេះ ។

អ្នកមានវិជ្ជាមិនល្ងង់ខ្លៅ ទោះបីខ្វនខ្មៅមុខក្រងេះ អាក្រក់តែរូបប៉ុន្តែបេះ គេថាអ្នកនេះជាមនុស្សល្អ អ្នកណាមិនបេះបំណេះអ្វី ទោះប្រុសឬស្រីសប្បុរស សាច់ឈាមល្អកល្អិនមុខមាត់ល្អ អ្នកផងគេក៏ថាមិនសម ។

អ្នកមានជម្ងឺមិនសប្បាយ ក្រហល់ក្រហាយកាយក្រៀមក្រំ ត្រូវការណាស់ត្រង់មន្តអាគម ឬពេទ្យបេះផ្សំឱសថថ្លៃ ។ នេះឯងជាតួឧបមា ដូចជនគ្រប់គ្នាគ្រាសព្វថ្ងៃ ត្រូវការអ្នកប្រាជ្ញបេះរៀងរៃ អាចបេះលកលៃសម្រួលចិត្ត ។ ហេតុនេះគួរដឹងថាអ្នកបេះ អ្នកមានបំណេះប្រសើរពិត ប្រៀបដូចគ្រូពេទ្យបេះពិនិត្យ ជាមនុស្សពេញចិតអ្នកជម្ងឺ ។

អ្នកនៅក្នុងទីងងឹតឈ្លប់ ទាំងថ្ងៃទាំងយប់មិនយល់ភ្លឺ មិនមានពេលណាមានពន្លឺ ឃើញភ្លើងភ្លឺៗគាប់ចិត្តពេក ។ ដូចជាមហាជនក្នុងលោកីយ៍ ទាំងប្រុសទាំងស្រីច្រើនអនេក ក្តីល្ងង់បិទជិតងងឹតពេក ឃើញប្រាជ្ញហើយត្រេកអរសាទរ ។

ជាតិជនអ្នកបេះដូចភ្លើងគោម ពន្លឺទ្រហោមឆោមបវរ ជន ផងបូលបិត្តរឹតត្រេកអរ រាប់អានឈ្មោះអស់ទាំងស្រុក ។

ល្បង្គ័ជសេតុប្បលរត្តុប្បល លូតហាស់ផុសផុលពីក្នុងភក់ ផុតផែនប្របរីទឹកគ្រក់ កន្លង់តត្រុកត្រឹបកេសរ ។ ក្លិនក្លែប ពិដោរក្រអូបសាយ កន្លង់ទាំងឡាយតែងត្រេកអរ ប្រទុម ក្រពុំក្លិនបវរ កន្លង់តែងបរមិនគេចចេញ ។ តែងត្រេកត្រេប ត្រង់ដម្រង់ត្រឹប មីរម្យូលរសឹបត្រឹបពេញ ៗ ប្រទុមជាតិនេះដូច ម្តេចមិញ ប្រុសប្រាជ្ញលំគេញក៏ដូច្នោះ ។ គឺជាកុលបុត្តវិសុទ្ធ ថ្លៃ កម្មព្រេងដឹកដៃឲ្យប្បុតបុះ ចាប់ជាតិត្រកូលទន់ទាបតុះ កើតឡើងលេចឈ្មោះជាអ្នកប្រាជ្ញ ។ លំអុតឱនអង្គត្រង់សិក្ខា នរណានរណាក៏កោតខ្លាច យ៉មខ្លួនជាខ្មៅទៅប្រសាច ប្រសប់ រកប្រាជ្ញដូចកន្លង់ ។

បុប្ផជាតិដែលគ្មានសុគន្ធា ដូចជាផ្កាចារីករហង់ ឬផ្កា រល្លួសគ្គរភិស្សរង់ លេចឡើងមានទ្រង់ពណ៌ឆ្អិនឆ្អៅ ។ ប៉ុន្តែ គេមិនមានប្រាថ្នា ស្ម័ប្បភមរាក៏កល់ជិន ព្រោះឃើញជាតិផ្កា នោះឥតក្លិន នរៈនារីនក៏ដូច្នោះ ។ គឺជាបុរសឬស្រីណា កប

ពូជពង្សរាមិនទាបតុះ ជាតិធំស័ក្តសមតែឥតឈ្មោះ ល្ងង់ខ្លៅ សូណ្យសោះទាស់កិរិយា ។ អ្នកផងមិនមានក្តីត្រេកអរ សូម្បីអ្នកក្រមិនប្រាជ្ញា ព្រោះល្ងង់សូណ្យសុងគ្មានបញ្ញា ពាក្យបាស់លោកថាមិនគ្រប់ដប់ ។

ប្រុសមានវិជ្ជាជាធនធាន ស្រីមានរឹកពាទុកជាទ្រព្យ អ្នកគ្មានបំណោះឥតគោរប់ លោកថាឥតភ័ព្វទុគ៌តក្រៃ ។ ប្តីបើខ្ជូនជាកូនអ្នកមាន សំបូរធនធានវិសេសថ្លៃ ទ្រព្យនោះបើមិនបេះសំបៃ គង់តែបង្រៃអន្តរធាន ។ ទុកជាបេះគិតយ៉ាងពូកែ យូរទៅគង់តែរកមួយគ្មាន បានមកចាយបាត់ធ្វើម្តេចមាន ទំរកឈ្លានពានគង់នៅខ្វះ ។ ចាយតិចអស់ប្រើនបំរើនថយ ប្រើដប់អស់រយនៅកន្លះ កន្លងយូរទៅ ៗ ជាខ្វះ គង់បានប្រទះទុក្ខ-វេទនា ។ បើមានវិជ្ជាជាទ្រព្យថ្លៃ ចាយឥតសំបៃសព្វវេលា ចាយមួយកើតហ្មឺនកើនសព្វគ្រា ទៅទីនានាក៏មិនក្រ ។ ទ្រព្យគឺវិជ្ជាចាយមិនទាល់ ទិញភោជន៍ទិញផលទិញសម្ល ទិញម្ហូបចំណីបាយបបរ ទិញស្រុកនគរក៏សឹងបាន ។ ទិញខោទិញខៀនបំពៀនអាវ ទិញសព្វបារព្រារិញាតិសន្តាន ទិញ

មិត្តសម្លាញទាំងប៉ុន្មាន ទិញបានទាំងបុណ្យទៅបរលោក ។ ទិញទាំងសួគ៌ាជាសុខសាន្ត ទិញទាំងនិព្វានស្ថានសិវមោក្ខ បាយតាំងពីក្នុងឥធលោក ហើយយោគទៅបាយបរលោកទៀត ។ ហេតុនេះគួរឃើញថាអ្នកមាន វិជ្ជាប៉ុន្មានមិនបោលមៀត គួរកែគួរគប់គួរប្របៀត គួរប្រឹងគួរផ្ទៀតយកជាគ្នា ។

អ្នកប្រាជ្ញប្រត្យក្ខ[១]ហាក់ភោជន ជាគ្រឿងសម្រន់ជននានា នៅក្នុងកំឡុងភពភារា ក្នុងគ្រាទុរភិក្ខ[២]នឹកប៉ុនប៉ង ។ ពុំនោះដូចជាវារី[៣]ថ្លា ជាទីប្រាថ្នានៃជនផង ក្នុងគ្រាដែលក្រវារីរង ប្រជាជនផងប៉ងរកទឹក ។ គឺថាប្រជាជនទាំងឡាយស្រេកទឹកឃ្លានបាយជាទុក្ខនឹក សង្រេងសង្រៃក្រៃពន្លឹក ឃ្លានបាយស្រេកទឹកជាទុក្ខផ្សា ។ សន្ធឹកសន្ធៃល្ហិតល្ហៃខ្លាំង ស្ងួតស្ងប់ហទយំគាំងឱរា លុះបានបរិភោគផ្អែតកាលណា សេចក្តីក្តៅផ្សាក៏បាត់ទៅ ។ ភោជនបំបាត់សេចក្តីឃ្លាន ជលសានបំបាត់សេចក្តីក្តៅ ដូចជាអ្នកប្រាជ្ញបើអ្នកខ្លៅ ចូលទៅសេពគប់គង់បានក្សាន្ត ។

---

១ ភាសាសំស្ក្រឹត ប្រែថាអ្នកចេះជាក់ច្បាស់ ។ ២ គ្រាក្របាយ ។ ៣ ទឹក ។

នរោនរៈជនគ្រប់គ្នា មានសុវិជ្ជា[1]ក្នុងសន្ដាន ប្រព្រឹត្ដត្រឹមត្រង់ត្រូវប្រមាណ ប្រមើលមើលប្រាណប្រមាណកាល ។ គង់កែអត្ដភាពដុនដាបទាល់ ឲ្យបានទៅស្គាល់ទីត្រអាល ព្រះបាទបមពៅម្ចាស់ភូបាល គង់លោកឈើឆ្កាលប្រោសប្រណី ។ នឹងបានជាម្លប់សម្រាប់ជ្រក ជនផងទៅមកទាំងប្រុសស្រី មានទុក្ខមានទោសទាល់ក្រអ្វី ក្សេមក្សាន្ដបានក្ដីសុខសម្រាន ។ សម្រួលសម្រាកក្ដីវិបត្ដិ នាំខ្លួនឆ្លងកាត់ទៅនិព្វាន កេរ្ដិ៍ឈ្មោះសាយសុះទៅសព្វស្ថាន ដូចនាំនិទានមកប្រតិស្ឋ ។

អតីតេកាលេកាលកន្លង ភពភាគរម្លងទៅហើយពិត ព្រះពោធិសត្វសាងសីលសិទ្ធ កើតនៅទីជិតពារាណសី ។ នាមសេនកៈរាជបណ្ឌិត បេះអ្វីបេះពិតមានរិទ្ធិល្បី ទើបមកពីរៀនសិល្បថ្មីៗ អំពីបុរីតក្កសិលា ។ ព្រះបាទជនករាជភូមិន្ទ នរិន្ទ្របមក្សត្រខត្តិយា ម្ចាស់ក្រុងពារាណសីរដ្ឋា ទ្រង់ព្រះមេត្ដាប្រោសប្រណី ។ ប្រទានមហិស្សរៈយស ឧត្ដមខ្ពង់ខ្ពស់ជាងប្រុសស្រី ជាទីមហាមាត្យរាជកវី ព្រះបមបក្រីប្រទានស័ក្ដិ ។ ទ្រង់តាំងឲ្យធ្វើអ្នកប្រាជ្ញធំ ក្នុងបុរីរម្យជាឯកអគ្គ អាចប្រៀន

១ បំណោះល្អ (មិនមានទោស) ។

ប្រដៅព្រះបមបក្រ នឹងអស់ពួកអ្នកនិគមផង ។ អស់ប្រជាជនទាំងប្រុសស្រី ទាំងរាស្ត្រមន្ត្រីច្រើនកន្លង ទាំងព្រះភូរិទាបជាតិជាច្បង តែងតែត្រាប់ត្រងស្ដាប់ទេសនា[១] ។ ព្រះពោធិវង្សទ្រង់សន្តោស សំដែងធម៌ប្រោសសព្វវេលា ដល់ពួកមហាជនគ្រប់ ៗ គ្នា ទម្នូងដូចជាព្រះពុទ្ធថ្លៃ ។

គ្រានោះមានតាព្រាហ្មណ៍ចាស់ម្នាក់ ដើរសូមលុយកាក់សព្វ ៗ ថ្ងៃ សន្សែរសន្សំបានច្រើនក្រៃ សំបែមួយពាន់កហាបណៈ ។ ផ្ញើទុកនឹងត្រកូលព្រាហ្មណ៍មួយ ឲ្យចាត់ចែងជួយថែទុកដាក់ ហើយគាត់លាចេញចាកសំណាក់ ស្វែងសូមមាសប្រាក់តទៅទៀត ។ គ្រាក្រោយតាព្រាហ្មណ៍ទៅបាត់ទៅ ត្រកូលព្រាហ្មណ៍នោះវិបត្តិបៀត ខូចខាតសម្បត្តិខាត់បង់សៀត ទើបនាំគ្នាផ្ទៀតយកចាយអស់ ។ លុះដល់តាព្រាហ្មណ៍មកតឹងទារ ប្រគល់ធីតារូបល្អស្រស់ ឲ្យជាភរិយាជួសរបស់ តាព្រាហ្មណ៍សោមនស្សនាំទៅស្រុក ។

ឯនាងព្រាហ្មណីជាស្រីក្មេង ព្រួយចិត្តសង្រេងតែងជាទុក្ខ តូចចិត្តផ្សិតចាស់អាមាស់មុខ បង់កែអផ្សុករកមួយទៀត ។

---
១ ត្រូវអានថាទេស្នា ។

ហើយគិតបណ្ដេញតាព្រាហ្មណ៍ទៅ ឲ្យឆ្ងាយលំនៅស្រណុកឆ្អៀត ទើបចូលទៅជិតស្ថិតប្រៀត លោមទោមដោយស្នៀតឧបាយថា ។

តាអើយៗតាសម្លាញ់ហៅ ខ្លួនខ្ញុំសែនក្ដៅណាស់ណាតា ការប្រើនបំពូកឥតគណនា មិនមានអ្នកណាមួយគ្រាន់ប្រើ ។ ទ្រាំអ្វីកម្លាំងខ្លួនជាស្រី សង្ឃឹមលើប្ដីថាគ្រាន់បើ ស្មានជាមានខ្ញុំគ្រាន់បម្រើ ឥឡូវម្ល៉េះតើធ្វើម្ដេចតា ។ អ្នកណាដាំបាយអ្នកណាស្ល អ្នកណាបបរឲ្យពីសា អ្នកណាប្រតិបត្តិគប់វេលា រងទុក្ខវេទនាណាស់តាអើយ ។ ហេតុនេះបើតាអាណិតហៅ ប្ដូរតាកុំនៅធ្វើព្រងើយ បើតែម្ល៉េះៗស្លាប់ខ្ញុំហើយ ទៅៗតាអើយនៅបានអ្វី ។ តាទៅសូមលុយតាសូមកាក់ តាសូមមាសប្រាក់គោក្របី តាសូមរទេះសេះដំរី សូមខ្ញុំប្រុសស្រីមកគ្រាន់ប្រើ ។

តាព្រាហ្មណ៍ស្លូតបិត្តគំនិតភាន់ ទទួលរូសរាន់ថាអើយអើ មិនអីទេនាងស្រីប្រសើរ គង់បានខ្ញុំប្រើកុំឲ្យថប់ ទើបប្រុងប្រដាប់សម្រាប់ប្រាណ រិត្តប៉ុន្មានទសឹងមានសព្វ សត្តូវខោតាកប្រហុកខ្ចប់ ត្បាល់បុកប្រអប់ប្រិកក្នុងថៃ ។ រៀបស្រេចតាព្រាហ្មណ៍

ស្ដាយលើស្មា តានតឹងឱរាស្មើរក្បិនក្បួយ ឈានជើងចេញទៅនៅអាល័យ អាឡោះស្រីថ្លៃហាទ័យតឹង ។ ខំទៅទាំងទាល់ខានពុំបាន ប្ដីបើខ្លួនប្រាណចាស់ប៉ុណ្ណឹង ស្រីប្រើហើយត្រូវតែខំប្រឹង ចេញដើរទំហឹងទៅចាកស្ថាន ។ ព្រាហ្មណ៍ដើរជជ្រិកមមកសូម តាមធម្មតាសូមបង់តែបាន សូមនេះសូមនោះមិនលោះខាន សូមត្រាតែបានដូចបំណង ។ បានប្រាក់ពីរយកហាប-ណៈ ព្រាហ្មណ៍ប្រមូលដាក់បុះក្នុងថង់ ប្រកញ្ញាត់ក្នុងទៃស្ដាយជម្រង់ សំដៅទៅត្រង់លំនៅស្ថាន ។ មកដល់ទីពាក់កណ្ដាលផ្លូវ ឈប់យកសត្វបំអែតប្រាណ បរិភោគម្នាក់ឯងវែងរំខានក្នុងចិត្តសន្តានមិនក្បាន្តនឹក ។ បរិភោគរួចហើយទើបតាព្រាហ្ម-ណ៍ ក្រោកដើរទឹមទាមទៅរកទឹក មាត់ទៃបំហារមិនបាននឹកពស់ពិសពន្លឹកបួលពេននៅ ។ តាព្រាហ្មណ៍ពុំបានពិចារណាមកដល់ស្រវាចងស្ដាយទៅ ដើរដោយដែនដុងដងព្រៃជ្រៅ នឹកតែស្រីពៅភ្លេចនឹកស្លាប់ ។ កាល្មោះមានរុក្ខទេវត្ដា នៅដើមព្រឹក្សាមេត្តាប្រាប់ ថាបើតាទៅដល់ផ្ទះឆាប់ ប្រពន្ធតាស្លាប់ហោលមិនលែង ។ បើតាមិនទៅឡៀដល់ឆាប់ ស្អែកមុខជាស្លាប់ខ្លួនតា

ឯង តាព្រាហ្មណ៍ឮហើយរឹងចម្លែង កណ្ដោចកណ្ដោងវែងព្រួយ ចិត្ត ។ គិតទៅគិតមករកទំនង មិនដឹងដើមទងតុះគំនិត មិនបាន ឃើញរូបអ្នកប្រាប់ពិត តាព្រាហ្មណ៍រឹងរឹតតែភិតភ័យ ។ ភាន់ ភាំងក្នុងចិត្តគិតបើថា តានតឹងឱភាស្មើរក្បិនក្បុយ តាព្រាហ្មណ៍ ក្បឹកក្បួលអួលហទ័យ រវាសរវៃទៅប្រញាប់ ។ ទៅដល់ទ្វារ ក្រុងពារាណសី ឃើញមនុស្សប្រុសស្រីមីតាន់តាប់ គ្រប់គ្នា សុទ្ធសឹងកាន់ប្រដាប់ ភ្ញីផ្កាមកស្ដាប់ធម៌ទេស្នា ។ ដែលព្រះប-រមពុទ្ធង្កុរ ជាតិជាបណ្ឌូលពង្សពុទ្ធា សេនកៈបណ្ឌិតសិទ្ធិវិទ្យា ប្រដៅប្រដាជនធិករ ។ តាព្រាហ្មណ៍ឃើញហើយទើបគិតថា ឱទីនេះណាគួរត្រេកអរ ជនផងប្រជុំគ្នាឈូឆរ ស្ដាប់សព្ទព្រះធម៌ កំសាន្តចិត្ត ។ បើអញចូលស្ដាប់ប្រហែលស្រួល ក្រែងពានទំ-នួលកែវិបរិត ធម្មតាធម៌លោកអ្នកប្រាជ្ញពិត ជាធម៌ស្រួលចិត្ត វិបរិតបាត់ ។ ហើយព្រាហ្មណ៍ទន្ទបលន្លបទៅ ចូលជ្រៀតឈរ នៅក្នុងបរិសទ្យ ស្ពាយទែទៅស្មាមិនឡូខ្ចាត់ ទើបព្រះមហាសត្វ សាកសួរថា ។ អឺព្រាហ្មណ៍ដែលទើបមកដល់ថ្មី តាស្វែងរកអ្វី មកពីណា តាកើតទុក្ខពីរឿងអ្វីតា បានជាភក្ត្រាតាក្រៀមក្រស់ ។

តាព្រាហ្មណ៍ឮហើយក៏ត្រេកអរ សន្តានស្មោះសរជាសោមនស្ស ទូលតបសេចក្ដីសព្វគ្រប់អស់ ទើបមហាបុរសសួរទៀតថា ។ កាលដែលព្រាហ្មណ៍ឯងបរិភោគស្រេច ព្រាហ្មណ៍ឯងបរទ្រេប ទៅទីណា មានដើរបោលទៃទេឬតា ព្រាហ្មណ៍តបវិញថាព្រះបាទម្ចាស់ ។ ខ្ញុំបាទទុកទៃនៅទីនោះ ហើយខ្ញុំបាទចុះទៅក្នុងស្រះ ទទួលទានទឹកដោយរហ័ស រួចរាល់ស្រទ្បះឡើងមកហោង ។ លុះខ្ញុំមកដល់ទៃកាលណា ទើបខ្ញុំស្រវាក្រ-ប្លូបបង មាត់ទៃហើយស្ដាយមិនផ្សរផ្សង ត្រេបតាមគន្លងដងមគ៌ា ។ ស្រាប់តែបានឮពាក្យដូច្នោះ នៅក្បែរផ្លូវនោះក្នុងអរញ្ញា សូមទានព្រះគុណទ្រង់មេត្តា ព្យាករប្រស្នានេះឲ្យទាន ។ ព្រះមហាបុរសប្រាជ្ញប្រត្យក្ខ លោកបានជ្រាបជាក់ដោយញេយ្យ-ញាណ ប្រាប់ថាក្នុងទៃតាឯងមាន ពស់វែកគង្គានចូលពេននៅ ។ ហេតុនេះបើតាឯងប្រញាប់ ទៅដល់ផ្ទះឆាប់គ្រាឥឡូវ ប្រពន្ធតារត់ទទួលផ្លូវ យកទៃស្រាយទៅពស់ចឹកស្លាប់ ។ បើតាបង្អង់ពុំទាន់ទៅ សំចតឈប់នៅពុំប្រញាប់ ពេលល្ងាចតាស្រាយមាត់ទៃឆាប់ ពស់វែកចឹកស្លាប់ខ្លួនតាឯង ។ ទើប

ពោធិសត្វបាត់ឲ្យយក ទេវតាព្រាហ្មណ៍មកពីកន្លែង ដាក់ក្នុងទីវាលស្រែទ្បះបែង ឲ្យយកឈើវែងផ្ដិសស្រាយគោះ ។ មនុស្សផងទទួលព្រះបង្គាប់ ផ្ដិសស្រាយប្រញាប់បានឃើញពស់ លូនចេញពីទេវតាព្រាហ្មណ៍នោះ ឃើញពិតដូច្នោះខ្លាចស្ញប់ស្ញែង ។ ទើបអាលម្ពាយហ្មពស់ម្នាក់ ចាប់អួសកន្ត្រាក់ពីកន្លែង កន្លងទីឆ្ងាយដាច់សង្វែង អាលម្ពាយលែងពស់នោះទៅ ។ ពួកជនទាំងឡាយទាំងប្រុសស្រី ទាំងរាស្ត្រមន្ត្រីដែលស្ថិតនៅ ក្នុងទីស្រុកក្រុងឬស្រុកក្រៅ មកប្រជុំនៅនាទីនោះ ។ បានឃើញពិតហើយក៏ស្ញប់ស្ញែង គួរកោតគួរក្រែងរងងព្ពោះ ត្រង់ព្រះប្រាជ្ញាបារមីនោះ ទាយត្រូវបំពោះដូចព្រះពុទ្ធ ។ ទះដៃស្រែកឲ្យសាធុការ សម្លេងខ្ទរខ្ទារដូចកល់ទ្រុត កល់ទ្រោមផែនដីញ័ររន្ធត់ ញ័រទាំងសមុទ្របពិតផង ។ ភ្លៀងធ្លាក់កើតជារតនាករ គួរឲ្យត្រេកអរប្រើនកន្លង បូជាពោធិសត្វប្បះប្បង អស់ពួកជនផងត្រេកអរក្រៃ ។ ឯព្រាហ្មណ៍ក៏អត់ទ្រាំពុំបាន ទ្រព្យទាំងប៉ុន្មានមិនសំចៃ ចាត់បែងបូជាមហាសត្វថ្លៃ មិនមានអាល័យអាឡោះឡើយ ។ ព្រះពោធិសត្វទ្រង់មេត្តា ទើបមានវាចា

យាត់ថាណ្ហើយ ខ្ញុំមិនយកទេតាព្រាហ្មណ៍អើយ ខ្ញុំអរគុណហើយណ្ហើយកុំតា ។ ស្រេចហើយប្រទានប្រាក់ទៅព្រាហ្មណ៍ បីរយភ្លាមៗដោយករុណា បន្ថែមឡើតគំរប់ជា មួយពាន់ផងគ្នានឹងប្រាក់គាត់ ។ ហើយព្រះអង្គសួរថាអើតា តាបរយាត្រាត្រេបខ្វាត់ភ្លាត់ បោលស្រុកបោលទេសទៅរង្គាត់ ស្វែងសូមព្រោះខ្សត់ឬគេប្រើ ។ ព្រាហ្មណ៍តបថាឱព្រះគុណធ្ងន់ រឿងនេះប្រពន្ធខ្ញុំទេតើ គេឃ្ញុញថាគ្មានខ្ញុំបម្រើ ហើយគេបាត់ប្រើឲ្យស្វះស្វែង ។ ព្រះអង្គសួរថាបុះភរិយា នោះចាស់ជរាដូចតាឯង ឬមួយនៅក្មេងល្អបិព្វែង បានជាឲ្យស្វែងមិនប្រណី ។ ព្រាហ្មណ៍តបថាក្មេងទេព្រះគុណ ទើបបានពេលមុននេះថ្មីៗ សំឡូតសំឡាញ់ពេញបេតី ល្អល្អះឥតបីស្រីណាដល់ ។ ព្រះអង្គជ្រាបច្បាស់ដោយប្រាជ្ញា ទើបប្រាប់ព្រាហ្មណ៍ថាតាកុំធ្ងល់ នេះឯងជាកិច្ចឧបាយកល់ តាឥតយោបល់បាញ់កល់ស្រី ។ ប្រពន្ធតាឯងមានទៀតហើយ នែតាព្រាហ្មណ៍អើយគិតវាថ្វី ណ្ហើយបុះបើចង់ច្បាស់ៈសបក្តី តាទៅរាត្រីនេះឡូដល់ ។ យកប្រាក់លាក់ទុកក្រៅលំនៅ សឹមតាបួលទៅសង្កេតកល់ គង់បានដឹងពិត

ផតពីផល់ ដេញពុតឡ្យទាល់កល់ប៉ុណ្ណឹង ។ តាព្រាហ្មណ៍ទទួលតាមបង្គាប់ រិះគិតសព្វៗគួរតែខឹង ក្រាបបង្គំលាហើយខំប្រឹង ដើរអស់ទំហឹងឆ្ពោះសំដៅ ។ ទៅស្រុកមិនមានឈប់សម្រាក មិនគិតលម្បាកព្រោះក្ដីក្ដៅ យកប្រាក់ទៅលាក់ទុកខាងក្រៅ ហើយចូលសំដៅទៅដោយស្ងាត់ ។ ដល់ហើយឃើញអុបភ្លើងភ្លឺៗ តែមិនទាន់ឮសួរស័ព្ទមាត់ ព្រោះនាងកំពុងតែសម្ងាត់ តាព្រាហ្មណ៍លើកហត្ថៈគោះទ្វារហៅ ។ ព្រាហ្មណីឮហើយក៏លត់ភ្លើង ក្រោកភ្លែតភ្លាមឡើងចេញមកក្រៅ ដឹកដៃប្ដីថ្មីឲ្យអែបនៅ នាំព្រាហ្មណ៍ចូលទៅដល់ក្នុងផ្ទះ ។ បពោសអង្អែលសព្វសារពាង្គ ជុសខាត់ជូតលាងដោយការល្អះ ហើយសួរថាតាបានអ្វីខ្លះ តាព្រាហ្មណ៍ថាខ្វះអ្វីភាណើយ ។ តាបានមួយពាន់កហាបណៈ ឥឡូវតាលាក់ទុកទៅហើយ លាក់ទុកត្រង់នោះណានាង៉ើយ កុំមាត់កឡើយក្រែងគេដឹង ។ ព្រាហ្មណីឮស្រែបគេចចេញទៅ ប្រាប់ប្រុសដែលនៅជិតនោះហ្នឹង ប្រុសនោះរកឃើញឆក់យករឹង ព្រឹកឡើងព្រាហ្មណ៍ដឹងជាប្រាក់បាត់ ។ ទោមនស្សទាស់ចិត្តឥតបើថា ហើយចេញយាត្រាត្រែបបរកាត់

សំដៅលំនៅពោធិសត្វ ព្រាហ្មណ៍ក្រាបប្រតិបត្តិសព្វប្រការ ។ ព្រះអង្គជ្រាបច្បាស់ដោយញេយ្យញាណ ទើបទ្រង់ប្រទានស្បៀងអាហារ ភោជនបំណាំគ្រប់បរិក្ខារ ល្មមព្រាហ្មណ៍ចាត់ការពីថ្ងៃបាន ។ ហើយប្រាប់ថាតាព្រាហ្មណ៍ឯងទៅ កាន់ទីលំនៅគេហស្ថាន ឲ្យនាងព្រាហ្មណីហៅសន្តាន ដែលវារាប់អានតាមចិត្តស្ម័គ្រ ។ បំនួនជប់ប្អូនទាំងអស់គ្នា ទាំងញាតិខាងវាញាតិខាងអ្នក មកជុំជប់លៀងដោយរាក់ទាក់ ផ្ញើកល់ជួបហាក់គ្មានហេតុអ្វី ។ មួយថ្ងៃបន្ថយចេញពីរនាក់ តាមដោយចិត្តស្ម័គ្រនាងព្រាហ្មណី ត្រូវផ្ញើជូប្បេះជាប្រក្រតី ប្រាំពីររាត្រីជាកំណត់ ។ បន្ថយទុកសល់តែពីរនាក់ ពិនិត្យឲ្យជាក់ស្តែងប្រាកដ មើលតែព្រាហ្មណីដែលវាឃាត់ ភ្ញៀវណាកំណត់ប្រាំពីរថ្ងៃ ។ ប្ចូរតាប្រាប់ខ្ញុំកុំបង្អង់ ខ្ញុំហានចោទត្រង់ពុំសង្ស័យ ចាប់វាឲ្យបានយកថ្វីដៃ ឲ្យចោរបង្រៀវារអា ។ តាព្រាហ្មណ៍ធ្វើគ្រប់តាមបង្គាប់ ស្រេចទើបត្រឡប់ចរយាត្រា ដំរាបរឿងរ៉ាវស្រេចកាលណា ទើបមានវាចាប្រើបំរើ ។ ឲ្យហៅព្រាហ្មណ៍ចោរចូលមកដល់ ព្រះអង្គទតស្គាល់សួរថាអើ ទ្រព្យតា

ព្រាហ្មណ៍នេះមួយពាន់តើ ឯងយកទៅធ្វើអ្វីទៅហើយ ។ ព្រាហ្មណ៍ចោរជជែកប្រកែកថា សូមទានមេត្តាព្រះគុណើយ ខ្ញុំបាទមិនបានយកសោះឡើយ ម្ចាស់ថ្លៃខ្ញុំមើលទេព្រះអង្គ ។ ព្រះពោធិសត្វឆ្លើយកាត់ថា នែចោរមោហាឋាឡត្រង់ គេហៅនថាហើយមិនមែនល្ងង់ នេះពេញជាពង្សអង្គអ្នកប្រាជ្ញ ។ ហ្នឹងហើយឈ្មោះសេនកៈបណ្ឌិត ល្បីល្បាញរងរិទ្ធិគេកោតខ្លាចមិនស្គាល់ទេឬចោរកំណាច បើឯងស្គាល់ប្រាជ្ញកុំប្រកែក ។ ព្រាហ្មណ៍ចោរភិតភ័យតក្កមា ក្នុងចិត្តគិតថាឱបំឡែក ថានេះដូចជាឃើញនឹងភ្នែក មិនហ៊ានប្រកែកតទៅទៀត ។ ជំរាបរឿងរ៉ាវទៅតាមត្រង់ ហើយទើបព្រះអង្គទ្រង់ផ្លាស់ធ្លៀត ជណ្តឹងបញ្ជាក់ថែម ៗ ទៀត ចោរខូចចោលម្សៀតមិនហ៊ានលាក់ ។ ក្រសួងរាជការរដ្ឋបាល ចាំស្តាប់នឹងអាលទាញទៅដាក់ ធ្វើទោសតាមដោយពិនិត្យដាក់ យកចោរអប្បលក្ខណ៍ដាក់អាជ្ញា ។ ព្រះពោធិសត្វទ្រង់ព្រះទាន មាសប្រាក់ធនធានដោយមេត្តា ដល់រូបតាព្រាហ្មណ៍អនាថា ដែលពឹងបេស្កាព្រះបារមី ។

រឿងរ៉ាវដូចថ្លែងសំដែងមក ខ្ញុំបានស្រង់យកពីបាឡី មក ដាក់បញ្ជាក់ខសេចក្ដី ឲ្យជនប្រុសស្រីស្ដាប់បានងាយ ។ សូម លោកអ្នកស្ដាប់ពិចារណា តាមដោយប្រាជ្ញដ៏ទូលាយ ឲ្យ ឃើញហេតុផលទៅវែងឆ្ងាយ ដូចបានអធិប្បាយជាទំនង ។ ដំណើរសេចក្ដីក្នុងរឿងនេះ យើងត្រូវត្រិះរិះតាមគន្លង ព្រះពោធិ-សត្វពីដើមទង ដោយន័យទំនងដ៏វែងឆ្ងាយ ។

ហៃសាធុជនទាំងអស់គ្នា បំណេះវិជ្ជាទាំងសម្ដាយ មាន គុណវិសេសធំទូលាយ គួរយើងរៀបស្ដាយកុំខ្លាចធ្ងន់ ។ មិន លម្បាកទុកស្រណុកលោក ជាជាងមាសប្រាក់សព្វទ្រព្យធន មិនខ្លាចចោរលួចឬចោរប្លន់ ទៅគង់ជាប់នឹងខ្លួនគ្រាន់ជាស្បៀង ។ ឥតកណ្ដៀរកោរកណ្ដុរកាត់ ចាយណាស់មិនបាត់មិនមានល្អៀង ប្រើប្រើនកើតប្រើនបំរើនទៀង ពីបច្ចុប្បន្នរៀងទៅបរលោក ។ មានសុវិជ្ជាគង់មានទ្រព្យ អ្នកផងមិនស្អប់មិត្តមូលមក មានមិត្ត ហើយបុណ្យតែងរត់រក ស្លាប់ទៅបរលោកយោគស្ថានសួគ៌ ។

វិជ្ជាមានគុណដូចបានថ្លែង សំដែងមកនេះក៏សមគួរ សង្ខេបសេចក្ដីត្រឹមស្ថានសួគ៌ បប់តាមសមគួរអម្បាល្មេះ ។

សូមលោកអ្នកប្រាជ្ញខមាទោស សូមទានសន្ដោសកុំជៀលតិះ ខ្ញុំនឹកឃើញរឿងរ៉ាវដូច្នេះ ដោយត្រិះរិះផ្សំនឹងបាឡី ។ គម្ពីរនានាជាមគធៈ ឃើញប្រាកដជាក់ដូចសេចក្ដី ដែលបានថ្លែងមកដោយខ្លី ៗ ប្រយោជន៍ដើម្បីអ្នកល្ងង់ខ្លៅ ។

វិជ្ជាគុណាកថាចប់ ក្នុងពេលព្រលប់យប់ថ្ងៃសៅរ៍ បួននឹងដប់រោចមិគសិរនៅ ហេមន្ដរដូវឆ្នាំរកា ។ បញ្ចូលកជាប់ទាក់ឆ្នាំបារាំង ចាប់ពីកតាំងគ្រិស្ដសាស្នា មួយពាន់ ៩ រយសាមបីជា កំណត់វេលាចប់ឯងហោង ។

## រឿងនំនៀមនំលាប់ខ្មែរ

វិធីរក្សាគតិ

*ព្រះមហាពិទូរក្រសេម រៀបរៀង*

ខ្មែរយើងជាប់និស្ស័យជឿវេទ មន្ដ អាគម តាមលទ្ធិសៃយសាស្ដ្រមកជាអង្វែងឆ្នាំហើយ ទោះបីវេលានេះបានឈ្មោះថាជាអ្នកកាន់ព្រះពុទ្ធសាសនាហើយ ក៏នៅមិនទាន់ទម្លាក់បោលលទ្ធិចាស់នោះទាំងអស់ទៅបាន នៅមានដោយមកខ្លះ យកមកប្រព្រឹត្តលាយឡំនឹងព្រះពុទ្ធសាសនាក៏មានជាច្រើន ៗ សូម្បីមានផ្លូវដទៃល្អមនឹងបៀសវាងបាន មិនបាច់ធ្វើតាមលទ្ធិនោះក៏មិន

ហ៊ានបៀសវាងឬបោះបង់ចោលតែម្តង ដោយខ្លាចនេះខ្លាចនោះ ដែលជារបស់ខ្លួនមើលមិនឃើញ ដូចយ៉ាងវិធីរក្សាគភ៌ ឬហៅថាផ្តុងគភ៌(១) អ្នកខ្លះនោះជាអ្នកដែលបានបន់សុំកូនក្តី អ្នកដែលមិនបានបន់សុំក្តី កាលណាដឹងថាមានគភ៌ហើយ រមែងខ្វល់ខ្វាយរកគ្រូអាចារ្យ ឬលោកសង្ឃឯណានីមួយដែលចេះមន្តអា-គម ឲ្យធ្វើជារបស់សម្រាប់ការពារអន្តរាយ ដែលហៅថា កថា កូនសង្កត់ ខ្សែចង្កេះ ឯណានីមួយមកពាក់នៅកណ្ឋឬចងនៅចង្កេះ ដើម្បីបង្ការខ្មោចបិសាច ព្រាយ ដូចយ៉ាងដែលហៅថាព្រាយព្រះខ្លាជាដើម ដោយជឿថា របស់អំបាលនោះមានអានុ-ភាពអាចនឹងកំចាត់ភ័យ ឧបទ្រព អន្តរាយ និងអពមង្គលទាំងពួងបាន ហើយនឹងអាចលើកឲ្យមានរាសី ជោគជ័យ សិរីសួស្តី និងមង្គលទាំងពួងឡើងបាន ។

## លក្ខណៈគាថា

ឯនឹងធ្វើជា កថា ជាកូនសង្កត់ ឬខ្សែចង្កេះ នោះទៅតាមវិស័យរបស់អាចារ្យអ្នកធ្វើ អាចារ្យណាចេះធ្វើអ្វី ក៏ប្រាប់

---

១ បូរាណមាននិយាយថា ផ្តុងគភ៌ ឬថ្នាំផ្តុងគភ៌ ។ ពាក្យថាផ្តុងនេះចេញទៅជាប្រផុង ដែលយើងចំណាំតែនិយាយថា ប្រផុងប្រផា បានដឹងការជួយគ្រោមគ្រែងរក្សា ។

ឲ្យសាមីខ្លួនរករបស់នោះមកក៏មាន ទៅតាមធនធានរបស់អ្នកសាមីខ្លួនក៏មាន ទៅតាមសេចក្ដីត្រូវការបំពោះវត្ថុក៏មាន ។

កថានោះគេធ្វើដោយផែនមាស-ប្រាក់-ទង្ហា-ស្ពាន់ ឬសំណាឯណានីមួយក៏បាន គឺគេផែរបស់នោះជាផែនស្ដើងហើយកាត់ជា ៤ ជ្រុងទ្រវែង ទំហំបណ្ដោយប្រមាណ ៤ សង់ទីម៉ែត្រ ទទឹងប្រមាណ ៣ សង់ទីម៉ែត្រ យកទៅឲ្យអាចារ្យ ៗ ឲ្យរៀបយកបាយសី ស្លាធម៌មកតាំង អុចទៀនធូបបូជាគ្រូតាមទំនៀមហើយ ទើបយកផែនមាសឬផែនប្រាក់ នោះមកប្រសិទ្ធិសូត្រសែពដោយ មន្ត អាគម នឹងបារបញ្ចុះយ័ន្ត បញ្ចុះមន្ត អាគមនៅបន្លោះយ័ន្ត ជាតួអក្សរភាយមួយ ៗ ហើយមូរឲ្យមូលឲ្យនៅមានប្រហោងក្នុង សណ្ឋានដូចបារ ឬបំពង់មូល តែមូរឲ្យតួអក្សរនៅខាងក្នុង ហើយយកខ្សែមាស ឬអំបោះដែលវេញស្លាតមកដោត បង់ក្រវាត់នៅចង្កេះ ដូចយ៉ាងក្រវាត់ខ្សែក្រវាត់ក៏បាន ចងប្រសប់មុខហើយពាក់នៅកណ្ដ ដូចយ៉ាងពាក់ខ្សែកណ្ដក៏បាន ។ បើធ្វើយ៉ាងតូចហោចបុះមក មិនបាច់មានបាយ

សី នឹងស្លាធម៌ទេ គ្រាន់តែអុចទៀនធូបហើយតាំងប្រសិទ្ធិបញ្ចុះយ័ន្ត នឹងមន្តអាគមតែម្តង ។ កឋានេះទម្លាប់ប្រើតែស្រី ៗ ប្រុសមិនសូវមានប្រើ ។

## លក្ខណៈកូនសង្កត់

ឯកូនសង្កត់នោះគេធ្វើដោយសំណក៏មាន ធ្វើដោយឈើមានខ្លឹមអំពិល ខ្លឹមបម្បុីជាដើមក៏មាន តែច្រើនធ្វើដោយសំណោ មានលក្ខណៈនឹងសណ្ឋានដូចអង្កាំ តែធំប្រមាណប៉ុនម្រាមដៃ ហើយយកខ្សែអំបោះមកដោតដូចយ៉ាងកឋា ជូនទៅអាចារ្យ ៗ ក៏ឲ្យរៀបយកបាយសី ស្លាធម៌ នឹងទៀនធូបមកតាំងនៅទីមួយដ៏សមគួរហើយយកខ្សែកូនសង្កត់នោះ មកឆ្វាយដាក់លើជើងពានដាក់ពីខាងមុខ ហើយអុចទៀនធូបតាំងពិធីប្រសិទ្ធិ គឺសូត្រសែពឧមអាមបញ្ចូលមន្តអាគមនៅកូនសង្កត់នឹងខ្សែនោះតែម្តងមិនបានបារបញ្ចុះដូចជាកឋា រួចហើយយកមកក្រវាត់នៅបង្កេះអ្នកសាមីខ្លួន ។

កូនសង្កត់មួយយ៉ាងទៀត គេធ្វើដោយសំពត់ស គឺគេយកសំពត់សមកសរសេរបញ្ចុះយ័ន្តនឹងមន្តអាគមដូចយ៉ាងកឋា

ជូនកាលមានទាំងថ្នាំដាក់ផង ហើយម្សូរខ្ចប់ឲ្យមូលទុកប្រហោងក្នុងដូចយ៉ាងកូនសង្កត់សំណ ដេរក្លាស់ឲ្យណែន កុំឲ្យររុស ហើយដោតខ្សែក្រវាត់ដូចគ្នា ។

ប្រយោជន៍ដែលប្រើកូនសង្កត់តាមសេចក្ដីនិយមដែលគេធ្លាប់ប្រើរៀងមកថា ដើម្បីការពារ ខ្មោច អាបព្រាយ ធ្មប់អំពើ និងគ្រាប់កាំភ្លើង ហើយច្រើនប្រើតែប្រុស ៗ ស្រីមិនសូវមានប្រើទេ ។

## លក្ខណៈខ្សែចង្កេះ

ឯខ្សែចង្កេះក្នុងទីនេះ បំពោះយកតែខ្សែអំបោះស ១ យ៉ាង ខ្សែដទៃប្រើមិនបាន វេលាដែលនឹងវេញ អាចារ្យចំណាំតែកំណត់ចំនួនសរសៃអំបោះឲ្យ វេញ គឺឲ្យយកក្នុង ១ ធ្លុង ៧ សរសៃឬ ៩ សរសៃ ត្រកួញឲ្យខ្លាញ់ហើយវេញបញ្ចូលគ្នាទៅ ។ ស្រេចហើយយកទៅជូនអាចារ្យ ៗ តាំងពិធីប្រសិទ្ធិសូត្រសែពមន្តអាគមដាក់នៅខ្សែនោះ ដូចគ្នានឹងកូនសង្កត់ តែជូនកាលមានចងថ្នាំនៅខ្សែនោះផង ហើយឲ្យក្រវាត់ដូចពោលហើយ ។

ប្រយោជន៍ដែលប្រើខ្សែបង្កេះ ក៏ដូចគ្នានឹងប្រើកឋា ហើយច្រើនប្រើតែស្រី ៗ ប្រុសមិនសូវប្រើ ។ ទំនៀមអំពាលនេះក៏រួមនៅក្នុងលទ្ធិសៃយសាស្ត្រនោះឯង ។

ក្នុងទីបំផុតនេះ សុំឲ្យជ្រាបថា ការបង្កកឋាក្តី ក្អូនសង្កត់ក្តី ឬខ្សែបង្កេះក្តី មិនមែនសុទ្ធតែបងទាំងអស់គ្នាទេ ច្រើនបងតែអ្នកបន់សុំកូន នឹងអ្នកដែលអារិសកូន ៗ មិនសូវគង់ នឹងអ្នកដែលមានគភ៌ជាដំបូង អ្នកក្រៅអំពីនេះ នឹងអ្នកដែលជឿស៊ប់ក្នុងព្រះពុទ្ធសាសនា គេមិនពឹងអានុភាពនៃរបស់អំពាលនេះក៏មានជាច្រើន វេលាមានគភ៌ឡើង គេច្រើនប្រើផឹកថ្នាំ ត្រ-ជាក់ថ្នាំក្រអូប ដែលគេធ្វើអំពីកេសរផ្កាឈូកនឹងផ្កាម្លិះជាដើម ប្រយោជន៍ឲ្យសម្រាលកូនងាយក៏មានជាច្រើន ។

## រឿងព្រេងខ្មែរ

### ១- រឿងសត្វដង្កូវនឹងសត្វក្អែកដោះប្រស្នា

មាននិទាន ១ ថាសត្វដង្កូវកំពុងស៊ីស្លឹកឈើ មានសត្វក្អែកហើររកចំណី ទៅប្រទះនឹងសត្វដង្កូវ សត្វក្អែកថាពេលនេះមានលាភបានសត្វដង្កូវស៊ី ក៏ហើរទៅទំជិតនឹងសត្វដង្កូវ សត្វ

ដង្កូវក្រឡេកឃើញសត្វក្អែកក៏គិតថាខ្លួនអាក្អែកនេះបិត្តឃោរឃៅនឹងចឹកស៊ីអញឥឡូវហើយ ដង្កូវក៏បានសួរទៅសត្វក្អែកថា មករកអ្វី ក្អែកឆ្លើយប្រាប់ទៅដង្កូវវិញថា អញមករកស៊ីដង្កូវឯង ថាក្អែកឯងបើស៊ីអញបាន លុះតែក្អែកឯងរកប្រស្នាអញឃើញ ទើបស៊ីអញបាន បើរកប្រស្នាអញមិនឃើញទេ ស៊ីអញមិនបានទេ ក្អែកថាដង្កូវប្រស្នាយ៉ាងដូចម្ដេច ក៏ប្រស្នាមកចុះនឹងរកឲ្យឃើញ នោះដង្កូវក៏បានប្រស្នាប្រាប់ទៅក្អែកដូចមានខាងក្រោមនេះ

១- ដូចម្ដេចដែលគេហៅថាផ្អែមជាងគេនោះ ។

២- ដូចម្ដេចដែលគេហៅថាចត់ជាងគេបំផុតនោះ ។

៣- ដូចម្ដេចដែលគេហៅថាស្អុយជាងគេបំផុតនោះ ។

៤- ដូចម្ដេចដែលគេហៅថាក្រអូបជាងគេបំផុតនោះ ។

កាលណាបើសត្វក្អែកបានឮសត្វដង្កូវប្រស្នាទាំង ៤ បទនេះហើយ នោះក្អែកមានសេចក្ដីត្រេកអរជាទីបំផុត ក៏ស្រែកហៅកញ្ជ្រៀវលេងថា ប្រស្នាសត្វដង្កូវទាំង ៤ បទនេះ អញនឹងរកជារកឃើញឥឡូវហើយ នឹងបានសត្វដង្កូវស៊ីឥឡូវនេះមិនខាននោះ ក្អែកដោះប្រស្នាដូចមានខាងក្រោមនេះ :

១ —ក្អែកដោះប្រស្នាដែលគេហៅថាផ្អែមនោះ គឺមានស្ករ នឹងទឹកឃ្មុំដែលផ្អែមជាងផ្អែមទាំងពួង ។

២ —ដែលគេហៅថាចត់ជូរនោះ គឺមានម្ទេសក្រៀមផ្ការ-អំពិល ម្ទេសខ្លាត-ម្ទេសក្រហាំងនឹងទឹកខ្មេះ ។

៣ —ដែលស្អុយជាងគេនោះ គឺប្រហុក គំរង់ខ្មោចសត្វ ទាំងពួង ។

៤ —ដែលក្រអូបជាងគេនោះ គឺផ្ការំដួល-ម្លិះ នឹងទឹកអប់ ។

នោះក្អែកក៏បានដោះប្រស្នាដង្កូវទាំង ៤ បទនេះប្រាប់ទៅ ដង្កូវវិញ ហើយដង្កូវឆ្លើយថា ក្អែកដោះប្រស្នានេះមិនត្រូវទេ នោះ ក្អែកក៏ដាក់មុខស្រងូតស្រងាត់និយាយទៅនឹងដង្កូវវិញថា បើ ដង្កូវថាខុសនេះសុំឲ្យដង្កូវប្រាប់ប្រស្នានេះមកក្អែកឲ្យបានដឹងផង ដង្កូវប្រាប់ទៅក្អែកវិញថា ប្រាប់បានតែឲ្យក្អែកកុំស៊ីដង្កូវទើបបាន ប្រាប់បាន ក្អែកថាទេឲ្យតែប្រាប់ចុះមិនស៊ីដង្កូវទេ បានចុះសន្យា គ្នាព្រមព្រៀងយ៉ាងហ្នឹងហើយ ក៏ដង្កូវបានប្រាប់ប្រស្នាទៅក្អែក ដូចមានខាងក្រោមនេះ ៖

១—ដែលហៅថាផ្អែម គឺមិនមែនផ្អែមស្ករទឹកឃ្មុំនោះទេ ដែលហៅថាផ្អែមនោះ គឺផ្អែមពាក្យសំដីដែលនិយាយទៅមករកគ្នាដោយពាក្យផ្អែមពីរោះស្មោះត្រង់រកគ្នា នេះហើយហៅផ្អែមជាទីបំផុត ។

២—ដែលជូរចត់នោះគឺមិនមែនជូរចត់អំពិល-សន្តាន់ក្រូចធ្នារ-ទឹកខ្មេះនេះទេ គឺដែលនិយាយកាត់គ្នាទៅវិញទៅមកពាក្យផ្ទុសវាទឃោរឃៅទៅរកគ្នាឥតគួរឥតសម នេះហើយហៅជូរចត់លើសជូរចត់ទាំងពួង ។

៣—ដែលស្អុយនេះ គឺមិនមែនស្អុយប្រហុក-អាចម៍-គំរង់នោះទេ ស្អុយកេរ្តិ៍ស្អុយឈ្មោះ ដែលធ្វើប្រព្រឹត្តអាក្រក់ក្នុងលោកនេះហើយហៅស្អុយប្រាសខ្យល់ ។

៤—ដែលគេហៅក្រអូបនោះ គឺមិនមែនក្រអូបផ្កា-ទឹកអប់នោះទេ គឺក្រអូបកេរ្តិ៍ឈ្មោះដែលប្រតិបត្តិល្អ នេះហើយហៅថាក្រអូប ។

## ២- រឿងចាបពួកប្រឈ្លោះនឹងចាបក្បាលទំពែក

អំពីចាបពួកនឹងចាបក្បាលទំពែកតែងដើររកស៊ីដោយខ្លួន ដោយពួកជារាល់ថ្ងៃ ឯចំណែកខាងចាបពួកមានមេបាប្រដៅថាបើរកស៊ីកុំឲ្យដែកប្រឈ្លោះឲ្យឮមាត់ជាគឹកកង ឲ្យបម្រុងប្រយ័ត្នខ្លួន បើព្រានភិភាយលប់ត្រូវឲ្យបបួលគ្នាខំហោះទួលលប់ឲ្យរបើកដើម្បីនឹងឲ្យបានរស់រូបជីវិត នោះពួកចាបពួកក៏តាមមេបាប្រដៅតែងដើររកស៊ីទៅមិនសូវបោកមាត់ឲ្យឮជាគឹកកង ជួនកាលបើមានព្រានភិយលប់ត្រូវក៏បបួលគ្នាខំហើរទួលលប់ព្រានតែងនឹងរស់រូបជីវិតតែរៀង ៗ មក មានកាល ១ ថ្ងៃពួកចាបក្បាលទំពែកនឹងពួកចាបពួកហើរបេញទៅរកស៊ី ជួបប្រទះហ្វូងគ្នានៅដើមត្រែង ១ គុម្ព ឯចាបក្បាលទំពែកទំនៅជាខាងក្រោម ឯពួកចាបពួកទំនៅពីខាងលើ ក៏បាក់មែកត្រែងពីលើមកត្រូវក្បាលចាបក្បាលទំពែក ៗ និយាយប្រកាន់ទៅចាបពួកថា ហេតុអីក៏កាប់មែកត្រែងទំលាក់មកឲ្យត្រូវក្បាលពួកចាបក្បាលទំពែកនោះ ចាបពួកបានប្រាប់ទៅចាបក្បាលទំពែកវិញថា មិនបានកាប់មែកត្រែងឲ្យបាក់ត្រូវចាបក្បាលទំពែកឯងទេ គឺមែក

ត្រែងនេះវាបាក់ឯងធ្លាក់មកទេ នោះពួកចាបក្បាលទំពែកជាពួកឥតកាន់ដំបូនមាន ក៏មិនពិចារណាឲ្យឃើញខុសត្រូវក៏បបួលគ្នាបង្ករហេតុ ទៅកើតជាឈ្លោះនឹងពួកចាបពួកឮមាត់ជាគឹកកងឡើង នោះពួកព្រានបានឮមាត់ចាបនៅទីគុម្ពត្រែងនោះប្រើនក់យកលប់ទៅវាយត្រូវទាំងអស់គ្នា កាលចាបទាំងពីរពួកនេះដែលបានត្រូវលប់ហើយក៏នៅជាប់ប្រឈ្លោះគ្នា ចាបពួកពោលទៅរកចាបក្បាលទំពែកថា ឯងគ្រាន់បើហេតុម្ដេចក៏មិនគិតបម្រះឲ្យរួចពីលប់ទៅ ឯចាបក្បាលទំពែកពោលមករកចាបពួកវិញថា បើពួកឯងគ្រាន់បើហេតុដូចម្ដេចក៏មិនបំរះឲ្យរួចពីលប់នេះទៅ គឺមានពាក្យបញ្ចូនឲ្យគ្នាទៅវិញទៅមក មិនគិតបំរះឲ្យរួចជីវិតស្រាប់តែព្រានក្រសោបឡើងចាប់បានចាបនេះទាំងអស់ ក៏ពិឃាតក្ស័យអស់ទៅ នេះហើយចាបពួកជាពួកចាបល្អ តែខកខ្លួនមករកស៊ីជួបបួល នឹងហ្វូងចាបក្បាលទំពែកជាពួកចាបប្រតិបត្តិអាក្រក់ក៏នាំឲ្យមានរឿងប្រឈ្លោះ លុះព្រានវាយលប់ត្រូវស្លាប់ទាំងអស់គ្នាជាមរណាបោង ។

### ៣. រឿងបុរសចាក់ស្នុគ្រ

កាលដើមមានបុរសម្នាក់ចេះចាក់ស្នុគ្រ បុរសនោះចង់បាន ខ្ញុំប្រើក៏ឡើងទៅលើចុងត្នោត ហើយបុរសនោះគិតតែម្នាក់ឯងថា បើអញចាក់ស្នុគ្របាន ១ លក់បាន ១០ សេន.បើចាក់ស្នុគ្របាន ១០០០ នឹងលក់ទៅបាន ១០០ រៀល រួចអញលោះមនុស្សប្រើ អញប្រើមិនបានដូចចិត្តអញពាក់វាយ បុរសនោះមិនថាតែមាត់ លើកដៃ.ជើងលើចុងត្នោត ហើយបុរសនោះធ្លាក់ពីលើចុងត្នោត ដៃប្រវាចាប់ចុងស្លឹកត្នោតជាប់ដូចជាគេព្យួរ គ្រានោះទ្រមាក់ដំរី ជិះដំរីម្នាក់ឯងមកជិតបុរសនោះ បុរសដែលតោងស្លឹកត្នោតស្រែក ប្រាប់ថា បើលោកណាជួយដាក់ខ្ញុំពីចុងត្នោតបាន ខ្ញុំសុខចិត្ត ចូលនៅបម្រើលោកអស់១ជីវិត ទ្រមាក់ដំរីឮហើយមានចិត្តត្រេក អរចូលទៅដល់ក្រោមដើមត្នោតឈរលើខ្នងដំរីទៅតោងជើងបុ-រសនោះជាប់ហើយដូចជាអង្រួនខ្នងដំរីនោះដំរីក៏ដើរទៅ ទ្រមាក់

ដំរីក៏ជាប់ព្យួរជាមួយនឹងបុរសនោះ គ្រានោះមានមនុស្សទំពែកទាំង ៤ នាក់ដើរស្វែងរកមនុស្សទៅបម្រើប្រពន្ធគ្រប់គ្នា លុះដើរទៅដល់ក្រោមដើមត្នោតនោះ ទ្រមាក់ដំរីនឹងបុរសស្រែកថា បើលោកណាជួយខ្ញុំឲ្យបានរួចពីចុងត្នោតទាំងពីរនាក់នេះខ្ញុំសុខចិត្តចូលនៅបម្រើអស់ ១ ជីវិត នោះទំពែកទាំង ៤ នាក់ឮហើយត្រេកអរគិតថាបានដូចសេចក្ដីប្រាថ្នាក៏ស្រែកថាដូច្នេះ យើងទាំង ៤ នាក់នឹងជួយអ្នករួច ទំពែកទាំង ៤ ឈរក្រោមដើមត្នោតយកសំពត់បងកខ្វែងទល់មុខគ្នាជា ៤ ជ្រុង ហើយស្រែកប្រាប់ទៅបុរសនោះនឹងទ្រមាក់ដំរីថា ឲ្យទំលាក់ខ្លួនពីលើចុងត្នោតមកចុះ បុរសនឹងទ្រមាក់ដំរីទំលាក់ខ្លួនទាំងពីរនាក់មកលើសំពត់ដែលទំពែកទាំង ៤ នាក់បងកនោះដូចជាគេទាញសំពត់ជាប់នឹងកទំពែកទាំង ៤ ផល់ក្បាលគ្នាស្លាប់ទាំង ៤ នាក់ ឯទ្រមាក់ដំរីនឹងបុរសទាំងពីរនាក់ឃើញទំពែកទាំង ៤ នាក់ស្លាប់ដូច្នោះភ័យណាស់ ទៅនិយាយនឹងយាយចាស់ម្នាក់ថា ឲ្យ

ជួយ បើគិតដូចម្តេចឲ្យបានសុខ នឹងនៅបម្រើយាយចាស់ទាល់អស់ជីវិត យាយចាស់មានចិត្តត្រេកអរដោយប្តីខ្លួនទៅកាប់ចង្កាឯព្រៃ ហើយគិតឧបាយថា បើដូច្នោះឲ្យអ្នកទៅយកខ្មោចទាំង ៤ នោះទុកដាក់ក្នុងផ្ទះយាយចាស់នោះបង្គាប់ឲ្យស្រែបរួចយាយចាស់ឲ្យយកខ្មោចចេញពីផ្ទះមកគាត់ស្រែកយំ អ្នកស្រុកទៅសួរគាត់ថា ប្តីគាត់ស្លាប់អ្នកស្រុកបានជួយយកខ្មោចនោះទៅដុត យាយចាស់ប្រាប់ថា សុំនាក់ទាំងអស់ដុតធ្វើឲ្យល្អ ប្តីខ្ញុំគាត់ស្រឡាញ់ខ្ញុំណាស់ លុះយកខ្មោច ១ ទៅដុតហើយយាយចាស់ស្រែកថា ប្តីគាត់នៅផ្ទះទៀតហើយ អ្នកស្រុកបានទៅយកមកដុតទៀត លុះដុតទៅគំរប ៤ លើកហើយឃើញតាចាស់ប្តីយាយចាស់នោះចេញមកពីព្រៃបំការហើយមានខ្លួននោះប្រឡាក់សុទ្ធតែធ្យូង ពួកអ្នកស្រុកឃើញហើយនាំគ្នាដេញចាប់តាចាស់នោះយកទៅដុតទាំងរស់នោះស្លាប់ទៅថែមទៀត ។

(ចប់រឿងនេះតែប៉ុណ្ណោះ)

# បញ្ជីរឿង


១– រឿងរាមាយណៈ ១ កន្លែង ដែលជាងរចនាខ្មែរបានឆ្លាក់ នៅស៊ុំទ្វារបណ្ណាល័យ
ខាងត្បូងនៃប្រាសាទបន្ទាយស្រី . . . . . . . . . . . . . . . . . ៧៥

២– អំពីការរចនាបុរាណក្នុងស្រុកខ្មែរ លោកប៉ែរ ឌុប៉ុងត៍រៀបរៀង ក្រមការដុំ-មៅ
ប្រែពីភាសាបារាំងមកជាភាសាខ្មែរ . . . . . . . . . . . . . . . . ៧៧

៣– សាសនប្រវត្តិ ព្រះមហាពិទូរក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ
រៀបរៀង (ត) . . . . . . . . . . . . . . . . . . . . . ៨៥

៤– ឯកនិបាតជាតក-៤-មហាសីលជាតក អាចារ្យ ហ៊ឹម ក្រុមជំនុំប្រែព្រះត្រៃបិដក
ប្រែពីបាឡីមកជាភាសាខ្មែរ . . . . . . . . . . . . . . . . . ៩៩

៥– រឿងទំនៀមទំលាប់ខ្មែរ-ព្រះរាជពិធីចងសំពោងមាស . . . . . . . . . . ១២៧

៦– រឿងព្រេងខ្មែរ ដែលមិនទាន់បានពុម្ពផ្សាយ:

១– រឿងស្រីមារយាផិតប្ដី . . . . . . . . . . . . . . . . . . ១៣១

២– រឿងលោកសង្ឃ ១ អង្គស្រឡាញ់ស្រី . . . . . . . . . . . . . ១៣៥

៣– រឿងអាវិលនឹងអាខ្វូច . . . . . . . . . . . . . . . . . . ១៣៧


# រូបចិត្រកម្ម


ស៊ុំទ្វារបណ្ណាល័យខាងត្បូង នៃប្រាសាទបន្ទាយស្រី រចនាត្រង់ក្រុងរាពណ៍អង្រួន
ភ្នំ . . . . . . . . . . . . . . . . . . . . . . . . . ៧៥

រូបក្រៅរឿង: ព្រះអវលោកិតេស្វរពោធិសត្វទ្រង់កួចចំណងព្រះពស្ត្រ ដើម្បី
ស្រោចស្រង់លោក . . . . . . . . . . . . . . . . . . . . ៧៧

# TABLE DES MATIÈRES


I. Une épisode de Rāmāyana sanscrit représenté par un artiste khmer sur le fronton d'une Bibliothèque de Bantéaï Sreï.......................................... 75

II. L'art ancien du Cambodge par Pierre Dupont, traduit du Français en Cambodgien par Kromokar Choum-Mau.. 77

III. Sāsanapravatti ou l'Histoire des Religions, par Préas Moha Pitou Krasém pandit à la Bibliothèque Royale (suite)........................................ 85

IV. Eka Nipāta Jātaka — IV Mahā Sīlava Jātaka, traduit du Pāli en Cambodgien par l'Achar Him, Membre de la Commission du Tripitaka.......................... 99

V. Les Coutumes Cambodgiennes — III Cérémonie Royale de l'attachement de l'amulette en or dite "Samrong méas"........................................ 127

VI. Contes populaires Cambodgiens inédits:

I° Une Femme qui trompe son mari.................. 131

II° Un bonze qui aime une femme...................... 135

III° Le malin et le roublard ou A-khel et A-khoch........ 137


## ILLUSTRATION:


Fronton d'une porte de la Bibliothèque sud de Bantéai Sreï représentant Rāvana secouant le Mont.................. 75

Hors-texte représentant Avalokitesvara faisant un nœud de son vêtement pour sauver l'Univers.................. 77

នៅចំងាយ ២១ គីឡូម៉ែត្រខាងជើងអង្គរធំ មានប្រាសាទដែលសាងឧទ្ទិស្សដល់ព្រាហ្មណសាសនា ១ ដែលគេហៅសព្វថ្ងៃថាបន្ទាយស្រី ហើយដែលកសាងក្នុងរវាង ព. ស. ១៤៥០ ។ ទីបណ្ណាល័យខាងត្បូងមានស៊ុំទ្វាររចនារឿងរាមា-យណសំស្ក្រឹត ដែលជាងរចនាខ្មែរក្នុងជាន់នោះ បានឆ្លាក់ជាប់យ៉ាងត្រឹមត្រូវហ្មត់ចត់លើផែនថ្ម — រឿងដែលឆ្លាក់នោះ គឺនៅក្នុងភាគទី ៣ នៃរឿងរាមាយណ ក្នុងឧត្តរកណ្ឌ ។ ក្នុងកណ្ឌនោះសំដែងថា ក្រុងរាពណាសូរបររាជរថទៅទើរនៅភ្នំកេលាស ហើយក៏ចុះចេញពីរាជរថ យកព្រះហស្តទាំងពីរចាប់ភ្នំអង្រន់រង្គើរក់រឺ លុះដល់នាងបរិតីភ័យស្លុតស្លុះទៅឱបព្រះឥស្សូរជាស្វាមី ក្នុងវេលានោះព្រះឥស្សូរក៏យកព្រះបាទឈ្លីភ្នំនោះខ្ទេចខ្ទី ខ្ទេចទាំងដៃក្រុងរាពណ៍ទៅផង ។ ជាងរចនាបានឆ្លាក់ត្រង់កន្លែងដែលក្រុងរាពណ៍ កំពុងតែលូកដៃទៅចាប់ភ្នំនឹងអង្រន់ ។

# អំពីការពនាប្វកណាក្នុងស្រុកខ្មែរ

លោកប៉ែរឱប៉ុងត៍អធិប្បាយ

ក្រម្ការ ដុំ-អៅ ប្រែពីភាសាបារាំងមកជាភាសាខ្មែរ

ពួកអ្នកតែងប្រវត្តិការជាតិចិន បានអធិប្បាយក្នុងសៀវភៅឈ្មោះ ណាំនត្សឺ នឹង លាងស៊ូ ថា មានស្រុក ១ ឈ្មោះ ហ៊្វូណន បានតាំងឡើងពីក្នុងរវាងឆ្នាំ ២០០ មុនគ្រិស្តសករាជ ស្រុកនោះសព្វថ្ងៃនេះបែកចេញទៅជា ស្រុកខ្មែរ, ស្រុកសៀម, ស្រុកលាវ, ស្រុកកូសាំងស៊ីន នឹងជ្រោយម៉ាឡេយូ ១ ចំណែក, អ្នកដែលតាំងស្រុកនេះ គឺឈ្មោះ ហ៊ុន-ទៀន ចូលមកដោយសំពៅពីទិសខាងត្បូង ។ គឺជារឿងរ៉ាវនៃសេចក្ដីស៊ីវិឡៃក្លឹង្គដែលចូលមកក្នុងប្រទេសឥណ្ឌូចិន ។ មានវិជ្ជាផ្សេង ៗ គ្រប់មុខចូលមកសង្កត់លើវិជ្ជាសម្រាប់ស្រុកជាច្រើនរយឆ្នាំ គឺវិជ្ជាអក្សរ, ភាសាសំស្ក្រឹត. អក្សរសាស្ត្រ, វិធីសាសនា, វិធីបរមត្ថនឹងការរបាំ ។ យើងមិនបានដឹងដោយជាក់ស្ដែងអំពីសេចក្ដីស៊ីវិឡៃក្លឹង្គដែលចូលមកនោះមានវង់ដែនត្រឹមណា គឺថាជ្រួតជ្រាបទៅដល់សាធារណជនយ៉ាងដូចម្ដេចខ្លះ ។ ឯប្រាសាទបូរាណនឹងសិលាចារិក ដែលមានពីក្នុងរវាងឆ្នាំ ៧០០ ដល់ ១៣០០ នោះមានធ្វើឲ្យយើងដឹងសាសនាដែលកាន់ក្នុងស្រុកខ្មែរ ប្រា-

សាទនឹងហារិកទាំងនេះសុទ្ធតែជាការរបស់ស្ដេចនឹងរបស់នាហ្មឺនធំៗ ដែលសុទ្ធតែជាអ្នកលុះក្នុងសុីវិល្បែស្រុកឥណ្ឌៀ; ប៉ុន្តែគ្មានអ្វីជាការនាំឲ្យយើងសន្និដ្ឋានអំពីជំនឿរបស់អ្នកស្រុកដែលជារាស្ត្រប្រជាធម្មតា, អំពីគុណសម្បត្តិក្នុងខ្លួនរបស់អ្នកស្រុកដែលជាការមិនងាយនឹងឲ្យសុីវិល្បែប្រទេសក្រៅជ្រាបចូលងាយ, ព្រមទាំងគ្មានអ្វីនាំឲ្យដឹងបានថា តើទំលាប់សណ្ដាប់ស្រុកនោះប្រែប្រួលទៅយ៉ាងណា វេលាដែលមានសាសនាថ្មីចូលមក ។

ទំនងជារូបនាគហើយដែលជាវត្ថុចូលក្នុងជំនឿយ៉ាងមាំ ១ ក្នុងកម្ពុជប្រទេសជាន់ដើម ។

គឺនាងនាគី នាគញី ដែលហ៊ុនទៀនយកធ្វើជាភរិយា ។ លុះតក្រោយមកពួកជាងរចនា វេលាដែលរចនាជារូបនាគម្ដងៗ នោះគេតាំងយកតាមរឿងដែលមានក្នុងក្បួនរចនារបស់ក្លិង្គ ។ ក្នុងសម័យដែលស្រុកខ្មែរកំពុងកាន់សាសនាព្រាហ្មណ៍ ពីឆ្នាំ ៩០០ ដល់ឆ្នាំ ១២០០ នោះរូបនាគច្រើនយកទៅបញ្ចូលនឹងរូបព្រះនារាយណ៍ ហើយជួនកាលជាមួយនឹងគ្រុឌ ដើម្បីរចនានូវសុំទ្វារបង្អួច, ដល់មកសម័យដែលកាន់ព្រះពុទ្ធសាសនា ពីឆ្នាំ

១២០០ ទៅដល់ ១៣០០ នោះគេប្រើនរបនាជាព្រះពុទ្ធរូបនាគប្រក់ជាញឹកញយ ហើយដែលជាការកម្រឃើញមានក្នុងស្រុកឥណ្ឌៀ ។

ដើម្បីនឹងឲ្យយល់នៃសេចក្ដីបំរើនទូទៅក្នុងការសូនបាន់រូបនោះត្រូវគិតដល់បែបយ៉ាងបូរាណរបស់ក្លឹង្គដែលចូលមកដល់ក្នុងស្រុកខ្មែរ គឺបែបបូរាណក្លឹង្គសុទ្ធ ដែលមានតាំងពីដាន់ដើមនោះ ។ ជាដំបូងគឺដរាបដល់មកទល់នឹងឆ្នាំ ៧០០ ជាសម័យដែលការរបនាមានភាពផ្ទាល់ពីស្រុកក្លឹង្គមក ក្នុងសម័យនេះហើយដែលមានកើតរូបភាពយ៉ាងល្អ ៗ ឆើត រូបភាពទាំងនេះសុទ្ធតែខាងសាសនាព្រាហ្មណ៍ទាំងអស់ ។ តមកទៀតពីឆ្នាំ ៩០០ ដល់ ១១០០ មានកើតរបនាដំរាប់បូរាណ គឺរបនាដែលធ្វើតាមបែបបូរាណ តែក្លាយ ៗ តាមភាពស្រុកទេស ជាការដែលអន់ល្អបិយ ៗ មកដោយសេចក្ដីមិនប៉ិនប្រសប់របស់អ្នកស្រុក ។ ក្នុងសម័យនេះហើយដែលកើតរូបភាពផ្សេង ៗ នៅបាកួង, ភ្នំបាខែងនឹងបាពួន ។ ហើយដល់មកសម័យក្រោយគឺពីឆ្នាំ ១២០០ ដល់ ១៣០០ មានកើតរបនាថ្មីជាបែបដើមយ៉ាង

ផ្សេងសម្រាប់ស្រុកខ្មែរ;មានរបនាជាព្រះពុទ្ធរូបនឹងទេវរូបផ្សេង ៗ ក្នុងព្រះពុទ្ធសាសនាយ៉ាងឆើត ៗ មានរាងរៅសក្តិសមនឹងព្រះភក្ត្រញញឹមបប្រិម ។ ជាងរបនាប្រើនផ្ចិតផ្ចង់ព្រះភក្ត្រជាងព្រះអង្គកាយ ដូចមានព្រះភក្ត្រព្រះរូប ៤ រូប នៅប្រាសាទបាយ័ននឹងព្រះខាន់ជាសមអាង ។

ការរបនាខ្មែរមានលក្ខណៈផ្សេងដោយការប្រកបផ្គាប់ផ្គិតនូវកំពូលនឹងថែវដោយងាយស្រួល ។ ហាក់ដោប្រាសាទនគរវត្ត( ឆ្នាំ ១២០០) នោះមានបែបផែនយ៉ាងសំខាន់របស់ប្រាសាទព្រាហ្មណ៍ ដែលសាងមុន ៗ ទាំងប៉ុន្មាន ។ ហាក់ដោនោះមានសភាពដូច្នេះ កំពូលប្រាសាទទាំង ៥ ប្រជុំនៅជាកណ្តាលរៀបរៀងតាមក្បួនខ្នាតយ៉ាងសក្តិសមមានជំបូលថែវតផ្គាប់គ្នាពី ១ ទៅ ១ ដំកល់លើផ្ទៃខឿនធ្វើដោយថ្មភក់ ហើយមានកំផែងព័ទ្ធជុំវិញ ។ ឯប្រាសាទព្រាហ្មណ៍ហាក់ដូចជាមានគ្រឿងសំគាល់បានដោយពង្រីកផ្ទៃកាន់តែធំ ៗ ឡើង ។ ការរបនាខាងព្រះពុទ្ធសាសនាដែលមានវ័យចំរើនឡើងក្នុងឆ្នាំ ១២០០ ទៅ ១៣៥០ ធ្វើឲ្យឃើញបែបផែនដោយឡែកផ្សេងទៅវិញ គឺរាប់អានបែបផ្តិជា

ជុំៗ ។ ក្នុងសម័យនោះហើយដែលមានកើតកំពូលមុខមនុស្ស បួនដែលជាការប្រតិស្ឋបែបយ៉ាងសំខាន់របស់របនាខ្មែរ ។

ក្នុងទីបំផុតនេះ រឿងរ៉ាវរបស់ប្រាសាទទាំងឡាយ បេះតែមានសេចក្ដីប្រែប្រួលតាំងពីប៉ុន្មានឆ្នាំមុននេះមក ។មានសិលាចារឹក ១ ពោលថា ព្រះបាទយសោវរម័ន ( ឆ្នាំ ៨៨៩ -៩១០ មុនគ្រិស្តសករាជ) បានសាង«ភ្នំកណ្ដាល» ដើម្បីដំកល់លិង្គស្ដេចដែលជាបែបសាសនាព្រាហ្មណ៍ ចូលមកក្នុងស្រុកខ្មែរក្នុងដើមឆ្នាំ៩០០ គេនាំគ្នាជឿមកជាយូរណាស់ហើយថា ភ្នំកណ្ដាលគឺជាប្រាសាទបាយ័ន ដែលជាប្រាសាទនៅចំកណ្ដាលក្រុងនគរធំ, តមក គេបានយល់ឃើញថា ប្រាសាទបាយ័នមិនមែនជាប្រាសាទសម្រាប់សាសនាព្រាហ្មណ៍ទេ គឺសម្រាប់ព្រះពុទ្ធសាសនា តែក្បាច់របនានោះប្លែកគ្នាទាំងអស់អំពីប្រាសាទទាំងប៉ុន្មានដែលកសាងក្នុងឆ្នាំ៩០០ទៅ១០០០ ។ ការស្រាវជ្រាវរបស់លោកស្ដែន៍នឹងសឺដេស នាំឲ្យបន្ថយឆ្នាំកសាងប្រាសាទបាយ័នមកដាក់ក្នុងចុងឆ្នាំ១២០០វិញ ។ ការស្រាវជ្រាវរិះរកភ្នំកណ្ដាលដែលពិតប្រាកដនោះមិនជាការងាយស្រួលឡើយព្រោះ

ទំហំទ្រង់ទ្រាយទីក្រុង ប្រះតែប្រែប្រួលច្រើនលើកច្រើនគ្រាមកហើយ។ បំណែកលោកស្តែន៍ដែលជាអ្នកយកចិត្តទុកដាក់ហើយរួមគំនិតក្នុងការរើជីរះរៀបចំប្រាសាទបូរាណខ្មែរជាថ្មីនោះបានដំរូបថា ឲ្យសំដៅយកប្រាសាទវិមានអាកាសទុកជាភ្នំកណ្តាលនៃក្រុងនគរធំ; ប៉ុន្តែការស្រាវជ្រាវជាថ្មីក្នុងជាន់ក្រោយនេះរបស់លោកម៉ារ្សាល់នឹងគោលូបែហ្វ៍ នាំឲ្យទាញគំនិតទៅរកភ្នំបាខែងវិញ ។ តែថាការនេះមិនទាន់មានអ្វីបញ្ជាក់ឲ្យបានជាការដាច់ស្រេចនោះឡើយ ។

ប៉ែរ្យឌុប៉ុងត៍

សាសនប្រវត្តិ បរិច្ឆេទទី ៧

# ព្រះរាជពង្សាវតារក្រុងកម្ពុជា (ត)

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ រៀបរៀង

### រជ្ជកាលព្រះបាទសម្ដេចព្រះជយវរ្ម័នទី ៤

កាលសម្ដេចព្រះហរិវរម័ន រុទ្រលោក ទិវង្គតទៅហើយ ព្រះជយវរម័ន បានទទួលរាជសម្បត្តិតមក រាប់ជាទី ៤ អំពី ព.ស. ១៤៧៣ ដល់ ១៤៨៦ (ព្រះរាជាអង្គនេះជាព្រះរាជបុត្រ សម្ដេចព្រះហរិវរម័នឬអង្គណា មិនទាន់ប្រទះទីមកជាប្រាកដ) ផែនដីនេះបានផ្លាស់ទីក្រុងទៅតាំងនៅកោះកែ ក្នុងខែត្រកំពង់ធំ ទ្រង់សាងប្រាសាទរាជមណ្ឌីរនៅទីនោះ ស្ដេចស្ថិតនៅក្នុងរាជ-សម្បត្តិបាន ១៤ឆ្នាំ ក៏ទិវង្គត វេលាសុគតហើយគេថ្វាយព្រះនាមព្រះបរមសពជា "បរមសិវបទ" ។

### រជ្ជកាលព្រះបាទសម្ដេចព្រះហរិវរម័នទី ២

កាលសម្ដេចព្រះជយវរម័នទី ៤ ទិវង្គតទៅហើយ ព្រះហរិវរម័នបានសោយរាជ្យជាដំណាមក រាប់ជាទី ២ នៅទីក្រុងដដែលពីព.ស. ១៤៨៦ ដល់១៤៩១(គ.ស.៩៤១ ដល់៩៤៤) ទើបទិវង្គត់ វេលាទិវង្គតហើយគេថ្វាយព្រះនាមព្រះបរមសពជា "ព្រហ្មលោក" ។

## រជ្ជកាលព្រះបាទសម្ដេចព្រះរាជេន្ទ្រវរ្ម័នទី ២

កាលព្រះបាទសម្ដេចព្រះហរិវរ្ម័នទី ២ ទិវង្គតទៅហើយ ព្រះជយវរ្ម័ន តែនៅសិលាចារិកខ្លះហៅថា ព្រះស្រីរាជេន្ទ្រវរ-មេស្វរ ហៅដោយខ្លីថា ឥន្ទ្រវរ្ម័ន បានសោយរាជ្យជាដំណមករាប់ជាទី២ពីព.ស.១៤៩១ដល់១៥១៥(គ.ស.៩៤៤–៩៦៨) តាមសិលាចារិកនៅប្រាសាទបក្សីចាំក្រុងថា ព្រះរាជេន្ទ្រវរ្ម័នជារាជបុត្រព្រះជយវរ្ម័នទី ៤ ត្រឡប់មកតាំងរាជធានីនៅក្រុងយសោធរបុរវិញ មានព្រះរាជបុត្រដែលប្រាកដព្រះនាម ១ អង្គនាមព្រះស្រីជយវរមទេវ ។ ក្នុងរជ្ជកាលនេះកើតសង្គ្រាមនឹងចាមទៀត ទ្រង់ដុតទ័ពទូកចាមក្នុងកាលព.ស.១៥០៧(គ.ស.៩៦០) ស្លាប់អនេកឥតបីបើគណនា ប្រាកដព្រះកិត្តិយសជា មហា-រាជា តាមក្នុងសិលាចារិកថា ព្រះមហារាជាអង្គនេះ ទ្រង់សាងប្រាសាទដែលយើងហៅក្នុងកាលឥឡូវថា តាព្រហ្ម ឬអង្គព្រហ្ម ១ ប្រាសាទបន្ទាយក្ដី (គឺបន្ទាយកុដី) ១ ឧទ្ទិស្សថ្វាយក្នុងព្រះពុទ្ធ-សាសនាប៉ែកខាងលទ្ធិមហាយាន នឹងប្រាសាទមេបុណ្យជាទេវស្ថានឧទ្ទិស្សថ្វាយក្នុងសាសនាព្រាហ្មណ៍ របស់អំបាលនេះ

ជាគ្រឿងដំកើងនឹងប្រកាសព្រះកិត្តិយសរបស់ព្រះអង្គជរាបដល់វេលានេះ កាលទិវង្គតទៅហើយគេថ្វាយព្រះនាមសម្រាប់ព្រះកិត្តិ-យសនេះថា "ព្រះសិរលោក". ។

រជ្ជកាលព្រះចៅឧសម្តេចព្រះជយវរ្ម័នទី ៥

កាលសម្តេចព្រះរាជេន្ទ្រវរម័ន សិវលោក សុគតទៅហើយ ព្រះស្រីរាជេន្ទ្រវរមទេវ រាជបុត្របានទទួលរាជសម្បត្តិតមក ព្រះនាមក្នុងសុវណ្ណបត្រថា ជយវរម័ន រាប់ជាទី៥ ពីព.ស. ១៥១៥ ដល់ ១៥៤៩ (គ.ស. ៩៦៨–១០០២) ក្នុងរជ្ជកាលនេះមិនប្រាកដថា កើតសឹកសង្គ្រាមនឹងប្រទេសណា តែក៏រាប់ថាជា មហារាជា ១ អង្គដែរ ដោយទ្រង់រក្សាព្រះកេរ្តិ៍របស់បុព្វបុរសឲ្យគង់វង្សនៅបរិបូណ៌ នឹងទ្រង់សាងប្រាសាទជាថ្មីឡើងទៀត តាមសិលាចារិកថា ទ្រង់សាងប្រាសាទហេមាទ្រិ ដែលហៅក្នុងកាលឥឡូវនេះថា បាពួន នៅក្នុងក្រុងយសោធរបុរ ឧទ្ទិស្សថ្វាយក្នុងសាសនាព្រាហ្មណ៍ នឹងទ្រង់សាងប្រាសាទកបិលបុរ នៅជាខាងពាយព្យនៃនគរវត្ត ឧទ្ទិស្សថ្វាយព្រះហរិ ។

វេលាទិវង្គតហើយគេថ្វាយព្រះនាមជាព្រះកិត្តិយសថា បរមវីរលោក (១) ។

### រជ្ជកាលព្រះបាទសម្ដេចព្រះសូរ្យវរ្ម័នទី ១

កាលព្រះបាទសម្ដេចព្រះជយវរ្ម័ន បរមវីរលោក ទិវង្គតហើយ ព្រះសូរ្យវរ្ម័នបានទទួលរាជសម្បត្តិតមក រាប់ជាទី ១ ពី ព.ស. ១៥៤៩ ដល់ ១៥៩៦ (គ.ស. ១០០២–១០៤៩) ក្នុងរជ្ជកាលនេះកើតសង្គ្រាមនឹងយួនជាច្រើនលើក តែទ្រង់កម្រាបយួនបានរាល់គ្រា ទ្រង់បងសម្ពន្ធមេត្រីនឹងប្រទេសចិននឹងប្រទេសចាម ក្នុងសិលាចារិកថា ទ្រង់សាងប្រាសាទព្រះខាន់នៅខេត្តកំពង់ស្វាយ ១ នៅលើភ្នំជីសូរខេត្តតាកែវ ១ ប្រាសាទកែវនៅមុខក្រុងនគរធំ ១ ក្នុងរជ្ជកាលនេះរាប់អានសាសនាពីរយ៉ាង គឺសាសនាព្រាហ្មណ៍នឹងព្រះពុទ្ធសាសនា វេលាទិវង្គតហើយគេថ្វាយព្រះនាមព្រះបរមសពថា "និព្វាណបទ" ។

---

(១) ឃើញខ្លះថាបរមវីរលោក ។

## រជ្ជកាលព្រះចៅសម្ដេចព្រះឧទយាទិត្យវរ្ម័ន

កាលសម្ដេចព្រះសូរ្យវរ្ម័នទី ១ ទិវង្គតហើយ ព្រះឧទយាទិត្យវរ្ម័នបានឡើងសោយរាជ្យពីព.ស. ១៥៩៦ ដល់ ១៦២៦ (គ.ស. ១០៤៩–១០៧៩) ក្នុងរជ្ជកាលនេះមានហេតុបាស់បោឡើងក្នុងព្រះនគរដល់ទៅ ៣ ដង តែសេនាបតីខាងទាហានរបស់ព្រះអង្គឈ្មោះ "ព្រះសង្គ្រាម" ជាអ្នកដែលមានឫទ្ធិក្នុងការសង្គ្រាម បានបេញកម្លាំងពួកបាស់បោនោះឲ្យរាបទាបទៅវិញ ក្នុងរជ្ជកាលនេះ ទ្រង់សាងប្រាសាទទេវស្ថានឧទ្ទិស្សថ្វាយក្នុងសាសនាព្រាហ្មណ៍នៅក្នុងស្រុកភីមបុរ (គឺភិម៉ាយនៅក្នុងដែនសៀមសព្វថ្ងៃនេះ) ។ លុះដល់ព.ស.១៦២៦ ក៏ទិវង្គត រីលោទិវង្គតហើយ គេថ្វាយព្រះនាមព្រះបរមសពជា "ឧទយកវរ្ម័ន" ។

## រជ្ជកាលព្រះចៅសម្ដេចព្រះហរ្សវរ្ម័នទី ៣

កាលសម្ដេចព្រះឧទយាទិត្យវរ្ម័នទិវង្គតហើយ ព្រះហរ្សវរ្ម័នបានឡើងសោយរាជ្យតមក រាប់ជាទី ៣ ពីព.ស. ១៦២៦ ដល់ ១៦៣៧ (គ.ស. ១០៧៩-១០៩០) ក្នុងរជ្ជកាលនេះជាមានរបស់ដំណែលខ្លះដែរឬដូចម្ដេច មិនទាន់បានប្រទះ ដល់មក

ព. ស. ១៦៣៧ ក៏ទិវង្គត វេលាទិវង្គតហើយ គេថ្វាយព្រះនាមព្រះបរមសពជា "សទាសិវបទ" ។

## រជ្ជកាលព្រះចៅឧសម្ដេចព្រះជយវរ្ម័នទី ៦

កាលព្រះហស៍វរម័នទី ៣ ទិវង្គតហើយ ព្រះជ័យវរម័នបានទទួលរាជសម្បត្តិតមក ពីព. ស. ១៦៣៧ ដល់ ១៦៤៦) គ. ស. ១០៩០-១១០៩) រាប់ជាទី ៦ ក្នុងរជ្ជកាលនេះក៏មិនទាន់បានប្រទះដំណែលរបស់លោកថា មានអ្វីខ្លះ ។ ដល់មកព. ស. ១៦៤៦ ក៏ទិវង្គត វេលាទិវង្គតហើយ គេថ្វាយព្រះនាមជា "បរមកៃវល្យបទ" ។

## រជ្ជកាលព្រះចៅឧសម្ដេចព្រះធរណិន្ទ្រវរ្ម័នទី ១

កាលសម្ដេចព្រះជ័យវរម័នទី ៦ ទិវង្គតហើយ ព្រះធរណិន្ទ្រវរម័នបានទទួលរាជសម្បត្តិតមក ពីព. ស. ១៦៤៦ ដល់ ១៦៥៩(គ. ស. ១១០៩–១១១២)ក៏ទិវង្គត វេលាទិវង្គតហើយ គេថ្វាយព្រះនាមព្រះបរមសពជា "បរមនិស្កលបទ" ។

រជ្ជកាលព្រះបាទសម្ដេចព្រះសូរ្យវរ្ម័នទី២

កាលសម្ដេចព្រះធរណិន្ទ្រវរ្ម័នទិវង្គតទៅហើយ គ្រានោះប្រទេសកម្ពុជាបែកជា ២ អាណាចក្រ មានក្សត្រិយ៍សោយរាជ្យ ២ អង្គ ទោះបីញែកជាពីរអាណាចក្រដូច្នេះហើយក៏មិនសុខនឹងគ្នា កើតសង្គ្រាមនឹងគ្នារឿយៗមក ដោយក្សត្រិយ៍ទាំងពីរនោះបំណងនឹងរួមអំណាចមកលើខ្លួនតែមួយវិញ តែក៏មិនដេបស្រេចទៅខាងណា ។

គ្រានោះមានក្សត្រិយ៍ខ្មែរ ១ អង្គទៀត ទ្រង់ព្រះនាមសូរ្យវរម័ន ទ្រង់ដំរិះថា ការដែលក្សត្រិយ៍ទាំងពីរវិវដណ្ដើមឥស្សរភាពគ្នាដូច្នេះ មិនយូរប៉ុន្មានពួកតាងប្រទេសឃើញបានឱកាសក៏នឹងលើកទ័ពមកវាយយកទៅ កាលទ្រង់ព្រះដំរិះដូច្នេះហើយ ទើបទ្រង់រួបរួមកងទ័ពឡើងមួយពួកទៀត លើកទៅកម្រាបក្សត្រិយ៍ទាំងពីរ ដណ្ដើមរាជសម្បត្តិបាន ស្ដេចប្រាប្ដាភិសេកកាល ព.ស. ១៦៥៥ ទ្រង់ព្រះនាមជា ព្រះសូរ្យវរម័ន ទី ២ ។ សេចក្ដីដែលទ្រង់ព្រះដំរិះមុននោះក៏មិនជាការឥតមូល គឺគ្រានោះក្សត្រិយ៍ចាមបានដំណឹងថា ប្រទេស

កម្ពុជាបែកគ្នាជាពីរបីពួក ក៏លើកទ័ពមកវាយ ។ ព្រះបាទសម្ដេចព្រះសូរ្យវរម័នស្ដេចលើកទ័ពហ្លួងចេញច្បាំងនឹងចាមមានជ័យជំនះ វាយផ្លាយរហូតដល់នគរចម្ប៉ា បានទាំងនគរនោះរួមមកជាអាណាខេត្តកម្ពុជាផង ទ្រង់ចាត់ឲ្យឧបរាជខ្មែរ ១ អង្គទៅឈរកាន់កាប់ចាមប្រទេសរាជ បំណែកឯនគរប៉ែកខាងលើដែលជាស្រុកបំណុះទាំងប៉ុន្មាន ទ្រង់មានព្រះរាជកំណត់ឲ្យនាំរាជបណ្ណាការមកថ្វាយគ្រប់ទាទសមាសដូចអំពីដើម ។

កាលស្រេចព្រះរាជសង្គ្រាម ប្រទេសសាន្តត្រាណប្រក្រតីហើយ ទ្រង់ឲ្យសាងប្រាសាទនគរតូច គឺប្រាសាទនគរវត្តសព្វថ្ងៃនេះជាទេវស្ថានឧទ្ទិស្សថ្វាយព្រះនារាយណ៍ នឹងត្រាស់ឲ្យឆ្លាក់រឿងព្រះរាជពង្សាវតារ ត្រង់ដែលព្រះអង្គលើកទ័ពទៅច្បាំងនឹងក្សត្រិយ៍ចាម ព្រមទាំងព្រះបរមរូបរបស់ព្រះអង្គ នៅព្រះបៀងថ្នាក់ទី ១ ជាន់ខាងត្បូងភាគខាងលិច ទុកជាព្រះកិត្តិយសដរាបដល់សព្វថ្ងៃនេះ ។ ស្ដេចស្ថិតនៅក្នុងរាជសម្បត្តិបាន ៤០ ឆ្នាំ ទើបទិវង្គត កាលព. ស. ១៦៩៥ វេលាសុគតហើយ គេថ្វាយព្រះ

បរមនាមាភិធៃយថា បរមវិស្ណុលោក ។ ព្រះមហាក្សត្រិយ៍អង្គនេះគួររាប់ជា មហារាជ ឬរាជាធិរាជក្នុងព្រះរាជពង្សាវតារ ។

## រជ្ជកាលព្រះបាទសម្តេចព្រះសូរ្យវរ្ម័ន ទី ៣

កាលសម្តេចព្រះសូរ្យវរ្ម័ន បរមវិស្ណុលោកទិវង្គតហើយ ក្សត្រិយ៍អ្នកជារជ្ជទាយាទព្រះនាមសូរ្យវរ្ម័ន ដូចរជ្ជកាលមុន តែរាប់ជាទី ៣ វេលាសោយរាជ្យនឹងទិវង្គតក្នុងសករាជប៉ុន្មាន មិនទាន់បានប្រទះជាប្រាកដ ដល់មកក្នុងរជ្ជកាលនេះចាមប្រ-ទេសរាជ ត្រឡប់តាំងខ្លួនជាឯករាជឡើងវិញបាន ។

## រជ្ជកាលព្រះបាទសម្តេចព្រះធរណិន្ទ្រវរ្ម័ន ទី ២

កាលសម្តេចព្រះសូរ្យវរ្ម័នទី ៣ ទិវង្គតហើយ ព្រះធរណិន្ទ្រវរ្ម័នបានឡើងសោយរាជ្យតមក រាប់ជាទី ២ តែមិនប្រាកដថា សករាជប៉ុន្មាន ។

## រជ្ជកាលព្រះបាទសម្តេចព្រះជយវរ្ម័ន ទី ៧

កាលផុតផែនដីព្រះធរណិន្ទ្រវរ្ម័នទី ២ ទៅហើយ ព្រះជយវរ្ម័នបានទទួលរាជសម្បត្តិតមក រាប់ជាទី ៧ ព្រះរាជាអង្គ

នេះសោយរាជ្យនឹងទិវង្គតពីសករាជប៉ុន្មាន មិនទាន់ប្រទះទីមក ក្នុងរជ្ជកាលនេះកើតសង្គ្រាមនឹងស្ដេចចាមឈ្មោះជយឥន្ទ្រវរម័ន នៅក្រុងវិជយ (សព្វថ្ងៃនេះឃ្លួនហៅ បិញឌិញ) គឺកាល ព.ស. ១៧៣៣ (គ. ស.. ១១៩០) ស្ដេចជយឥន្ទ្រវរម័ន បានលើកទ័ពមកច្បាំងនឹងប្រទេសកម្ពុជា សម្ដេចព្រះជយវរម័នទី ៧ទ្រង់ចាត់ព្រះអង្គម្ចាស់ ១ អង្គព្រះនាមវិទ្យានន្ទន ជារាជវង្សចាម ដែលមកជ្រកនៅក្នុងម្លប់ព្រះពោធិសម្ភាររបស់ព្រះអង្គ ឲ្យជាមេទ័ពចេញទៅតយុទ្ធនឹងចាមជំនួសព្រះអង្គ ព្រះវិទ្យានន្ទនច្បាំងឈ្នះចាម ចាប់ព្រះជយឥន្ទ្រវរម័នបានទាំងរស់ នាំមកថ្វាយល្អងធុលីព្រះបាទ ហើយទ្រង់ចាត់ព្រះអង្គម្ចាស់ឥន្ទ្រ ជាព្រះអនុជថ្លៃ ឲ្យទៅគ្រងនគរចាម ៗ នៅជាស្រុកបំណាុះក្រុងកម្ពុជារហូតមកដល់ គ.ស. ១២២០ រួមជា ៣០ ឆ្នាំ ។

ព្រះជយវរម័ន មានព្រះអគ្គមហេសីដំបូងទ្រង់ព្រះនាមជយរាជទេវី ជាធីតាព្រាហ្មណ៍ តែបិតាមិនប្រាកដនាម មាតាឈ្មោះរាជេន្ទ្រលក្សី ជាត្រកូលខ្ពស់ស្ដុកស្ដម្ភ ក្នុងសិលាចារិកថា ព្រះនាងនេះទាំងល្អឆោមទាំងប្រាជ្ញ ដោយបានរៀនវិជ្ជា

ពីនាងឥន្ទ្រទេវីជាជេដ្ឋភគិនី ហើយជាអ្នកកាន់ព្រះពុទ្ធសាសនាយ៉ាងមុតមាំ ព្រះនាងបានបង្រៀនគម្ពីរពុទ្ធសាសនាក្នុងវត្តឬក្នុងសាលាឈ្មោះនាគេន្ទ្រតុង្គ ១ តិលកោត្តរ ១ នរេន្ទ្រាស្រម ១ ការដែលបានជាគ្រូបង្រៀនវិជ្ជាទាំងនេះ ជាគ្រឿងសំគាល់ថាព្រះនាងនេះវិជ្ជាដ៏សំខាន់ពិតមែន ក្នុងប្រវត្តិនេះនាំឲ្យយើងជឿថា ព្រះនាងចេះភាសាសំស្ក្រឹតយ៉ាងសំខាន់ទៀតផង ដោយឃើញសិលាចារិកនៅប្រាសាទវិមានអាកាស សុទ្ធតែស្នាព្រះហស្ថរបស់ព្រះនាងធ្លាក់ទាំងអស់ ។ ក្រោយនោះព្រះនាងក៏ទិវង្គត តែក្នុងឆ្នាំប៉ុន្មានមិនប្រាកដ តែស្មានមើលប្រហែលជាក្រោយបំបាំងស្រុកចាម ។ កាលព្រះនាងជយរាជទេវីទិវង្គតហើយ ព្រះជយវរ្ម័នទ្រង់លើកនាងឥន្ទ្រទេវីដ៏ជាជេដ្ឋភគិនីរបស់ព្រះនាងឡើងជាអគ្គមហេសី ។

ព្រះជយវរ្ម័នទី ៧ នេះវេលាទិវង្គតហើយ គេថ្វាយព្រះនាមព្រះបរមសពជា «ជយវរមទិវមេស្វរ» ។

បឋមភាគពង្សាវតារចប់តែប៉ុណ្ណោះ ។

# ឯកនិបាតជាតក

## ៤ — មហាសីលវជាតក

អាចារ្យហ៊ិម អាំងស្ប៉ិកទ័រ ត្រួតសាលាវត្ត ប្រែពីបាឡីមកជាភាសាខ្មែរ

អាសីសេថេវ បុរិសោតិ ឥទំ សត្ថា ជេតវនេ វិហរន្តោ ឱសដ្ឋវីរិយំ អារព្ភ កថេសិ ។ (សេចក្ដីថា) កាលព្រះមុនីនាថសាស្ដាចារ្យទ្រង់គង់ក្នុងព្រះវិហារឈ្មោះជេតវន ព្រះអង្គទ្រង់ប្រារព្ធបំពោះនូវភិក្ខុដែលមានព្យាយាមដាក់ចុះ ហើយទ្រង់សម្ដែងនូវព្រះធម៌ទេសនានេះថា អាសីសេថេវ បុរិសោ ដូច្នេះជាដើម ។ ក្នុងសម័យ ១ មានភិក្ខុ ១ អង្គបន្ថយចុះនូវសេចក្ដីព្យាយាមរបស់ខ្លួន ព្រះជិនស្រីទ្រង់មានព្រះពុទ្ធដីកាសួរថា ម្នាលភិក្ខុបានឮថា អ្នកឯងបន្ថយចុះនូវព្យាយាមរបស់ខ្លួនពិតមែនឬ ។ ភិក្ខុនោះយកសេចក្ដីក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោសពិតមែនហើយព្រះអង្គ ។ ព្រះទីបទុត្តមាចារ្យទ្រង់ឲ្យឱវាទថា នែភិក្ខុអ្នកបានបួសហើយ ក្នុងពាក្យប្រៀនប្រដៅណែនាំមានសភាពដូច្នេះ មិនសម្បីបើនឹងបន្ថយចុះនូវការសន្សំល្អរបស់ខ្លួនសោះ នែភិក្ខុ អ្នកប្រាជ្ញទាំងឡាយក្នុងមុន ស៊ូលះបង់រាជសម្បត្តិហើយស្ថិតនៅក្នុងការសន្សំល្អរបស់ខ្លួន ញ៉ាំងលាភនឹងយសដែលវិនាសហើយឲ្យកើតឡើងវិញ (ជាភិយ្យោភាព) ហើយព្រះបរមលោក-

ត្តមាចារ្យ ទ្រង់នាំមកនូវរឿងរ៉ាវដ៏កន្លងរម្លងទៅហើយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលស្តេចទ្រង់ព្រះនាមថា ព្រះបាទព្រហ្មទត្តរាជ គ្រងរាជសម្បត្តិក្នុងព្រះនគរឈ្មោះពារាណសី (កាលនោះ) ព្រះបរមពោធិសត្វជាម្ចាស់នៃយើង ទ្រង់សម្ភពក្នុងគភ៌នៃព្រះអគ្គមហេសីនៃព្រះបាទព្រហ្មទត្តនោះ ។ ព្រះអង្គយាងចេញចាកគភ៌ បាននាមបញ្ញត្តិថា មហាសីលវកុមារក្នុងថ្ងៃកំណត់នូវព្រះនាម មហាសីលវកុមារនោះ សម្រេចនូវសិល្បសាស្ត្រទាំងពួងក្នុងកាលព្រះអង្គប្រកបដោយឧទ្ទេសនៃឆ្នាំទាំងឡាយជាគម្រប់ ១៦ ។ ដល់អំណើះឥតអំពីព្រះវររាជ-បិតាទៅ ព្រះអង្គទ្រង់សោយរាជសម្បត្តិស្នងព្រះវររាជបិតា ទ្រង់ព្រះនាមថា ព្រះបាទសីលវមហារាជ ព្រះអង្គទ្រង់រាជ្យប្រកបដោយទសពិធរាជធម៌ ទ្រង់បាត់ឲ្យធ្វើសាលាទាន ទាំងឡាយ ៦ អន្លើ គឺ សាលាទាន ៤ នៅនាទៀបទ្វារទាំង ៤ សាលាទាន ១ ទៀតនៅត្រង់ពាក់កណ្តាលនគរ និងសាលាទាន ១ ទៀតនៅទៀបទ្វារនិវេសរាជស្ថាន ព្រះអង្គទ្រង់បំណាយព្រះរាជទ្រព្យ ឲ្យ

ជាទានដល់អ្នកដំណើរនឹងអ្នកកំសត់ផងទាំងឡាយ ជានិច្ច-
កាលទៅ ។

ព្រះបាទសីលវមហារាជ ទ្រង់រាជ្យប្រកបដោយគន្លងធម៌ទ្រង់
រក្សាសីល ៥ ទ្រង់ធ្វើនូវឧបោសថ ទ្រង់ប្រកបដោយខន្តិមេត្តានឹង
ករុណា ហើយទ្រង់ញាំងសត្វទាំងឡាយទាំងអស់ឲ្យសោមនស្ស
រីករាយ បីដូចជាបុគ្គលលើកស្ទួយបុត្រ ឲ្យជិះលើចង្កេះឬដើម
ទ្រូងហើយលួងលោមឲ្យត្រេកអររីករាយសប្បាយសាទរ ។
(កាលនោះឯង) មានអាមាត្យ ១ នាក់មានបិត្តអាក្រក់ ធ្វើកម្ម
ទ្រុស្តក្បត់ក្នុងខាងក្នុងបុរីនៃព្រះអង្គនោះ កម្មនោះកាន់តែប្រាកដ
ឡើងអាមាត្យដទៃក៏យកសេចក្តីក្រាបបង្គំទូល ។ ព្រះអង្គទ្រង់
ជ្រាបហើយព្រះអង្គទ្រង់កំណត់សង្កេតបំពោះព្រះអង្គ លុះជ្រាប
ច្បាស់ប្រាកដហើយ ព្រះអង្គទ្រង់ឲ្យហៅអាមាត្យនោះមកហើយ
ទ្រង់មានព្រះរាជឱង្ការថា ម្នាលបុរសអន្ធពាលកម្មអាក្រក់ឈ្មោះ
នោះដែលអ្នកឯងធ្វើហើយ កម្មនោះលាមកអាក្រក់ក្រៃពេក
ណាស់ អ្នកឯងជាមនុស្សមិនគួរនៅក្នុងដែនរបស់យើងឡើយ
(ល្ហើយបុះបើដូច្នោះ) អ្នកឯងចូរកាន់យកបុត្រភរិយានឹងទ្រព្យ

របស់អ្នកឯង ចេញទៅនៅដែនដទៃក្រៅចាកដែនយើងនេះឲ្យដាច់បុះ ។ អាមាត្យនោះមិនហ៊ានទទឹងទាស់ក៏នាំបុត្រភរិយាចេញចាកទៅកន្លងដែនកាសិក តាំងទីនៅក្នុងកោសលជនបទ (ក្រោយនោះ) បានចូលទៅថ្វាយខ្លួននៅគាល់បម្រើព្រះបាទកោសលរាជជាស្ដេចដែនកោសល) បង្កើតជាបុគ្គលស្និទ្ធស្នាលក្នុងខាងក្នុងនៃព្រះរាជានោះ ។ ក្នុងថ្ងៃ ១ អាមាត្យនោះបានឱកាសល្អក៏យកសេចក្ដីក្រាបបង្គំទូលព្រះបាទកោសលរាជថា បពិត្រព្រះសម្មតិទេព រាជសម្បត្តិក្នុងនគរពារាណសី (សព្វថ្ងៃនេះ) ប្រៀបដូចសម្បុកឃ្មុំឥតមេ បើព្រះអង្គទ្រង់ប្រាថ្នារាជសម្បត្តិនោះអាចនឹងចាប់ស្ដេចពារាណសីបានដោយងាយ ដោយពលពាហណតិចតួច (ព្រោះស្ដេចពារាណសីនោះទ្រង់ធម៌) ។ ព្រះបាទកោសលរាជទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះបន្ទូលថា ស្ដេចពារាណសីជាស្ដេចធំ មិនអាចនឹងចាប់ដោយពលពាហណតិចតួចបានឡើយ ។ អាមាត្យនោះក្រាបទូលញុះញង់ថែមទៀតថា ព្រះអង្គទ្រង់ប្រកបចាប់ស្ដេចពារាណសីបុះ មិនមែនកម្រទេ ។ ព្រះបាទកោសលរាជទ្រង់សួរថា អាមាត្យអ្នក

ឯងជាអ្នកប្រកបបានឬ បើយើងប្រកបពួកចោរតើនឹងប្រកបដូច ម្ដេចហ្ន ។ អាមាត្យក្រាបទូលថា ខ្ញុំទូលបង្គំប្រកបមិនបានទេ សូមព្រះអង្គទ្រង់បញ្ជូនពួកចោរ ឲ្យទៅប្លន់ក្នុងជនបទនោះល្បង មើលចុះ បើទុកជារាជាមាត្យចាប់ពួកចោរនោះយកទៅថ្វាយ (ក៏ស្ដេចពារាណសីមិនធ្វើទោសឡើយ) ថែមទាំងព្រះរាជទាន ធនធានដល់ពួកចោរនោះហើយលែងមកវិញ (ជាពិតប្រាកដ) ។ ព្រះបាទកោសលរាជទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ព្រះចិន្ដាថា អាមាត្យនេះពោលពាក្យក្លៀវក្លាក្រៃពេក ហើយព្រះអង្គរៀបចាត់ ពួកចោររបស់ព្រះអង្គ ឲ្យទៅប្លន់ក្នុងបច្ចន្តគ្រាមនៃនគរពារាណ-សីដោយឧបាយ ។ (កាលនោះ អ្នករក្សាបច្ចន្តគ្រាមនោះ) ចោមចាប់ពួកចោរទាំងអម្បាលនោះ នាំយកទៅថ្វាយព្រះបាទ សីលវមហារាជ ។ ព្រះអង្គទតយល់ហើយទ្រង់សួរពួកចោរថា ម្នាលអ្នកទាំងឡាយហេតុអ្វី បានជាធ្វើកម្មអាក្រក់ប្លន់អ្នកស្រុក ដូច្នោះ ។ ចោរទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព យើងទាំងឡាយ (បានជាប្លន់អ្នកស្រុក) ព្រោះទាល់ក្រណាស់ មិនអាចនឹងរកចិញ្ចឹមជីវិតបានព្រះអង្គ ។ ព្រះរាជាទ្រង់មានព្រះ

បន្ទូលថា នែអ្នកទាំងឡាយបើទាល់ក្រហេតុអ្វីបានជាមិនមករកយើង ហើយទ្រង់ព្រះរាជទានទ្រព្យរបស់ដល់ចោរទាំងឡាយនោះហើយទ្រង់ឲ្យឱវាទសព្វគ្រប់ហើយហាមឃាត់ថា នែអ្នកទាំងឡាយចាប់អំពីថ្ងៃនេះទៅ រាល់គ្នាលែងធ្វើអំពើលាមកអាក្រក់ដូច្នេះទៀត ហើយព្រះអង្គលែងចោរទាំងឡាយនោះឲ្យរួចចេញទៅ ។ ចោរទាំងឡាយនោះលុះរួចខ្លួនហើយថែមទាំងមានលាភផង ក៏ស្រូតរូតទៅនាំពណ៌ដំមាននោះទៅថ្លែងក្រាបទូលព្រះបាទកោសលរាជដោយសព្វគ្រប់ ។ ព្រះបាទកោសលរាជមិនអាចនឹងយាងទៅចាប់ស្ដេចពារាណសី ដោយហេតុមានប្រមាណប៉ុណ្ណោះ ក៏ទ្រង់ចាត់បញ្ជូនពួកចោរឲ្យទៅប្លន់ក្នុងទីកណ្ដាលនៃព្រះនគរទៀត ។ លុះចោរទាំងឡាយនោះបានធនធានហើយ រួបមកវិញដូចន័យមុនចូលក្រាបទូលទៀតជាគម្រប់ពីរដង ។ ព្រះបាទកោសលរាជក៏នៅមិនទាន់ហ៊ានយាងទៅចាប់ស្ដេចពារាណសីនៅឡើយ ក៏តែងបញ្ជូនពួកចោរឲ្យទៅប្លន់នៅថ្នល់ជាលំដាប់ទៀត លុះព្រះបាទសីលវ-មហារាជ អនុគ្រោះពួកចោរដូចមុនហើយលែងទៅ ចោរទាំង

អម្បាលនោះ ចូលក្រាបទូលទៀតជាគម្រប់បីដង ។ ទើបព្រះបាទកោសលរាជទ្រង់ជ្រាបថា ស្តេចពារាណសីនេះប្រកបដោយធម៌មែនហើយ ។ ស្តេចរៀបនូវពលពាហណទ្រង់ត្រាស់ថា អញចេញទៅនឹងចាប់ស្តេចពារាណសី ហើយយាងចូលទៅកាន់ដែនពារាណសី ។ កាលនោះព្រះបាទសីលវមហារាជព្រះអង្គមានយោធាទាំងឡាយចំនួន ១ ពាន់ ជាសេនាទាហានហ៊ានក្លាមានព្យាយាមរប៉ឹងរឹងរូសឥតភ្លឹក ទោះដំរីបុះប្រែងដេញមកចំពោះមុខក្តី ក៏មិនរញ់រាថយក្រោយ ទោះរន្ទះបាញ់ក្នុងអាកាសធ្លាក់ចុះលើសិរសាក្តី ក៏មិនតក់ស្លុត ទោះព្រះបាទសីលវមហារាជត្រូវការរាជសម្បត្តិក្តី ក៏អាចនឹងចាប់ស្តេចក្នុងសកលជម្ពូទ្វីបថ្វាយក៏បាន ។ យោធាទាំងឡាយនោះលុះដឹងថាព្រះបាទកោសលរាជចូលមកដោយបទអាក្រក់ដូច្នោះហើយ ក៏ចូលទៅយកសេចក្តីក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេពឥឡូវនេះព្រះបាទកោសលរាជរុករានចូលមក ប៉ុនប៉ងនឹងដណ្តើមរាជ-សម្បត្តិរបស់ព្រះអង្គហើយ យើងទាំងឡាយទទួលយកអាសានឹងគម្រាមរាំងឃាត់ស្តេចនោះ កុំឲ្យចូលមកក្នុងសីមារបស់

ព្រះអង្គបានឡើយ ។ ព្រះបាទសីលវមហារាជទ្រង់មានព្រះបន្ទូលថា នែសេនាទាហានទាំងឡាយ កិច្ចដែលនឹងឲ្យគេឯងព្រួយលំបាក ព្រោះតែពីយើងមួយនោះកុំគប្បីមានឡើយ ណ្ហើយបុះថាបើស្តេចកោសលត្រូវការរាជសម្បត្តិ ក៏តាមសព្វព្រះរាជហឫទ័យបុះ (ឥតមានទទឹងទាស់) ។ លំដាប់នោះព្រះបាទកោសលរាជនាំពួកពល កន្លងសីមាចូលមកដល់កណ្ដាលជនបទ ។ យោធាមាត្យទាំងឡាយចូលយកសេចក្ដីក្រាបបង្គំទូលថា នឹងទាំងឃាត់ព្រះបាទសីលវមហារាជ រារាំងហាមឃាត់ដូចមុនទៀត ។ ព្រះបាទកោសលរាជមួយអន្លើដោយពួកពលចូលដល់(ក្បែរជើងកម្ពែង)ហើយទ្រង់បញ្ជូនទូវរាជសារទៅថាស្ដេចពារាណសីច្បាំងនឹងយើង ឬនឹងប្រគល់រាជសម្បត្តិដល់យើង ។ ព្រះបាទសីលវមហារាជតបរាជសារទៅវិញថា កិច្ចដែលច្បាំងផងនោះមិនមានទេ ថាបើព្រះអង្គត្រូវការរាជសម្បត្តិ ក៏ទ្រង់កាន់យកតាមសព្វព្រះរាជហឫទ័យបុះ ។ សេនាមាត្យទាំងឡាយក៏យកសេចក្ដីក្រាបបង្គំទូលថា យើងទាំងឡាយនឹងតស៊ូដេញដោលកំចាត់កំចាយកុំឲ្យស្ដេចកោសលចូលមកក្នុងនគរនេះឡើយ ។ ព្រះបាទសីល-

វិមហារាជទ្រង់ឃាត់ដូចន័យអំពីមុន ព្រះអង្គទ្រង់ឃាត់បរិសទ្យរបស់ព្រះអង្គ មិនឱ្យបិទទ្វារព្រះនគរ ហើយព្រះអង្គទ្រង់គង់លើបល្លង្ក ឰដ៏ល្អធំនាកណ្តាលបំណោមនៃអាមាត្យទាំង ១ ពាន់ ដូចប្រកតីរៀងមក ។ ព្រះបាទកោសលរាជមានពួកពលពោមរោមហើយ ទ្រង់យាងទៅតាមទ្វារចម្ហស្រាប់ ដោយហេតុមិនឃើញមានសត្រូវនឹមួយ ទ្រង់ទតយល់ព្រះបាទសីលវ-មហារាជគង់កណ្តាលរឿនរង់ មានអាមាត្យ ១ ពាន់គាល់បម្រើត្រៀបត្រា ។ ព្រះបាទកោសលរាជបង្គាប់ពលរបស់ព្រះអង្គ ឲ្យចាប់ព្រះបាទសីលវមហារាជ មួយអន្លើដោយរាជាមាត្យទាំង ១ ពាន់ (ជាបុគ្គលឥតទោស) ឲ្យចងមានដើមដៃទៅខាងក្រោយ ទ្រង់បង្គាប់ឲ្យនាំទៅកាន់ព្រៃស្មសាន ដែលគេតែងចោលខ្មោចស្រស់ ឲ្យជីករណ្តៅប្រមាណត្រឹមកឲ្យកប់លុបអាចម៍ដីភ្ជាប់ដៃកុំឲ្យលើកឡើងបាន ចាំដល់កណ្តាលរាត្រី ឆ្កែចចកវាធ្លាប់បរិភោគខ្មោចស្រស់ វានឹងសម្រេចកិច្ចដែលគប្បីសម្រេចដល់បុគ្គលទាំងឡាយនោះ សម័យនោះឯងជនទាំងឡាយក៏ស្ញប់ស្ញែងខ្លបខ្លាចអំណាចនៃព្រះបាទកោសលរាជជាពន្លឹក

លើកព្រះនាមថាស្ដេចបោរ រាជបុរសទាំងឡាយក៏ទទួលធ្វើតាមព្រះអាជ្ញា នាំព្រះបាទសីលវមហារាជនឹងរាជអាមាត្យទៅតាមបង្គាប ។ ព្រះបាទសីលវមហារាជព្រះអង្គទ្រង់ផ្សាយព្រះរាជហឫទ័យមេត្តាគឺ ពុំបងគំនុំគុំគួនដល់ស្ដេចបោរនោះឡើយ ចំណែកឯអាមាត្យទាំង ១ ពាន់ ដែលជាបុគ្គលធ្លាប់រឹងរូសខាហានហានក្លាក្រៃលែង តែក្នុងពេលនោះមិនហ៊ានប្រព្រឹត្តិកន្លងព្រះបន្ទូលនៃស្ដេច (របស់ខ្លួន) សូម្បីតែ ១ មាត់ក៏មិនហ៊ានពោលឡើយ ដោយព្រោះអាមាត្យទាំងអម្បាលនោះ ជាសុរិបោប្រដៅងាយមែនពិត ។ លំដាប់នោះរាជបុរសទាំងឡាយ ដឹករណ្ដោកប់ព្រះបាទសីលវមហារាជត្រង់កណ្ដាល កប់អាមាត្យទាំងឡាយដោយខាងទាំងសងខាង លុបអាចម៍ដីតាមរាជបង្គាប់ហើយចៀសចេញទៅ ។ ព្រះបរមរាជាសីលវទ្រង់មានមធុរកថានឹងពួកអាមាត្យថា នែអ្នកទាំងឡាយចូរចំភាវនាមេត្តាចិត្តចូរកុំធ្វើសេចក្ដីក្រោធខឹងបងគំនុំគុំគួនដល់ស្ដេចបោរនោះឡើយ ទោសទាំងឡាយនេះ ជាទោសវិជ្ជសង្សារពិតប្រាកដព្រះអង្គឲ្យឱវាទយ៉ាងនេះហើយ ព្រះអង្គផ្សាយព្រះរាជហឫ

ទ័យផ្លូវផង់ជ្រិះប្លាត់តកអើ្រកឡើយ ។ លុះដល់ពេលពាក់កណ្តាលនៃរាត្រី នោះសត្វផ្តែបបកទាំងឡាយមានហ្វូងធំ (ធ្លាប់មកបរិភោគខ្មោចស្រស់) ក៏លើកគ្នាវាទាំងហ្វូងចូលមកតាមទម្លាប់ (កាលនោះ) ព្រះរាជាផង រាជអាមាត្យផង លុះជ្រាបថាហ្វូងផ្តែបបកចូលមកជិត ក៏ស្រែកនូវសម្រែកព្រមគ្នា ដោយសម្លេងដ៏ខ្លាំង បណ្តាផ្តែបបកក៏ភ្ញាក់ផ្អើលស្ទុះហោលចេញទៅដល់ក្រឡេកមើលមកខាងក្រោយ មិនឃើញមនុស្សដេញតាមហ្វូងបបកក៏ហោលសារត្រឡប់ចូលមកវិញ ។ អាមាត្យទាំងឡាយមានស្តេចជាដើមស្រែកនូវសម្រែកបំភ្លកជាច្រោះទៀត ហ្វូងផ្តែបបកភ្លកហោលចេញទៅបន្តិច ដឹងថាមិនមានមនុស្សដេញតាមក៏ហោលចូលមកវិញទៀត ព្រះរាជាមួយអន្លើដោយរាជអាមាត្យស្រែកបន្លើល ហ្វូងផ្តែបបកផ្អើលហោលទៅជាគម្រប់ ៣ ដងមិនមានឃើញមនុស្សដេញតាមក្រោយ ពួកផ្តែបបកដឹងជាក់ថាមនុស្សទាំងឡាយនេះជាមនុស្សដល់ហើយនូវទោស ហេតុនោះឮសម្រែកស្រែកបន្លើលក្រោយទៀត ផ្តែបបកទាំងឡាយលែងភ្ញាក់ផ្អើល ផ្តែបបកដែលធំជាងគេ ចូលសំដៅទៅរកព្រះបាទ

សីលវមហារាជ ឆ្កែចចកដ៏សេសក៏ចូលទៅកាន់រាជអាមាត្យទាំងឡាយ ។

ព្រះបាទសីលវមហារាជព្រះអង្គឆ្លាសក្នុងឧបាយ ទ្រង់ជ្រាបថាឆ្កែចចកប្រុងនឹងខាំ ព្រះអង្គងើយព្រះសូរងឡើង ដូចជានឹងឲ្យឱកាសងាយខាំ ។ លុះឆ្កែចចកលោតចូលមកនឹងខាំ ក៏ព្រះអង្គងក់ព្រះកេសបុះ ឆ្កែចចកនោះក៏ជាប់នៅក្រោមបង្កា ដូចជាឃ្នាបគាបជាប់ដោយកម្លាំងដ៏រហ័ស (មួនមាំក្រៃពេក) ។ ឆ្កែចចកនោះពុះជ្រុលខ្លួន ជាប់បំណាប់មិនអាចនឹងស្ទុះបម្រះឲ្យល្បូតរួចទៅបាន ក៏ភិតភ័យខ្លាចសេចក្ដីមរណក៏ស្រែកសម្រែកខ្លាំងក្រៃពេក ។ ហ្វូងឆ្កែចចកដ៏សេសបានឮសម្រែកនោះ គិតថា បុរសចាប់ឆ្កែចចកជាធំនោះជាប់ហើយ ម្លោះហើយមិនហ៊ានចូលទៅជិតរាជអាមាត្យទាំងឡាយនោះឡើយ ភិតភ័យខ្លាចសេចក្ដីស្លាប់ក៏ប្រាសបោលបេញទៅ ។ ឯឆ្កែចចកដែលជាប់ក្នុងឃ្នាបបង្កា ព្រះអង្គគាបខ្សែរសង្កត់សង្កិនមិនបន្ធូរបន្ថយ ក៏ភិតភ័យញាប់ញ័រប្រឹងស្ទុះបម្រះទៅមកជើងទាំងបួនធាក់ក្រាញកកាយដីដែលលុបថ្មី ៗ ស្មើកល្បាញអាចម៍ដីជាគំនរខាងលើ ។ ព្រះបរម-

រាជាក៏បានធូរស្រាលព្រះអង្គបន្តិច ព្រះអង្គទ្រង់ជ្រាបដូច្នោះហើយ ក៏បន្ធូរបន្ថយលែងផ្ដេកបកឡេបទៅ ផ្ដេកបកភិតភ័យប្រាសបោលទៅ (លែងរមិលមើលមកក្រោយ) ។

ព្រះបាទសីលវមហារាជជាបរមពោធិសត្វ ព្រះអង្គទ្រង់រេរម្លៀកប្រែប្រួលចុះឡើង ដោយកម្លាំងដ៏ក្លៀវក្លា ព្រះអង្គដកព្រះហស្ដទាំងសងខាងឡើងបាន ហើយព្រះអង្គប្រឹត្តូវមាត់រណ្ដៅដោយព្រះហស្ដទាំងពីរ ដកព្រះអង្គឡើងពីរណ្ដៅ បីដូចខ្យល់ព្យុះបក់ផាត់កាត់ពលាហកមេឃភ្លៀង ហើយឡើងគង់លើមាត់រណ្ដៅ ព្រះអង្គទ្រង់ស្ដារបាររាជ្យម៍ដ៏ ដកអាមាត្យទាំងឡាយឲ្យរួចឡើងទាំងអស់ អាមាត្យទាំងឡាយមានដង្ហើមធូរហើយសោមនស្សរីករាយចោមរោមព្រះអង្គ នៅក្នុងព្រៃស្មសាននោះ។ សម័យនោះឯងអ្នកស្រុកនាំខ្មោចស្រស់ ១ មកបោះបោលក្នុងព្រៃស្មសាន ត្រង់ព្រំដែនរបស់យក្សពីររូប ។ យក្សទាំងឡាយមិនអាចចែកខ្មោចមនុស្សនោះ (ឲ្យស្មើភាគគ្នាបាន) កើតជាវិវាទគ្នានឹងគ្នាថា បើដូច្នោះគ្នាយើងមកនឹងនាំខ្មោចនេះ ទៅកាន់សម្នាក់ព្រះបាទសីលវមហារាជព្រះអង្គជាស្ដេចទ្រង់ធម៌ ឲ្យចែក

ខោបនេះដល់យើង (ទើបសុខចិត្ត) យក្សពីររូបប្រែតគ្នាចាប់ផើងខោបអួសទៅ ថ្វាយព្រះបរមពោធិសត្វក្រាបទូលថា សូមទានព្រះអង្គទ្រង់ចែកខោបនេះ ស្មើភាគឲ្យទានដល់យើង ។ (កាលនោះ) ព្រះបរមពោធិសត្វទ្រង់មានព្រះបន្ទូលថា ម្នាលយក្សទាំងឡាយ យើងគប្បីចែកខោបនេះដល់ប្រស្នែង (ក៏ប៉ុន្តែថា) ខ្លួនយើងកំពុងស្រះស្រាប់ពាប់មន្ទិលពេកណាស់ យើងបង់ងូតទឹកជម្រះមន្ទិលសិន ។ យក្សទាំងឡាយបានស្តាប់ហើយក៏រលះរលាំងទៅនាំយកទឹកអប់ ដែលស្តេចចោរដម្កល់ទុកដោយកម្លាំងអានុភាពរបស់ខ្លួន មកថ្វាយព្រះអង្គស្រង់ហើយនាំយកនូវសម្ពត់សាដកមកថ្វាយព្រះអង្គផ្លះ ក្នុងកាលស្រង់ទឹករួច ហើយនាំយកនូវគ្រឿងក្រអូបប្រកបដោយបតុជាតិ នឹងគ្រឿងផ្សេង ៗ មានផ្កាភ្ញីជាដើមមកថ្វាយ រួចហើយយក្សទាំងឡាយ ទៅនាំយកក្រយាស្ងោយដ៏មានរសផ្សេង ៗ ដែលស្តេចចោរដម្កល់ទុក មកថ្វាយទ្រង់អង្គសោយរួចហើយ យក្សទាំងឡាយ នាំយកគន្ទីមាសដ៏ពេញដោយទឹកអប់មួយអន្លើដោយផ្តិលមាស ហើយនាំយកនូវភេសជ្ជៈដ៏ប្រកបដោយសុគន្ធជាតិ ៥

យ៉ាង ដែលស្តេចចោរតាក់តែងទុក យកមកថ្វាយព្រះអង្គរួច ស្រេចហើយ ព្រះអង្គទ្រង់ត្រាស់បង្គាប់យក្សឲ្យទៅយកព្រះខាន់ មង្គល នៅលើក្បាលដំណេកនៃស្តេចចោរ ។ យក្សទាំងនោះទៅ នាំព្រះខាន់មង្គលមកថ្វាយហើយ ។ ព្រះអង្គទ្រង់កាន់ព្រះខាន់ ហើយទ្រង់បង្គាប់យក្សទាំងពីររូប ឲ្យលើកខ្មោចនោះបញ្ឈរត្រង់ ព្រះអង្គពុះបំកណ្តាលក្បាលរហូតចុះមកក្រោម ដោយព្រះខាន់ ដ៏មោះមុតជាពីរបំណែក បែកឲ្យយក្សទាំងពីររូប បានភាគស្មើ គ្នាហើយ ។ ព្រះអង្គទ្រង់លាងជូតនូវព្រះខាន់ហើយ ទ្រង់សៀត ព្រះខាន់ហើយទ្រង់ប្រថាប់នៅ ។ ឯយក្សទាំងនោះសោតក៏បរិ-ភោគសាច់ខ្មោចនោះហើយ ត្រេកអរសាទរណាស់ ។ យក្ស ទាំងឡាយយកសេចក្តីក្រាបបង្គំទូលថា បពិត្រព្រះអង្គជាស្តេចធំ យើងខ្ញុំត្រូវធ្វើកិច្ចដទៃដូចម្តេចថ្វាយព្រះអង្គទៀត ។ ព្រះបរម-ពោធិសត្វទ្រង់មានព្រះបញ្ជាថា នែយក្ស បើដូច្នោះចូរអ្នកយក អាសាយើងម្តងចុះ ចូរនាំនូវអាមាត្យទាំងឡាយ ទៅដម្កល់នៅ ក្នុងគេហស្ថានរបស់ខ្លួនរៀងខ្លួន ហើយនាំយើងទៅដម្កល់ ក្នុងដំណេកនៃស្តេចចោរ (ដោយកម្លាំងអានុភាពរបស់អ្នក) ។

យក្សទាំងនោះទទួលថា ប្រពៃណាស់ព្រះអង្គ ហើយយក្សក៏ធ្វើដោយប្រការដូច្នោះក្នុងមួយរម្ពេច ។ ក្នុងសម័យនោះស្តេចចោរកំពុងផ្ទំស្តូលលើសិរិសេយ្យាស ក្នុងល្វែងមានសិរីសួស្តីដ៏ប្រ-ដាប់ហើយ ។

ព្រះបាទសីលវមហារាជព្រះអង្គទ្រង់យល់ ស្តេចចោរផ្ទំលក់ដោយប្រមាទដូច្នោះហើយ ព្រះអង្គទ្រង់ប្រហារត្រង់ឧទរដោយដម្បងនៃព្រះខាន់ ។ ស្តេចចោរភ្ញាក់លើងដឹងស្មារតីទតយល់ស្គាល់ជាក់ជា ព្រះបាទសីលវមហារាជដ៏ជាទីពឹងនៃសត្វលោក ក៏ភិតភ័យហើយស្ទុះប៉ុះបាកក្រឡាបន្ទំ ស្ថិតនៅក្នុងទីទាបហើយក្រាបទូលសួរថាបពិត្រមហារាជទីនេះមានគយល្បាតច្រើនជាន់ច្រើនសង្កាត់ផងមានបន្ទោះវិចិត្រទៅដោយគ្រឿងប្រដាប់ប្រដា ដម្ទើរមហា-រាជស្មៀតព្រះខាន់ហើយទ្រង់យាងមក ដោយទ្វារបិទជិតមិនល្បើក តើព្រះអង្គយាងមកដោយដម្ទើរដូចម្តេចព្រះអង្គ ។ ព្រះប-រមពោធិសត្វទ្រង់បានព្រះបន្ទូលរៀបរាប់តាំងពីដើម រហូតដល់ព្រះអង្គទ្រង់យាងមក ដោយអានុភាពនៃយក្សទាំងឡាយដោយ

សព្វគ្រប់ ។ ស្តេចហោរនោះបានស្តាប់សព្វសេចក្តីហើយ ស្រាប់តែកើតព្រឺព្រួចព្រឺរោមាតក់ស្លុតរន្ធត់ញាប់ញ័រ ក្នុងព្រះហឫទ័យដោយសេចក្តីសង្វេគ ហើយក្រាបទូលថា បពិត្រមហារាជ ខ្ញុំនេះជាតិជាមនុស្សអាឥតសតិបញ្ញាដឹងសេចក្តីខុសត្រូវ ទៅជាមិនដឹងគុណរបស់ព្រះអង្គ ជាតិជាយក្សដែលមានបិត្តរឹងរូស កាចសាហាវអាក្រក់ ទំពាស៊ីតែសាច់ឈាមមានឈាមប្រឡាក់ប្រឡូសនៅដៃ ក៏ទៅជាអ្នកដឹងគុណរបស់ព្រះអង្គវិញ កើតឡើងជាអ្នកជួយទំនុកបម្រុងទៅបាន ហើយលើកប្រណ្ឌូលឡើងនូវព្រះខាន់រាជ្យស្បថស្បែថា បពិត្រមហារាជចាប់ដើមតាំងពីថ្ងៃនេះទៅ ខ្ញុំលែងធ្វើចិត្តទុស្តក្បត់ក្នុងព្រះអង្គ ដ៏ទ្រង់នូវសីលបរិសុទ្ធបរិបូណ៌ មានសភាពយ៉ាងនេះតទៅទៀតហើយ សូមព្រះអង្គអត់ទោសប្រោសប្រណីខ្ញុំ (បើខ្ញុំត្រឡប់ទៅជាទុស្តក្បត់ព្រះអង្គទៀត សូមឲ្យត្រូវនឹងព្រះខាន់រាជ្យនេះឯង) ហើយលើកព្រះបរមពោធិសត្វឲ្យឡើងផ្ទំលើក្រឡាព្រះបន្ទំដ៏ប្រសើរ ឯស្តេចហោរឯងក៏ក្រាបបង្គំនាទីទាប ប្រកបដោយអង្គ ៥ ដរាបដល់រាត្រីស្វាងឡើង លុះព្រះអាទិត្យរះរុងរឿងឡើង ក៏ទ្រង់ឲ្យប៉ាវគងទូងភេរីប្រជុំ

ព្រមនោរាជាមាត្យព្រាហ្មណ៍នឹងគហបតីទាំងឡាយហើយ ព្រះបាទកោសលរាជជាស្តេចហោរទ្រង់ប្រកាសសរសើរគុណសម្បត្តិនៃព្រះបាទសីលវមហារាជ បីដូចជាលើកឡើងនូវមណ្ឌលនៃព្រះចន្ទ្រពេញបូណ៌មីក្នុងកណ្តាលអាកាស ឆាកណ្តាលជំនុំនៃពួកបរិសទ្យហើយ ធ្វើកិច្ចខមាទោសរួចស្រេចប្រគល់នូវរាជសម្បត្តិថ្វាយថា បពិត្រមហារាជសូមព្រះអង្គទ្រង់ទទួលរាជសម្បត្តិសោយជាសុខតរៀងអង្វែងទៅចុះ ចាប់ដើមតាំងពីថ្ងៃនេះទៅបើមានបច្ចាមិត្តឯណាទ្រុស្តក្បត់ព្រះអង្គ នោះទុកជាការលើខ្ញុំទទួលរម្ងាប់ថ្វាយព្រះអង្គជាដរាបទៅ ហើយលើកនូវព្រះអាជ្ញាផ្ចាញ់ផ្ចាល់នៃអាមាត្យដែលពោលពាក្យញុះញង់ហើយ ព្រះបាទកោសលរាជកាន់យកនូវពលពាហណត្រឡប់វិលទៅកាន់ដែនកោសលគង់នៅជាសុខដូចប្រក្រតីរៀងទៅ ។

(លំដាប់នោះ) ព្រះបាទសីលវមហារាជ (កាលព្រះអង្គមានជ័យជំនះបានសុខសាន្តត្រានហើយ) ព្រះអង្គទ្រង់គង់លើបល្ល័ង្កមានជើងវិចិត្រទៅដោយរូបនៃសត្វប៉មា ន៍ហើយទៅដោយមាសឰដ៏ក្រោមស្វេត្រឆត្រ ដ៏ប្រដាប់ដោយគ្រឿងតាក់តែងហើយព្រះ

អង្គទ្រង់រមិលមើលនូវរាជសម្បត្តិរបស់ព្រះអង្គ ហើយទ្រង់ព្រះចិន្តាថា ឱដូចអាត្មាអញគិតទៅអើយ រាជសម្បត្តិក្នុងដែននេះក្តី អាយុជីវិតរបស់រាជអាមាត្យទាំងឡាយនេះក្តី ដែលបានតាំងនៅមានសភាពដូច្នេះនេះ ក៏ព្រោះសេចក្តីព្យាយាមដែលអាត្មាអញមិនបានប៉ុនប៉ងនឹងបន្ធូរបន្ថយចោល រាជសម្បត្តិជាដើមនេះឈ្មោះថាតាំងនៅហើយ ដល់នូវសេចក្តីចម្រើនដោយផលនៃសេចក្តីព្យាយាម គឺសន្សំនូវកុសលធម៌មិនឲ្យដាច់ ទើបសម្រេចនូវប្រយោជន៍នេះដោយបរិបូណ៌ ព្រះបរមពោធិសត្វទ្រង់សម្តែងនូវព្រះគាថានេះ ដូច្នេះថា៖

អាសីសេថេវ បុរិសោ ន និព្វិន្ទេយ្យ បណ្ឌិតោ
បស្សាមិ វោហំ អត្តានំ យថា ឥច្ឆិំ តថា អហុតិ ។

(សេចក្តីថា) បុរសគប្បីប្រាថ្នានូវសេចក្តីព្យាយាមមាំ អ្នកប្រាជ្ញមិនគប្បីបំបាក់បង់នូវសេចក្តីព្យាយាម អញនឹងឃើញប្រយោជន៍របស់ផងខ្លួនពិត អញមានប្រាថ្នាយ៉ាងណាគង់នឹងសម្រេចយ៉ាងនោះមិនឃ្លៀងឃ្លាត ។

ព្រះអង្គទ្រង់មានព្រះបន្ទូលថា អាត្មាអញបានរួចចាក សេចក្ដីទុក្ខលំបាកនេះក៏ដោយកម្លាំងព្យាយាមរបស់ខ្លួន អ្នកប្រាជ្ញទាំងឡាយមិនគប្បីនឿយណាយនូវការព្យាយាមសន្សំ ៗ នោះក៏គង់មានផលទៅខាងនាយ អាត្មាអញនឹងឃើញច្បាស់នូវផលរបស់ខ្លួនក្នុងថ្ងៃនេះ អាត្មាអញបានរួចចាករណ្ដៅគឺបុគ្គលកប់ហើយ ៗ បាននូវរាជសម្បត្តិរបស់ខ្លួនថែមទៀត មានប្រាថ្នាយ៉ាងណាក៏នឹងបានសម្រេចយ៉ាងនោះ ដោយផលព្យាយាមមាំ ។

ព្រះបរមពោធិសត្វព្រះអង្គបន្លឺឡើងនូវសោមនស្សវាចាថា នែអ្នកទាំងឡាយដ៏ចម្រើន ចូរអ្នករាល់គ្នាប្រកបនូវសេចក្ដីព្យាយាមមាំផង ចូររក្សានូវសីលឲ្យបរិសុទ្ធបរិបូណ៌ផង ។

ព្រះបរមលោកុត្តមាចារ្យ នាំមកនូវព្រះធម៌ទេសនានេះហើយ ប្រកាសនូវសច្ចទាំងឡាយសព្វគ្រប់ ភិក្ខុដែលបន្ធូរបន្ថយនូវសេចក្ដីព្យាយាម ក៏បានស្ថិតនៅចំពោះក្នុងព្រះអរហត្តក្នុងកាលជាទីបំផុតនៃសច្ច ។

ព្រះបរមគ្រូទ្រង់សម្ដែងប្រជុំនូវជាតកថា ភិក្ខុទាំងឡាយ អាមាត្យដែលទ្រុស្ដក្បត់ក្នុងកាលនោះ បានមកជាទេវទត្តក្នុងឥឡូវនេះ រាជអាមាត្យទាំងឡាយ ១ ពាន់ក្នុងកាលនោះ បានមកជាពុទ្ធបរិសទ្យក្នុងកាលឥឡូវនេះ ព្រះបាទសីលវមហារាជក្នុងកាលនោះ មិនគឺអ្នកឯណាដទៃឡើយ គឺអង្គអញតថាគតនេះឯងហោង ។

មហាសីលវជាតកំ និដ្ឋិតំ ។

រឿងរ៉ាវទី ៤ នេះខ្ញុំខំប្រែរៀបរៀង ដោយសេចក្តីព្យាយាមសន្សំបន្តិច ៗ ម្តងតាមពេលដែលមានឱកាស ដោយសេចក្តីជ្រះថ្លាធំបំផុតក្នុងគុណសម្បត្តិរបស់ព្រះបរមពោធិសត្វជាម្ចាស់ដែលព្រះអង្គស្វែងរកនូវគុណធំ ព្រះអង្គសន្សំបានព្រះធម៌ ៤ ប្រការ គឺ វិរិយ ខន្តី មេត្តា និងករុណា ទុកក្នុងព្រះរាជហឫទ័យព្រះអង្គ ព្រះធម៌នោះមានគុណខ្ពង់ខ្ពស់ ធ្វើបច្ចាមិត្តក្នុងសង្គ្រាមធំ ឲ្យបាក់បបខ្លបខ្លាចទៅបាន ជាធម៌មានជ័យជំនះដ៏ប្រសើរឧត្តមក្រៃលែង ។ ម្យ៉ាងទៀតព្រះធម៌នេះមានគុណធំវិសេស ព្រោះជាធម៌ដាស់សតិបញ្ញា របស់ខ្ញុំឲ្យភ្ញាក់រឭកដឹងខ្លួនថា អាត្មាជាអ្នកមានគំនិតយល់ផ្ទុយឬទទឹងបាកពុទ្ធាធិប្បាយ ដោយធ្លាប់ឃើញធ្លាប់ឮនិងធ្លាប់ធ្វើខ្លះរួចទៅហើយ ក្នុងកាលដែលមានប្រាថ្នាជ័យជំនះរបស់ខ្លួន នោះតែងអួតអាងរាងកាយកាន់សស្ត្រាវុធ អួតអាងវាចាពោលគម្រាមគម្រាបនឹងអួតអាងចិត្តគិតរិះរកកលឧបាយធ្វើគេឲ្យបាលបាញ់ ការអួតអាងយ៉ាងនេះបុះក្នុងទុច្ចរិតពេញទី ដល់តយុទ្ធគ្នាទៅក៏មិនឃើញមានបាញ់ឈ្នះ ដោយហេតុខ្លួន

ឯងអាងរាងកាយ បច្ចាមិត្តគេក៏អាងរាងកាយស្មើគ្នាដែរ ខ្លួនឯងអាងវាចាពោលសង្កត់សង្កិន គេក៏មានវាចាពោលសង្កត់សង្កិនស្មើគ្នាដែរ ខ្លួនឯងអាងគំនិតគិតរកកលឧបាយផ្ចាញ់ផ្ចាល គេក៏មានគំនិតគិតរកកលឧបាយផ្ចាញ់ផ្ចាលវិញស្មើ ៗ គ្នាដែរ ហេតុនោះហើយទោះតយុទ្ធយ៉ាងណា ក៏ឃើញស្មើ ៗ គ្នាលើសខ្វះបន្តិចបន្តួច ដែលតាំងខ្លួនជាឈ្មះនោះអាស្រ័យដោយអំនួតអួតអាងនោះទេ ។ ដូចព្រះបរមពោធិសត្វដែលព្រះអង្គអាងធម៌មានវីរិយជាដើម ហើយស្តេចចោរចុះចាញ់មានក្នុងរឿងជាតកនេះសព្វគ្រប់ យ៉ាងនេះទើបរាប់ជាឈ្មះពេញបន្ទុកលែងចាញ់វិញ ឥតមានពៀរតទៅទៀតឡើយ សមនឹងសុភាសិតនេះដូច្នេះថា៖

អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ
កទរិយញ្ច ទានេន សច្ចេនាលិកវាទិនំ ។

(សេចក្តីថា) ឈ្នះសេចក្តីក្រោធដោយអំណត់អត់ធន់ ឈ្នះសេចក្តីអាក្រក់ដោយប្រព្រឹត្តត្រឹមត្រូវល្អ ឈ្នះកំណាញ់ដោយឱ្យទ្រព្យរបស់ ឈ្នះពាក្យឡេះឡោះដោយពោលទៀងមែន ។

ចំណែកឯគំនិតផ្ទុយដែលធ្លាប់ឃើញធ្លាប់ឮមក យកឯសេចក្ដីទុច្ចរិតជាគ្រឿងជ័យជំនះទៅវិញ ឈ្នះយ៉ាងនេះមិនល្អទេ នឹងជាប់ជាអាពៀរតទៅមុខ ការឈ្នះហើយជាប់ជាពៀរយ៉ាងនេះ គង់តែនឹងចាញ់វិញក្នុងខាងឆាយ ។

តែងរឿងការនេះសូមបង្រួបតែប៉ុណ្ណោះ ។

### ៣ — ព្រះរាជពិធីចងសំពេងមាស

នៅមានព្រះរាជពិធី ១ យ៉ាងមានលក្ខណៈនិងអាការប្រហែលគ្នានឹងពិធីចងកថាដែលពោលមកហើយ ជាករណីយកិច្ចរបស់ព្រះមហាក្សត្រិយ៍ ១ យ៉ាងហៅថា "ព្រះរាជពិធីចងសំពេង" ។

ដែលហៅថាសំពេងនោះព្រោះគេយកមាសទៅធ្វើឲ្យមានសណ្ឋាន ទ្រង់ទ្រាយដូចផ្លែសំពេង មិនមែនជាមានអាថ៌កំបាំងជ្រៅជ្រះជាងនេះទៅទៀតទេ ហើយធ្វើឲ្យមានប្រហោងសម្រាប់នឹងដោតខ្សែផង មានចំនួន ៥ គ្រាប់ អាចារ្យ-ចារបញ្ចុះមន្តអាគមដូចកូនសង្កត់ ហើយមានខ្សែមាស ១ ខ្សែសម្រាប់ដោតចង ដូចយ៉ាងកូនសង្កត់ ។

ព្រះរាជពិធីនេះសម្រាប់ធ្វើឲ្យស្ត្រី ១ បំពូក គឺក្នុងវេលាដែលព្រះអគ្គមហេសី ឬព្រះស្នំ ទ្រង់គភ៌ មានគភ៌បាន ១-២ ខែហើយ ព្រះករុណាជាអំម្ចាស់ជីវិតលើត្បូង ក៏ត្រាស់បង្គាប់ឲ្យបាត់ធ្វើព្រះរាជពិធីនោះឡើង ។ ហៅភ្នាក់ងារក៏រៀបចំតែង

តាំងអាសនៈនឹងប្រទីបជ្វាលាទៅព្រះទីនាំងឯណានីមួយ ហើយពួកព្រាហ្មណ៍រាជគ្រូក៏និមន្តព្រះពុទ្ធរូបសំខាន់ដែលសម្រាប់ធ្វើពិធី នឹងទេវរូប គឺរូបព្រះឥសូរ ព្រះនារាយណ៍ ព្រះពិឃណេស (ភគណេស) មកប្រតិស្ឋានជាប្រធាននៅគ្រែពិធី ។ វេលាយប់និមន្តព្រះសង្ឃមកចំរើនព្រះបរិត្ត អ្នកសាមីខ្លួនក៏ចេញមកអង្គុយស្តាប់ព្រះបរិត្តក្នុងទីនោះផង ។

ព្រឹកឡើងព្រះករុណា ទ្រង់អង្គាសប្រិយបង្ហាន់សង្ឃក្នុងទីដែលធ្វើពិធីនោះ លុះព្រះសង្ឃឆាន់ហើយ ព្រាហ្មណ៍រាជគ្រូអញ្ជើញអ្នកសាមីខ្លួន មកអង្គុយលើអាសនៈ១ដែលក្រាលដោយសំពត់ស សឹងតាំងនៅចំពោះមុខគ្រែពិធី ព្រះរាជគ្រូបង្វិលពពិល ១៩ ជុំហើយ យកម្សៅក្រអូបដែលគេបំរុងទុកថ្វាយទៅប្រឹម (គឺដៅ) នៅថ្ងាស នឹងបាទដៃទាំងសងខាងនៃអ្នកសាមីខ្លួននោះ រួចហើយព្រះករុណា ទ្រង់ប្រឹម ១ សារទៀតតាមកន្លែងដដែលនោះ ។ លំដាប់នោះព្រះរាជគ្រូលើកយកសំរោងមាសដែលដាក់ក្នុងពានមាស ថ្វាយទៅថ្វាយព្រះករុណាៗទ្រង់ទទួលយកទៅបំពាក់នៅកណ្ដៀ ឬបងនៅបង្កេះនៃអ្នកដែល

មានគភ៌ ខណៈនោះព្រះសង្ឃក៏សូត្រជយន្តោ ដើម្បីសួស្តីជ័យមង្គលដល់អ្នកនោះនឹងបុត្រក្នុងឧទរ ។

ប៉ុណ្ណោះឈ្មោះថាស្រែបព្រះរាជពិធីបង់សំពោងមាស ។

ព្រះរាជពិធីនេះ ពោលដោយប្រយោជន៍នឹងសេចក្តីបំណងក៏ដើម្បីសេចក្តីសុខសម្រាន ប្រាសចាកឧបទ្រពអន្តរាយ ដល់មាតានឹងបុត្រក្នុងឧទរ តែព្រះរាជពិធីនេះ មិនសូវប្រើ ឬមិនប្រើមន្តអាគមដូចពិធីបង់កឋិនរបស់រាស្ត្រ ហើយមានទាំងពិធីសង្ឃលាយផង ដោយហេតុព្រះប្រាជ្ញាញាណទ្រង់ឈ្វេងយល់ដល់ប្រយោជន៍មែនៗផង មិនមែនត្រឹមតែខមអាមប៉ុណ្ណោះ ។

## រឿងព្រេងខ្មែរ

### ១ — (រឿងស្រីមារយាទឥតខ្ទី)

មានបុរសប្តីនឹងប្រពន្ធ នៅក្នុងស្រុក ១ នោះ ឯប្តីនោះជាមនុស្សចិត្តត្រង់តែគ្មានប្រាជ្ញា ឯនាងប្រពន្ធនោះជាស្រីចិត្តមិនទៀងត្រង់នឹងប្តី ហើយមានគំនិតប្រាជ្ញាច្រើន ។

ថ្ងៃ ១ នោះនាងប្រពន្ធមានចិត្តប្រាថ្នា ចង់ជួបនឹងសហាយនោះណាស់ដោយសារឃ្លាតគ្នាយូរហើយ តែមិនដឹងនឹងទៅជួបបានដោយភូមិនោះនៅឆ្ងាយពីគ្នា ព្រោះដើរទៅគេថា ខ្មោចវាលង នាងប្រពន្ធនោះក៏និយាយនឹងប្តីខ្លួនថា អ្នកៗល្ងាចនេះយើងគិតទៅរកទិញមាន់១មកធ្វើស៊ីបានម្តង អ្នកឯងចង់ស៊ីអីហ៎ះ ប្តីតបវិញថា ចង់ស៊ីដែរ នាងប្រពន្ធថា ខ្ញុំចង់ស៊ីខ្ទី ប្តីថាអើ អញក៏ចង់ស៊ីខ្ទីដែរ និយាយគ្នារួចហើយបបួលគ្នាចុះដើរទៅរកទិញមាន់អ្នកស្រុកនៅជិតភូមិសហាយនៅនោះ ប្តីនឹងប្រពន្ធបបួលគ្នាសួររកទិញគ្រប់តែផ្ទះ នាងប្រពន្ធនោះវាមានគំនិតដើរបែកទៅជួបនឹងសហាយវា និយាយកិច្ចកល់ផ្សេងរួចមកជួបនឹងប្តីខ្លួនវិញ ហើយប្រាប់ប្តីថា អ្នក ៗ ផ្ទះឯណោះគេមានមាន់លក់គេប្រាប់ខ្ញុំមិញ ៗ នោះប្តីក៏ព្រមទៅតាមប្រពន្ធប្រាប់ទិញបានមេមាន់ ១

បបួលគ្នាឃ្លរមាន់ត្រឡប់នឹងទៅផ្ទះវិញ ពេលនោះក៏ពន់ព្រលប់ទៅហើយដល់ពាក់កណ្តាលផ្លូវ ស្រាប់តែនាងប្រពន្ធធ្វើមារយា (គក់ជើងទ្រូងម៉ាំង) ថាឱអ្នកអើយភ្លេចដួបគេលត់ទៅហើយ ប្តីសួរថាភ្លេចអី ប្រពន្ធប្រាប់ថា ខ្ញុំភ្លេចខ្ទីទៅហើយអ្នក បើចុះអ្នកឯងនៅៗនេះសិនចុះ ខ្ញុំរត់ទៅវាឆាប់ ហើយនាងនោះរត់ទៅ ប្តីក៏ឈរនៅចាំប្រពន្ធ ឯនាងប្រពន្ធកាលណាឃ្លាតពីប្តីហើយ ក៏គេចទៅជួបនឹងប្រុសសហាយខ្លួន ហេតុតែរឭកសហាយនោះខ្លាំងណាស់ ក៏ប្រាស់ដេកនៅដីមិនរកផ្ទះសំបែងទេ ប្រញាប់ប្រញាល់នឹងទៅជួបឯប្តីវិញ ។

ឯប្រុសសហាយនោះក៏ទទួលភារៈនាងនោះទៅ រួចហើយទើបយកខ្ទីពីសហាយនោះ ហើយផ្តាំថា ល្ងាចឲ្យអ្នកទៅដេកម្តងទៀត ឲ្យអ្នកឯងចាំមើលបើមានពេលស្រួលឲ្យចូលទៅដេកចុះ និយាយកិច្ចការសព្វគ្រប់ហើយ ក៏នាងនោះត្រឡប់មកឯប្តីដើម ឯដីដែលប្រាស់ដេកនោះក៏នៅជាប់នឹងខ្លួនមិនទាន់បោសនៅឡើយទេ ព្រោះដើរមកដោយប្រញាប់ លុះដើរមកដល់ប្តីខ្លួនហើយ ក៏សើចថា ហះហាយៗនិយាយទៅកាន់ប្តីខ្លួន

ថា អ្នក ៗ បើអ្នកឃើញខ្ញុំមិញ ៗ សើចដាច់ខ្យល់ស្លាប់ហើយ ប្តីសួរថា សើចអី នាងប្រពន្ធតបថា នែអ្នកឯងមើលខ្លួនខ្ញុំ បោសឲ្យបន្តិចមក ហ្នឹងហើយខ្ញុំដកខ្ទះទៅវារបូតដៃទាំងអស់ មកខ្ញុំដួលផ្ងារទៅក្រោយ បាស់ជើងប្រោងបានជាប្រឡាក់ខ្លួនខ្ញុំ អស់ ប្តីនោះមិនអាចដឹងក៏បោសខ្លួនឲ្យប្រពន្ធនោះរួចហើយនាំ គ្នាដើរទៅផ្ទះអាត្មា ធ្វើបាយនឹងធ្វើមាន់នោះស៊ី ធ្វើរួចហើយពេល ងងឹតស៊ីបាយរួច នាងប្រពន្ធនិយាយនឹងប្តីថា អ្នកផ្លុំប៉ីទៅខ្ញុំនឹង ស្តាប់ ប្តីយកប៉ីមកផ្លុំ ប្រពន្ធនោះដេកស្តាប់ បន្តិចទៀតក៏កកិល មកដេកលើភ្លៅប្តី ហើយថាពីរោះណាស់អ្នក អ្នកឯងផ្លុំប៉ីភ្នែក មើលរន្ធដែរឬទេ បើអ្នកឯងមិនមើលរន្ធ ធ្វើម៉ិចនឹងចាប់បើក បិទត្រូវនឹងទំនុក ប្តីតបថាទេមិនចាំមើលរន្ធទេ ព្រោះដៃចាំស្ទាត់ ទៅហើយចំណាំរន្ធផង នាងប្រពន្ធថា បើដូច្នោះខ្ញុំបិទភ្នែកអ្នក ឯងទាំងពីរមើល៍ អ្នកឯងនៅតែផ្លុំពីរោះដូចដែលឬទេ ប្តីតបថា បិទប៉ះផ្លុំក៏នៅដដែលដូចមុននោះដែរ រួចនាងប្រពន្ធនោះយកដៃ ទៅបិទភ្នែកប្តីខ្លួនទាំងពីររួចហើយ ក៏កន្តែងជើងឲ្យសហាយ នោះឃើញ ប្រុសសហាយយល់ឃើញសហាយខ្លួនបិទភ្នែកប្តី

បានហើយ កន្ទែងជើងឲ្យឃើញដូច្នោះ ក៏បួលទៅធ្វើការមិនគួរ ដល់រូបនាងសហាយនោះលុះតែរួបទៅ ។

នាងប្រពន្ធនោះលុះសហាយថយបេញទៅ ទើបលែងបិទភ្នែកប្ដី ប្ដីនោះក៏មិនអាចនឹងដឹងដើមអាទ៍សោះ ។

នេះហើយបុរាណលោកថា មារយាស្រីដកខ្វី បេះនិយាយរកពាក្យឲ្យល្មមប្ដីជឿចិត្ត តែគំនិតវាជិតសោះ ។

(ចំនុកកាព្យកាផា)

ស្រីអើយនាងស្រី ស្រស់ទៅដកខ្វី ដកដួលទាំងខ្លួន កាលដកលើកមុន ត្ងបតន់លាក់ពួន ដកក្រោយសំនួន ជូនឲ្យប្ដីស្លាប់ ។ ប្ដីនាងអ្នកផ្ទំ នាងសុំធ្វើក្រាប់ បន្ទរអឹងអាប់ បប់បទអុំទុក ។៚

២ — រឿងលោកសង្ឃមួយអង្គ

មានលោកសង្ឃមួយអង្គ មានកូនសិស្សនោះពីរនាក់ ឈ្មោះអាមោក-អាគាំង,មាន ១ ព្រឹកនោះលោកសង្ឃនោះនិមន្ត ទៅទ្រង់បាត្រជាមួយនឹងលោកឯទៀត អាមោកអាគាំងក៏ទៅជាមួយ លុះទៅដល់ផ្ទះសិកាម្នាក់សស្អាតមេម៉ាយស្លាប់ប្ដីគេក៏ចេញមកដាក់បាត្រលោកហើយគេកាប់ផ្លែបេក ដាក់ក្នុងបាត្រលោក ៗ សង្ឃមួយអង្គដាក់បេក ២ លុះដល់ទៅលោកសង្ឃមួយអង្គនោះនៅក្រោយគេ ហើយនៅសល់បេកនោះបីសិកានោះក៏ដាក់ទៅក្នុងបាត្រលោកនោះ ៗ គិតឃើញថា ហេតុដូចម្ដេចបានជាលោកសង្ឃឯទៀតសិកានេះដាក់តែផ្លែបេកពីរ ដល់មកត្រង់អញដាក់ដល់ទៅបេកបី ប្រហែលជាសិកានេះស្រឡាញ់អញ ហើយគិតដូច្នោះហើយក៏និមន្តទៅកុដិវិញទៅ លុះយប់លោកសង្ឃនោះលួចចុះមកបាត់ មិនឲ្យអាមោកអាគាំងសិស្សទាំងពីរនោះដឹងឡើយ ហើយមកឯផ្ទះសិកាពីថ្ងៃនោះ ទៅដល់ចូលទៅក្រោមផ្ទះ ឆាងនោះអង្គុយនៅខាងក្រៅជិតប្រហោង ១ ហើយអុជបន្ទុសដាក់នៅជិតខ្លួន លោកសង្ឃនោះទៅនៅពីក្រោមផ្ទះហើយ

និយាយទៅនឹងសិកានោះថា ញោមភ្លេបហើយបេកបីពីថ្ងៃនោះ សិកានោះឮហើយនឹកឆ្ងល់ណាស់ លុះគិតយូរបន្តិចទៅទើបដឹងជាលោកសង្ឃនោះស្រឡាញ់ខ្លួនហើយនៅស្ងៀម លោកសង្ឃនោះថាទៀត ញោមភ្លេបហើយបេកបីពីថ្ងៃនោះ ហើយសិកានោះឆ្លើយតបមកវិញ អើតតាមប្រហោងនេះមក លោកសង្ឃក៏ខំអើតជិតទៅ ៗ សិកានោះយកភ្លើងបន្ទុសគប់កណ្ដាលមុខលោកសង្ឃនោះ ៗ ក៏ស្ទុះរត់ទៅកុដិវិញ ទៅដល់ប្រទះនឹងអាមោកអាគាំងជាកូនសិស្ស អាមោកអាគាំងសួរទៅលោកគ្រូនោះថា លោកគ្រូទើបនឹងនិមន្តមកពីណាបានជាខ្មៅហើយជាំមុខអស់ លោកគ្រូឆ្លើយប្រាប់ទៅវិញថា អញទើបនឹងមកពីដើរធុតង្គប្រទះនឹងសត្វឱមាល់ ៗ ដេញទិបហើមមុខអស់ទៅធុតង្គមិនរួចបានជាអញត្រឡប់មកវិញ ។៚—

## ៣ — រឿងអាខិលនឹងអាខ្វប

មានបុរសពីរនាក់ អាម្នាក់ខិលអាម្នាក់ខ្វប តែអាទាំងពីរនាក់នេះមានប្រាជ្ញាស្មើគ្នា អាខិលតាំងធ្វើកំបិតៗតូចខ្លីហើយដាក់ដងធំធ្វើស្រោមនោះវែងប្រវែងស្រោមដាវ ហើយស្ពាយដើរទៅ អាខ្វបនោះតាំងយកដីខ្សាច់ញាត់ពេញពាង ហើយយកប្រហុកទៅពាសស្តើងពីខាងលើហើយលីដើរទៅ អ្នកទាំងពីរលីទៅស្ពាយមកប្រទះគ្នាកណ្តាលផ្លូវ ទើបឯអាខិលក្រឡេកឃើញអាខ្វបតាំងសួរទៅថា បុះអ្នកលីអ្វី អាខ្វបឆ្លើយថា ខ្ញុំលីនេះពាងប្រហុក ទើបអាខ្វបសួរទៅអាខិលវិញថា បុះអ្នកស្ពាយអ្វី អាខិលឆ្លើយថា ខ្ញុំស្ពាយដាវ អាខិលសួរទៅអាខ្វបថា អ្នកចង់ដូរដាវនឹងប្រហុកនេះទេ អាខ្វបថា ដូរក៏ដូរ អ្នកទាំងពីរក៏ព្រមសុខចិត្តដូរទៅវិញទៅមកហើយមានសេចក្តីអំណរស្មើគ្នា អាខិលនឹកថា ដាវអញតូចមួយដូរបានប្រហុក ១ ពាង ទើបឯអាខ្វបវិញនឹកថា ប្រហុកអញសុទ្ធតែដីខ្សាច់មានតែប្រហុកស្តើងបន្តិច ឥឡូវដូរបានដាវមួយនេះវែងយ៉ាងបំណាច់ ប៉ុន្តែអាម្ចាស់ដាវចង់កកាយប្រហុកមើលតែខ្លាចក្រែងគេហូតដាវខ្លួនមើលវិញ អាម្ចាស់ប្រហុក

បង់ហ្វូតដារមើល តែខ្លាចក្រែងគេកកាយប្រហុកខ្លួនមើលវិញ អាទាំងពីរនាក់គិតដូច្នោះហើយក៏ដើរឆ្ងាយពីគ្នាបេញទៅ លុះទៅឆ្ងាយអាម្ចាស់ដារតាំងកកាយប្រហុកនោះមើល ហើយអស់សំណើចថា អានេះប្រាជ្ញាដូចអញដែរ ទើបអាម្ចាស់ប្រហុកតាំងហ្វូតដារមើលឃើញតែកូនកំបិតតូច១ ហើយសើចថា អានេះប្រាជ្ញាដូចអញដែរ អ្នកទាំងពីរប្រាជ្ញាស្មើគ្នា រួចក៏នាំគ្នាដើរទៅផ្ទះរៀងខ្លួន ។

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាឡីនឹងប្រែ) ១ ចប់ចំនួន ១០០ សៀវភៅ. . . . | ថ្លៃ | ២៥០៛,១០ |
| ទស្សនាវដ្ដី. . . . . . . . . . . . . . . . . . . . . . | — | ៤, ០០ |
| សាសនកិច្ចានុក្រម ១២ ខ្សែ . . . . . . . . . . . . . . . | — | ០, ៥០ |
| ដំណាលពុទ្ធចេតិយ. . . . . . . . . . . . . . . . . . . . | ១ សៀវភៅ ថ្លៃ | ១, ៨០ |
| អំពីព្រះពុទ្ធសាសនា. . . . . . . . . . . . . . . . . . | — | ១, ៥០ |
| កច្ចាយនូបត្ថម្ភក ខ្សែ ១. . . . . . . . . . . . . . . . | — | ១, ៣០ |
| " " ខ្សែ ២. . . . . . . . . . . . . . . . . . . . | — | ១, ៤០ |
| អភិធម្មត្ថសង្គហ. . . . . . . . . . . . . . . . . . . | — | ០, ៩០ |
| មិលិន្ទបញ្ហា ខ្សែ ១. . . . . . . . . . . . . . . . . . | — | ០, ៩០ |
| " " ខ្សែ ២. . . . . . . . . . . . . . . . . . . . | — | ០, ៧០ |
| អរិយសច្ចកថា. . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| វុត្តោទយ. . . . . . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| ធម្មបទដ្ឋកថា. . . . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| សុរិយាត្រឡើងស័ក. . . . . . . . . . . . . . . . . . | — | ០, ៦០ |
| សតិបដ្ឋានសុត្ត. . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| មរណានុស្សតិ. . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| បញ្ញាសជាតក. . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| គិហិបដិបត្តិ. . . . . . . . . . . . . . . . . . . . | — | ០, ៤៥ |
| អំពីប្រាសាទនៅអង្គរ. . . . . . . . . . . . . . . . | — | ០, ៣៥ |
| មាតាបិតុឧបដ្ឋាន. . . . . . . . . . . . . . . . . . | — | ០, ៣៥ |
| សិង្គាលោវាទសុត្ត. . . . . . . . . . . . . . . . . | — | ០, ៣០ |
| ទសបារមីកថា. . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សាមណេរវិន័យ. . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| បាដិមោក្ខសង្ខេប. . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សេកសោមបណ្ឌិត. . . . . . . . . . . . . . . . . . | — | ០, ៣០ |
| អំពីព្រះនិព្វាន. . . . . . . . . . . . . . . . . . . | — | ០, ៦០ |
| ១០០ គាថា. . . . . . . . . . . . . . . . . . . . . | — | ០, ២០ |

| | | |
|---|---|---|
| មនោបុព្វកថា | ១ សៀវភៅថ្លៃ | ០, ១៥ |
| ពុទ្ធោវាទានុសាសនី | — | ០, ១៥ |
| កាលាមសុត្តនិងបរាភវសុត្ត | — | ០, ១៥ |
| គតិលោកខ្មែរ ១ | — | ០, ១៥ |
| ច្បាប់ថ្មី | — | ០, ១៥ |
| ពាក្យសក្រាវ ទី ១ | — | ០, ១៥ |
| ״ ״ ២ | — | ០, ១៥ |
| ״ ״ ៣ | — | ០, ១៥ |
| ញាណកថា | - | ០, ១២ |
| សំវេជនីយធម៌ | — | ០, ១២ |
| សីមាវិនិច្ឆ័យ | — | ០, ១០ |
| អនត្តលក្ខណសុត្ត | — | ០, ១០ |
| នាគោបមាទិកថា | — | ០, ០៨ |
| សេចក្ដីផាស់តឿន | — | ០, ០៦ |
| សុរាទោសកថា | — | ០, ០៥ |
| អក្ខទោសកថា | — | ០, ០៥ |
| ព្រះចង្កូមកែវ | — | ០, ១០ |
| ពុទ្ធប្រវត្តិ | — | ០, ០៥ |
| រឿង ៤ ពាន់ ១ យប់ | — | ០, ០៤ |
| បាយាសិរាជញ្ញសុត្ត | — | ០, ០៤ |
| គិរិមានន្ទសុត្ត | — | ០, ០៧ |
| ពាក្យកាព្យក្រមង្វ | — | ០, ០៥ |
| សប្បុរិសធម៌ | — | ០, ០៥ |
| សារទេសនា | — | ០, ០៣ |
| អនុត្តរិយសុត្ត | — | ០, ០២ |
| បុណ្ណោវាទសុត្ត | — | ០, ០២ |
| សត្តបរិត្តនិងទ្វាទសបរិត្ត | — | ០, ៣៥ |
| ធម្មបទីប | — | ០, ៤០ |
| ល្បើកទូន្មានកូនចៅចិន | — | ០, ១៥ |

| | | |
|---|---|---|
| ជ័យវរ្ម័ន ទី ៧ (អក្សរខ្មែរ) . . . . . . . . . . . . . . . . . . | ថ្លៃ | ០រ ២៥ |
| ជ័យវរ្ម័ន ទី ៧ (អក្សរបារាំង) . . . . . . . . . . . . . . . . | — | ០, ៤៥ |
| អត្ថានុសាសនី . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| វិជ្ជាចរណកថា . . . . . . . . . . . . . . . . . . . . . | — | ០, ៣៥ |

## រូបថតពុម្ពផ្សេង ៗ

| | | |
|---|---|---|
| រូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . . . . | ថ្លៃ | ០រ ២៥ |
| " " ក្រដាសទន់ . . . . . . . | — | ០, ០៦ |
| " ព្រះស៊ីសុវត្ថិ . . . . . . . . . . . . . . . . . | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . . . . . | — | ០, ១០ |
| រូបសម្តេចព្រះវររាជជននី . . . . . . . . . . . . . . . . . . | — | ០, ០២ |
| ព្រះពុទ្ធរូបមានអគ្គសាវកអទ (របនាពការ) . . . . . . . . . . . | — | ០, ១៥ |
| ព្រះពុទ្ធរូប និព្វាន . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ៣ ព្រះអង្គ . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ១ ព្រះអង្គ . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក ១ សន្លឹក . . . . . . . . . . . . . | — | ០, ០៦ |
| រូបព្រះពុទ្ធបាទ ១ សន្លឹក . . . . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបព្រះឥន្ទ្រលាសំពត់រៀងពុទ្ធបរិវត្តន៍ . . . . . . . . . . . . . | — | ០, ០៣ |
| ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀង) . . . . . . . . . . . | — | ០, ០៧ |
| ព្រះពុទ្ធរូបបាយ័ន ១៣ សន្លឹក ១ សន្លឹក . . . . . . . . . . . . | — | ០, ០២ |
| រូបគំនូរ តេមិយជាតក ១៣ សន្លឹក . . . . . . . . . . . . . . | — | ០, ១៥ |
| " មហាជនកជាតក ១៣ សន្លឹក . . . . . . . . . . . | — | ០, ១៥ |
| " សុវណ្ណសាមជាតក ១៣ " . . . . . . . . . . . . . | — | ០, ១៥ |
| ប្រក្រតិទិនឆ្នាំថ្មី . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ព្រះពុទ្ធរូបមានព្រះឥន្ទ្រនឹងព្រះព្រហ្មឈរអម . . . . . . . . . . . | — | ០, ០៥ |

ÉCOLE FRANÇAISE
★ BIBLIOTHÈQUE ★

កេរង



INSTITUT
DE CIVILISATION
INDIENNE
N° 10 2625

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMPUCHÉA SURIYA

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំគំរប់ ៧

ខែ ៤, ៥, ៦ រួមគ្នា

ក្រសួងសេនាបតីបានអនុញ្ញាតហើយ

សម្ដេចសង្ឃនាយកទាំងពីរគណយល់ព្រម

PER
933




ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព. ស. ២៤៧៨

គ. ស. ១៩៣៥

1935

ÉCOLE FRANÇAISE
BIBLIOTHÈQUE
D'EXTRÊME ORIENT

# បញ្ជីរឿង

ទំព័រ

១ — អំពីព្រះអង្គម្ចាស់ពេជ្ររ័តន៍ មកទតកិច្ចការរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យ. . . . ៥

២ — អំពីទស្សនាការទីសារនាថ ជាទីសំដែងនិយស្លាករបស់ព្រះពុទ្ធសាសនា ស្រង់យកពីទស្សនាវដ្ដី «មហាពោធិ». . . . . . . . . . . . . . . . . ១១

៣ — សេចក្ដីស្រង់ពីកព្វរលោកអាំងស្ប៉ិកទ័រក្លិតសាលាបឋមវិជ្ជា ក្នុងខេត្តស្រុកត្រាំង អំពីសាលារៀនសម្រាប់ជាតិខ្មែរក្នុងខេត្តនេះ. . . . . . . . . . . ១២

៤ — សាសនប្រវត្តិ បរិច្ឆេទទី ៨ ព្រះមហាពិទូរ ក្រសេម ឧន្លាបនបណ្ឌិតនៅព្រះរាជបណ្ណាល័យរៀបរៀង. . . . . . . . . . . . . . . . . . ២១

៥ — រឿងទំនៀមទំលាប់ខ្មែរ-វិធីសម្រាលកូន. . . . . . . . . . . . . . . . ៤៥

៦ — រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយៈ

១ — រឿងតាចាន់រំលោក, ឃុនអក្ខរាឯក អធិប្បាយ. . . . . . . . . . . ៥៣

២ — រឿងប្លែកនៅស្រុកកំពង់ធំ កាលពីឆ្នាំ១៩០៥. . . . . . . . . . . ៦២

## រូបផ្តិតពុម្ពៈ

ព្រះអង្គម្ចាស់ពេជ្ររ័តន៍ ព្រមទាំងកុងស៊ីយសេនាបតី នឹងនាហ្មឺនបារាំងសែស. ៥

## រូបជនក្រៅរឿង

ភ្ញោងទ្វារប្រាសាទបន្ទាយស្រីឆ្លាក់រឿងមហាភារត ១ កន្លែងអសុរបងប្អូនពីរនាក់ សុន្ទនឹងឧបសុន្ទ ច្បាំងគ្នាដណ្ដើមនាងអប្សរឈ្មោះតិលោត្តមា. . . . . . ១៩

# TABLE DES MATIÈRES

I. Visite de S. E. le Tiao Phetsarat, Président de l'Institut bouddhique de Vientiane, à l'Institut Bouddhique de Phnôm-Penh.................... 5

II. Une Visite du vice-Roi des Indes anglaises et du Mahārāja de Bénarès à Sarnath grand lieu de pélérinage bouddhique....................... 11

III. Extrait du rapport de l'Inspecteur des Écoles primaires de Soctrang sur les Écoles Cambodgiennes de cette Province.............................. 12

IV. Sāsanapravatti ou Histoire des religions, par Préas mahā pitou Krasém, pandit à la Bibliothèque Royale.................................... 21

V. Les coutumes Cambodgiennes — De l'accouchement........................ 45

VI. Contes populaires Cambodgiens inédits:

1° Ruong Tachan romléak, recueilli par Khun Akkhara Ek du service des Annales au Palais royal...... 53

II° Ce qui se passait mystérieusement à Kompong-Thom en 1905.............................. 62

## ILLUSTRATIONS:

S. E. le Tiao Phetsarat au milieu des ministres..... 5

Hors texte représentant une épisode de mahā Bhārata sur le fronton de Prasat Bantéai Sréi, probablement la scène entre les deux frères asuras, Sunda et Upasunda qui se disputent L'Apsara tilottamā...... 19



## ព្រះអង្គម្ចាស់ពេជ្ររ័តន៍

### ស្ដេចមកកាន់មន្ទីរពុទ្ធសាសនបណ្ឌិត្យ

កាលថ្ងៃ ១៦ ខែម៉ារ្ស ឆ្នាំ ១៩៣៥ នេះ ព្រះអង្គម្ចាស់ពេជ្ររ័តន៍ អធិបតីពុទ្ធសាសនបណ្ឌិត្យប្រទេសលាវ ស្ដេចមកឋានពុទ្ធសាសនបណ្ឌិត្យកម្ពុជានេះ ដើម្បីនឹងបានពិនិត្យមើលកិច្ចការដែលក្រុមនេះបានធ្វើរួចទៅហើយដូចម្ដេចខ្លះ នឹងមានរបៀបរៀបរយដូចម្ដេចខ្លះ នឹងបានកាន់យកជាតួយ៉ាងទៅធ្វើតាម ព្រោះក្រុមពុទ្ធសាសនបណ្ឌិត្យនៅប្រទេសលាវនោះ ទើបនឹងបង្កើតឲ្យមានឡើងក្នុងកាលគ្រិស្ដសករាជ ១៩៣២ នេះឯង ។ វេលានោះក្រុមពុទ្ធសាសនបណ្ឌិត្យ បានរៀបទទួលដោយសមគួរតាមខត្តិយស័ក្តិ ។

ដល់ម៉ោង ៤ ខ្វះ ១៥ មីនុត បណ្ដាអស់លោកសេនាបតី នឹងអស់លោកចៅក្រសួងផ្សេង ៗ គឺៈ

សម្ដេចក្រុមព្រះវរចក្ររណរិទ្ធ អធិបតីក្រុមពុទ្ធសាសន-បណ្ឌិត្យ សម្ដេចចៅហ្វាវាំង សេនាបតី ក្រសួងព្រះបរមរាជវាំង ក្រុមហ្លួងស៊ីសុវត្ថិសុភាណុវង្ស សេនាបតី ក្រសួងសិក្សាធិការ

លោកអ្នកឧកញ៉ាអគ្គមហាសេនា សេនាបតី ក្រសួងមហាផៃធម្មការ លោកអ្នកឧកញ៉ាយោមរាជ សេនាបតី ក្រសួងយុត្តិធម៌ លោកអគ្គលេខាធិការ ក្រុមពុទ្ធសាសនបណ្ឌិត្យ លោកវ៉ារូហ៍ ដេឡេគេ លោក បាប់ទិស កុងត្រូលើរ៍ នឹងគណសង្ឃក្រុមប្រែព្រះត្រៃបិដក នឹងគ្រូបង្រៀនសាលាបាឡី មានព្រះតេជព្រះគុណព្រះសិរីសម្មតិវង្សជាប្រធាន ព្រមទាំងព្រះសង្ឃជាតិលាវជាកូនសិស្សសាលាបាឡីផង រួមទាំងអស់ប្រមាណ ៥០ រូបបានស្ដេចយាងមកអញ្ជើញមកនិមន្តមកជួបជុំព្រមនៅមន្ទីរពុទ្ធ-សាសនបណ្ឌិត្យ ។ លុះដល់ម៉ោង ៤ គត់ព្រះអង្គម្ចាស់ពេជ្ររ័តន៍ស្ដេចយាងមកដោយរថយន្ត លោកអគ្គលេខាធិការឱ្យអ្នករាជ-ការក្រុមព្រះរាជបណ្ណាល័យ គឺព្រះសោភណភាសិត ១ ព្រះមហាពិទូរ ១ ក្រុម្ការ វ៉ែ-ប៊ុក ១ ព្រះលេខានុវត្រ ១ បានចុះទៅទទួលអញ្ជើញស្ដេចចូលទៅក្នុងមន្ទីរពុទ្ធសាសនបណ្ឌិត្យ ជួបជុំដោយព្រះរាជវង្សនឹងបណ្ដាអស់លោកដែលពោលហើយ ទ្រង់គំនាប់នឹងថ្វាយគំនាប់គ្នាទៅវិញទៅមកសព្វគ្រប់ហើយ សម្ដេចក្រុម

ព្រះវរបក្ររណាវិទ្ធ ស្ដេចយាងតាំទៅគង់នៅព្រះទីនាំងកៅអីដែលរៀបបម្រុងទុក នៅបន្ទប់ធំខាងលិច ។

### រឿងការដែលព្រះអង្គម្ចាស់ពេជ្ររ័តន៍មក

ខណៈនោះលោកអគ្គលេខាធិការ ក្រោកឡើងថ្លែងហេតុដែលព្រះអង្គម្ចាស់ពេជ្ររ័តន៍ស្ដេចយាងមកក្នុងគ្រានេះថា ព្រះអង្គម្ចាស់ពេជ្ររ័តន៍នេះជាអធិបតី ក្រុមពុទ្ធសាសនបណ្ឌិត្យក្រុងប្រទេសលាវ ការដែលស្ដេចយាងមកនេះ សូម្បីជាការលំបាកដល់ព្រះអង្គ ដោយផ្លូវឆ្ងាយក៏ពិត តែស្ដេចឧស្សាហ៍យាងមកដើម្បីនឹងជួបជុំដោយអស់លោកក្រុមជំនុំ ក្រុមពុទ្ធសាសនបណ្ឌិត្យ ហើយនឹងបានពិនិត្យមើលកិច្ចការរបស់ក្រុមពុទ្ធសាសនបណ្ឌិត្យកម្ពុជានេះឲ្យដឹងថា បានធ្វើអ្វីបានខ្លះរួចទៅហើយនឹងមានរបៀបផែនដូចម្ដេចខ្លះ ដើម្បីនឹងបានកត់សំគាល់យកជាតួយ៉ាង ហើយយកវិធីនោះទៅបាត់រៀបបំពុទ្ធសាសនបណ្ឌិត្យនៅប្រទេសលាវ ការដែលស្ដេចយាងមកនេះមិនមែនមានប្រយោជន៍តែត្រង់ដែលទ្រង់បំណាងប៉ុណ្ណោះទេ នៅមានប្រយោជន៍

មួយយ៉ាងទៀត គឺជាបំណងសម្រាប់បងប្រទេសកម្ពុជានឹងប្រទេសលាវឲ្យទាក់ទងជាប់ជាស្ពានមេត្រីនៃគ្នានឹងគ្នា ដោយហេតុបានបែករំលែកផ្ទេរបំណេះវិជ្ជាឲ្យគ្នាទៅវិញទៅមក ។

### សុន្ទរកថារបស់លោកគ្រូព្រះភិរីសម្មតិវង្ស

អាត្មាភាពទាំងពួងមានសេចក្ដីសោមនស្សដ៏ក្រៃពេក ក្នុងការដែលស្ដេចឧស្សាហ៍យាងមក ដើម្បីនឹងបានត្រួតមើលរបៀបបែបផែននៃក្រុមពុទ្ធសាសនបណ្ឌិត្យកម្ពុជា ១នេះជាគ្រឿងពិសោធ្យឲ្យឃើញថា ដំណាតទៅ ប្រទេសកម្ពុជានឹងប្រទេសលាវរមែងមានបំណងទាក់ទាមគ្នា ដោយមន្ទីរពុទ្ធសាសនបណ្ឌិត្យនឹងសាលាបាឡីជាមូលជាការជួយផ្ដល់គ្នា ឲ្យបានដំណើរឡើងទៅកាន់សេចក្ដីចំរើន ។ ក្នុងរវាងមិនយូរប៉ុន្មានមុននេះប្រទេសលាវក៏បានបង្កើតឲ្យមានសាលាព្រះរាជបណ្ណាល័យនឹងមន្ទីរពុទ្ធសាសនបណ្ឌិត្យឡើង រាប់ថាបានឈានទៅកាន់សេចក្ដីចំរើនដោយជំហានដ៏វែងណាស់ដែរ នេះក៏មិនគឺដោយហេតុដទៃ ដោយហេតុដែលបានជួយផ្ដល់គ្នាក្នុងផ្លូវបំណេះវិជ្ជានោះឯង

នឹងដោយគុណបុណ្យរបស់រាជការប្រូតិកតូរាត់ មេត្តាប្រោសទំនុកបម្រុងឲ្យមានឡើង ។

១ ទៀតសូមថ្វាយព្រះពរទ្រង់ព្រះករុណាសូមទ្រង់ជ្រាបថា សាលាបាឡីជាន់ខ្ពស់នៅក្រុងភ្នំពេញនេះ ទៅឆ្នាំមុខនឹងបង្កើតឲ្យមានរៀនអក្សរថៃ (គឺអក្សរលាវ) ផង ១ បំណែកទៀត ដើម្បីជាគ្រឿងប្រដាប់សតិបញ្ញារបស់សិស្សតទៅ ។

ព្រះសុន្ទរកថារបស់ព្រះអង្គម្ចាស់ពេជ្ររ័តន៍

ខ្ញុំព្រះករុណាជាដំណាងក្រុមពុទ្ធសាសនបណ្ឌិត្យ ប្រទេសលាវ មកនេះបំពោះមកកាន់មន្ទីរពុទ្ធសាសនបណ្ឌិត្យ ដោយកិច្ចដើម្បីពិនិត្យមើលការងារបំពូកខ្លះរបស់មន្ទីរនេះ ដែលខ្ញុំនៅមិនទាន់អស់អញក្នុងចិត្ត មកដល់វេលានេះ ខ្ញុំបានទទួលសេចក្ដីបដិសណ្ឋារយ៉ាងខ្ពស់គួរជ្រះថ្លា ហេតុនេះខ្ញុំសូមអំណរគុណព្រះករុណាគ្រប់អង្គ នឹងអំណរព្រះតេជព្រះគុណសម្ដេចក្រុមព្រះវរបក្ររណរិទ្ធ អធិបតីពុទ្ធសាសនបណ្ឌិត្យ នឹងអស់

លោកសេនាបតី មានសម្តេចចៅហ្វាជាដើម និងអ្នកស្រីការ ប៉ុន្មែរ្បស យ៉ាងខ្ពស់ ។

ក៏ហេតុដែលខ្ញុំមកនេះ ឬហេតុដែលប្រទេសលាវនឹងប្រ-ទេសកម្ពុជាមានផ្លូវទាក់ទងជាសម្ពន្ធមិត្រមេត្រីនឹងគ្នានោះ មកពីហេតុដែលរាជការប្រតិកត្តរាត់មេត្តាទំនុកបម្រុងបង្កើតឲ្យមានក្រុមពុទ្ធសាសនបណ្ឌិត្យ ៗ នេះឯងជាខ្សែស្រឡាប់បងប្រទេសទាំងពីរឲ្យសាមគ្គីនឹងគ្នា ហើយជាគ្រឿងសួយប្រទេសទាំងពីរឲ្យត្រកាលឡើង ។

១ ទៀតដែលលោកគ្រូបាងហ្វាងសាលាបាឡីបា ទៅឆ្នាំមុខនឹងថែមវិជ្ជាអក្សរបាំឲ្យកូនសិស្សសាលាបាឡីរៀន ១បំណែកទៀតនោះជាការប្រសើរណាស់ ព្រោះបាអក្សរបាំនោះលោកបានចារិកគម្ពីរធម៌ក្បួនខ្នាតជាច្រើនយ៉ាង បើយើងចេះអក្សរនោះហើយនឹងមានផ្លូវស្រាវជ្រាវរកបំណោះវិជ្ជា ក្នុងអក្សរនោះបានខ្លះ បើមិនច្រើនក៏តិច ហេតុនេះឃើញថា គួរសមនឹងរៀនណាស់ ។

ប៉ុណ្ណោះហើយលើក ។

## អំពីទស្សនាគារនៃសារនាថ

(ប្រែចេញពីទស្សនាវដ្ដី មហាពោធិ)

កាលពីថ្ងៃអង្គារ ១៦ យ៉ាំងវីយេរ ១៩៣៤ ស្ដេចអនុរាជអាំងក្លេសដែលឈរកាន់កាប់ការរាជការក្នុងស្រុកឥណ្ឌៀបំណុះអាំងក្លេស បានអញ្ជើញទៅទស្សនាគារ មូលគន្ធកុដិវិហារនៅទីសារនាថមួយអន្លើដោយព្រះអគ្គទេវី ហើយមានមហារាជនៅក្រុងពារាណសីស្ដេចជូនទៅផង ។

ក្នុងវេលានោះពួកភិក្ខុសង្ឃលង្កា, ភូមានឹងឥណ្ឌាបានឈរបំនៅទីជណ្ដើរព្រះវិហារ, វេលាដែលបានដោះសុពណ៌បាទចេញទុកនៅទីខាងក្រៅជាស្រេចហើយ ក្សត្រទាំង ៣ អង្គក៏យាងចូលទៅក្នុងទីព្រះវិហារ-ទីអាសនៈក្នុងព្រះវិហារក៏រៀបចំប្រដាប់ដោយប្រទីបទៀនភ្លឺប្រិះ នឹងប្រដាប់ដោយបុប្ផាមាលាដេរដាស ។

ឯក្សត្រទាំង ៣ ព្រះអង្គ ក៏យាងចូលទៅបំពោះព្រះភក្ត្រព្រះពុទ្ធរូប- ក្នុងវេលានោះពួកភិក្ខុសង្ឃក៏តាំងសូត្រធម៌ជាភាសាបាឡីព្រម ៗ គ្នា លុះចប់ធម៌ហើយ បានថ្វាយផ្កា ៣ សំណុំទៅក្សត្រទាំងបីអង្គ ៗ ក៏ទ្រង់កាន់ចូលទៅធ្វើពុទ្ធបូជានៅទីដំកល់ព្រះពុទ្ធរូប ។

ឯប្រអប់ដំកល់ព្រះសារីរិកធាតុ ដែលស្តេចអនុរាជនេះបានប្រគេនមកពីឆ្នាំ ១៩៣១ ដើម្បីធ្វើបុណ្យឆ្លងព្រះវិហារក៏បានបើកគ្របឡើងក្នុងវេលានោះដើម្បីឲ្យឃើញនូវព្រះសារីរិកធាតុដែលជាព្រះសារីរិកធាតុយ៉ាងពិតប្រាកដ របស់ព្រះសម្មាសម្ពុទ្ធបរម-គ្រូ រកឃើញក្នុងព្រះស្តូបចេតិយ៍ ១ ដែលព្រះបាទកនិស្កបានកសាងនៅក្រុងតក្កសិលា កាលពីក្នុង ព.ស. ៦២២ ឆ្នាំ ។

សេចក្តីស្រង់ពីភក្ត្រ លោកអាំងស្ប៉ិកទ័រ ត្រួតសាលាបឋមវិជ្ជា ក្នុងខែត្រស្រុកត្រាំង អំពីសាលាសម្រាប់ជាតិខ្មែរ.............................

.........................................

យើងមានភ័ព្វយ៉ាងប្រសើរ ដោយកាលពីក្នុងខែដេសម ១៩៣៣ បានលោកគ្រូព្រះសាសនសោភ័ណ ណាត ជាងហ្វាងវងសាលាបាឡីជាន់ខ្ពស់និមន្តទៅកាន់ទីនោះ លោកគ្រូអង្គនេះជាអ្នកប្រាជ្ញយ៉ាងធំខាងភាសាបាឡី ហើយពូកែរៀងវ៉ែខាងផ្លូវបង្រៀន លោកចេះភាសាបារាំងដោយច្បាស់លាស់ ខ្ញុំបានសូមឲ្យលោកឲ្យដំបូន្មានដល់គ្រូដែលត្រូវបង្រៀនវិជ្ជាបា-

ឡី ហើយក្នុងវេលានោះលោកក៏ពេញព្រះទ័យ នឹងអធិប្បាយ ហើយពន្យល់ជាបែបបង្រៀននៅមុខសិស្សយើងទាំងអស់ ។ លុះលោកយកសៀវភៅសិស្សទាំងអស់មកពិនិត្យមើល លោកសំគាល់ឃើញថា បែបភាពបង្រៀនរបស់លោក ដែលជាគ្រូបង្រៀនរបស់យើងនោះ ខ្សោយពេកណាស់ មានបែបបង្រៀនវេយ្យាករណ៍ជាដើម ។ លោកបាងហ្វាងរងសាលាបាឡីក៏សំដៅយកត្រង់ "លិង្គ" មកអធិប្បាយ (ព្រោះភាសាបាឡីមានលិង្គដូចភាសាបារាំងយើងដែរ) ហើយលោកទាញឧទាហរណ៍ជាបាឡីនឹងជាបារាំងមកពន្យល់ ក្នុងវេលានោះខ្ញុំឃើញច្បាស់ថាលោកអ្នកប្រាជ្ញធំនេះបង្រៀនតាមរបៀបសម័យថ្មី ។ លោកមិនបានលោក់នឹងខ្ញុំទេ អំពីដែលលោកសង្ឃគ្រូបង្រៀនរបស់យើងមានបំណេះបាឡីទន់ខ្សោយ ហើយលោកបានសន្យានឹងខ្ញុំថាដល់ឆ្នាំមុខលោកនឹងបញ្ជូនលោកសង្ឃប្រាជ្ញ ១ អង្គមកឲ្យគង់នៅវត្ត ញាំឡាង ។

## អំពីអ្នកស្រីការប៉ឺឡែស អគ្គលេខាធិការពុទ្ធ-សាសនបណ្ឌិត្យទស្សនាការខេត្រស្រុកត្រាំង

អ្នកស្រីការប៉ឺឡែស បានអញ្ជើញទៅទស្សនាការខេត្រស្រុកត្រាំង ជាមួយនឹងលោកគ្រូព្រះសាសនសោភ័ណ ណាត បាង ប៉្យាងវងសាលាបាឡី កាលពីក្នុងខែដើសមមុនបានអញ្ជើញចូលមើលវត្តជាច្រើន ក្នុងខែត្រនេះ ហើយបានប្រារព្ធនឹងខ្ញុំថា អ្នកស្រីមានសេចក្ដីសោមនស្សណាស់ អំពីដែលពិនិត្យឃើញសេចក្ដីចំរើនកើតឡើង ក្នុងសាលាវត្តដែលរាជការជួយផ្គត់ផ្គង់ការស៍ក្សាតាំងពីក្នុងរវាង ១៨ ខែហើយ ។ ការដែលលោកអ្នកប្រាជ្ញយ៉ាងធំក្នុងស្រុកខ្មែរដែលមាននាមល្បីខ្ចរខ្ចាយដល់កូសាំងស៊ីន បាននិមន្តមកពិនិត្យវត្តអារាមនេះជាមានប្រយោជន៍យ៉ាងសំខាន់ណាស់ ។ អ្នកស្រីការប៉ឺឡែសនឹងលោកគ្រូព្រះសាសនសោភ័ណបានឃើញច្បាស់អំពីចិត្តគំនិតរបស់អ្នកស្រុក អំពីដែលសាលារៀបចំទទួល នឹងអំពីសេចក្ដីខ្វល់ខ្វាយរបស់ឧបាសកឧបាសិកា ។ បានសម្ដែងធម៌ទេសនាក្នុងវត្តធំៗ ទាំងឡាយ ហើយភិក្ខុសង្ឃដែលទទួលដំណឹងទាំងប៉ុន្មាន

និមន្តមកកាន់ទីប្រជុំស្ទើរតែគ្រប់អង្គ ។ ខ្ញុំបានទៅស្ដាប់ធម៌ទេសនា ១ កន្លែង ដែលសម្ដែងនៅទីវត្តញាំឡាង ។ គ្រូបង្រៀនខ្មែរនឹងសិស្សទាំងអស់ក៏មកស្ដាប់ក្នុងទីនោះ ។ ក្នុងរវាង ២ ម៉ោងលោកបានញ៉ាំងបរិសទ្យទាំងអស់ឲ្យផ្ចិតផ្ចង់ត្រងត្រាប់ស្ដាប់រសព្រះសទ្ធម្មដែលលោកសម្ដែងយ៉ាងបែបធួររហុយដោយសំឡេងស្រទន់ហើយពីរោះក្បោះក្បាយពេញជាអ្នកមេរោហារ ១ ។ លោកបានសម្ដែងផ្ដើមអំពីកិច្ចការដែលក្រុងបារាំងសែសបានធ្វើដើម្បីជួយស្រោចស្រង់យោងសតិបញ្ញាជាតិខ្មែរឡើងដោយគប់នៅក្នុងគំនរសេចក្ដីល្ងង់ដែលជាមេអន្តរាយយ៉ាងធំ ។ លោកបានសម្ដែងការពារដល់បរិសទ្យទាំងអស់អំពីដែលមានពាក្យគរហោនិន្ទាដល់ការជាកុសល ហើយលោកឲ្យដំបូន្មានឲ្យតាំងសមាគមនឹងគ្នាព្រមព្រៀងមូលបិត្តគំនិត តាមលំអានព្រះពុទ្ធសាសនាដែលមានសេចក្ដីទូន្មានឲ្យស្រឡាញ់គ្នាទៅវិញទៅមក ។ លោកបានប្រារព្ធនឹងលោកចៅអធិការទាំងអស់ហើយថ្លែងសេចក្ដីសង្ឃឹម សង្ឃឹមដើម្បីឲ្យបានសេចក្ដីសុខកើតមានដល់អ្នកបួសនឹងអ្នកដែលសឹកទៅហើយដែលធ្វើជាគ្រូបង្រៀន

ក្នុងទីវត្ត គឺលោកបង់បំបាត់រឿងរ៉ាវដែលកើតមានឡើងថា ពួកគ្រូបង្រៀនយើងមានប្រាជ្ញានឹងដកយកអំណាចខ្លះអំពីលោកនឹងសេចក្ដីគោរពរាប់អានដែលឧបាសកឧបាសិកា អាពុកម្ដាយសិស្សគណនឹងខ្លួនសិស្សគណ ដែលធ្លាប់មានដល់លោក ។

"សូមកុំឲ្យយល់ថា ការប្រែព្រះត្រៃបិដក មកជាភាសាខ្មែរ ជាការនាំឲ្យសាបរលាបដល់ព្រះពុទ្ធសាសនាឡើយ" មានមនុស្សតិចណាស់ដែលចេះភាសាបាឡី ហើយអ្នកឯណាដែលបានសិក្សាភាសានេះដោយជ្រៅជ្រះ ទើបអាចនឹងយល់សំដីរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ។អ្នកឯណាដែលជាអ្នកប្រទុស្តរាយហើយនិត្យាដល់ការបំរើនដល់ការសិក្សា អ្នកនោះឯងជាខ្មែរអាក្រក់ ជាខ្មែរពាល ។ សំដីដែលលោកគ្រូបាងហ្វាងរងសាលាបាឡីបាទពោលនេះ នាំឲ្យអ្នកស្ដាប់ទាំងអស់ភ្ញាក់ខ្លួនយ៉ាងខ្លាំង ។ លោកអ្នកប្រាជ្ញធំ ជាអ្នកគាំពារការសិក្សាសាលាវត្តដែលរាជការរៀបចំនេះ បានធ្វើការដ៏មានប្រយោជន៍ធំក្នុងស្រុកកូសាំងស៊ីន ។ វេលាដែលចប់សេចក្ដីអធិប្បាយហើយ បានចែកសៀវភៅនឹងរូបថតពុម្ពដល់កូនសិស្ស ហើយអ្នកស្រីការប៉ុឡែសបានធ្វើ

អំណោយដល់ហោសៀវភៅសម្រាប់សាលា សៀវភៅបាឡី-ខ្មែរ ១ក្បាល ដែលព្រះរាជបណ្ណាល័យផ្សាយ ពោះពុទ្ធនៅរោង ពុម្ពភាក្ដារប្រេតិកតួភាគ៌ ជាការស្នាដៃរបស់ពួកអាចារ្យសាលាបាឡីទាំងអស់ គឺជាសៀវភៅព្រះត្រៃបិដកខ្មែរ ១ ដែលលោកប៉ូលរេយណូទ៍សេនាបតីក្រសួងប្រទេសរាជ បានបេញប្រាក់ពោះពុម្ព ដើម្បីឱ្យឃើញជាភស្ដុតាង ដល់ប្រយោជន៍ដែលរាជ្ការក្រុងបារាំងសែស នាំឱ្យមកបណ្ដាជនខ្មែរ ។

អ្នកស្រីការប៉ុឡែសឱ្យដំណឹងថា អំណើសតទៅលោកសង្ឃដែលត្រូវបញ្ជូនទៅរៀននៅវត្តលង្កា ត្រូវធ្វើសេចក្ដីសញ្ញាដោយលិខិតថា នឹងនៅក្នុងភេទជាសង្ឃកំណត់៥ឆ្នាំ ។ ប្រសិនបើយើងបានគិតឱ្យបុះសញ្ញា៥ឆ្នាំឬក៏ ១០ ឆ្នាំដូច្នេះតាំងពីដំបូងនោះប្រហែលជាយើងចៀសផុតអំពីសេចក្ដីបំរូងបំរះ ដែលកើតមានឡើងដល់លោកសង្ឃខ្លះនឹងអ្នកដែលសឹកទៅ ។អ្នកស្រីការប៉ុឡែសបានបន្ថែមថា បំពោះនឹងភ្នែកសាធារណជន នោះអ្នកដែលសឹកទៅមិនជាមានដំឡៃ ដូចកាលនៅភេទជាសង្ឃឡើយ ហើយគេមិនគិតដល់ការស្លៀកដណ្ដប់ជាន់មុននោះទេ ។

. . . . . . . . . . . . . . . . . . . . . . . . . . .



នេះជាសុំទ្វារប្រាសាទបន្ទាយស្រី មានរចនារឿងមហាភារត ប្រហែលជាត្រង់អសុរបងប្អូនពីរនាក់ ឈ្មោះសុន្ទ ១ ឧបសុន្ទ ១ ច្បាំងគ្នាដណ្តើមយកនាងអប្សរឈ្មោះតិលោត្តមា ។

# បរិច្ឆេទទី ៨

# ព្រហ្មញ្ញសាសនា

# បរិច្ឆេទទី ៨

ប្រទេសកម្ពុជាជាប្រទេសដែលបានទទួលរាប់អានសាសនាផ្សេង ៗ គឺព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា ទាំងលទ្ធិថេរវាទ ទាំងលទ្ធិអាចារិយវាទ មកតាំងអំពីសម័យព្រេងនាយ ។

ដើមកំណើតនៃព្រហ្មញ្ញសាសនាក្តី នៃព្រះពុទ្ធសាសនាក្តី កើតឡើងក្នុងមជ្ឈិមប្រទេសឯណោះ លុះបំណោរកាលយូរមក ទើបបានផ្សាយមកដល់ប្រទេសកម្ពុជាយើង តែនឹងឲ្យដឹងជាប្រាកដថា សាសនាណាផ្សាយមកមុន សាសនាណាផ្សាយមកក្រោយ ពីពុទ្ធសករាជប៉ុន្មាន ៗ នោះពេញទើសទាល់ ព្រោះគ្មានចារិកលិខិតទុកជាសំគាល់ឲ្យជាក់ស្តែង ។ តែទោះបីម្លឹងក៏មិនផុតវិស័យនៃសតិបញ្ញារបស់មនុស្សសោះតែម្តង គឺនៅមានបុរាណវត្ថុក្នុងសាសនានោះ ៗ នឹងសិលាចារិក ព្រមទាំងរឿងផ្សេង ៗ មានព្រះរាជពង្សាវតារជាដើម ល្មមនាំយកមកពិចារណាហើយធ្វើសេចក្តីសន្និដ្ឋានតាមអនុរូបដូចមានតទៅនេះ ។

## លើកដំបូង

### ព្រហ្មញ្ញសាសនា

សម័យក្រោយពុទ្ធកាលមិនយូរប៉ុន្មាន ជនជាតិខេមរនេះ បាននាំគ្នាចុះមកអំពីប្រទេសតិព្វេ មកតាំងភូមិលំនៅ ៗ ក្នុងដែនប្រទេសសុវណ្ណភូមិ គឺតាំងអំពីប្រទេសមន ចុះរៀងមកដល់ជ្រោយមលៃយូ នឹងស្រុកស្រីវិជ័យ (គឺមឿងនគរបឋមរបស់សៀមសព្វថ្ងៃនេះ) ជាដំបូង លុះនៅយូរទៅ កាលដឹងកន្លែងដែលជាទីទំនេរទៅក្នុងទីដទៃទៀត ក៏នាំគ្នាឆ្លងទន្លេស្ទឹង (ដែលសៀមហៅម៉ែណាំចៅព្រះយ៉ា) មកតាំងភូមិលំនៅក្នុងត្រើយខាងកើតនៃទន្លេនោះ រៀងរាយមកដល់ប្រទេសកម្ពុជាក្នុងវេលានេះ ។

គ្រានោះ ប្រទេសកម្ពុជាគង់មានព្រះមហាក្សត្រិយ៍ដ៏ទ្រង់នូវព្រះតេជានុភាពជាះប្រិនអង្គ ទើបអាចរាតព្រះរាជអាណាចក្រឲ្យធំទូលាយបាន កាលផ្សាយអាណាខេត្តទៅដល់ណា ក៏អាចបាត់ការគ្រប់គ្រងឲ្យនៅក្នុងអំណាចនឹងសាសនារបស់ខ្លួន ត្រឹម

នោះ ក៏បណ្ដាខ្មែរក្នុងសម័យនោះ ទាំងស្ដេចទាំងរាស្ដ្រ អ្នកខ្លះកាន់សាសនាព្រាហ្មណ៍ អ្នកខ្លះកាន់ព្រះពុទ្ធសាសនា ដោយហេតុនេះ ទើបឃើញមានបូរាណវត្ថុ ទាំងជារបស់ក្នុងសាសនាព្រាហ្មណ៍ ទាំងជារបស់ក្នុងសាសនាព្រះពុទ្ធ មាននៅក្នុងទីត្រើយខាងលិចនឹងទីត្រើយខាងកើតនៃទន្លេរស្លុជាច្រើនណាស់ណា របស់អំបាលនោះដឹងបានជាប្រាកដថា សុទ្ធតែស្នាដៃរបស់ខ្មែរដែលមកពីឥណ្ឌៀសាង មិនតែប៉ុណ្ណោះ សូម្បីអក្សរនឹងភាសាដែលចារិកក្នុងជាន់នោះ ក៏ជារបស់ខ្មែរដើមទាំងអស់ ។

១ដែលថា ខ្មែរយើងកាន់សាសនាព្រាហ្មណ៍មកមុននោះ ដោយអាស្រ័យគោល ២ ប្រការ គឺ ១– ប្រទេសឥណ្ឌៀជាដែនកើតសាសនាព្រាហ្មណ៍មុនសាសនាដទៃ ៗ ហើយបានផ្សាយរាយទៅក្នុងដែនឥណ្ឌៀ អ្នកនគរទាំងអស់សុទ្ធតែធ្លាប់រាប់អានសាសនានោះមកហើយ វេលាដែលខ្មែរបុះពីឥណ្ឌៀមកនៅក្នុងប្រទេសកម្ពុជានេះ ក៏ដោយទាំងសាសនាព្រាហ្មណ៍នោះមកផង ឬនឹងថា ដោយទាំងព្រះពុទ្ធសាសនាមកព្រមជាមួយគ្នាក៏ថាបាន តែសាសនាព្រាហ្មណ៍ជាទី ១ សាសនាព្រះពុទ្ធ

ជាទី ២ ។ ២ — សង្កេតមើលបុរាណវត្ថុដែលសាងក្នុងប្រទេសកម្ពុជានេះ ឃើញរបស់ចាស់ ៗ ច្រើនតែជារបស់ក្នុងសាសនាព្រាហ្មណ៍ ដូច្នេះទើបថា "សាសនាព្រាហ្មណ៍ផ្សាយមកក្នុងប្រទេសកម្ពុជានេះមុនសាសនាដទៃ ៗ" ។

ក៏វត្ថុអ្វីខ្លះដែលរាប់ថាជាវត្ថុក្នុងសាសនាព្រាហ្មណ៍ គឺស្ថានទីដែលហៅថា "អគ្គ" សឹងមានទូទៅក្នុងប្រទេសកម្ពុជាដូចយ៉ាងអង្គតាសោម អង្គរកា អង្គខ្ជាយ ជាដើម និងប្រាង្គណ៍ប្រាសាទ ដូចយ៉ាងព្រះប្រាង្គណ៍នាងខ្មៅ នៅក្នុងខណ្ឌបាទីព្រះប្រាង្គណ៍ នៅទន្លេបាទី និងព្រះប្រាង្គណ៍ក្រវ៉ន ព្រះប្រាង្គណ៍មេបុណ្យ ព្រះប្រាង្គណ៍វិមានអាកាស នៅក្នុងខេត្តសៀមរាប ព្រះប្រាង្គណ៍ភិមបុរ នៅស្រុកភិមាយជាដើម និងប្រាសាទហេមាទ្រិ ប្រាសាទយសោធរេស្វរ ប្រាសាទនគរវត្តជាដើម និងរូបព្រះព្រហ្ម រូបព្រះឥស្វរ រូបព្រះនារាយណ៍ រូបសិវលិង្គ រូបទេពជុំនុំ រូបព្រះគណេស អំបាលនេះជាដើមសឹងមានដេរដាសនៅក្នុងដែនកម្ពុជា រាប់ថាជាវត្ថុក្នុងសាសនាព្រាហ្មណ៍ ។ តែក្នុងវេលានោះមិនមែនមានសុទ្ធតែសាសនាព្រាហ្មណ៍ ព្រះពុទ្ធសា-

សនា ក៏បានផ្សាយមកដល់ហើយដែរ តែប្រហែលជាមិនសូវរុង
រឿងណាស់ ដូចជានឹងមានពោលក្នុងបរិច្ឆេទតទៅឯមុខ ។
ព្រះមហាក្សត្រិយ៍ខ្មែរអំពីបូរាណច្រើនកាន់ព្រហ្មញ្ញសាសនា តែ
មានអង្គខ្លះរាប់អានទាំងព្រហ្មញ្ញសាសនា ទាំងពុទ្ធសាសនាដូច
យ៉ាងព្រះបាទសម្ដេចព្រះយសោវរ្ម័ន ទ្រង់សាងប្រាសាទយ-
សោធរេស្វរឧទ្ទិស្សថ្វាយក្នុងព្រហ្មញ្ញសាសនា ទ្រង់សាងវត្តសុ-
គតអាស្រម ឬហៅថា វត្តទេពប្រណម្យឧទ្ទិស្សថ្វាយក្នុងពុទ្ធ-
សាសនា ។ ព្រះបាទសម្ដេចព្រះរាជេន្ទ្រវរ្ម័ន (ទី ២) ទ្រង់
សាងប្រាង្គណ៍មេរុបុណ្យ ឧទ្ទិស្សថ្វាយក្នុងព្រហ្មញ្ញសាសនា
ទ្រង់សាងប្រាសាទបន្ទាយកុដី ឧទ្ទិស្សថ្វាយក្នុងពុទ្ធសាសនា
អំបាលនេះជាដើមជាតួយ៉ាង ។

យោបល់ដែលកាន់ព្រហ្មញ្ញសាសនា ដោយប្រាថ្នាសេចក្ដី
រុងរឿងក្នុងលោកនេះ ព្រោះការប្រតិបត្តិក្នុងព្រហ្មញ្ញសាសនា
ច្រើនឲ្យប្រយោជន៍រុងរឿងក្នុងផ្លូវគតិលោក ការប្រតិបត្តិក្នុង
ពុទ្ធសាសនាច្រើនឲ្យប្រយោជន៍រុងរឿងក្នុងផ្លូវគតិធម៌ ដ្បិតគតិ
ព្រហ្មញ្ញសាសនាច្រើនប្រដៅក្នុងផ្លូវសាស្ត្រាគម គឺវេទ មន្ត

អាគម គាថាឲ្យទៅជាអ្នកខ្លាំងពូកែឡើង ជាប្រយោជន៍ដល់ការការពាររក្សាខ្លួននឹងស្រុកទេសផង គតិពុទ្ធសាសនាប្រដៅតែក្នុងផ្លូវធម្មបដិបត្តិ ។ សាសនាទាំងពីរនេះមិនជាសត្រូវគ្នាដោយត្រង់តែម្តង ហេតុនោះ ខ្មែរយើងទើបកាន់ទាំងពីរយ៉ាងមកជាមួយគ្នា កាលផុតរាជវង្សវរម័នមកហើយ ប្រមាណពី ព.ស. ១៧០០ មកសាសនាព្រាហ្មណ៍ក៏អាប់ឱនចុះដោយលំដាប់ ព្រោះខ្មែរយើងបោះបង់ចោល ត្រឡប់ទៅរាប់អានព្រះពុទ្ធសាសនាបែបលង្កាជាជំនួសសាសនាចាស់នោះ នឹងព្រះពុទ្ធសាសនាលទ្ធិអាចរិយវាទក៏អាប់ឱន តែមិនសាបសូន្យរលីងតែម្តង សូម្បីសព្វថ្ងៃនេះក៏នៅមានអ្នកខ្លះកាន់លាយឡំគ្នានឹងព្រះពុទ្ធសាសនា ក៏សាសនានោះមានក្រិសែប្រតិបត្តិនឹងប្រកបដោយយោបល់ដូចម្តេចខ្លះ គប្បីជ្រាបដូចមានតទៅនេះ៖ —

ក្នុងបូរាណសម័យ ព្រហ្មញ្ញសាសនាឧប្បត្តិឡើងក្នុងជម្ពូទ្វីបជាសាសនាចាស់កើតឡើងក្នុងលោកនេះមុនគេទាំងអស់ ដែលហៅដូច្នេះដោយអធិប្បាយថា សាសនារបស់ព្រះព្រហ្ម ឬ

សាសនាតមកអំពីព្រះព្រហ្ម ។ ពួកព្រាហ្មណ៍ជាអ្នកកាន់កាប់ និងប្រតិបត្តិតាមសាសនានេះ ហេតុនោះពួកយើងទើបហៅថា សាសនាព្រាហ្មណ ។

មនុស្សក្រុងសម័យនោះ យកចិត្តទុកដាក់ក្នុងវិជ្ជាធម៌ច្រើន ឧស្សាហ៍ត្រិះរិះជ្រៀតជ្រែករកធម៌វិធម៌ទៅផ្សេង ៗ ទើបទៅជា មនុស្សមេទិដ្ឋិ ប្រារព្ធសេចក្តីកើត សេចក្តីស្លាប់ និងប្រារព្ធសុខ ទុក្ខផ្សេង ៗ គ្នា បំព្រួញបុះគង់នៅជា ២ យ៉ាង គឺកាន់ថា ស្លាប់ ហើយកើតក៏មាន ស្លាប់ហើយសូណ្យក៏មាន ។ ក្នុងពួកដែល កាន់ថា ស្លាប់ហើយកើតវិញ ពួកខ្លះយល់ថា ធ្លាប់កើតជាអ្វី ក៏ កើតតែយ៉ាងនោះគង់ទី មិនប្រែប្រួលទៅកើតក្នុងកំណើតដទៃ ពួកខ្លះយល់ថា កើតហើយអាចចុតិប្រែប្រួលក្លាយជាតិទៅ ផ្សេង ៗ បានមិនមានខិតខាន់ ។ ក្នុងពួកដែលកាន់ថា ស្លាប់ ហើយសូណ្យ ពួកខ្លះយល់ថា សូណ្យដោយប្រការទាំងពួង ពួកខ្លះយល់ថា សូណ្យតែដោយយ៉ាង មិនសូណ្យទាំងអស់ ។

ពួកដែលយល់ឃើញថា ស្លាប់ហើយកើតវិញ យល់ថា ប្រព្រឹត្តដួចម្តេច នឹងអំណោយវិបាកឲ្យទៅកើតក្នុងសួគ៌និងសុគតិ

ក៏ប្រព្រឹត្តយ៉ាងនោះ ដើម្បីនឹងបង្កើនជាតិរបស់ខ្លួនឲ្យខ្ពស់ឡើង ឲ្យបានសេចក្ដីសុខកើន ៗ ឡើងទៅ ។ ពួកអ្នកដែលយល់ឃើញថា ស្លាប់ហើយសូន្យនោះ នឹងប្រព្រឹត្តអ្វីក៏ប្រព្រឹត្តឲ្យតែរួចខ្លួនក្នុងបច្ចុប្បន្ន មិនតោងខ្លាចដល់សេចក្ដីកើតក្នុងនរកឬទុគតិ អស់ផ្លូវប្រាថ្នានឹងឲ្យទៅកើតជាអ្វីទៀត ។

ពួកខ្លះកាន់ថា សត្វទាំងឡាយនឹងបានសុខឬទុក្ខ បានឯង សុខទុក្ខគ្មានហេតុគ្មានបច្ច័យ ។ អ្នកខ្លះកាន់ថា សុខទុក្ខមានមកព្រោះហេតុបច្ច័យ ។ ក្នុងពួកដែលកាន់ថា សត្វនឹងបានសុខឬទុក្ខ បានឯង សុខទុក្ខគ្មានហេតុគ្មានបច្ច័យ ក៏មិនខ្វល់ខ្វាយនឹងកសាងបុណ្យកុសល រង់ចាំតែពេលសុខឬទុក្ខនឹងមានមកកាលណា ក៏ទទួលសោយកាលនោះទៅ ។ ពួកដែលកាន់ថា សុខទុក្ខមានមកព្រោះហេតុបច្ច័យនោះញែកចេញជា ២ ពួក គឺពួកខ្លះឃើញថា សុខទុក្ខមានមកព្រោះហេតុបច្ច័យខាងក្រៅ មានទេវតាជាដើមជាអ្នកបណ្ដាលឲ្យ ។ ពួកខ្លះឃើញថា សុខទុក្ខមានមកហេតុបច្ច័យខាងក្នុងគឺ កម្ម ។ ឯពួកដែលកាន់ថា សុខទុក្ខមានមកព្រោះហេតុបច្ច័យ តែជាហេតុបច្ច័យខាងក្រៅ

ក៏បួងសួងបន់ស្រន់ទេវតាសុំឲ្យជួយខ្លះ ខ្វល់ខ្វាយក្នុងផ្លូវដទៃខ្លះ តាមដែលឃើញថា ផ្លូវណានឹងបៀសផុតទុក្ខ បានប្រសពសុខ ក៏ធ្វើទៅយ៉ាងនោះ ។ ពួកដែលកាន់ថា សុខទុក្ខមានមក ព្រោះហេតុបច្ច័យ គឺ កម្ម ឃើញថា កម្មណាជាហេតុនៃទុក្ខ ក៏លះវៀរកម្មនោះបង់មិនធ្វើ ឃើញថា កម្មណាជាហេតុនៃសុខ ក៏ធ្វើកម្មនោះ ប្រព្រឹត្តកាយវាចាចិត្តតាមសេចក្ដីឃើញរបស់ខ្លួន នឹងដឹកនាំអ្នកដទៃឲ្យប្រព្រឹត្តតាមយ៉ាងនោះ ។

ក្នុងសម័យមុនពុទ្ធកាលជាអង្វែងឆ្នាំ ក្នុងរឿងមហាភារត[១] នឹងគម្ពីរឫគវេទរបស់ព្រាហ្មណ៍សំដែងថា ក្នុងជាន់ដំបូងមានមនុស្សជាតិមួយពួកហៅថា កវារិកីរ ឬហៅថា ទមិឡ តាំងភូមិលំនៅ ៗ ក្នុងជម្ពូទ្វីបភាគបស្ចិម កាន់លទ្ធិសាសនា ១ យ៉ាង គឺ គោរពបូជាផែនដី ភ្នំ សត្វមានពិស្មដែលអាស្រ័យនៅក្នុងរន្ធដី មានសត្វនាគជាដើម យកជាសរណទីពឹងដោយប្ញលចិត្តថា ផែនដី ភ្នំ ជាមាតាបិតារបស់សត្វទាំងពួង សព្វសារពើអ្វី ៗ រមែងកើតអំពីដីនឹងភ្នំទាំងអស់ ជា

១ រឿងមហាភារតកើតឡើងមុនពុទ្ធកាល ៨០០ ឆ្នាំ ។

របស់សក្តិសិទ្ធិវិសេស ១ យ៉ាង សម្បីតែសត្វពិពួកខ្លះដែលអាស្រ័យនៅក្នុងរន្ធដីមានពស់នាគជាដើម ក៏មានពិស្មពន្លកមុកគួរស្ញែង គេទើបនាំគ្នាគោរពបូជា ។ តែពាក្យថា "នាគ" ជាពាក្យសម្រាប់ហៅ វត្ថុ សត្វ នឹងមនុស្សដែលជាទីគោរពរាប់-អានទូទៅ ហេតុដូច្នោះគេទើបបញ្ញត្តិហៅលទ្ធិនេះថា "សាសនានាគ" ហៅប្រទេសនីមួយ ៗ ថា "នគរ" ក៏ក្លាយមកពីពាក្យថានាគនេះឯង ហៅអ្នកគ្រងផែនដីនីមួយ ៗ ថា ឫស្យ-ឫឫវី ឬ-រាម-រាម វេលាក្រោយមកក្លាយជា "រាជា" សឹងប្រែថា ដី ៗ ឬអ្នកគ្រប់គ្រងដីដូចគ្នាគ្រប់សព្វ ។

មានលទ្ធិ ១ យ៉ាងទៀត ប្រាកដឡើងក្នុងសម័យដែលពួកទមិឡ ឬមិឡក្ខផ្សាយចុះមកកាន់ជម្ពូទ្វីបភាគខាងកើត ក្នុងកាលមុនដែលពួកអរិយកចុះមក ពួកទមិឡផ្សាយចុះមកមិនយូរប៉ុន្មាន មានជនជាតិ ១ ហៅថា កោឡារី បានផ្សាយឡើងទៅអំពីទ្វីបខាងកើត ទៅបានជាធំលើពួកទមិឡ ពួកនេះរាប់អានលទ្ធិផ្សេងអំពីពួកទមិឡ គឺរាប់អានដើមឈើ នឹងសត្វផ្សេង ៗ ដោយបូលបិត្តថា មនុស្សទាំងពួងយកកំណើតអំពីព្រឹក្សាជាតិ

ផ្សេង ៗ នឹងអំពីសត្វផ្សេង ៗ ។ ក្នុងអធិសម្ភារវៃឫគវេទពោលថា ពួកភារតកើតអំពីដើមជ្រៃ, ពួកកោរពកើតអំពីអណ្តើក, ពួកឥ-រាវ័តកើតអំពីដំរី, ពួកកម្ពោជកើតអំពីគោ, ពួកគន្ធារកើតអំពីសេះ ពួកកុសិកើតអំពីហង្ស, នាងអម្ពិកា អគ្គមហេសីព្រះបាទវិចិត្រវិរ័យ អ្នកគ្រងក្រុងហស្តិនបុរី កើតអំពីផ្លែស្វាយ, ព្រះកមលឫសីរើសបាននាងបទុមាវតីអំពីផ្កាឈូក អំពាលនេះជាតួយ៉ាង ។

សម័យនោះប្រាកដមានលទ្ធិមួយយ៉ាងទៀត រាប់អានបូជាព្រះចន្ទ្រព្រះអាទិត្យ មានក្នុងប្រទេសសុសៈ ប្រទេសអា-សិរី ប្រទេសសីមែត៍ ប្រទេសបាបីឡោន៍ ក្នុងរជ្ជសម័យក្សត្រិយ៍សិប្រឳរទាគ គ្រប់គ្រងនគរកាស្យបបុរី ឬហៅរាជបុតន បានទ្រង់សាងវិហារព្រះចន្ទ្រនៅដំបន់ស្រុកមុខេរ សាងវិហារព្រះអាទិត្យនៅដំបន់ស្រុកលារ័ស ក្នុងកាលមុនគ្រិស្តសករាជ ៤៧០០ ឆ្នាំ ប្រមាណជាមុនពុទ្ធកាល ៤១៥៧ ឆ្នាំ មានកំណត់វេលាធ្វើពលិកម្មនមស្សការព្រះចន្ទ្រ នៅថ្ងៃព្រះចន្ទ្រសោយកត្តិកឫក្សពួកអ្នកស្រុករាជបុតន ឬសោមបុណ៌សិរិរៀបពិធីយ៉ាងអឹកធឹកជាទីសប្បាយជ្រើមជ្រួលទូទៅទាំងព្រះនគរ ថ្ងៃនមស្សការជា

ធម្មតា គឺថ្ងៃទីបំផុតនៃប័ក្សខាងរនោច ថ្ងៃទីបំផុតនៃប័ក្សខាងខ្នើត នឹងថ្ងៃពាក់កណ្ដាលប័ក្ស រាល់ៗខែទៅ ។

វេលាក្រោយមក អ្នកតែងគម្ពីរទក្សញាណបានតែងកែរឿងព្រះចន្ទ្រទៅជាព្រះ ៣៣ អង្គ គឺរាប់យកព្រះចន្ទ្រ ១ ហៅថា បុសករនាគ ឬបិត្រង្គទ, រាប់យកផ្កាយឫក្ស ២៧ ហៅថា រុទ្រ ឬមារុត ន៍យមួយទៀតហៅថា នក្សត្រ ២៧, រាប់យកផ្កាយព្រះគ្រោះហ៍ ៥ គឺផ្កាយព្រះសៅរ ហៅថា បក្សភទ្រនាគ ឬសង្គហរ ១ ផ្កាយព្រះសុក្រ ហៅថា ករកោដនាគ ឬមហាបឋម ១ ផ្កាយព្រះអង្គារហៅថា បុសករព្រាហ្មណ ឬតក្សក ១ ផ្កាយព្រះពុធហៅថា ធព្រិហស្ដ ឬការកោដ ១ ផ្កាយព្រះព្រហស្បត៍ហៅថា ឯលាបត្រ ឬបឋម ១ ព្រះគ្រោះហ៍ ៥ នេះហៅថា បញ្ចនាគា ។ ព្រះចន្ទ្រ ១ ផ្កាយនក្សត្រ ២៧ ព្រះគ្រោះហ៍ ៥ សិរិរួមជាព្រះ ៣៣ អង្គ ក្នុងគតិដែលរាប់អានព្រះចន្ទ្រ ។

វេលាក្រោយមកទៀត អែតរេយ្យព្រាហ្មណបានចាត់បង្រិមព្រះ ៣៣ អង្គនោះជា ៣ ពួក ក្នុងមួយពួក ១១ អង្គ ។ ពាក្យថា "៣ ពួក" ក្នុងទីនេះគេអធិប្បាយទៅថា

បានដឹង ដី, អាកាស, មេឃ, ហើយចាកចេញទៅមួយជាន់ទៀត ជារដូវ ៣ គឺ ១ វស្សកាល រដូវភ្លៀង, ២ សីតកាល រដូវត្រជាក់, ៣ ឧស្ណកាល រដូវក្ដៅ ។

ជួនកាលពួកឥណ្ឌៀខាងលើរាប់ថា សារទ រដូវភ្លៀង, ហិម រដូវត្រជាក់, សម រដូវក្ដៅ ។ ក្នុងរដូវមួយ ៗ មាននក្សត្រ ៩ មានព្រះគ្រោះហ៍ ២ គឺក្នុងរដូវត្រជាក់ជានាទីព្រះសៅរ៍នឹងព្រះសុក្រ រដូវក្ដៅជានាទីព្រះបន្ទ្រនឹងព្រះអង្គារ រដូវភ្លៀងជានាទីព្រះពុធនឹងព្រះព្រហស្បត៍ ។

លុះកាលកន្លងមកទៀត វរាហមហិរព្រាហ្មណបានតែងកែរដូវ ៣ ទៅជារដូវ ៦ តាមអង្គព្រះគ្រោះហ៍ គឺតាំងដើមរដូវក្នុងរដូវត្រជាក់ជានាទីព្រះសៅរ រដូវទី ២ ជានាទីព្រះសុក្រ រដូវទី ៣ ជានាទីព្រះអង្គារ រដូវទី ៤ ជានាទីព្រះបន្ទ្រ រដូវទី ៥ ជានាទីព្រះពុធ រដូវទី៦ជានាទីព្រះព្រហស្បត៍ ។ តាំងដើមឆ្នាំក្នុងរដូវត្រជាក់គឺក្នុងខែមិគសិរ តាមវិធីបន្ទ្រគតិ (ខ្មែរយើងរាប់ខែមិគសិរ ជាលេខ ១ អំពីដើមដោយកាន់តាមបន្ទ្រគតិនេះ) ។ វិធីរាប់ថ្ងៃ ខែ ឆ្នាំ ក្នុងសម័យនោះ បែងថ្ងៃជា ៧ គឺ អាទិត្យ ១

បន្ទ្រ ១ នឹងបញ្ចនាគា ៥ ត្រូវជាថ្ងៃ ៧ រួមហៅថា សប្តនាគា ឬសត្តនាគា ។ ខែមាន ១៣ ក្នុង ១ ខែ ២៨ ថ្ងៃ ដោយកំណត់យកតាមកាលឫក្ស ២៧ នឹងព្រះចន្ទ្រ១ ត្រូវជាថ្ងៃ ២៨ ។ ហេតុនោះក្នុងសម័យក្រោយមក ពួកព្រាហ្មណ៍ទើបតែងធៀបថា ព្រះទក្ស (បុត្រព្រះព្រហ្ម) លើកធីតា ២៧ អង្គឲ្យជាភរិយាព្រះសោម លើកធីតា ១៣ អង្គទៀតឲ្យជាភរិយាព្រះកាស្យបដ៏ជាបុត្រព្រះមារិចិ សឹងជាដើមពន្ធុវង្សរបស់ឥណ្ឌៀ ។ បើនឹងអធិប្បាយទៅក៏ជាសេចក្តីធៀបឬសម្មតិ គឺកាលឫក្ស ២៧ គេសម្មតិជានាង ២៧ អង្គ ខែឬរាសី ១៣ គេសម្មតិជានាង ១៣ អង្គ ដោយហេតុកាលឫក្សនឹងរាសីអំបាលនេះជាបរិវារហែហមអមព្រះចន្ទ្រដូចដែលយើងធ្លាប់ដឹងស្រាប់ហើយ គេទើបសម្មតិឲ្យទៅជាជាប្តីប្រពន្ធគ្នាតែម្តងទៅ ។

ក្នុងជាន់ដើមក្នុងវិហារព្រះចន្ទ្រ គ្មានរូបភាពអ្វីជាគ្រឿងសំគាល់មានតែវិហារទទេ ៗ យ៉ាងវិហារបាមផ្កាក្នុងស្រុកយើងសព្វថ្ងៃនេះ មកនាកាលសម័យមួយនោះ ក្សត្រិយ៍ទ្រង់នាម សិរអគ្គមហេសី នាម ឧមា ជាឱរសព្រះបាទឧសីនរនឹងនាងមាទរី

ត្រង់នគរហៃហយប៉ុរី ជាត្រកូលអ្នកបិញ្ចឹមគោ បានស្តេចទៅនមស្សការព្រះចន្ទ្រ តែមិនឃើញរូបព្រះចន្ទ្រនៅក្នុងវិហារនោះ ទើបត្រាស់ឲ្យសាងរូបព្រះចន្ទ្រដោយសិលា ដំកល់លើសសរថ្ម ប្រតិស្ឋានទុកកណ្តាលវិហារ រូបព្រះចន្ទ្រនោះគេហៅថា សោមនាថ(១) ន័យថាមានសណ្ឋានដូចរូបលិង្គ ។

ឯពួកអ្នករាប់អានព្រះអាទិត្យ កំណត់វេលាធ្វើពលីកម្មឬនមស្សការព្រះអាទិត្យ ក្នុងថ្ងៃដែលព្រះអាទិត្យឡើងកាន់មេសរាសី គឺក្នុងខែចែត្រ មានពិធីលៀងលោមអាហារគ្នាដូចយ៉ាងពិធីនមស្សការព្រះចន្ទ្រ នមស្សការជាធម្មតាក្នុង ៧ ថ្ងៃម្តង គឺក្នុងថ្ងៃអាទិត្យ កំណត់វេលាចូលឆ្នាំថ្មីក្នុងខែចែត្រ (ខ្មែរយើងចូលឆ្នាំថ្មីក្នុងមេសរាសី គឺក្នុងខែចែត្រក៏ដោយកាន់តាមសុរិយគតិនេះ) ។

លុះសម័យតមក ការកំណត់វេលានមស្សការព្រះអាទិត្យរបស់ពួកអាសិរីខត់ទៅធ្វើនៅវេលាព្រះអាទិត្យឡើងកាន់ព្រឹសភរាសី គឺក្នុងខែពិសាខ ទាំងជាពិធីឡើងសករាជថ្មីផង ថ្ងៃនមស្សការជាធម្មតា ធ្លាក់នៅក្នុងរយៈ ៧ ថ្ងៃម្តងដូចអំពីដើម ព្រោះហេតុ

---

(១) រូបសោមនាថនេះវេលាក្រោយពួកព្រាហ្មណ៍កែទៅជា រូបសិវលិង្គ ។

នោះ ខបញ្ញត្តិរបស់មោសេអ្នកតែងគម្ពីរបីពើល ទើបបញ្ញត្តិថ្ងៃអាទិត្យជាថ្ងៃឈប់ធ្វើការងាររបស់ព្រះ សម័យនេះគេបានបញ្ញត្តិថ្ងៃអាទិត្យជាថ្ងៃសម្រាកការងារទូទៅគ្រប់ប្រទេស ប្រហែលជាកាន់យកតាមគតិនេះ តាមវិធីសុរិយគតិនេះគេរាប់ ១២ ខែជា ១ ឆ្នាំដូចដែលយើងកំណត់រាប់សព្វថ្ងៃនេះ តែវេលានោះហៅព្រះអាទិត្យថា សម ហើយក្លាយតៗមកជា ស័ន ជាវិស្ណុ ជាសូរ្យ។ អ្នកស្រុកបាតាលឬហៅសុវណ្ណប្រទេស សឹងតាំងភូមិលំនៅនៅឆ្នេរទន្លេសិន្ធុហៅព្រះអាទិត្យថា វិស្ណុ, វាសុ, ឬ វាសុក្រី ប្រែថា "អ្នកទ្រង់គោ" ដោយហេតុដើមឆ្នាំរបស់ពួកនេះ កំណត់យកក្នុងកាលព្រះអាទិត្យឡើងកាន់ឧទ្ធរាសី ឬហៅថាព្រឹសភរាសី (រាសីគោ) ជាប់ដរាបដល់សព្វថ្ងៃនេះ ។ ព្រះក្នុងលទ្ធិព្រះអាទិត្យនេះគេបំណែកជាព្រះ ៣៣ អង្គ គឺព្រះអាទិត្យ ១២ អង្គ បាននឹងព្រះអាទិត្យឡើងកាន់រាសីទាំង ១២, រុទ្រ ៩ បាននឹងរដូវ ៣ រដូវ ៦ ផ្សំគ្នា សប្តនាគា ៧ បាននឹងថ្ងៃទាំង ៧, មហានាគ ៥ បាននឹងព្រះគ្រោះទាំង ៥ រួមជា ៣៣ អង្គ ។ ការរាប់អានបូជាព្រះអាទិត្យក្តី ព្រះចន្ទ្រក្តី មិនមែនមានតែក្នុងសម័យព្រេងនាយប៉ុណ្ណោះ

ទេ   សូម្បីក្នុងសម័យនេះក្នុងប្រទេសឥណ្ឌៀក៏នៅមានរាប់អាន ដើម្បីប្រយោជន៍មួយយ៉ាង ៗ របស់គេ ដោយសេចក្ដីជឿថា ព្រះអាទិត្យព្រះចន្ទ្រជាអ្នកមានឫទ្ធិ កាលបុគ្គលមកបំពេញតបៈ្យប-រិយាឯណានីមួយ ដោយចិត្តបំពោះស្មោះត្រង់ទៅព្រះអង្គហើយក៏គង់នឹងប្រទានតេជានុភាព ឬអ្វីៗ ដល់កអ្នកនោះខ្វះមិនខាន កិច្ចដែលគេប្រព្រឹត្តក្នុងលទ្ធិនេះដែលយ៉ាងតឹងក្រៅពីនមស្សការបូជាធម្មតា គឺគេប្រព្រឹត្តឥរិយាបថឈរតែជើងម្ខាង កន្ត្រាញជើងម្ខាងឡើង ហើយលើកដៃប្រណម្យ ឬជួនកាលកាន់វត្ថុឯណានីមួយនៅដៃផង ភ្នែកក៏សំឡឹងមើលឆ្ពោះទៅព្រះអាទិត្យ ដោយមិនព្រិចមិនងាកចេញ មាត់ក៏បរិកម្មអ្វីទៅ រហូតដល់អស់ពេលដែលគេកំណត់ទុក ដោយបួលចិត្តថា នឹងសម្រេចប្រយោជន៍ផ្សេះផ្សោះតាមដែលត្រូវការ ។

កាលអំណិសលង់មក ស្រុកទេសចំរើនឡើងហើយ សេចក្ដីរាប់អានក្នុងលទ្ធិបែបចាស់ ៗ ក៏តោងរើរុះប្រែកែទៅតាមសម័យជាធម្មតា ដើម្បីនឹងលើកជាតិកំណើតឲ្យផុតអំពីការរាប់អានវត្ថុដ៏ចិយហោកមានតិរច្ឆានជាដើមនោះចេញ ហេតុនោះ

ក្នុងសម័យមុនពុទ្ធកាលមិនយូរប៉ុន្មាន ពួកព្រាហ្មណបានកែលទ្ធិចាស់ៗនោះឡើងជាថ្មីខ្លះ ដូចមានបញ្ញត្តិទុកក្នុងសាស្ត្ររបស់វសិដ្ឋព្រាហ្មណ ដូច្នេះ: —

១ បញ្ញត្តិយកព្រះព្រហ្ម ជាព្រះ ១ អង្គ

២ បញ្ញត្តិយកព្រះសិវ ជាព្រះ ១ អង្គ

៣ បញ្ញត្តិយកព្រះវិស្ណុ ជាព្រះ ១ អង្គ

៤ បញ្ញត្តិយកសាសនានាគជាពិធីបូជាភ្លើង

៥ បញ្ញត្តិពិធីសិវរាត្រី ។

កាលបញ្ញត្តិឡើងដូច្នេះហើយ ក៏តាក់តែងជាតិប្រវត្តិនឹងពណ៌នាព្រះតេជព្រះគុណនៃព្រះទាំងនោះយ៉ាងវិចិត្រពិស្ដារ គួរអស្ចារ្យ ល្មមនឹងដឹកនាំចិត្តមនុស្សទាំងពួងដែលទន់ក្នុងផ្លូវវិបារញាណឲ្យកើតជ្រះថ្លារាប់អានបាន ក៏ឯប្រវត្តិនឹងគុណសម្បត្តិនៃព្រះអំបាលនោះដូចម្ដេចខ្លះ សូមនាំយកមកសំដែងដោយសង្ខេបដូចមានតទៅនេះ: —

# ព្រះព្រហ្ម

ព្រះជាម្ចាស់ ឬទេវតាដែលពួកព្រាហ្មណ៍តែងគោរពបូជាក្នុងសាសនារបស់គេមានច្រើនអង្គ តែព្រះដែលធំបំផុត ៣ អង្គ គឺ ព្រះព្រហ្ម ព្រះសិវ ព្រះវិស្ណុ ។ អំពីនេះនឹងពណ៌នាប្រវត្តិនៃព្រះអំបាលនោះដោយលំដាប់ទៅ :—

ពាក្យថា ព្រហ្ម ក្នុងទីនេះជាសាធារណនាម ដែលរាប់ថាជាព្រះក្នុងលទ្ធិនេះ គឺគេសំដៅយកមហាព្រហ្ម[១] ដែលធំជាងគេទាំងអស់ នាមជាអ្វីមិនប្រាកដ មានព្រះជាយានាមសរស្វតី មានឱរសធីតាដែលប្រាកដនាម ៣ អង្គ គឺព្រះទក្ស ១ ព្រះភឫគុ ១ នាងសន្ធ្យា ១ ។ ព្រះទក្សបានជាប្រជាបតីរបស់លោក ព្រះភឫគុបានជាអ្នកវិសេសមួយក្នុងសម័យនោះ នាងសន្ធ្យាបានជាជាយាព្រះសិវមុននាងឧមា ។ មានលក្ខណជាគ្រឿងសំគាល់តាមរូបដែលគេសាងទុក គឺទ្រង់ហង្សជាពាហណ ព្រះហស្តច្រើនកាន់ផ្កាឈូក ព្រះភក្ត្រច្រើនធ្វើជា ៤

---

(១) ក្នុងរឿងពុទ្ធប្រវត្តិថា ព្រហ្មឈ្មោះសហម្បតិ ជាធំក្នុងលោក តែក្នុងរឿងរាមកេរ្តិ៍ហៅព្រះធាតា ។

ព្រះភក្ត្រតែ ១ ក៏មានខ្លះដែរតែតិច ហេតុដែលគេធ្វើជាព្រះភក្ត្រ ៤ ដូច្នេះ ដោយអនុមានមើលប្រហែលជាសំដៅយកត្រង់សេចក្ដីថា ព្រះព្រហ្មរមែងប្រកបដោយព្រហ្មវិហារធម៌ ៤ គឺ មេត្តា ករុណា មុទិតា ឧបេក្ខា តែងផ្សាយព្រហ្មវិហារនេះដល់ពពួកសត្វគ្រប់ទិសទាំង ៤ ឲ្យបានសេចក្ដីសុខរាល់ប្រាណពុំបានរើសមុខ ហេតុនោះគេទើបសាងជាព្រះភក្ត្រ ៤ ជាគ្រឿងសំ-ដែងព្រហ្មវិហារធម៌របស់លោកនេះឯង ។ ជាអ្នកទ្រង់ញាណដ៏វិសេស អាចជ្រាបហេតុផលក្នុងអតីតអនាគតបច្ចុប្បន្នបានមានព្រហ្មវិទ្យាដ៏ប្រសើរ ជានិយ្យានិកអាចញុំាងអ្នកប្រតិបត្តិតាមឲ្យរួចចាកសង្សារវដ្ដ និងកាត់បង់នូវសេចក្ដីសន្ទេះក្នុងហេតុផលទាំងពួងបានដោយមិនមានទើសទាល់ ដូចមានសំដែងក្នុងគម្ពីរអៃតរេយោបនិស័ទ និងគម្ពីរមក្ឌុកោបនិស័ទ ។ ជាអ្នកទ្រង់នូវអានុភាពសក្ដិសិទ្ធិ៍ អ្នកណាមួយមានចិត្តភក្ដីបំពេញតបះឆ្ពោះព្រះអង្គដោយមុតមាំហើយ អាចប្រសិទ្ធិ៍ប្រទានពរឲ្យឲ្យសម្រេចប្រយោជន៍តាមដែលត្រូវការ ។ ព្រះអង្គជាបិតាឬជាជនករបស់លោក គឺទ្រង់មាននាងសរស្វតីជាទេពី មានព្រះ

ទក្សជាដើមជាឱរស ព្រះទក្សលើកធីតា ២៧ ឲ្យទៅជាភរិយាព្រះសោម ១៣ នាងទៀតឲ្យទៅជាភរិយាព្រះកាស្យប អ្នកទាំងនេះមានកូនចៅដំណពូជពង្សជាមនុស្ស គឺពួកភរតជាដំបូងបង្អស់ គេទើបរាប់ថា ព្រះព្រហ្មជាបិតារបស់លោក ព្រះទក្សជាប្រជាបតីរបស់លោក ដោយប្រការដូច្នេះ ។ តែក្នុងគម្ពីរព្រហ្មណ្ឌបុរាណមសំដែងផ្សេងអំពីនេះថា កាលដែលនឹងកើតជាទឹកដីឡើង គឺព្រះមហាព្រហ្មទ្រង់និម្មិតឬជប់ឲ្យកើតជាអណ្ឌជាតិ គឺជាពងមួយហៅថា "ពងព្រះព្រហ្ម" តមកទ្រង់ជប់ពងនោះឲ្យទៅជាលោក ហើយទ្រង់បែងភាគឲ្យមកកើតជាមនុស្សអាស្រ័យនៅក្នុងលោកនោះ ដំបូងតែពីរនាក់ ប្រុស ១ ស្រី ១ ប្រុសហៅ បុម ស្រីហៅ វិរដ្ឋា បុមនឹងវិរដ្ឋានេះរួមរសប្រវេណីគ្នាទៅ ទើបកើតពូជជារពេញពាសទាំងលោកដូចដែលយើងឃើញនៅសព្វថ្ងៃនេះស្រាប់ ។ បំណែកឯក្នុងគម្ពីរបទុមបុរាណមសំដែងផ្សេងអំពីនេះទៅទៀតថា ដំបូងដែលនឹងកើតលោកនេះឡើង មានផ្កាឈូក ១ ផុះឡើង ឲ្យឃើញប្រាកដជាមុន ក្រោយនោះទើបកើតលោកនេះឡើង តែនៅមិនទាន់មានមនុស្សកើត

ឡើង ទាល់តែពួកព្រហ្មនាំគ្នាចុះមកលេងនៅផែនដីប៉ុន្នោះ ធុំក្លិន
កំញ៉ាមដីប៉ុន្នឈ្ងុយឈ្ងប់មុកគួរឆ្ងាញ់ ក៏នាំគ្នាបរិភោគ លុះបរិ-
ភោគយូរទៅក៏ដេបឈានហោះទៅព្រហ្មលោកវិញមិនរួច ក្លាយ
ទៅជាមនុស្សអាស្រ័យនៅក្នុងលោកដរាបដល់សព្វថ្ងៃនេះ ។
ដោយហេតុទាំងឡាយដែលបានបរិយាយមកនេះ ពួក
ព្រាហ្មណ៍ទើបរាប់អានព្រះព្រហ្ម នឹងមានសេចក្ដីប្រកាន់ថា
ត្រកូលរបស់គេជាត្រកូលខ្ពស់បំផុតជាងត្រកូលទាំងពួង មាន
ក្សត្រិយ៍ជាដើមដោយដំណាត្រកូលមកអំពីព្រហ្មវង្ស ។

## វិធីសម្រាលកូន

ក្នុងកិច្ចសម្រាលកូននេះ ខ្មែរមានសន្មតពាក្យសម្រាប់ហៅដល់ទៅ៥យ៉ាង គឺកើតកូន សម្រាលកូន ឆ្លងទន្លេ សម្ភព ប្រសូតិ ។ ពាក្យថា កើតកូន ហៅបានទូទៅទាំងមនុស្សទាំងតិរច្ឆាន វៀរលែងតែក្សត្រិយ៍ ។ ពាក្យថា សម្រាលកូន និងឆ្លងទន្លេ ហៅបានចំពោះតែមនុស្សដែលជាតិជារាស្ត្រទូទៅទាំងអ្នកធំទាំងអ្នកតូច ជាពាក្យដែលគេវាយដំឡៃហើយថា ខ្ពស់ជាងពាក្យថា កើតកូន ។ ពាក្យថា សម្ភព មានបញ្ញត្តិក្នុងរាជ-សព្ទថា សម្រាប់ហៅអ្នកដែលបិតាជាក្សត្រិយ៍ មាតាជាព្រះស្នំ ។ ពាក្យថា ប្រសូតិចំពោះហៅបានតែក្សត្រិយ៍ទាំងមាតាទាំងបិតា ជាពាក្យដ៏មានដំឡៃជាងពាក្យឯទៀតទាំងអស់ តែក្នុងភាសាដើម គឺភាសាមគធៈនិងសំស្ក្រឹត លោកប្រើទូទៅទាំងក្សត្រិយ៍ទាំងរាស្ត្រ យើងយកមកកំណត់ប្រើចំពោះតែក្សត្រិយ៍ ។

កិច្ចសម្រាលកូននេះជាការក្រការទម្ងន់ ជាទីភិតភ័យព្រួយដល់អ្នកសាមីខ្លួនទាំងប្ដីទាំងប្រពន្ធ និងបណ្ដាញាតិទាំងឡាយ

ព្រោះជាផ្លូវដែលអាចនឹងអន្តរាយជីវិតនៃមាតា ឬបុត្រឯណានីមួយក៏បាន ឬទាំងពីរនាក់ក៏បាន ហេតុនោះ គេទើបសន្មតពាក្យហៅថា សម្រាល ដើម្បីឲ្យធូរ ឲ្យស្រាលទៅតាមមាត់ ១ យ៉ាងទៀតគេហៅតាមអាការៈ គឺក្នុងវេលាមានគភ៌ហៅថា ទម្ងន់ វេលាកើត ហៅថា សម្រាល គឺស្រាលបេញអំពីពោះ ។ ពាក្យថា ឆ្លងទន្លេ ជាពាក្យប្រៀបនៃការក្រ ព្រោះការសម្រាលកូននោះជាការក្រណាស់ ប្រៀបបីដូចជាបុគ្គលហែលទឹកឆ្លងទន្លេ កម្រនឹងរួចរស់ដល់ត្រើយបានដូច្នោះ ។

ក៏ឯវិធីសម្រាលកូនយ៉ាងរាស្ត្រ ៗ អ្នកស្រុកនោះ កាលណាដឹងជាគភ៌នោះចាស់ខែ ជិតដល់កំណត់នឹងសម្រាលហើយ គឺក្នុងរវាងមុនសម្រាល ២ ៣ ខែ គេរមែងស្វែងរកថ្នាំ នឹងរបស់ផ្សេង ៗ ដែលសម្រាប់ប្រើក្នុងកិច្ចនេះ មកបម្រុងទុកដើម្បីនឹងបានប្រើការក្នុងវេលាសម្រាលកូនរួចហើយ ។

ថ្នាំធំដែលសម្រាប់ប្រើក្នុងកិច្ចនេះមាន ២ យ៉ាង គឺថ្នាំផង់ ឬហៅថាថ្នាំត្រាំស្រា ១ យ៉ាង ថ្នាំផ្ទាង ១យ៉ាង ។ ឯថ្នាំផង់នោះគេឲ្យយកដើមឈើខ្លះ សំបកឈើខ្លះ ឫសឈើខ្លះ មើម

ឈើខ្វះ មកហាន់បុកឲ្យល្អិតទុក ។ មុននឹងប្រើត្រូវយក ថ្នាំនោះមកដាក់ក្នុងដប ចាក់ស្រាត្រាំទុកប្រមាណ ២-៣ ខែ ទើបយកមកផឹក ។ ឯថ្នាំឆ្នាំងនោះ ក៏គឺគ្រឿងថ្នាំជាមួយគ្នានឹងថ្នាំផង់នោះឯង ប្លែកតែគេយកមកកាត់ជាកំណាត់ ៗ ដាក់ក្នុងឆ្នាំងថ្មី ១ ទុកសម្រាប់ដាំផឹក ។ ថ្នាំទាំង ២ យ៉ាងនេះ ជាថ្នាំក្ដៅ មានសព្វគុណដូចគ្នា សម្រាប់លាងជំរះទម្លាក់ឈាមអាក្រក់ដែលជាដុំខន់នៅក្នុងខ្លួន សឹងអាចបណ្ដាលឲ្យទៅជារោគផ្សេងៗ នោះឲ្យធ្លាក់បុះមក នឹងសម្រាប់ផ្គុំធាតុក្នុងខ្លួនឲ្យមានកំលាំងស្មើភាគគ្នាឡើងវិញ នឹងរក្សាសាច់ ឈាមសរសៃ ឲ្យល្អឲ្យស្រស់ឡើងវិញ ថ្នាំទាំងពីរយ៉ាងនេះ ត្រូវផឹកតាំងពីវេលាសម្រាលកូនហើយរហូតទៅ ទាល់តែឃើញជាស្រួលខ្លួនហើយទើបឈប់ នឹងផឹកជាមួយគ្នាទាំងពីរយ៉ាងទៅក៏បាន ឬនឹងផឹកតែយ៉ាងឯណានីមួយក៏បាន អ្នកដែលមិនបេះផឹកស្រាគេច្រើនប្រើថ្នាំឆ្នាំង ពុំនោះសោតគេយកថ្នាំផង់នោះមកធុងទឹកក្ដៅផឹកក៏មាន ។

ដល់មកក្នុងខែដែលនឹងសម្រាល ត្រូវត្រៀមរកធ្យូងឈើចំនួនយ៉ាងតិច ១ ហាប ឬបើគ្មានធ្យូងត្រូវរកឧសក្រសាំងចំនួនតិច ១ ម៉ែត្រ និងគ្រែដេក ១ កំពស់ប្រមាណ ៦៥ សង្ទីម៉ែត្រនិងបង្គ្រានដី ១-២ មកបម្រុងទុកដើម្បីនឹងបានដុតឲ្យអ្នកសម្រាលកូនដេកអាំងក្នុងវេលាសម្រាលរួចហើយ ។

ប្រយោជន៍ដែលប្រើអាំងភ្លើងធ្យូងនោះ ព្រោះភ្លើងធ្យូងក្តៅធំហើយមិនសូវមានផ្សែងផង ។ ប្រយោជន៍ដែលប្រើអាំងភ្លើងឧសក្រសាំងនោះ ព្រោះភ្លើងឧសក្រសាំងក្តៅធំល្អហើយធុំក្លិនក្រអូបផង ។ និងប្រើដុតទាំងពីរយ៉ាងជាមួយគ្នាក៏បាន ឬតែយ៉ាងឯណានីមួយក៏បាន ទៅតាមភូមិស្ថានដែលរកងាយឬរកក្រ ។

គុណប្រយោជន៍ដែលផឹកថ្នាំពីរមុខខាងដើមនឹងអាំងភ្លើងនេះជាឧបការៈជួយទំនុកបម្រុងសាច់ឈាមសរសៃឲ្យល្អ ឲ្យបានសុខសប្បាយក្នុងខ្លួន កុំឲ្យបណ្តោលទៅជារោគាព្យាធិផ្សេង ៗ មានរោគស្គមរីងរៃជាដើម ។ ត្រង់នេះចាស់ៗតែងនិយាយថាអ្នកសម្រាលកូន បើផឹកថ្នាំបានច្រើនអាំងភ្លើងបានច្រើនថ្ងៃ នឹង

មានសាប់ឈាម-សំបុរល្អ ក្រហស់ មិនសូវមានពោគាព្យាធិ មកញាំញីរាងកាយ តាមដែលបានសង្កេតមក ឃើញពិតដូច្នោះមែន ។

តមកត្រូវបាត់បែងដេរម៉ក់ (ខ្លះហៅថាកែប) សណ្ឋានយ៉ាងពូក តែតូចល្មមកូនខ្ចីនោះដេកស្រួលញាត់គរធួរ ៗ ឲ្យបានបំនួទ២ឬ៣ នឹងកំណាត់សំពត់សធ្វើជាទ្រនាប់ម៉ក់នោះឲ្យបានបំនួន ៧-៨ កំណាត់ នឹងមុងតូប១ អង្រឹង ១ បម្រុងទុកដើម្បីនឹងឲ្យកូនខ្ចីនោះដេកក្នុងវេលាសម្រាលហើយ ។

ដល់វេលាឈើពោះជិតនឹងសម្រាលហើយ ត្រូវរៀបបំបន្ទប់ ១ក្នុងផ្ទះរបស់ខ្លួននោះ បិទបាំងដោយជញ្ជាំង ឬដោយរាំងននន (តែអ្នកខ្លះគេសង់រោង ១ តូបនៅក្បែរផ្ទះនោះ) ទុកសម្រាប់ឲ្យសម្រាលកូន នឹងត្រូវទៅអញ្ជើញឆ្មបស្រីស្រុកអាយម្នាក់មកជួយជ្រោមជ្រែងក្នុងការសម្រាលនោះ ក្នុងខណៈសម្រាលនោះមានជាទំនៀមហាមមិនឲ្យអ្នកដទៃក្រៅចូលទៅក្នុងបន្ទប់ ចូលបានតែស្រីដែលជាឆ្មប ជាជីដូន-ម្តាយបងប្អូនផ្ទាល់ឬស្រីដែលស្និទ្ធស្នាលជិតជិតណាស់ ដែលមានកិច្ចត្រូវចូលទៅជួយគាំ

ពារដោយប្រការឯណាទីមួយ ឬបើមានហេតុមិនស្រួលជាខ្លាំង កើតឡើង ប្រុសដែលជាអាពុក- ប្ដី-បងប្អូនបង្កើត ឬគ្រូពេទ្យនឹង ប្ដូលទៅជួយឧបត្ថម្ភបាន ។ ផលាសម្រាលហើយ ឆ្មបត្រូវ លាងជំរះមន្ទិលឲ្យម្ដាយដោយទឹកក្ដៅអ៊ុន ៗ ដែលគេដាំបម្រុង ហើយត្រូវប្រកបថ្នាំស្រស់ ១មុខ គឺយកស្លឹកក្រសាំងដង្ហុំ ម្រេច ជីប្លី ក្រវាញ ម្រែងភ្លើង ប្រមាណស្មើភាគគ្នា នឹងអំបិលលើស គេប្រមាណ ២ ភាគ មកបុកឲ្យល្អិតហើយលាយនឹងទឹកនោម កូនក្មេងឬស្រា ឲ្យម្ដាយផឹកក្នុងខណៈនោះភ្លាម ។ សុកត្រូវខ្ចប់ ហើយយកទៅកប់តាមទិសដែលអាចារ្យកំណត់ឲ្យ ។

លំដាប់នោះត្រូវបែរមកបាត់ការឲ្យកូនខ្ចីនោះវិញ គឺត្រូវ លើករលាក់ទឹកព្រៃក្នុងខ្ទះកូននោះឲ្យធ្លាក់អស់ហើយ យកអំ- បោះខ្មៅមកបងសណ្ដាប់ផ្ចិត ហើយកាត់ទុកតែល្មមសមគួរ នឹង ត្រូវប្រកបថ្នាំ ១មុខទៀត គឺយកសត្វសង្កើចប្រមាណ ៦-៧ មក ប្រិបាច់លាយនឹងស្រាបន្តិច ហើយយកនោះទៅក្បៀសជូតជំរះ អណ្ដាតកូនខ្ចី ស្រេចហើយលើកដាក់លើម៉ក់ឲ្យមនុស្សទទួល យកទៅដាក់ក្នុងមុងដែលគេបាត់ទុក ។

លំដាប់នោះអ្នកម្ចាស់ការ ត្រូវរួសរាន់យកបង្ក្រាន ធ្យូង នឹងគ្រែដែលពោលខាងលើទៅរៀបដុតភ្លើងហើយដាក់គ្រែពីលើ នៅបន្ទប់ដែលសម្រាលនោះឬនៅបន្ទប់ណា ១ តាមដែលឃើញថាស្រួល ហើយជួយគ្រាអ្នកសាម៉ីខ្លួនទៅដាក់ឲ្យដេកអាំងនឹងត្រូវចាត់មនុស្សម្នាក់ឲ្យនៅមើលបៃភ្លើងឲ្យឆេះតែល្មមអាំងបាន។

លំដាប់នោះអ្នកម្ចាស់ការ ត្រូវរៀបរបស់ដែលជាគ្រឿងកំណាល់ធ្មប ១ ប្រដាប់ទៀត គឺស្រូវ ១ កញ្ជើ (ស្រូវនេះគេហៅថាស្រូវពន្លៃ) បេក ១ ស្និត ស្រា ១ ដប អំបោះ ១ ប៉ោយ ទៀន ៥ ធូប ៥ ដាក់លើកញ្ជើស្រូវនោះ នឹងមានអង្ករ ១ បានទៀត យកទៀនស្នែងក្របី (គឺទៀនដែលពត់ជារង្វង់ដូចស្នែងក្របី ហើយយកទៀន ១ ដើមទៀតមកបិទភ្ជាប់ត្រង់កណ្ដាល) ដោតបញ្ឈរលើអង្ករនឹងដាក់ប្រាក់ ៤ ប៉ែ (ឬ ៤ សេន) នៅលើអង្ករនោះទៀត។ របស់អំបាលនេះត្រូវយកទៅរៀបទុកក្បែរគ្រែដែលអាំងភ្លើង ទុកទៅដល់គ្រប់ ៣ ថ្ងៃ ទើបលើកជូនទៅធ្មប ដូចជានឹងមានពោលទៅខាងក្រោយ ។

លំដាប់អំពីនោះទៀត ត្រូវរកគ្រូឬអាចារ្យ ឬអ្នកឯណានីមួយដែលចេះមន្តអាគមមកព័ទ្ធសីមា គឺគេយកអំបោះសមកសូត្រសែពដោយមន្តអាគមហើយចងព័ទ្ធជុំវិញគ្រែដែលអាំងភ្លើង ជារបងសម្រាប់ការពារកុំឲ្យខ្មោច បិសាច អាប ព្រាយ មានព្រាយក្រឡាភ្លើងជាដើម ដែលនឹងមកបៀតបៀនយាយីដល់អ្នកសម្រាលកូន ព្រោះក្នុងពេលដែលសម្រាលកូនឈឺទ្ររន់ទូរាដូច្នេះ ខ្មោច បិសាច អាប ព្រាយ បំណាំតែមកបន្លំធ្វើឲ្យទៅជាឈឺផ្សេងៗថែមទៀត ។

នៅក្រោមផ្ទះត្រង់កន្លែងដែលសម្រាលកូននោះ គេតែងយកបន្លាមកស្រោស ដើម្បីកុំឲ្យអាបមកយាយីដល់អ្នកសម្រាលកូន និងកុំឲ្យមកលិតស៊ីឈាម ឬរបស់ស្មោកគ្រោកទាំងពួង ព្រោះអាបនោះវាខ្លាចបន្លាដោយធម្មជាតិរបស់អាបនោះ វាតែងតែដើរបួលធ្វើគេឲ្យឈឺ ដើម្បីយករបស់សំណែន ហើយនឹងតែងដើរលិតស៊ីខ្ទុះឈាមក្នុងទីផ្សេងៗទូទៅ ។

រឿងព្រេងខ្មែរ

១ — រឿងតាប័នរំលោក

រឿងឈ្មោះតាប័នរំលោកមាននិយាយថា កាលណោះមានព្រៃ ១ ធំមានសត្វខ្លាសាហាវតែងខាំមនុស្សផងជាច្រើន នឹងចូលទៅរកបោចផ្តៅវល្លិពុំបាន គ្រានោះតាប័នគាត់ចូលទៅបោចផ្តៅវល្លិក្នុងព្រៃនោះ វាលបចេញពីក្នុងព្រៃប៉ងនឹងខាំ តាប័នគាត់ចូលទៅបោចវល្លិ គាត់ឃើញជាមុនហើយគាត់រកពុទ្ធោថា ឱពុទ្ធោ ៗ អើយ ឆ្នាំនេះឆ្នាំខាលទឹកបែកពាសវាលស្លាប់ខ្លាដំរី ស្លាប់អស់ទាំងសត្វម្រឹគបក្សី ស្លាប់ខ្លាដំរីគ្មានគង់តួប ១ ផ្តៅអញនេះអាណាវែង ៗ អញព្យួរកូន អញព្យួរចៅ អាណាខ្លី ៗ អញព្យួរត្បាល់អង្រែ ឱសត្វទាំងឡាយអើយ ក្នុងឆ្នាំខាលនេះនឹងស្លាប់ហើយគ្មានគង់ទេ តាប័ននិយាយរកពុទ្ធោយ៉ាងនេះជាច្រើនដងសត្វខ្លាស្តាប់បានឮច្បាស់ ខ្លាគិតថា គួរអញនឹងសួរតានេះបង់ដឹងមើល ទើបខ្លាសួរទៅតាប័នវិញថា តាអើយក្នុងឆ្នាំខាលនេះទឹកធំមែនឬ ទើបតាប័នធ្វើជាភ្ញាក់និយាយទៅនឹងសត្វខ្លាថា ឱចៅពីរឆ្នាំនេះទឹកធំណាស់ បានជាតាភ័យនឹងកូនចៅតា ៗ មក

រកផ្ដៅព្យួរកូនហៅតាឲ្យផុតពីទឹក ឯសត្វខ្លាក៏មានចិត្តគិតភ័យនឹង ពាក្យតាប៉ិនថា មានចិត្តគិតខ្លាចស្លាប់ ចូលមកជិតហើយនិយាយ នឹងតាប៉ិនថា តាអើយអាណិតបងព្យួរខ្ញុំផង ឲ្យផុតពីទឹកផងបាន ឬទេ តាប៉ិននិយាយឆ្លើយថា បានមិនអីទេហៅ មកអង្គុយចាំតានៅ នេះសិនចុះ សត្វខ្លាក៏ចូលមកអង្គុយចាំ លុះតាប៉ិនបោចផ្ដៅបាន ក៏ត្រក្លួញធ្វើជាលំងកហើយចូលទៅចងបង្កេះខ្លា តាប៉ិនក៏កាន់ គល់ផ្ដៅឡើងទៅលើឈើខ្ពស់ ហើយបង្គាប់ឲ្យខ្លាលោតឡើង តាប៉ិនក៏ស្រាវទាញឡើងឲ្យផុតជើងខ្លាពីដី តាប៉ិនក៏ចុះមកវិញ ខ្លាក៏សួរថា តាប៉ុណ្ណេះផុតពីទឹកហើយឬអី តាប៉ិនឆ្លើយថា ផុត ហើយហៅ តាប៉ិនក៏កាន់កំបិតទៅកាប់ឈើធ្វើដំបង ខ្លាឃើញសួរ ថា តាកាប់ដំបងធ្វើអី តាប៉ិនថា កាប់យកទៅផ្ទះក្រែងប្រទះនឹង សត្វឯទៀតវាប្រមាទតា ទើបខ្លាឆ្លើយថា គ្មានខ្លាឯណាទេតា មានតែខ្ញុំនេះឯងតែងតែនឹងចាំគេរាល់ថ្ងៃ ទើបតាប៉ិនគាត់ដឹង ថា ឱអានេះជាសត្វកាច បើដូច្នេះអញនឹងវាយអានេះឲ្យអស់ ចិត្តក្នុងគ្រានេះ ទើបតាប៉ិនកាន់ដំបងចូលទៅដល់ខ្លាថា ហៅនៅ ឲ្យស្ងៀមតានឹងមើលបំណងឲ្យ ក្រែងវារបួតលង់ទឹងស្លាប់ ខ្លាក៏

នៅស្មៀម ទើបតាច័នលើកដំបងវាយខ្លា ៗ ក៏ប្រឹងរើបម្រះស្រែក ជាខ្លាំង រលាត់រលួតស្បែកហើទខ្លួនជាខ្លាំង មុខគួរវេទនាហើយ ខ្លាក៏ប្រឹងរើបម្រះក្រឡាស់ខាំខ្សែផ្តៅដាច់គេចរត់ទៅ តាច័នក៏វិល ទៅខ្ទមស្រែវិញ ។ ទើបនិយាយឯសត្វខ្លារត់រួចទៅជួបនឹងដំរី ១ ដំរីឃើញខ្លារត់ ដំរីស្រែកសួរថា បងខ្លាឯងរត់ភ័យនឹងអី ក៏បានជាមិនមើលក្រោយសោះ ទើបខ្លាប្រាប់ទៅដំរីវិញថា បងអើយ អាច័នវំលាកបញ្ឆោតវាយខ្ញុំហើមខ្លួនអស់ ដំរីសួរ ថា អាច័ននោះវានៅឯណា ខ្លាប្រាប់ថា វាធ្វើស្រែនៅមាត់បឹង នោះឯង បើជួប្រទះអញនឹងព្រៀជវាឲ្យស្អិតកុំឲ្យវាធ្លាប់ធ្វើបាបគេ ឯខ្លាក៏រត់ទៅ ។ ដំរីក៏ដើរមករកតាច័ននឹងព្រៀជតាច័ន ជួបនឹងតា ច័នតែដំរីពុំស្គាល់តាច័ន ហើយសួរថា តា ៗ ស្គាល់អាច័នវំលាក ដែរ ទើបតាច័នសួរដំរីថា ចៅឯងសួររកគាត់ធ្វើអ្វី ដំរីថា ខ្ញុំខឹង ណាស់វាបញ្ឆោតវាយបងខ្លាហើមខ្លួនអស់ ទើបតាច័នឆ្លើយថា អាច័នវានៅខ្ទមស្រែត្រើយខាងកើតមាត់បឹងខ្ទមគាត់ស ៗ នោះ ឯង ដំរីថា តាអាណិតជូនខ្ញុំទៅ បើខ្ញុំព្រៀជវាស្លាប់បានរបស់អ្វី ប៉ុន្មានខ្ញុំជូនតាឯងទាំងអស់ តាច័នឆ្លើយថា តាអរណាស់ ប៉ុន្តែ

ទឹកបឹងនេះជ្រៅណាស់ តាទៅមិនរួចទេ ដំរីថា បើទឹកជ្រៅតាជិះលើក្បាលខ្ញុំ ទើបតាប័នឆ្លើយថា អើបើដូច្នោះទៅក៏ទៅ ឯតាប័នក៏កាន់កំបិតព្រា ១ ជាប់ទៅផង លុះទៅបានបម្ងាយ ១ ស្រែ តាប័នក៏កាប់ក្បាលដំរី ៣-៤ កំបិតមុតឈាម ដំរីក៏គេចរត់មកវិញដល់គោករលាស់ទំលាក់តាប័ន ហើយដំរីក៏រត់ទៅជួបនឹងសត្វខ្លាឃ្មុំ ៗ ក៏ស្រែកសួរថា បងដំរីរត់អីគ្មានមើលក្រោយម្លេះ ដំរីឆ្លើយប្រាប់ថា បងខ្លាឃ្មុំអើយ អាប័នវំលោកបញ្ឆោតកាប់ក្បាលខ្ញុំឈាមអស់ ឯខ្លាឃ្មុំក៏ជួយខឹងដំរី ហើយសួរទៅដំរីវិញថា អាប័នវំលោកនោះវានៅឯណា ដំរីប្រាប់ថា វានៅធ្វើស្រែនៅមាត់បឹងធំនោះឯង ដំរីក៏រត់បាត់ទៅ ឯសត្វខ្លាឃ្មុំក៏មានចិត្តខឹងគុំគួនប្រមាទនឹងខាំក្បាលតាប័នបំបែកឡើស្លាប់ លុះថ្ងៃក្រោយខ្លាឃ្មុំដើរទៅឃើញតាប័នភ្ជួរស្រែពេលព្រឹក ខ្លាឃ្មុំនឹកថា នេះហើយអាប័នវំលោកនោះ ដូច្នេះអញពួនចាំនៅនេះចុះ ចាំវាមកជិតអញលោតទៅខាំឡើបាន ខ្លាឃ្មុំក៏ក្រាបចាំនៅសំយាកព្រៃ តាប័នក៏មិនទាន់ដឹងខ្លួន ឯតាប័នក៏ភ្ជួរស្រែយូរក្រដល់ទៅ ខ្លាឃ្មុំក៏ក្រោកឈរអើតមើលមកតាប័នៗក៏មើលទៅឃើញខ្លាឃ្មុំ ហើយតាប័ន

គិតថា សត្វនេះវាចង់មកប្រមាទធ្វើទុកអញទៀតហើយ ទើបតាប័នប្រុងខ្លួនហើយវាយក្របីដេញថា ហើយអានាងទំទាញឡើងតាយកឃ្មុំឲ្យស៊ី ឃ្មុំតែពីរកំពុងពេញទឹកផ្អែមមើយផ្អែម តាប័នគាត់ថាយ៉ាងនេះជាប្រើនដង ឯខ្លាឃ្មុំក៏ឮច្បាស់មានចិត្តចង់ស៊ីឃ្មុំហើយឆ្លើយមកនឹងតាប័នថា តាៗបែកទំស៊ីផង ទើបតាប័នឆ្លើយប្រាប់ទៅខ្លាឃ្មុំវិញថា ចៅអើយឃ្មុំតាតែពីរ ទុកឲ្យក្របីវាស៊ី ១ ម្នាក់សោះតែញវខ្លួន បើចៅចង់ស៊ីចូលមកនិយាយគ្នាសិន ឯសត្វខ្លាឃ្មុំក៏ចូលមកអង្គុយ ទើបតាប័ននិយាយថា បើចៅចូលចិត្តចង់ស៊ីដែរនឹងឲ្យស៊ីតែម្តងទៅ ខ្លាបក្រែងក្របីវាខឹងវា ព្រោះវាធ្លាប់ស៊ីដែរ តែតាគិតថា ចៅឯងឲ្យតាភ្ជួរស្រែឲ្យបាន ១ ព្យាមបុះ តានឹងឲ្យចៅស៊ីទាំងពីរតែម្តង ក្របីតាវាអត់សិនទៅបុះសុំកទៀត ឯខ្លាឃ្មុំស្តាប់ក៏ត្រេវចិត្តនឹងបំណើបំណងរបស់ខ្លួនក៏អរណាស់ថា បើដូច្នោះឲ្យដោះក្របីបេញបុះ តាប័នក៏ដោះក្របី ១ រំពេច ខ្លាឃ្មុំក៏ចូលទៅឲ្យតាប័នទឹម ដាក់ខ្សែទាមចងរឹតរួតរូបជាស្រេច តាប័នគាត់ស្ទុះទៅកាន់កន្ទុយនង្គ័ល ហើយគាត់ដេញថា ហើយអានាងទំឡើងតាយកឃ្មុំឲ្យស៊ី ឃ្មុំតែពីរកំ-

ពុងពេញទឹក ឯខ្លាឃ្មុំក៏ខំប្រឹងទាញនង្គ័លនោះពុំកក្រើកឡើយ តាប៉នគាត់ទឹងលែងកន្ទុយនង្គ័លហើយទៅវាយខ្លាឃ្មុំ ៗ ក៏ប្រឹងរើបម្រះ តាប៉នវាយខ្លាំងណាស់បែកហើម ឯខ្លាឃ្មុំរើរួចរត់ទៅជួបនឹងសត្វបបក ៗ សួរទៅខ្លាឃ្មុំថា បងខ្លាឃ្មុំរត់អី គ្មានមើលក្រោយម្ល៉េះ ខ្លាឃ្មុំប្រាប់ទៅបបកវិញថា បងបបកកើយអាប៉នរំលោភវាបញ្ឆោតវាយហើមខ្លួនអស់ ខ្លាឃ្មុំក៏រត់ទៅ ឯបបកក៏អួតថា បើដូច្នោះទុកឲ្យអញឯងនឹងទៅហែកលបអាប៉នរំលោកបែកគ្នាស៊ីឲ្យអស់កុំទុកឲ្យវាឡើយ លុះព្រឹកឡើងតាប៉នគាត់កាន់កំ-បិតព្រា ១ នឹងប្រវា ១ ទៅលើកលបក្នុងបឹង ៗ និយាយឯបបកមកដល់កណ្តាលផ្លូវជួបនឹងខ្លាត្រី ១ បបកក៏បបួលខ្លាត្រីថា បងខ្លាត្រីទៅស៊ីនឹងអញ ខ្លាត្រីថា បងបបកឯងបានត្រីពីណា បបកថា អញទៅហែកលបអាប៉នរំលោកបែកគ្នាស៊ី ខ្លាត្រីក៏ព្រមតាម បបកមកអង្គុយនៅមាត់បឹង យូរបន្តិចឃើញតាប៉នអុំទូកចូលមក បបកសួរថា តាស្គាល់អាប៉នរំលោកដែរ តាប៉នថា ស្គាល់ដែរ តែអាប៉ននោះវានៅត្រើយបឹងខាងកើតឯណោះទេ បើដូច្នោះតាឯងអាណិតជូនខ្ញុំទៅ បើខ្ញុំហែកលបវាបានត្រីខ្ញុំបែក

ពាក់កណ្ដាល តាប័នថា ទៅក៏ទៅ ដ្បិតលបតាក៏វាពុំត្រូវផង ថាហើយចចកក៏លោតទំក្បាលទុក តាប័នថា ហៅកុំទៅអង្គុយ ក្បាលទុកនោះវាលេបណាស់ មកអង្គុយខ្ទង់មុខតាងណោះទើបវាមិនលេប ចចកក៏មកអង្គុយនៅខ្ទង់មុខតាប័ន ហើយហៅទៅខ្លាត្រីថា មកបងប្រញាប់នឹងអាលទៅ ខ្លាត្រីឆ្លើយថា បងចចកអញមិនហ៊ានទៅទេ អញក្រែងតាប័នហើយនេះ ចចកបែរមើលក្រោយថា មិនមែនទេ តាប័នក៏នៅស្ងៀម ខ្លាត្រីក៏ឡើងមកអង្គុយទំមគ្នា តាប័នក៏អុំទូកទៅប្រមាណជា ១០ ព្យាមពីច្រាំង តាប័នគាត់កាប់ក្បាលចចក ១ កំបិតលោតធ្លាក់ទឹក ខ្លាត្រីក៏លោតធ្លាក់ទឹកទាំងអស់គ្នា ខ្លាត្រីបន្ទោសចចកថា អញថាតាប័នហើយឯងថាមិនមែនតាប័ន ចចកថា កុំមាត់ខំតែហែលទៅ សត្វទាំងពីរក៏ហែលរួចដល់គោកហើយរត់ទៅ តាប័នក៏ទៅធ្វើស្រែស្រួលរួចហើយ តាប័នក៏ទៅផ្ទះបានសេចក្ដីសុខទៅហោង ៗ ក្រោយតាប័នមានចិត្តសង្ស័យថា ឱសត្វទាំងបួននេះនឹងមានវេរានឹងអញតទៅមុខពុំលែងឡើយ វានឹងធ្វើបាបអញនោះមិន

ខាន ដូច្នេះអញទិញដែកឲ្យច្រើន ធ្វើកំបិតកោរដងដែកឲ្យបាន៥០ឬ៦០ទុកបម្រុងការខ្លួនដែលស្លាប់ទៅនោះ តាប៉ននិតធ្វើកំបិតបានស្រេចហើយ គាត់ក៏បានហៅកូនចៅមកផ្ដាំថា បើអញស្លាប់ទៅហើយយកអញទៅកប់ ឲ្យយកកំបិតទាំងអស់នេះទៅដាក់លើផ្នូកុំឲ្យខាន-បូកដីលុបឲ្យជិតលុះដល់ ៥-៦ ថ្ងៃឲ្យកូនចៅនាំគ្នាទៅមើលផ្នូរអញកុំឲ្យខាន តាប៉នបានផ្ដាំកូនចៅរួចហើយ គាត់មានជម្ងឺឈឺក្បែរទៅ ឯកូនចៅបានយកខ្មោចតាប៉នទៅកប់ធ្វើដូចបង្គាប់គាត់មិនខាន ។ និយាយពីសត្វទាំង ៤ ដែលមានពៀរនឹងគ្នានោះ កាលតាប៉នស្លាប់ទៅបាន៣ថ្ងៃ សត្វបបកស៊ើបដឹងថា តាប៉នស្លាប់ ទៅប្រាប់ខ្លាឃ្មុំៗប្រាប់ដំរីៗទៅប្រាប់ខ្លាធំ ផ្ដុំបបួលគ្នាចូលមកកាយខ្មោចតាប៉ននាំលោកស៊ី បបកកាយបុងជើង ខ្លាឃ្មុំកាយខាងក្បាល ខ្លាធំសុំកាយកណ្ដាលខ្លួន ឯដំរីឈរចាំមើលឃើញសត្វទាំង៣ មុតជើងពិការជាខ្លាំងដួលដេកអស់ ដំរីនឹកខឹងនឹងខ្មោចតាប៉នថា ដើរអាប៉នកាបតាំងពីរស់ទាល់តែស្លាប់មិនលែងសោះ ទុកឲ្យអញឯង

ឈ្លូសតែម្តងឲ្យប៉ើងខ្មោចមកនៅលើគោក ដំរីខឹងណាស់លើក ជើងឈ្លូសជាខ្លាំងត្រូវនឹងកំបិតមុតពេញជើង ក៏ដួលដេកទាំងអស់គ្នាជាស្លូវរេបហោង ។ និយាយពីកូនចៅដល់កំណត់៣ថ្ងៃនាំគ្នាទៅមើលខ្មោច ស្រាប់តែឃើញដំរី ខ្លា បបកស្លាប់ខាងផ្ទួ នាំគ្នាពន្លះយកសាច់ ស្បែក ឆ្អឹង ភ្លុក មកលក់យកប្រាក់ធ្វើបុណ្យខ្មោចតាបន់រំលោកជាស្លូវរេបហោង ៚

ស្រុកកំពង់ធំពីដើមមកមានបណ្ដាលហេតុជាប្លែកណាស់ កាលណោះនៅឆ្នាំ ១៩០៥ មិនដឹងហេតុអ្វី ផ្ទះសំបែងតែពេលថ្ងៃត្រង់ឡើងឆេះតែឆេះមនុស្សជ្រួលច្របល់ វត្តកំពង់ធំឆេះក្នុង ១ ថ្ងៃ ពីរឬបីដង កុដិលោកសង្ឃនៅស្ងៀមស្ងាត់ ៗ ស្រាប់តែឆេះ លោកសង្ឃរត់ព្រោងព្រាតបោលកុដិអារាមអស់ ខ្សែមាសអ្នកស្រុកដាក់ក្នុងហិបសោះ ស្រាប់តែទៅឃើញពាក់នៅលើដើមស្វាយ ទៅមើលហិបនៅជិតឈឹងសោនៅទាំងអស់ ស្រាប់តែបាត់មាសប្រាក់ពីក្នុងហិបទៅ ម្ចាស់ដើរទៅលេងក្រោមដើមស្វាយ ស្រាប់តែឃើញជ្រុះពីលើដើមស្វាយមក តែនឹងរកមនុស្សដែលអុចនោះមិនឃើញ ឆេះផ្ទះនេះកំពុងតែនាំគ្នាលត់មិនទាន់រលត់អស់ ស្រាប់តែឆេះផ្ទះរបិនឯណោះទៀត ឆេះនោះគឺចំនួនប្រហែលមួយខែទើបបាត់ អំពីខ្សែមាសលោកចៅហ្វាយស្រុកកែវដាក់នៅក្នុងហិប លោកចៅហ្វាយស្រុកកែវដើរទៅតាមថ្នល់ទៅឃើញខ្សែមាសនោះនៅកណ្ដាលផ្លូវ ហេតុទាំងនេះធ្ងល់ណាស់ តែតាមពាក្យចាស់ ៗ និទានមកនោះថា

ខ្មោចកាចវាដើរអុចតែសង្កេតមើលទៅប្រហែលជាមែន ព្រោះរកមនុស្សមិនឃើញសោះស្រាប់តែឆេះយ៉ាងនេះ ហើយបាត់អស់មាសប្រាក់ទៅនៅឯកណ្ដាលថ្នល់វិញ រឿងនេះបណ្ដាលមកពីលោកតេជោ នុត ព្រោះលោករើព្រះវិហារចាស់ដើម្បីនឹងធ្វើព្រះវិហារថ្មី ហើយលោកយកព្រះពុទ្ធរូបទៅដាក់នៅក្រោមដើមពោធិកណ្ដាលវាល នោះទាល់តែយកព្រះពុទ្ធរូបនោះមកដាក់កន្លែងដដែលវិញ ហើយនិមន្តលោកសង្ឃសូត្រមន្តបីយប់បីថ្ងៃ ទើបបាត់ទៅ ។

## បញ្ជីរឿង


១ — អំពីប្រាសាទខ្មែរ ១ ដែលលោក ដាឡេត៍ ទើបរកឃើញក្នុងខែត្រកំពង់ឆ្នាំង ក្រមការ ដុំ-មៅ ប្រែជាភាសាខ្មែរ . . . . . . . . . . . . . . . ៦៧

២ — សប្បុរិសធម្មកថា របស់សម្ដេចព្រះមហាសមណ ប្រែនឹងរៀបរៀងជាភាសាសៀម ភិក្ខុ ឈិន-ស៊ុម (សទ្ធម្មបញ្ញា) ក្រុមជំនុំប្រែព្រះត្រៃបិដក ប្រែនឹងរៀបរៀងជាភាសាខ្មែរ . . . . . . . . . . . . . . . . . ៧៥

៣ — សាសនប្រវត្តិ ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិត នៅព្រះរាជបណ្ណាល័យ រៀបរៀង (ត) . . . . . . . . . . . . . . . . . . ៨៧

៤ — រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយ៖

១ — រឿងមនុស្សលោក . . . . . . . . . . . . . . . . . . . ១០៩

២ — អំពីស្រុកកំពង់ធំពីដើម . . . . . . . . . . . . . . . . ១១២

៣ — រឿងអាខ្វាក់នឹងអាខ្វិន . . . . . . . . . . . . . . . . . ១១៣


## រូបថត


ប្រាសាទខ្មែរ ១ ដែលលោក ដាឡេត៍ រកឃើញក្នុងខែត្រកំពង់ឆ្នាំង . . . . ៦៧

# TABLE DES MATIÈRES

I. Un nouveau monument khmèr découvert et décrit par M. R. Dalet ........................................ 67

II. Sappurisadhamma katha par Mahâ Samana chef suprême des bonzes au Siam, traduit du Siamois par l'Achar Chhim - Soum (Saddhamma Panna) membre de la commission du Tripitaka ............................ 75

III. Sasanapravatti ou Histoire des religions, par Préas Maha Pitou Krasém, pandit à la Bibliothèque Royale (suite)... 87

IV. Contes populaires cambodgiens inédits:

I° Conséquence d'une cupidité .......................... 119

II° Histoire du Srok de Kompong-Thom ................ 112

III° L'Aveugle et le Paralytique ........................ 113

## ILLUSTRATION.

Un monument khmèr nouvellement découvert par M. R. Dalet dans la Province de Kompong-Chhnang....... 67



ប្រាសាទបុរាណខ្មែរមួយនៅក្នុងខែត្រកំពង់ឆ្នាំង ដែលលោកផាទៀត់បានរកឃើញ

# អំពីប្រាសាទខ្មែរ ១ ដែលទើបរកឃើញ

ខ្ញុំមានសេចក្ដីសង្ស័យក្នុងចិត្ត ដោយបានឃើញសន្ទឹកផែនទីស្រុកខ្មែរមានកត់សំគាល់ប្រាសាទបុរាណ ក្នុងដំបន់ខេត្តកំពង់ឆ្នាំង សេចក្ដីសង្ស័យនេះ នាំឲ្យខ្ញុំតាំងប្ដេជ្ញាចិត្តនឹងយាត្រាទៅកាន់ទីប្រាសាទបុរាណ ដែលមិនទាន់មានអ្នកណាពោលរឭកនាដល់ជាប់ដល់មកសព្វថ្ងៃនេះ ។

នៅថ្ងៃអាទិត្យ ១ ខ្ញុំក៏បានចេញទៅ ហើយវេលាដែលបានបែកផ្លូវពីកន្លែងទៅតាមផ្លូវឆ្នុកទ្រូទៅ ខ្ញុំក៏ទើនឹងទឹកលិចទាន់ ព្រោះជាផ្លូវដែលទឹកលិចពាសពេញទីដំបន់ដែលជាមាត់ទន្លេសាប ។

ក្នុងវេលានោះខ្ញុំបានជួលទូកចែវ ១ ដែលរកជួលបានដោយងាយឥតលំបាក លុះឆ្លងទូកទៅប្រមាណកន្លះម៉ោងក៏ដល់ទៅទីទួល ១ កន្លែង ដែលនាំឲ្យខ្ញុំចង់ដឹងចង់ឃើញ ។

គឺជាទីទួលដែលមិនដែលលិចទឹកសោះ ហើយមានពួកអ្នកនេសាទ ១ ពួកនៅ ៗ ទីនោះ ។

នៅចំកណ្ដាលទួលមានវត្តសម័យថ្មី ១ សាងនៅលើនោះ ហើយនៅកន្លែងជ្រលខាងជើងនៃទួលនោះ ខ្ញុំប្រទះឃើញប្រាសាទបុរាណ ២ ធ្វើដោយឥដ្ឋ ១ នៅល្អ ១ ទៀតបាក់បែកគ្រាំគ្រា គឺជាប្រាសាទកំពង់ព្រះ ។

វេលាដែលបានឃើញដូច្នេះហើយ ខ្ញុំក៏តាំងកត់ត្រាសំគាល់បែបបទប្រាសាទទាំងពីរនេះ តាំងគូរជាហាត់ដោ ហើយកត់ត្រានូវរូបភាពទៀត ។

ប្រាសាទទាំងពីរនេះផ្ដោះមុខទៅខាងទិសពាយព្យ ទំនងជាទិសនេះរើសយកតាមភពទំនងលំនាំភូមិស្ថានពីដើម តែសព្វថ្ងៃនេះមិនឃើញមានទេ មិនមែនជាយកតាមលំនាំទំនប់មាត់ទន្លេ ដែលគេប្រទះឃើញជាច្រើនកន្លែងតាមផ្លូវត្រើយខាងទិសនិរតីនៃទន្លេសាប ដែលមានទំនងជាវង់វៀនតាមមាត់ទន្លេសាបទៅ ។

ប្រាសាទដែលនៅល្អជាងគេ គឺប្រាសាទដែលជាការរចនាជាន់ដើម គឺក្នុងសម័យមុនអង្គរ, ជាប្រាសាទដែលមានប្រយោជន៍ ហើយកម្រមនុស្សបានស្គាល់ ព្រោះប្រាសាទទាំងនេះ ស្ទើរតែមិនមានបែបផែន នៅក្នុងប្រជុំអង្គរ គឺជាប្រាសាទដែលមានហាត់ដោរ តម្លូនជ្រុងទ្រវែង (ទទឹង ៤ ម៉ែត្រ ជំរៅ ៣ម, ៧៤) ។ នៅចំពីមុខមានទ្វារមែនទែន ១ ផ្ដោះមុខទៅខាងជើង ហើយមានទ្វារបញ្ឆោត ៣ ទៀតផ្ដោះទៅទិសឯទៀត, ឯស្លាបទ្វារ, ក្របមេទ្វារ, សសរឯបះម ទ្វារនឹងស៊ុំទ្វារសុទ្ធតែធ្វើពីថ្មភក់ទាំងអស់ (រូបទី ១) ។

ឯស្លាបទ្វារបញ្ឆោតទាំងអស់សុទ្ធតែប្រដាប់ដោយផ្កាភ្ញីនិងស្លឹកពាសពេញ ហើយឯប្រអប់ស្លាបទ្វារទាំង ៤ សម្រាប់ទ្វារនីមួយ ៗ សុទ្ធតែរចនាដោយចំឡាក់យ៉ាងឆ្មារក្បាច់រស់រវើក ជារូបសត្វឬជារូបមនុស្ស ។ ឯសសរអមមេទ្វារក៏រចនាយ៉ាងមូលក្ងំ ហើយយ៉ាងសំខាន់ ហើយស៊ុមទ្វារនោះរចនាជាក្បាច់ភ្ញីសន្លឹកឈើ (រូបទី ២) ។

នៅពីខាងលើទ្វារពិតឬទ្វារបញ្ឆោតនោះ មានហោជាងធ្វើដោយឥដ្ឋមានរាងជាអក្សរ(អ៊ីយ. ហាំង ប ផ្កាប់ចុះទៅវិញ ហើយបំពៀចបន្តិច ។

ឯតួប្រាសាទនោះប្រដាប់ដោយសសរ ៤ ជ្រុងរចនាដោយក្បាច់ស្លឹកកន្ទុត ហើយនៅចន្លោះកណ្ដាលមានក្បាច់ពងត្រី (នៅសសរក្លោងទ្វារនោះគ្មានក្បាច់បន្ទុំពងត្រីទេ) ។ នៅទីផ្ទៃខាងក្រោមមានក្បាច់សិទ្ធពុម្ពរចនាដោយក្បាច់មានបែបផ្សេង ៗ ចំណែកឯក្បាច់ក្បាំងខាងលើក៏រចនាដូចគ្នានឹងខាងក្រោមដែរ ប៉ុន្តែផ្ទុយគ្នានឹងខាងក្រោយ ត្រង់ក្បាច់សិទ្ធពុម្ពធ្វើជាដរនោះត្រឡប់ធ្វើជាហ្វូងសត្វហើរវិញ ប្រហែលជារូបសត្វហង្ស ។

ក្នុងថ្នាក់នីមួយ ៗ ក៏មានរចនាជាក្បាច់ចំឡាក់ផ្សេង ៗ ដែរ ប៉ុន្តែជាក្បាច់បន្ថយទំហំនឹងកំពស់ឲ្យតិចចុះ ។

កំពូលប្រាសាទកប់បាត់ក្នុងសុំទ្រុំមែកឈើ ពិនិត្យមើលទៅឃើញមានការជួសជុល ក្នុងសម័យក្រោយណាស់មកហើយ ។

ស្នាមជានដែលជាប់នៅ ៗ ឡើយ ធ្វើឲ្យឃើញជាដំបូលរោងភាងជាដំបូលផ្ទះខ្មែរ មានផ្ទៃដំរាលសងខាង ខាងជើងនឹងខាងត្បូង ហើយប្រកបដោយក្បាច់លំអតូច ៗ ។ ដំបូលនេះកាលពីដើមទំនងជាមានកំពូលស្រួច ៗ យ៉ាងដើត ដែលសព្វថ្ងៃធ្លាក់មកនៅលើដី នៅជិតគេហស្ថានថ្មីមួយដែលសាងជិតទីនោះ ។ ជាចន្លោះកំពូលទាំងពីរនេះទំនងជាមានក្បាច់ដរធ្វើដោយថ្មភក់បន្តុបលើមេដំបូលនោះ ។

ឯប្រាសាទទី ២ គឺប្រាសាទខាងត្បូង នោះបាក់បែកគ្រាំគ្រាជាខ្លាំងណាស់ នៅឃើញតែតួប្រាសាទធំប៉ុណ្ណោះ ហើយក្បាំងក្លោងទ្វារខាងជើងស្ទើរតែនឹងរលាសបាក់បង់ ប្រាសាទនេះមានហាត់ដោរាងបួនជ្រុងធម្មតា មានក្បាំងក្លោងទ្វារបញ្ឆោត ៣ ធ្វើដោយឥដ្ឋ ឃើញនៅសល់តែចំណែកថ្នាក់ទី ១ បន្តិច ។ ជាមានក៏ពួងលំយើងពេកណាស់ ព្រោះប្រាសាទនេះមិនសូវមានប្រយោជន៍ដូចប្រាសាទឯទៀតក្នុងទីនោះ ។

ប្រាសាទដែលបាក់បែកអស់ពាក់កណ្ដាលនេះ តាមដំណឹងថាជាកន្លែងសម្រាប់តម្កល់នូវកំទេចទេវរូបផ្សេងៗ ដែលបាក់បែកតាំងពីជាន់ណាៗមក គឺជាម៉ឺនសម្រាប់បញ្ចុះរូបទាំងឡាយ ។

ក្នុងបណ្ដាកំទេចបាក់បែកទាំងប៉ុន្មានក្នុងទីនោះ គ្មានណាមួយដែលគួរឲ្យប្រារព្ធពោលដល់ទេ មិនដូចជាថ្មមូលពីរដែលមាននៅក្នុងប្រាសាទធំឡើយ ។

នៅទីខាងលើថ្មនេះ មានស្នាមជើងពីរ ដែលមានសណ្ឋានខ្វងហើយរាងស្រាល មានជណ្ដើរ ៤ ឡើងទៅកាន់ទីនោះ ដែលមានលាក់ជាកាំៗ នៅជាប់នោះជណ្ដើរនីមួយៗ នោះមានថ្នាក់ ៣ ដែលមានរចនាជារូបមនុស្សនឹងរូបសិង្ហ មានក្បាច់ស្លឹកកន្ធូតខាង ពីមួយទៅមួយ ។ ថ្មខាងក្រោមក៏មានជណ្ដើរ ៤ ដែរ មានរចនាជារូបដូចគ្នាដូច្នោះដែរ ។ គឺជាសិរីបាទ (ស្នាមជើងព្រះឥស្វរ) ដែលគេសាងទុកដោយមានសេចក្ដីជឿដូចគ្នានឹងក្នុងព្រះពុទ្ធសាសនាដូច្នោះដែរ គឺអ្នកកាន់ព្រះពុទ្ធសាសនាគេតែងធ្វើព្រះពុទ្ធបាទសម្រាប់គោរពនមស្សការ ប៉ុន្តែក្នុងស្រុកខ្មែរដូចជាក្របន្តិច ព្រោះសព្វថ្ងៃនេះបានដំណឹងថា មានតែមួយនៅឯថាតបាបុង ក្នុងស្រុកលាវ ។

ប្រាសាទនេះទំនងជាកសាងតាំងពីសម័យជាន់ដំបូង ព្រោះសិរីបាទនៅកំពង់ព្រះនោះជាការរចនាជាន់ដើម គឺក្នុងរវាងពុទ្ធសាសនា ១០៤៣ ដល់ ១៣៤៣ ឆ្នាំ (រូបទី ៣ នឹងទី ៤) ។

ឥតមានអក្សរចារឹកអ្វីជាទីអាងនាំឲ្យដឹងថា ប្រាសាទទាំងពីរដែលបានរកឃើញនេះសាងពីកាលណាឡើយ ប្រាសាទខាងកើតនោះមានទំនងជាសម្រាប់ព្រះពុទ្ធសាសនា តែមិនមានអ្នកឯណាដឹងជាច្បាស់លាស់ទេ ។ កន្លែងនោះកាលពីដើមជាកន្លែងសំខាន់ ១ ក្នុងបណ្ដាភូមិឋានដែលរៀងរាយតាមមាត់ទន្លេសាប ដូចជាសព្វថ្ងៃនេះមានផ្លូវពីភ្នំពេញទៅបាត់ដំបង ដែលភ្ជាប់ខេត្រផ្សេងៗ ពីទិសខាងត្បូងទៅទិសខាងលិច ដូច្នោះឯង ។

រ. ជាឡេត

# សប្បុរិសធម្មកថា

របស់សម្តេចព្រះមហាសមណ ប្រែនិងរៀបរៀងជាភាសាសៀម

ភិក្ខុឈឹម-ស៊ុំ (សទ្ធម្មបញ្ញា) ក្រុមជំនុំប្រែព្រះត្រៃបិដក

ប្រែនិងរៀបរៀងជាខេមរភាសា ។

ព្រះសិរីសម្មតិវង្ស បាងហ្វាងសាលាបាឡីជាន់ខ្ពស់

បានពិនិត្យផ្ទៀងផ្ទាត់

សប្បុរិសជម្មកថា

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ជីរន្តិ វេ រាជរថា សុចិត្តា
អថោ សរីរម្បិ ជរំ ឧបេតិ
សតញ្ច ធម្មោ ន ជរំ ឧបេតិ
សន្តោ ហវេ សព្ភិ បវេទយន្តិ ។

សម្ដេចព្រះសម្មាសម្ពុទ្ធម្ចាស់ ជាបរមសាស្ដាចារ្យ មានព្រះករុណាក្នុងសត្វទាំងឡាយមិនរើសមុខ ទ្រង់ស្វែងរកប្រយោជន៍ ព្រះទានជានិច្ច ទ្រង់បំពេញពុទ្ធកិច្ចត្រាស់ទេសនាប្រៀនប្រដៅប្រជាជន ឲ្យបានសម្រេចប្រយោជន៍ទាំង ៣ គឺប្រយោជន៍ជាតិនេះ ប្រយោជន៍ជាតិមុខ នឹងប្រយោជន៍ផុវព្រះនិព្វានជាទីរំលត់ទុក្ខ តាមសមគួរដល់ឧបនិស្ស័យ នឹងសេចក្ដីបដិបត្តិរបស់ជនទាំងឡាយ ។ កាលបើមានហេតុអ្វីកើតឡើង ព្រះអង្គទ្រង់ប្រារព្ធហេតុនោះហើយ ត្រាស់ប្រៀនប្រដៅដឹកនាំឲ្យដម្កល់នៅក្នុងផ្លូវដែលជាប្រយោជន៍ ។

ព្រះសទ្ធម្មទេសនារបស់ព្រះអង្គ ដែលប្រារព្ធហេតុដទៃ ៗ លើកទុកចុះ នឹងសម្តែងតែព្រះសទ្ធម្មទេសនាដែលប្រារព្ធនូវវិបរិណាមធម៌ គឺសេចក្តីប្រែប្រួលរបស់សង្ខារ ដោយអំណាចជរា ព្យាធិ នឹងមរណៈ ។ សេចក្តីចាស់ សេចក្តីឈឺ សេចក្តីស្លាប់ មិនមែនជារបស់ពេញចិត្តទាំងអស់ មិនមានអ្នកឯណាចង់ប្រទះចង់ឃើញសោះ តែជាធម្មតារបស់សង្ខារត្រូវតែដូច្នោះ។ កាលបើនឹកដល់សេចក្តីចាស់ -ឈឺ- ស្លាប់ដោយឧបាយដ៏ប្រពៃក៏រមែងញ៉ាំងប្រយោជន៍ឲ្យកើតបាន ដូចជាថ្នាំដែលមានរសល្វីងមិនជាទីគាប់ចិត្តឡើយ តែបើអ្នកមានរោគបេះបរិភោគឲ្យត្រឹមត្រូវតាមវិធីថ្នាំ ថ្នាំក៏រមែងញ៉ាំងរោគឲ្យវិនាសបាត់បង់ទៅបាន ។

ហេតុដូច្នោះសាធុជនអ្នកមកប្រទះឃើញ វិបរិណាមធម៌របស់សង្ខារ ដូចជាក្នុងពេលបុណ្យបូជាសពញាតិមិត្ត ក៏គួរគិតដល់ជរា ព្យាធិ នឹងមរណៈជាហេតុ តែត្រូវគិតដោយអាការដ៏ប្រពៃ ដែលជាអាការធ្វើឲ្យបានប្រកបកិច្ចគួរសម ដោយអប្បមាទធម៌ ។ សម្តេចព្រះបរមសាស្តាចារ្យ ទ្រង់ប្រារព្ធនូវ

ហេតុគឺជរា ព្យាធិ នឹងមរណ ដូច្នេះហើយ ទើបត្រាស់ប្រៀនប្រដៅឲ្យកំណត់ដឹងនូវធម្មតារបស់សង្ខារ នឹងឲ្យដម្កល់ខ្លួនក្នុងធម្មានុធម្មបដិបត្តិ គឺប្រព្រឹត្តធម៌ដ៏សមគួរដល់ធម៌ ។

ឥឡូវនេះនឹងនាំព្រះបាលីដែលព្រះអង្គប្រៀនប្រដៅនោះ មកអធិប្បាយឲ្យដាក់ច្បាស់ ។ ក្នុងទីមួយ ព្រះអង្គត្រាស់ទេស្នាថា ជីរន្តិ វេ រាជរថា សុចិត្តា រាជរថរបស់ម្ចាស់ផែនដីដ៏វិចិត្រល្អក៏ចាស់គ្រាំគ្រា អថោ សរីរម្បិ ជរំ ឧបេតិ ម្យ៉ាងទៀត សរីររាងកាយ ក៏រមែងចូលទៅកាន់សេចក្ដីគ្រាំគ្រា សតញ្ច ធម្មោ ន ជរំ ឧបេតិ មានតែធម៌របស់សប្បុរសទាំងឡាយ ទើបមិនចូលទៅកាន់សេចក្ដីគ្រាំគ្រា សន្តោ ហវេ សព្ភិ បវេទយន្តិ សប្បុរសទាំងឡាយរមែងបរបាឲ្យពួកសប្បុរសផងគ្នាចូលចិត្តដូច្នេះ ។

អធិប្បាយសេចក្ដីនៃព្រះបាលីនោះថាៈ សភាវៈ គឺជាតុផ្សេងៗដែលហេតុនោះៗតុបតែងឡើង បានឈ្មោះថាសង្ខារ ។ សង្ខារនោះ ចែកចេញជា ២ ប្រការ សង្ខារមិនមានចិត្តគ្រប់គ្រង ហៅថា អនុបាទិន្នកប្រការ ១ សង្ខារមានចិត្តគ្រប់គ្រង ហៅថា ឧបាទិន្នកប្រការ ១ ។ សង្ខារទាំង ២ ប្រការនេះ មាន

សេចក្ដីប្រែប្រួលជាលក្ខណដូចគ្នាតែម្យ៉ាង សម្ដេចព្រះដ៏មាន
ព្រះភាគជាម្ចាស់ ទ្រង់លើកសេចក្ដីចាស់គ្រាំគ្រារបស់រាជរថ
ឡើង សម្ដែងជាតួយ៉ាងនៃសេចក្ដីប្រែប្រួលរបស់សង្ខារមិនមាន
ចិត្តគ្រប់គ្រង ទ្រង់លើកសេចក្ដីគ្រាំគ្រានៃរាងកាយឡើងសម្ដែង
ជាតួយ៉ាងនៃសេចក្ដីប្រែប្រួលរបស់សង្ខារមានចិត្តគ្រប់គ្រង ។

ឯរថដែលនាយជាងកាន់យកសម្ភារៈនោះៗ មកប្រុងផ្ដុំធ្វើ
ឡើងហើយតាក់តែងឲ្យវិចិត្រល្អ កាលបើប្រើទៅៗ ក៏ចាស់គ្រាំ
គ្រាគ្រប់អន្លើ គ្រឿងប្រដាប់ប្រដាក៏សៅហ្មង អវយវក៏វៀចវេរបែ
របោមិនគង់ទ្រង់ លុះរបស់ថ្មីៗកើតឡើង ក៏ល្អជាងរបស់ចាស់
ឡើងទៅជាឯរាប របស់ចាស់ៗ ក៏អាប់អួនថយចុះមកតាម
លម្ដាប់ ។ (រថដែលគ្រាំគ្រាទៅដូច្នេះ ក៏មិនកំណត់តែត្រឹមរថ
ដែលទឹមសេះឡើយ ទុកជារទេះដែលទឹមគោ ឬរថយន្តដែលប្រើ
គ្រឿងម៉ាស៊ីន ក៏រមែងដូច្នេះជាធម្មតា មិនត្រឹមតែរថនឹងគ្រឿង
ពាហណប៉ុណ្ណោះឡើយ សេចក្ដីគ្រាំគ្រានេះតែងមានជាសាធា-
រណទូទៅដល់ទ្រព្យរបស់ដទៃៗទៀត ដូចគ្នាទាំងអស់ ដូច
គ្រឿងតែងកាយរបស់មនុស្ស ល្អបានតែក្នុងសម័យ ១ គឺក្នុង

សម័យដែលនៅថ្មីហើយអ្នកផងគេនៅត្រូវការប្រើប្រាស់ប៉ុណ្ណោះ លុះដល់សម័យដែលគ្រឿងនោះចាស់ហើយ អ្នកផងគេមិនត្រូវការ គេតែងចាត់ថាជារបស់មិនល្អរបស់ទាស់សម័យ បើអ្នកឯណាប្រើរបស់ចាស់របស់ទាស់សម័យអ្នកនោះនឹងជាសំណើចអ្នកផង ។

ម្យ៉ាងទៀតសរីរាងកាយនេះក៏ដូចគ្នា កាលនៅក្នុងបឋមវ័យ ក៏បរិសុទ្ធស្អាតរពេញរពៅស្រដៅស្រដើប្រសើរថ្លៃថ្លា ពណ៌សម្បុរក៏ភ្លឺបំព្រងមានកម្លាំងរឹងប៉ឹង សេចក្ដីគិតអានក៏ឆ្លៀវឆ្លាស លុះកន្លងវ័យនោះទៅ ក៏ទ្រុតទ្រោមដោយលម្ដាប់ សេចក្ដីបរិសុទ្ធក៏បាត់បង់ទៅ កម្លាំងក៏ថយទៅ ចិត្តក៏រវាតរវើរវាយ សេចក្ដីដែលគួរចេះគួរដឹងដោយងាយក៏ត្រឡប់ទៅជាក្រ ចំណេះចំណាំដែលធ្លាប់ចេះធ្លាប់ចាំ ក៏ភ្លេចភ្លាំងទៅដោយច្រើន ភ្នែកក៏ងងឹត ត្រចៀកក៏ថ្លង់, មិនតែប៉ុណ្ណោះឡើយ កាលដើមជាមនុស្សរៀងវៃមានសេចក្ដីចេះដឹងច្រើន ជាមនុស្សអង់អាច បានជាទីនិយមរាប់អានក្នុងទីប្រជុំជន លុះហួសសម័យនោះហើយ សេចក្ដីចេះដឹងក៏ត្រឡប់ជាប្រើមិនបាន មិនទាន់មនុស្សខាង

ក្រោយ ព្រោះគុណសម្បត្តិទាំងនោះជាសំខតធម៌ រមែងប្រែប្រួលទៅតាមកាលៈ និងទេសៈ គឺផ្លាស់ផ្ទូរទៅតាមវេលា និងផ្លាស់ផ្ទូរទៅតាមប្រទេស នេះជាតួយ៉ាងនៃសេចក្ដីប្រែប្រួលរបស់សង្ខារមានចិត្តគ្រប់គ្រង ។

សម្ដេចព្រះបរមសាស្ដាចារ្យ ទ្រង់សម្ដែងសង្ខារដែលមានជរា សេចក្ដីចាស់គ្រាំគ្រាជាលក្ខណស្មើគ្នាទាំងពីរប្រការដូច្នេះ ហើយក៏ដឹកនាំបរិសទ្យ ឲ្យដម្កល់នៅក្នុងគុណសម្បត្តិដែលជាសេចក្ដីល្អដល់ខ្លួន ទើបទ្រង់សម្ដែងធម៌របស់សប្បុរសថា ជាគុណមិនចូលទៅកាន់ជរា គឺមិនមែនចាស់ មិនមែនគ្រាំគ្រា មិនប្រែប្រួល ។

សេចក្ដីប្រព្រឹត្តស្ងប់ស្ងៀមសុភាពរៀបរយ និងសេចក្ដីបដិបត្តិដ៏ដឹកនាំឲ្យជាអ្នកដូច្នោះ ឈ្មោះថាធម៌របស់សប្បុរសដោយឫសគល់ ។ ពោលដោយប្រភេទ ធម៌របស់សប្បុរសនោះមានច្រើនយ៉ាង នឹងសម្ដែងល្មមជាឧទាហរណ៍តែមួយយ៉ាងដែលហៅថាធម៌ ៧ ប្រការ ។ ធម៌ ៧ ប្រការនោះគឺ សទ្ធា ហិរិ ឱត្តប្ប ពាហុសច្ច វីរិយ សតិ បញ្ញា ។

សទ្ធានោះគឺជឿហេតុផលដែលគួរជឿ ដូចជឿក្នុងផ្លូវកម្ម ផ្លូវផលថា ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ ។ សទ្ធានេះ ជាគុណដែលឲ្យបុគ្គលប្រព្រឹត្តសេចក្ដីល្អមាំមួន បើគ្មានសទ្ធា នោះ សេចក្ដីប្រព្រឹត្តក៏នឹងប្រែប្រួលទៅព្រោះហេតុការណ៍នោះៗ ចូលមកលុកលុយសម្រើបសម្រាល ឬគម្រាម ហេតុដូច្នោះ បានជាមានពុទ្ធភាសិតសរសើរថា សទ្ធាទុកដូចជាភើនសម្លាញ់ ពីរនាក់ ឬទុកដូចជាស្បៀង របស់អ្នកដំណើរ ។

ហិរិនោះគឺសេចក្ដីខ្មាសដល់ចិត្ត មិនក្លាហានក្នុងអំពើ បាប ។ ឱត្តប្បនោះគឺសេចក្ដីក្រែងខ្លាចការខុសបាកធម៌ ។ គុណពីរប្រការនេះ មានពុទ្ធភាសិតសរសើរថាជាធម៌ដ៏ផ្លូវផង់ផង ថាជាធម៌រក្សាលោកផង បើកើតក្នុងសន្តានអ្នកឯណាហើយ នឹងញ៉ាំងអ្នកនោះឲ្យប្រព្រឹត្តកាយវាចាចិត្ត ក្នុងផ្លូវបរិសុទ្ធ ក្នុង ទីដ៏កំបាំងនឹងក្នុងទីដ៏មិនកំបាំង នឹងឃុំគ្រងអ្នកនោះមិនឲ្យធ្លាក់ ទៅក្នុងទីអាក្រក់ ។ ពួកជនទាំងឡាយមានហិរិឱត្តប្បប្រើន គ្នា ពួកនោះ សេចក្ដីបៀតបៀនដល់គ្នានឹងគ្នារមែងមានតិច ។

ពាហុសច្ចនោះ គឺសេចក្ដីបានស្ដាប់បានឮច្រើន បានសូត្ររៀនច្រើន ដឹងខុសដឹងត្រូវ ដឹងបានដឹងបង់ ដឹងអស់ដឹងគង់ ដឹងបាបដឹងបុណ្យ ដឹងគុណដឹងទោស ។ គុណខនេះជាបច្ចាត់នៃសេចក្ដីប្រព្រឹត្ត បើមិនបានស្ដាប់មិនបានឮហើយក្រនឹងប្រព្រឹត្តកាយវាចាចិត្តឲ្យត្រឹមត្រូវបាន ។

វីរិយនោះ គឺសេចក្ដីព្យាយាមដែលឲ្យក្លាហានក្នុងទីវៀសវៃ នឹងវៀរចាកសេចក្ដីអាក្រក់ផ្សេង ៗ នឹងក្នុងទីដែលធ្វើ ឬរក្សាសេចក្ដីល្អនោះ ៗ ។ គុណខនេះជាហេតុធ្វើបុគ្គលឲ្យកន្លងបង់នូវសេចក្ដីទុក្ខបាន អ្នកឯណាប្រាសចាកសេចក្ដីព្យាយាម អ្នកនោះរមែងលិចនៅក្នុងសេចក្ដីទុក្ខ រកសេចក្ដីសុខមិនបានឡើយ ។

សតិនោះ គឺសេចក្ដីនឹកបានមុន ក្នុងកាលនឹងធ្វើនូវអំពើអ្វី នឹងពោលនូវពាក្យអ្វី ឬនឹងគិតនូវគំនិតអ្វី ។ មនុស្សប្រាសចាកសតិ រមែងច្រើនធ្វើខុស និយាយខុស គិតខុស ។ ចិត្តដែលគ្មានសតិឃុំរក្សា រមែងស្ទុះទៅក្នុងអារម្មណ៍ផ្សេង ៗ ដូចរថដែលសេះនាំបោលទៅតាមទំនើងវា គ្មាននាយសារថីកាន់

កាប់ សតិនេះរមែងញាំងបុគ្គលឲ្យបេះប្រយ័ត្ន លោកពោលថាជាធម៌ដាស់ឲ្យភ្ញាក់ក្នុងលោក ។

បញ្ញានោះ គឺសេចក្ដីដឹងហេតុដឹងផលនោះ ៗ ដោយពិតប្រាកដ ។ មនុស្សទាំងឡាយដែលកើតមកក្នុងលោកឈ្មោះថាធ្លាក់នៅក្នុងក្រសែធម្មតា បើមិនចូលចិត្តហេតុផលក៏មិនអាចចៀសចេញចាកវិបត្តិបាននឹងមិនបានលុះសេចក្ដីសួស្ដី បើមានបញ្ញាដឹងហេតុនឹងផលដរាបណា ក៏ចៀសចេញចាកវិបត្តិនឹងលុះសេចក្ដីសួស្ដីដរាបនោះ ។ មានព្រះពុទ្ធភាសិតសរសើរបញ្ញាថា ជាពន្លឺស្វាងដ៏ប្រសើរ មិនមានពន្លឺដទៃស្មើឡើយ បុគ្គលមានបញ្ញា មិនឃុំរក្សាបានតែត្រឹមខ្លួនឯងឡើយ រមែងឃុំរក្សាបានរហូតដល់អ្នកដទៃទៀតផង ហេតុដូច្នោះបានជាបណ្ឌិតបានសរសើរជីវិតរបស់អ្នកមានបញ្ញាថា ជាជីវិតដ៏ប្រសើរ ។ សតិនឹងបញ្ញាពីរប្រការនេះ មានឧបការៈដល់គ្នានឹងគ្នា ជួយគ្នាទៅវិញទៅមក បញ្ញាផ្ទះពន្យល់ហេតុនឹងផលនោះ ៗ សតិចាំកាន់កាប់ឲ្យគ្រាន់តែល្មម រើសយកតែដែរគួរជាប្រមាណ បញ្ញាទុកដូចជាសេះ សតិទុកដូចជានាយសារថី សេះមានកម្លាំង

អាចស្មុះទៅតាមតែបាន ដោយសារបើមានសេចក្ដីដឹងវិធីផ្សេះបោលទៅ ដោយសារបើជាអ្នកញាក់ អ្នកទាំងពីរអ្នកអាស្រ័យគ្នានឹងគ្នា ត្រាតែទៅតាមផ្លូវដ៏ត្រង់បាន ។

ធម៌ទាំង ៧ ប្រការនេះ មានក្នុងបុគ្គលជាសប្បុរស ទើបបានឈ្មោះថា ធម៌របស់សប្បុរស ព្រមទាំង ៧ ប្រការ ជាឧបការៈឲ្យប្រព្រឹត្តស្ងប់ស្ងៀមសុភាពរៀបរយ ។ បណ្ឌិតក្នុងអតីតកាលបានសរសើរធម៌ទាំង ៧ ប្រការនេះមកហើយ ក្នុងបច្ចុប្បន្ននេះក៏នៅតែដូច្នោះ ក្នុងអនាគតក៏នឹងមិនប្រែត្រឡប់ជានិន្ទាវិញឡើយ តែងសរសើរថា បើមាននៅក្នុងសន្ដានជនណា ជននោះ គង់មិនមានសេចក្ដីជឿរវើរវាយ មិនមែនជាមិនអាឥតខ្មាស មិនមែនជាមិនកោតក្រែងដល់សេចក្ដីខុស មិនមែនជាមិនយកចិត្តទុកដាក់ក្នុងការសិក្សា មិនជាអ្នកខ្ជិលច្រអូស មិនមែនជាអ្នកពព្លឹពព្លើលីល្ងើល្ងង់ខ្លៅឡើយ ហេតុដូច្នោះ ទើបធម៌របស់សប្បុរសឈ្មោះថា មិនចូលទៅកាន់ជរា ចាស់គ្រាំគ្រាឡើយ ។

ឯសប្បុរិសធម៌នេះ ជាធម៌បរិជាជរាប ជាធម៌ល្អជានិច្ច ជាបដិបក្ខនឹងអសប្បុរិសធម៌ ៗ នោះក៏មាន ៧ ប្រការដូចគ្នា គឺ

អសទ្ធា អហិរិ អនោត្តប្ប អប្បស្សុត អវីរិយ អស្សតិ អប្ប-ញ្ញា ។ សេចក្ដីអធិប្បាយដូចគ្នានឹងសប្បុរិសធម៌ តែត្រូវថែមពាក្យថា មិនមែនឬមិនមាន នឹងថាជាទោសដូច្នេះវិញ ។

ដែលជាបដិបក្ខនឹងគ្នានោះដូច្នេះគឺ សប្បុរិសធម៌ ជាឧបការៈឲ្យអ្នកជាសប្បុរសបដិបត្តិស្ងប់ស្ងៀម មិនស្វែងរកទោសអ្នកដទៃ ឲ្យបដិបត្តិសុភាពរៀបរយ មិនជំទាស់ឲ្យទើសទែងដល់សេចក្ដីបដិបត្តិរបស់អ្នកដទៃ ឯអសប្បុរិសធម៌ជាឧបការៈឲ្យអ្នកជាអសប្បុរសបដិបត្តិជ្រុលជ្រើមតែងស្វែងរកទោសអ្នកដទៃ ឲ្យបដិបត្តិប្រឆែងប្រឆាំង នាំឲ្យទើសទែងដល់សេចក្ដីបដិបត្តិរបស់អ្នកដទៃ ជនជាសប្បុរសតែងត្រេកអរតាមធម៌ ជនជាអសប្បុរសតែងត្រេកអរតាមទំនើងចិត្ត ។ បណ្ឌិតទាំងឡាយតែងពិន្ទាអសប្បុរិសធម៌ថា បើមាននៅក្នុងសន្ដានជនណា ជននោះតែងមានសេចក្ដីជ្រើសរើសរាយ មិនមានខ្មាស មិនកោតក្រែងដល់សេចក្ដីខុស ជាអ្នកមិនយកចិត្តទុកដាក់ក្នុងការសិក្សា ជាអ្នកខ្ជិលច្រអូស ជាអ្នកពព្លឹពព្លើល្ងីល្ងើល្ងង់ខ្លៅ ប្រកាន់ខុសថាជាត្រូវវិញ ។ ហេតុដូច្នោះទើបធម៌របស់អសប្បុរសឈ្មោះថា ចូលទៅកាន់ជរា

ជាធម៌ចាស់ ធម៌លាមក ធម៌គគ្រក់គ្រាំគ្រា ។ សប្បុរស ទាំងឡាយតែងពេញពាឲ្យពួកសប្បុរសផងគ្នាចូលចិត្តដូច្នេះឯង ។

សាធុជនទាំងឡាយបានស្តាប់ព្រះពុទ្ធភាសិតដូចបានពោល មកហើយនេះ ឃើញថាសង្ខារទាំងឡាយមានសេចក្តីប្រែប្រួល ដោយសេចក្តីចាស់ជរាគ្រាំគ្រាគ្រប់យ៉ាង ឃើញតែសប្បុរិសធម៌ នេះ ជាធម៌ថ្មីសំអាងមិនបានចូលទៅកាន់ជរា សេចក្តីចាស់ គ្រាំគ្រា គួរដម្កល់អាត្មាក្នុងធម៌ជារបស់សប្បុរស ដែលជាគុណ ដ៏ស្ថិតស្ថេរមិនប្រែប្រួលនេះចុះ ទើបសមគួរនឹងព្រះពុទ្ធភាសិត សរសើរទុកថា ជរាព្យាធិមរណមានជាធម្មតា បើអ្នកណាស្វែង រកគុណដែលផុតចាកជរាព្យាធិមរណនោះ ទើបឈ្មោះថា ស្វែង រកដ៏ប្រសើរ ។

សាធុជនអ្នកប្រាជ្ញឃើញវិបរិណាមធម៌នៃសង្ខារគប្បីរំពឹង ដល់ដោយឧបាយដ៏ប្រពៃ ធ្វើឲ្យកើតប្រយោជន៍ដល់ខ្លួនដោយ គួរដល់វេលា ដូចពណ៌នាមកដូច្នេះ ។

# សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម គន្ធវេទបណ្ឌិត

នៅព្រះរាជបណ្ណាល័យរៀបរៀង

(៣)

## ព្រះសិវ

សិវជានាមព្រះជាម្ចាស់របស់ព្រាហ្មណ ១ អង្គ ប្រែថា ករុណា, ថា ក្រុមប្រាសចាកទុក្ខភ័យ, នាមនេះដើមឡើយ ជានាមផ្កាយក្នុងពួកបញ្ចនាគាក្នុងរឿងព្រះបន្ទ្រ នឹងជានាមព្រះរាជាគ្រងក្រុងហៃហយបុរី ដូចពោលហើយ ដើមកំណើតរបស់ព្រះសិវមានរឿងពោលថា កាលនោះ ព្រះព្រហ្មយកឈើកៀរញើសនៅប្រជុំចិញ្ចើម ស្បែកធរីរលាត់លោហិតហូរចេញមកស្រក់ទៅក្នុងទឹកកើតឡើងជាទេវបុត្រ ១ អង្គ នាមរុទ្រ តែទំព្យាយាមសុំនាមនេះនឹងព្រះព្រហ្មដល់ទៅ ៨ ដង ទើបបាន វេលាក្រោយដែលបានជាព្រះហើយ ទើបមាននាមទាំង ១.០០០ យ៉ាង មានសិវ ឥស្វរ (ឥស្វរ) សយម្ភូ ភវានីបតិ នីលកណ្ឋ នឹងភៃរវ ជាដើម ទីលំនៅ ស្ថិតនៅក្នុងប្រាសាទលើកំពូលភ្នំកៃលាស (ដ៏តាំងនៅលើកំពូលភ្នំហិមាល័យជ្រុងខាងជើង មានសម្បុរសដូចប្រាក់ មានកំពូលខ្ពស់ត្រដួចជាប់នឹងមេឃ) មានព្រះជាយានាម ឧមា តែន័យមួយថា មានព្រះជាយាដើម ២ អង្គ

គឺនាងសន្ធ្យា(១) ជាធីតាព្រះព្រហ្ម ១ អង្គ នាងគង្គា ជាបងប្អូនរួមមាតាបិតានឹងនាងឧមា ១ អង្គ, ៣ ទាំងនាងឧមា តែនាងឧមាប្រាកដជា លើកជាឯកអគ្គទេវីក្នុងជាន់ក្រោយ មានឱរស ២ អង្គ គឺព្រះវិឃ្នេស ១ ព្រះកត្តិកេយ ឬហៅមួយយ៉ាងទៀតថា ព្រះស្កន្ទកុមារ ១ មានគោឧសភឈ្មោះ នន្ទិន ជាពាហណា ។ លក្ខណព្រះអង្គគឺមានព្រះមោលីសំបុរលឿងវិលគួបផ្តុំគ្នានៅកណ្តាលព្រះសិរ ជាព្រះត្រីនេត្រ គឺមានព្រះនេត្រ ៣ ព្រះនេត្រ ២ នោះតាំងនៅត្រង់កន្លែងដូចភ្នែកមនុស្សធម្មតា ព្រះនេត្រ ១ ទៀតតាំងនៅកណ្តាលព្រះនលាត ព្រះនេត្រទាំង ៣ នេះ ជាគ្រឿងសំគាល់ព្រះញាណដែលជ្រាបហេតុផលក្នុងអតីត អនាគត បច្ចុប្បន្ន លើព្រះនេត្រទី ៣ មានពិនព្រះចន្ទ្របញ្ចេញរស្មីភ្លឺព្រាក ៗ ជាគ្រឿងសំគាល់រាប់ខែ. មានពុកបង្កាវែងភាពយ៉ាងព្រាហ្មណ៍ តែបើតែងព្រះអង្គជាមហាទេព រមែងគ្មានពុកបង្កា ព្រះសូរង្គសំបុរនិល. មាននាគជាសង្វារពាក់នៅព្រះសូរង្គជាគ្រឿងសំគាល់រាប់ឆ្នាំ, មានឆ្អឹងរលាក្បាលខ្មោចជាផ្គាំពាក់

---

(១) បានជាឈ្មោះថា សន្ធ្យា ព្រោះនាងនេះខ្មៅងងឹតដូចយប់ ។

ទៅព្រះសួរគ្គ ឬជួនកាលកាន់ទៅព្រះហស្តជាគ្រឿងសំគាល់រាប់កល្បរាប់យុគ. ទ្រង់ស្បែកដំរីជាព្រះភូសា, មានស្បែកខ្លាជាកម្រាលរងបង្គុយ, របៀបតែងអង្គ ជួនកាលទ្រង់គ្រឿងបែបក្សត្រិយ៍ ដោយភាវជាមហាទេព, ជួនកាលទ្រង់បែបឫសីដោយភាវជាមហាយោគី, ទ្រង់អាវុធឈ្មោះបក្រករីនិងគទា (ដំបង) និងព្រះខាន់ឬសរ និងត្រីសូល៍ មានកោរី ១ ឈ្មោះឧមរូ ។

ព្រះសិវជាមហាទេពធំក្រៃលែងទេវតាទាំងឡាយ ជាអ្នកទ្រទ្រង់នូវសិល្បសាស្ត្រនិងនាដសាស្ត្រ គឺ ទ្រង់ចេះស្ទាត់ក្នុងក្បួនក្បាច់របាំច្រើនបែបច្រើនយ៉ាង, ជាមហាយោគី គឺជាឫសីធំប្រកបដោយក្តីព្យាយាមបំពេញតបៈ, ជាអ្នកសាងលោក ជាបិតារបស់លោក, ជាអ្នកទ្រង់នូវអានុភាព, ជាអ្នកទ្រង់នូវព្រះគុណ ។ ក្នុងគម្ពីរសិវបុរាណ៍ម និងគម្ពីរកឋាសរិតសាគរសំដែងអំពីការសាងលោករបស់ព្រះសិវថា ទ្រង់រិះសាប់ភ្លៅឲ្យឈាមមួយដំណក់ស្រក់ចុះក្នុងទឹក កើតឡើងជាពង ១ នោះបែកជា ២ បំហៀង ១ បំហៀងទ្រង់និម្មិតឲ្យទៅជាសួគ៌លោក ១ បំហៀងទៀតឲ្យទៅជាមនុស្សលោក លំដាប់នោះទើបកើតជា "បុម" ជាតិបុរស

គឺជីវ (ជីវិត) ឬវិញ្ញាណរបស់លោកឡើង ប្រុមនោះទើបសាងប្រ-ជាបតី គឺបិតាលោកទាំងឡាយមួយដំណាមកទៀត ប្រជាបតីអំ-បាលនោះក៏សាងប្រជាជនតៗទៅ ទើបកើតជាផៅពន្ធុវង្ស មនុស្សនៅក្នុងលោកនេះច្រើនឡើងដោយលំដាប់ ដោយហេតុនេះ លោកទើបហៅ ប្រុម នោះថា "បិតាមហា" ប្រែថា បិតាធំ ។

ក្នុងគម្ពីរឫគវេទថា ប្រុម បុរសដែលកើតអំពីពង ជាយក្ខតួដើមបង្អស់ដែលព្រះជាម្ចាស់សម្លាប់បូជា ស្រេចហើយព្រះជាម្ចាស់ យកកាយយក្ខនោះមកសាងជាលោកនេះឡើង បាននឹងជីវិតិន្ទ្រិយ៍ គឺឥន្ទ្រិយ៍ដ៏មានជីវិត មិនមែនអវិញ្ញាណកសង្ខារ ទើបរាប់ថា បុរសនេះឯងជាលោកនេះនឹងលោកឯមុខ កាលសម្លាប់យក្ខនោះហើយព្រះសិរទ្រង់នឹកអាណិតដល់វា ទើបយកលលាដ៍ក្បាលមកកាន់ទុកជានិច្ច រឿងត្រង់នេះ សុំឲ្យមើលរូបព្រះឥសូរ រូបខ្លះនឹងឃើញលលាដ៍ក្បាលខ្ចោបនៅព្រះហស្ត ជួនកាលនៅក្រោមបង្គុយ ជួនកាលដោតខ្សែពាក់យ៉ាងផ្កា ។

ន័យ ១ ទៀតថា មានធម្មជាតិមួយយ៉ាងហៅថា «ប្រកូតិ» កើតអំពីបុរស លោកថា ប្រកូតិនេះជាតួដើម ឬជាធម្មតាជាតួអំណាចដែលបង្គាប់ឲ្យនានាវត្ថុកើតឡើងក្នុងលោក និងបណ្ដាលវត្ថុទាំងពួងនោះ ឲ្យប្រព្រឹត្តទៅដោយប្រភេទផ្សេង ៗ គ្នា តាមប្រកូតិនិយាម ដូចយ៉ាងបង្គាប់ធាតុនោះ ៗ ឲ្យមករួមផ្សំគ្នាកើតឡើងជាព្រឹក្សជាតិជាដើម ឲ្យមានលក្ខណៈផ្សេងគ្នាច្រើនប្រភេទជាអនេកប្រការ កើតជាឈើយ៉ាងនេះ ហើយនឹងប្រែទៅជាឈើយ៉ាងដទៃទៀតមិនបាន អាស្រ័យអំណាចប្រកូតិឲ្យប្រព្រឹត្តទៅឯងគ្រប់ប្រភេទ ។ ក៏ឯរឿងបុរសនេះ មានន័យសំដែងផ្សេងគ្នា ក្នុងទីខ្លះថា ជាភាគរបស់ព្រះព្រហ្ម ៗ បែងភាគឲ្យមកកើតជាមួយនឹងរីរដ្ឋា ក្នុងទីខ្លះថា ជាភាគរបស់ព្រះឥសូរ ក្នុងទីខ្លះថា ជាភាគរបស់ព្រះនារាយណ៍ ដូច្នេះនឹងសម្រេចថា ជាភាគរបស់ព្រះណាមួយក៏មិនងាយនឹងគិត ។

ដោយសេចក្ដីជឿថា ព្រះសិវជាបិតាលោក ជាអ្នកសាងលោក ពួកអ្នកកាន់សាសនានេះទើបប្រឌិតសាងអនុសាវរីយ៍មួយយ៉ាងទុកជាគ្រឿងរលឹកក្នុងការសាងលោក គឺធ្វើជារូប

សិវលិង្គ (លិង្គព្រះសិវ) នឹងរូបឧមាយោនី (យោនីនាងឧមា) តាមដែលធ្លាប់ឃើញមក ច្រើនធ្វើដោយថ្មហើយបញ្ចុះភ្ជាប់ជាមួយគ្នាយកទៅដំកល់ទុកនៅទីវិហារ ឬទីសម្រាប់គោរពបូជាឯណានីមួយ[១] តែខ្មែរយើងច្រើនហៅថា "ថ្មសយម្ភូ" ហេតុនេះនាងឧមាទើបមាននាមថា ភវានី នាងជាមាតារបស់ភព ព្រះឥស្វរមាននាមថា ភវានីបតិ ប្ដីរបស់នាងមាតាភព ។ រូបនេះមិនសាងទុកសម្រាប់តែជាអនុស្សាវរីយ៍ប៉ុណ្ណោះ ទុកសម្រាប់ធ្វើពិធីសិវរាត្រីលាងបាបលាងចង្រៃឧបទ្រពទាំងពួងផង ។

សំដែងអំពីអានុភាព នឹងព្រះគុណយ៉ាងដទៃទៀតរបស់ព្រះរុទ្រថាជាអ្នកមានអំណាចកាចពន្លឹក អាចនឹងលាងបំផ្លាញលោកនេះឲ្យវិនាសទៅក៏បាន ទើបមាននាមថា ភៃរវ ប្រែថាជាអ្នកលាងយ៉ាងសំបើមមុខគួរស្ញែង ។ តែលាងដូច្នេះគេរាប់អានថាជាល្អ ព្រោះថាកាលទ្រង់លាងរលីងទៅហើយអាស្រ័យព្រះមហាករុណាក៏ទ្រង់ដប់ឬស្ថិតស្ថាងលោកជាថ្មីឲ្យស្អាតប្រាសចាកទោសមន្ទិលឡើងវិញ ព្រោះព្រះគុណ

---

(១) រូបនេះនៅទីប្រាសាទបុរាណក្រុងកោះកេរមានច្រើនណាស់ ។

ខនេះ គេទើបហៅព្រះរុទ្រថា សិវ (ករុណា ឬជប់ឲ្យស្អាត) ១ យ៉ាងទៀត ដោយហេតុទ្រង់ជាអធិបតីក្នុងសារពើគ្រប់យ៉ាង ដូចយ៉ាងនឹងលាងឲ្យស្អាតទៅក៏បាន លាងហើយនឹងជប់ឲ្យកើតឡើងវិញក៏បាន ទើបមាននាមថា ឥស្សរ ព្រះជាធំក្នុងការសាងសារពើនោះ ៗ ។ ព្រះសិវជាព្រះគុណ គឺក្រាស់ទៅដោយគុណ មានព្រះហឫទ័យពេញទៅដោយករុណា សង្គ្រោះទេវតាយក្ខមារមនុស្សទូទៅ ទោះបីអាក្រក់ក្ដីល្អក្ដីមិនថា តែអ្នកណាមានក្ដីភក្ដីតាំងតបពិធីមាំទាំហើយ ក៏តោងប្រទានពរឲ្យអ្នកនោះជាជំរាប ពរដែលប្រទានទៅនោះជាឲ្យទោសឬឲ្យគុណយ៉ាងណា មិនសូវអំពល់នឹងពិនិត្យ ជួនកាលត្រឡប់ឲ្យទោសដល់ព្រះអង្គឯងវិញក៏មាន ដូចមានរឿងថា៖-

គ្រាមួយនោះ អសុរម្នាក់ឈ្មោះពិកាសុរ ជាបុត្រកាស្យបាសុរ ទៅបំពេញតបៈឆ្ពោះព្រះសិវដើម្បីសូមពរ បានធ្វើទុក្ករកម្មរមានរាងកាយយ៉ាងតឹងរឹង ត្រឹម៧ថ្ងៃប៉ុណ្ណោះ បានអារសាច់របស់ខ្លួនបូជាព្រះភ្លើងទាល់តែអស់ទាំងខ្លួន ដល់ថ្ងៃគំរប់៨ប្រារព្ធនឹងកាត់ក្បាលបូជាទៀត ព្រះមហាយោគីទ្រង់ជ្រាប ក៏ត្រាស់

ហាមថា នឹងប្រទានពរឲ្យតាមដែលប្រាថ្នា ព្រឹកាសូរទូលសុំឲ្យ
មានដៃសក្តិសិទ្ធិ ទះក្បាលអ្នកណា ឲ្យឆេះខ្ទេចទៅមួយរំពេច
ព្រះមហាយោគីក៏ប្រទានឲ្យ ព្រឹកាសូរបានពរហើយព្យាយាម
នឹងទះព្រះសិរគ្រូលរមើលជាសក្តិសិទ្ធិមែនឬទេ ព្រះសិវខ្លាចឆេះ
ក៏រត់កើងទៅរកព្រះវិស្ណុជួយ ព្រឹកាសូរក៏ដេញតាមទៅ តែ
គ្រោះហាជា បានព្រះវិស្ណុជួយទើបរួចខ្លួន គឺព្រះវិស្ណុដំណែងខ្លួន
ជាព្រាហ្មណមកសួរព្រឹកាសូរថា ម្តេចអ្នកដេញលោកនេះមក ។
ព្រឹកាសូរតបតាមដំណើរ ។ វិស្ណុព្រាហ្មណទើបប្រើឧបាយដោះ
ស្តុននេះថា អ្នកឯងជាអ្នកមានបញ្ញាជ្រៅជ្រះ ម្តេចក៏មកវង្វេង
ជឿពាក្យកុហកដូច្នេះ បើត្រូវការចង់ដឹងជាសក្តិសិទ្ធិពិតឬមិន
ពិត ក៏ប្តូរទះក្បាលខ្លួនឯងមើល ក៏នឹងដឹងភ្លាម ។ អសុរឆោត
យកដៃស្ទាបក្បាលខ្លួនឯង ក៏ឆេះរឹបទៅជាផេះអស់មួយរំពេច ព្រះ
ឥស្សូរក៏បានរួចអំពីស្មៀតខ្លួនឯងដោយសារគំនិតព្រះវិស្ណុជួយ ។
រឿងនេះជាគួយ៉ាងនៃមហាករុណារបស់ព្រះសិវ ។

## ព្រះវិស្ណុ

នាមវិស្ណុនេះដើមឡើយជានាមព្រះអាទិត្យ តែវេលាក្រោយបានមកជានាមព្រះអង្គនេះ នៅមាននាមឯទៀតជាច្រើនមានហរិ នារាយណ៍ជាដើម ។ លក្ខណៈរូបនៃព្រះវិស្ណុនោះ សំបុរកាយខ្មៅ ព្រះហស្តដោយប្រក្រតីតែ២ តែអាចបែងភាគជាព្រះហស្ត៤ ឬ ៨ ក៏បាន ព្រះឧរាមានលាយលក្ខណ៍ឆ្នូត ៗ ហៅស្រីវត្ស, ទ្រង់អាភរណៈទិព្វពណ៌លឿង. ទ្រង់ស័ង្ខឈ្មោះបញ្ចជន្យជាអាវុធ, ចក្រឈ្មោះសុទស្សន, គទា (ដំបង) ឈ្មោះកោមោទកី, ធនូឈ្មោះសាង្គ្រ, ព្រះសែងខាន់ឈ្មោះនន្ទក, និងកាន់ផ្កាឈូកជាគ្រឿងសំគាល់, មានគ្រុឌរាជបក្សីជាពាហនៈ, ព្រះជាយានាមលក្ស្មី តែគេថា មានជាយាដើម២អង្គឈ្មោះអទិតិ ១ សិនីវាលី ១, ឱរសឈ្មោះកាមទេព, ទីដែលស្ថិតឈ្មោះវៃកុណ្ឋ ។ ក្នុងវេលា១កល្បឬ ១ ថ្ងៃរបស់ព្រះព្រហ្មដែលជាវេលាឈប់សាងលោក ព្រះវិស្ណុទ្រង់ផ្ទំលើផ្កាឈូក ផ្ទួនកាលផ្ទំលើខ្នងនាគរាជក្បាល១០០០ ឈ្មោះសេស តែក្នុងទីខ្លះហៅឈ្មោះស្តេចនាគនោះថា អនន្តនាគ-

រាជ វេលាផ្ទុំមានទឹកព្រះគង្គាហូរចេញអំពីចុងព្រះបាទជាប្រក្រតី មាននាងលក្ស្មីប្រថាប់នៅជាមួយផងជាអាបិណ្ឌ ។

ក្នុងយុគបូរាណពោលថា ជាទេវតាជាន់រង វេលាក្រោយទើបបានជាព្រះ ១ អង្គក្នុងបំនួន ៣ នោះ តែមុននឹងរួមគ្នាសិប់តោងកើតសង្គ្រាមនឹងគ្នាជាញឹកញយ ដោយហេតុកាន់លទ្ធិផ្សេងគ្នា លុះរួមគ្នាហើយគេញែកសំដែងព្រះគុណនៃព្រះទាំង ៣ នោះថា ព្រះព្រហ្មជាអ្នកសាងលោក ព្រះឥស្វរជាអ្នកសាងលោកផង ជាអ្នកលាងលោកផង ព្រះវិស្ណុជាអ្នកជួយស្រោចស្រង់លោកក្នុងវេលាដែលដល់នូវក្តីបាស់បោចលាបល ឲ្យបាននូវសេចក្តីសុខសាន្តត្រានផង ទើបមាននាមថា ហរិ អ្នកប្តូម អ្នកស្រោចស្រង់, ជាអ្នកសាងលោកផង ទើបមាននាមថា នារាយណ ការដែនកើតនៃនរៈ ។ ខដែលថា ព្រះនារាយណ៍ជាអ្នកសាងលោកដែរនោះ ប្រហែលជាសំដៅយកត្រង់ដែលលោកបែងភាគមកម្តង ៗ ដូចមានប្រាកដក្នុងគម្ពីរវិស្ណុបុរាណ៍មសំដែងអំពីអវតារ ១០ គ្រាក្នុងសត្យយុគ គឺយុគជាដំបូងដូច្នេះ :—

១ មច្ឆាវតារ ប្រារព្ធទឹកវិនាស ទ្រង់បែងភាគមកកើតជាត្រី ។ សេចក្ដីថា គ្រានោះព្រះវៃវស្វត គឺព្រះមនុទី ៧ ស្ដេចចុះស្រង់ទឹកឃើញត្រី ១ តូច ត្រីនោះប្រាប់ដំណឹងថា នឹងមានទឹកវិនាសកើតឡើង ធ្វើឲ្យមនុស្សសត្វលិចលង់វិនាសអស់ ។ ព្រះមនុជឿក៏ចាត់ការការពារ គឺគូទូក ១ យ៉ាងធំ លុះតរូបហើយត្រីនោះក៏បង្រីកខ្លួនធំឡើង ៗ ទាល់តែបង្អៀតមហាសមុទ្រ លុះទឹកវិនាសជោរជន់លិចមក ព្រះមនុក៏ចងទូកនឹងស្នែងត្រី (ធ្មុងត្រី?) ត្រីក៏នាំទៅកាន់ទីដែលផុតអន្តរាយ ព្រះមនុក៏យកទៅចងនឹងដើមឈើឡើងដើរទៅលើគោក ក្នុងលោកនេះនៅសល់តែព្រះមនុម្នាក់ឯងដែលរួចអំពីឧទកភ័យក្នុងគ្រានោះ ។

២ កូម៌ាវតារ ប្រារព្ធការកូរសមុទ្រទឹកដោះ ទ្រង់បែងភាគមកកើតជាអណ្ដើក ។ សេចក្ដីថា គ្រានោះទេវតានឹងអសុរទាំងឡាយភិតភ័យខ្លាចស្លាប់ ទើបនាំគ្នាទៅទូលសុំឲ្យព្រះវិស្ណុជួយរកឧបាយកែកុំឲ្យស្លាប់ ព្រះវិស្ណុក៏ទទួលធុរ ត្រាស់ឲ្យកូរសមុទ្រទឹកដោះយកហ្វាំទិព្វផឹក គ្រានោះព្រះវិស្ណុទ្រង់ដំណែងខ្លួនជាអណ្ដើកទៅនៅក្នុងបាតសមុទ្របាំទ្រភ្នំមន្ទរ ដែលពួកទេវតា

យកធ្វើជាឈើកូរទឹកសមុទ្រ ពួកទេវតានឹងអសុរ កូរទៅក៏កើតជាថ្នាំទិព្វឈ្មោះ"អម្ឫត" ពួកទេវតាបានផឹកហើយអាយុយឺនមិនចេះស្លាប់ ទើបមានឈ្មោះថា"អមរោ"ប្រែថា អ្នកមិនចេះស្លាប់អំពីនោះមក ។

៣ វរាហាវតារ ប្រារព្ធអសុរឈ្មោះហិរណ្យកយក្សអូសផែនដីផ្ទៀបបុះទៅក្នុងទឹក ធ្វើឲ្យមនុស្សសត្វបាននូវសេចក្តីវិនាសយ៉ាងធំ គ្រានោះព្រះវិស្ណុទ្រង់អវតារជាជ្រូកទៅច្បាំងតស៊ូនឹងអសុរនោះ មួយពាន់ឆ្នាំទើបប្រហារអសុរសម្រេច ហើយយកខ្នាយស្ទួយផែនដីឡើងអំពីទឹក អូសយកមកទុកនៅទីដើមវិញ ។

៤ នរសិង្ហាវតារ ប្រារព្ធអសុរឈ្មោះហិរណ្យកសិបុ អ្នកណាព្យាយាមសម្លាប់ដូចម្តេចក៏មិនស្លាប់ មានបុត្រ ១ ឈ្មោះប្រហ្លាទ ហិរណ្យកសិបុក្រោធនឹងបុត្រនេះខ្លាំងណាស់ ព្រោះទៅរាប់អានព្រះវិស្ណុ ព្យាយាមតាមសម្លាប់បុត្រនេះជាច្រើនគ្រាក៏មិនស្លាប់ ព្រោះព្រះជាម្ចាស់ជួយការពារ គ្រាមួយនោះបានតាមទៅស្រែកសន្ធាប់គម្រាមឲ្យបុត្រលើកលែងរាប់អានព្រះវិស្ណុ

បុត្រក៏មិនស្តាប់ គង់រឹងសំដីថា ព្រះវិស្ណុជាព្រះ ត្រូវតែរាប់អាន អសុរិតតែក្រេវក្រោធខ្លាំងឡើង ស្រែកសួរទៅថា ព្រះវិស្ណុនោះ នៅក្នុងទីនេះដែរឬ? ប្របាលាទតបថា លោកនៅក្នុងទីនេះ ដែរ, អសុរថា បើដូច្នោះអញនឹងទៅសម្លាប់វាឥឡូវនេះ ព្រះ វិស្ណុឮដូច្នោះ ទើបអវតារជានរសីហ៍ កាច់សសរបាក់ធ្លុងផាង ចេញមកចាប់ក្រញីហែកហិរណ្យកសិបុស្លាប់ទៅ ។

៥ វាមនាវតារ ប្រាវត្តក្រុងពលីជាតិជាបិសាច បានជា ធំក្នុងលោក តែងតែដើរបៀតបៀនទេវតាមនុស្សសត្វឲ្យបានក្តៅក្រហាយ គ្រានោះព្រះវិស្ណុកអវតារជាមនុស្សគម ចូលទៅសុំ ដីពលីប្រមាណ ៣ ជំហាន ក្រុងពលីឃើញជាមនុស្សគម មិន អាចនឹងឈានឲ្យវែងបានប៉ុន្មាន ក៏ព្រមឲ្យ វាមនបុរសក៏ឈាន ដោយកំលាំងឫទ្ធិរបស់ខ្លួន ជំហានទី ១ ផុតឋានមនុស្សលោក ជំហានទី ២ ផុតឋានទេវលោក ជំហានទី ៣ ជាន់លើក្បាល ក្រុងពលី សង្កត់លិចទៅដល់ឋានបាតាល បង្អង់ព្រះបាទ ត្រឹមនោះ មិនដាក់ឲ្យកប់ជ្រៅទៅទៀត ដោយអាណិតថា នឹង

គ្មានទីនៅ អំពីនោះមក ក្រុងពលីរាប់ថា អស់អំណាចរាជសក្តិ ក្នុងឋានទេវលោកនឹងមនុស្សលោកនេះហើយ[១] ។

៦ បរសុរាមាវតារ ប្រារព្ធសេចក្តីមិនតាំងនៅក្នុងយុត្តិធម៌ នៃព្រះមហាក្សត្រិយ៍ទាំងឡាយ គានោះព្រះវិស្ណុទ្រង់អវតារជា បរសុរាម (រាមពូថៅ) កាន់ពូថៅដើរកម្រាបប្រាបប្រាមក្សត្រិយ៍ ទាំងពួង ឲ្យត្រឡប់តាំងនៅក្នុងសុចរិតយុត្តិធម៌តទៅ ។

៧ រាមាវតារ ប្រារព្ធស្តេចយក្សឈ្មោះរាវណាសូរ (ក្រុងរាពណ៍) ដែលគ្រប់គ្រងកោះលង្កា គានោះព្រះនារាយណ៍ ទ្រង់បែងភាគឲ្យមកកើតជាព្រះរាម បុត្រព្រះបាទទសរថ ព្រះ ចៅក្រុងស្រីអយុធ្យា កម្រាបរាពណ៍នោះឲ្យអបរាជ័យទៅ (រឿង អវតារត្រង់នេះ មានសេចក្តីពិស្តារក្នុងរឿងរាមាយណ) ។

៨ ក្ឫស្ណាវតារ ប្រារព្ធស្តេចពាណាសូរជាហេតុ ទ្រង់ បែងភាគឲ្យមកកើតជាព្រះក្រឹស្ណ (ក្ឫស្ណ) កម្រាបអសុរនោះ វិនាសទៅ (ចូរមើលក្នុងរឿងហរិវង្ស) អវតារគានេះថា ព្រះនារាយណ៍ទ្រង់ដកសក់ខ្មៅ ១ សរសៃបណ្តាលឲ្យមកកើត

---

(១) សព្វថ្ងៃនេះ មានអ្នកខ្លះនៅធ្វើពិធីសែនព្រេនដល់ក្រុងពលី ប្រហែលជាខ្លាចជាប់មក តាំងពីកាលគាត់មានអំណាចនៅក្នុងលោកនេះ ។

ជាព្រះក្រស្ណា បង, ទ្រង់ដកសក់ស ១ សរសៃទៀតបណ្ដាលឲ្យមកកើតជាព្រះពលរាម ប្អូន (តែខ្លះថា ព្រះពលរាមនេះ នាគរាជឈ្មោះសេសមកយកកំណើត) ហេតុនោះ បងទើបមានពណ៌កាយខ្មៅ ប្អូនមានសំបុរកាយសល្អ តាមសំបុរសក់ ។

៩ ពុទ្ធាវតារ ទ្រង់អវតារឲ្យមកកើតជាព្រះពុទ្ធ គឺព្រះសមណគោតម ដែលត្រាស់ក្នុងភទ្ទកប្បនេះរួចហើយ ។

១០ កលកិយាវតារ អវតារទី ១០ នឹងមានមកក្នុងអនាគតក្នុងកលិយុគនេះ គឺទ្រង់ប្រារព្ធសេចក្ដីលាមកអាក្រក់ដែលត្រានៅក្នុងសន្ដានមនុស្សលោក ទើងទ្រង់បែងភាគមកកើតជាមហាបុរសជិះសេះស[១] កាន់ដាវដើរជំរះលោក ហើយនឹងទំនុកបំរុងលោកឲ្យត្រឡប់ល្អឡើងវិញ មនុស្សលោកនឹងបានសេចក្ដីសុខដូចឋានសួគ៌ ។

ព្រះនារាយណ៍បែងភាគទាំង ១០ គ្រានេះ សុទ្ធតែមកជួយលោកដែលដល់នូវសេចក្ដីទុរគតឬចលាចលម្ដង ៗ ឲ្យត្រឡប់

---

(១) មហាបុរសនេះឯង ដែលអ្នកខ្លះស្រវៃទៅថា ដល់ពាក់កណ្ដាលសាសនា គឺ ព. ស. ២៥០០ នឹងមានមក ។

សុខសាន្តត្រានទៅវិញ ។ ក្រៅអំពីអវតារ ១០ គ្រានេះ ទ្រង់ធ្លាប់ទៅជួយកម្រាបសត្រូវអ្នកដទៃ ឲ្យអបរាជ័យទៅជាច្រើនដង ដូចយ៉ាងទ្រង់ជួយព្រះឥន្ទ្រកម្រាបបិត្រាសូរជាដើម ទាល់តែបានស្និទស្នាលនឹងព្រះឥន្ទ្រ រហូតដល់នៅបាននាមថា ឥន្ទ្រានុជ មានព្រះកិត្តិយសជាឯកអគ្គមហាយោធិន ទ្រង់នូវតេជះដ៏មោះហ៊ឹមាទទួលសិរោង្ការមកកម្រាបពួកអរិរាជបច្ចាមិត្រឲ្យខ្លប់ខ្លាចទូទៅគ្រប់ទិស ហេតុដូច្នោះ ព្រះមហាក្សត្រិយ៍អំពីបុរាណទើបសព្វព្រះហឫទ័យយកនាម វិស្ណុ ហរិ នារាយណ៍ អំបាលនោះជាដើមមកជាព្រះបរមនាមាភិធ័យរបស់ព្រះអង្គ នឹងតាំងជាឈ្មោះមន្ត្រីខាងក្រសួងទាហាន ។ ១ ទៀតក្នុងគ្រឿងយុទ្ធភណ្ឌមានរបស់មួយយ៉ាងហៅ "គ្រុឌពាហ" គឺធ្វើជារូបគ្រុឌមានដងវែងសម្រាប់កាន់ ជារបស់សម្រាប់នាំទ័ពប្រហែលគ្នានឹងទង់ជ័យដែលយកមកធ្វើដូច្នេះ ដោយសំគាល់ថា គ្រុឌជាទីនាំងរបស់ព្រះនារាយណ៍ រូបគ្រុឌពាហនេះបើអ្នកណាប្រាថ្នាចង់ឃើញ ក៏គួរទៅមើលរូបភាពចម្លាក់អំពីក្បូនទ័ពរបស់ព្រះបាទសម្តេចព្រះសូរ្យវរ្ម័នទី ២ ដែលឆ្លាក់ទុកនៅប្រាសាទនគរវត្ត នាព្រះរបៀងថ្នាក់

ទី ១ ជាតខាងត្បូងភាគខាងលិច ឬនឹងទៅមើលឯប្រាសាទបាយ័ន ក្រុងមហិន្ទ្របុរក៏បាន ។

ទេវីរបស់ព្រះទាំង ៣

ព្រះសរស្វតី ជាទេវីរបស់ព្រះព្រហ្ម ជាទេវីប្រចាំភាសានឹងជំនេះវិជ្ជា គឺជាអ្នកមានភាសាជាសិរី នឹងទ្រង់នូវសិល្បសាស្ត្រទាំងពួង យ៉ាងព្រះព្រហស្បត៍ ដ៏ជាគ្រូនៃទេវតាទាំងឡាយ (តែជាមានកំណើតមកដូចម្ដេច ឬជាធីតារបស់អ្នកណា យើងខ្ញុំស្រាវជ្រាវរកទៅមិនទាន់ប្រទះ សូមស្លេះទុកតែប៉ុណ្ណោះ) ។

ព្រះឧមា ជាទេវីរបស់ព្រះសិវ មាននាមឯទៀតដល់ទៅ ១,០០០ យ៉ាង មាននាមថា ឧមា, ភគវតី[១] ភវានី, គិរីជា បតិតី, ហេមវតី, ទុគា កាឡី ជាដើម ។ នាមអំបាលនេះជាគ្រឿងសរជាតិត្រកូលខ្លះ ជាគ្រឿងសំដែងគុណសម្បត្តិខ្លះ ដូចយ៉ាងនាមថា ហេមវតី, បតិវតី, គិរិជា, ជាគ្រឿងសរត្រកូល ព្រោះនាងជាធីតាភ្នំហិមវត៍ (គឺហិមពាន្ត) នឹងនាងមេនកា ។ នាមថា

---

(១) ខ្មែរយើងចំណាំតែហៅភ្ជាប់ថា ឧមាភគវតី ឈ្មោះក្រោយហៅឃ្លាតទៅ ។

ភគវតី ព្រោះនាងជាអ្នកមានជោគលាភ, នាមថា ភវានី ព្រោះនាងជាមាតានៃទេវតានឹងមនុស្សទាំងឡាយ ទុរគានឹង កាឡីជានាមខាងអាក្រក់ ដែលមានបណ្ដាលឲ្យវិនាសហិន ហោចទៅ សំដែងមកប៉ុណ្ណោះជាតួយ៉ាង ។

លក្ខណារបស់នាងនេះ ពីដើមមានសំបុរកាយខ្មៅញាប់ វេលាក្រោយបានបំពេញតបៈធ្វើសេចក្ដីភក្ដីដល់ព្រះជាម្ចាស់ ទើបមានសំបុរកាយលឿងនួន មានខ្លាជាពាហណ ។ បានជាជាយាព្រះឥស្វរ កាលកាមទេពបាញ់ព្រះឥស្វរដោយធនូផ្កាឲ្យកើតរាគឡើង, ជាអ្នកទ្រង់នូវអានុភាពអាចនឹងប្រទានពរ ឬដាក់បណ្ដាសាដល់អ្នកឯណានីមួយក៏បាន ព្រះហឫទ័យប្រើនធុលធៀរក្រោធងាយ ៗ សព្វព្រះហឫទ័យតែបូជាដោយឈាមមនុស្សឬសត្វ បើអ្នកណាចង់បានពរអំពីនាង គប្បីបំពេញតបៈឲ្យមាំមួន ហើយយកមនុស្សឬសត្វទៅសម្លាប់នៅទេវាល័យ យកឈាមបូជា នឹងធាប់ប្រទានពរ ។

ព្រះលក្ស្មី ជាទេវីរបស់ព្រះវិស្ណុ មានកំណើតកើតមកអំពីសមុទ្រទឹកដោះ គឺកើតព្រមគ្នានឹងថ្នាំ អមឫត ដែលទេវតា

នឹងអសុរក្ខរសមុទ្រទឹកដោះ ជាទេពីដ៏ឯកខាងឯលំអឆោមនឹង
ជោគលាភ ។ ទ្រង់អ្វីជាពាហណមិនប្រទះទីមក ។ ពួកអ្នកកាន់
សាសនាព្រាហ្មណមិនបំពោះរាប់អានតែព្រះ ៣ អង្គប៉ុណ្ណោះ
រមែងគោរពរាប់អានដល់ព្រះជាយាទាំង ៣ នាងនេះផង ។

## ទេពជំនុំ

ពួកអ្នកកាន់សាសនាព្រាហ្មណរាប់អានទេវតាដែលមាន
បណ្តាសក្តិ មួយពួកទៀតដែលហៅថា ទេពជំនុំ ឬហៅ
គណទេព ទាំងអស់មាន៩អង្គ គឺ ព្រះព្រហ្ម១ ព្រះឥស្សូរ១ ព្រះ
ឥន្ទ្រ១ ព្រះអាទិត្យ១ ព្រះបន្ទ្រ១ ព្រះវរុណ១ ព្រះកុវេរ១ ព្រះយម១
ព្រះស្កន្ទ១ ។ គណទេពជំនុំអំបាលនេះ តែងចូលគាន់ទីទេវសន្និ-
បាតផងគ្នាជារឿយៗទើបមានឈ្មោះដូច្នេះពួកអ្នកកាន់សាសនា
នេះច្រើនធ្វើរូបទេពជំនុំជាឃុតជាមួយគ្នា អ្នកមើលស្គាល់បាន
ថា ជាព្រះនេះព្រះនោះ ដោយសង្កេតមើលពាហណដែលទ្រង់
ផ្សេងគ្នា ក៏ក្នុងទេពជំនុំអំបាលនេះ គេមិនរាប់ព្រះវិស្ណុចូលផង
ដោយហេតុអ្វី មិនអាចដឹងបាន ។ បំណែកឯគុណសម្បត្តិនៃ

ព្រះទាំងនេះ ព្រះព្រហ្មនឹងព្រះឥស្សរបានបរិយាយមកហើយ ក្នុងទីនេះនឹងបានសំដែងចំពោះតែអង្គដែលមិនទាន់សំដែង ដូចមានតទៅនេះៈ —

## ព្រះឥន្ទ្រ

ព្រះឥន្ទ្រក្នុងគម្ពីរខាងព្រះពុទ្ធសាសនាក្តី ខាងព្រាហ្មណ៍ក្តី ថា ជាទេវរាជា គឺជាស្តេចនៃទេវតាទាំងឡាយ មាននាមសម្រាប់ហៅច្រើនយ៉ាង មានសក្ក ទេវរាជ ទេវិន្ទ្រ អមរិន្ទ្រ សហស្សន័យន៍ ជាដើម ស្ថិតនៅឯឋានសួគ៌ឈ្មោះ "ត្រៃត្រិង្ស" សោយរាជ្យគ្របគ្រង ៣ នគរ លក្ខណសំបុរកាយខៀវ មានវជិរ ព្រះខាន់ នឹងត្រីសូរជាអាវុធសម្រាប់អង្គ មានទេពី ៣ អង្គ ឈ្មោះសុធម្មា ១ សុនន្ទា ១ សុជាតា ១ មានដំរីឈ្មោះឯរាវណ្ណ ក្បាល ៣៣ ជាទីតាំងគង់ ជួនកាលគង់រថសេះ មានមាតុលីទេវបុត្រជាសារថី ក្នុងគម្ពីរខាងព្រះពុទ្ធសាសនាថា ក្នុងឋានសួគ៌គ្មានសត្វតិរច្ឆាន ដំរីឬសេះដែលពោលក្នុងទីនេះជាទេពនិម្មិត ។ ក៏រឿងព្រះឥន្ទ្រនេះមានពោលក្នុងគម្ពីរខាងព្រះពុទ្ធសាសនាដោយច្រើនហើយ ក្នុងទីនេះទើបមិនបាច់ពោលឲ្យពិស្តារ ។

## ព្រះអាទិត្យ

អាទិត្យជាឈ្មោះនៃទេវបុត្រ ១ អង្គ មាននាមសម្រាប់ហៅយ៉ាងដទៃទៀតជាច្រើន មាននាមថា សុរិយ ទិវាករ រវិសវិតជាដើម ស្ថិតនៅឯអាទិត្យលោកគឺក្នុងរវាងទេវលោកនឹងមនុស្សលោក ។ ខាងព្រាហ្មណថា ព្រះអាទិត្យមានព្រះជាយានាម សរន្យុ មានបុត្រ ១ អង្គ គឺព្រះយម តែក្នុងរឿងរាមាយណថា ពាលីនឹងសុគ្រីព ជាបុត្រព្រះអាទិត្យដែរ ។ សំដែងអំពីតេជគុណថា ជាអ្នកមានតេជ មានពន្លឺរស្មីខ្លាំងក្លា តែងបរទៅតាមចក្ររាសី ដើម្បីបំភ្លឺលោកក្នុងវេលាថ្ងៃ ។ ពួកអ្នកកាន់សាសនាព្រាហ្មណ៍ មានសេចក្ដីរាប់អានព្រះអាទិត្យដូចម្ដេច បានពោលហើយក្នុងលទ្ធិព្រះអាទិត្យ ។

(នៅមានតទៅទៀត)

### ១ — រឿងមនុស្សលោភ

មានរឿងព្រេងបូរាណស្រដីថា មានកុមារីម្នាក់អាយុ ១៤ ឆ្នាំ ម្ដាយប្រើឲ្យទៅជីកដម្លូង ក្មេងនោះរៀបចបរួចស្រេចចេញដើរទៅរកដម្លូង ដល់ព្រៃធំមានដំបូកមួយហើយមានរូងនោះជ្រៅ កុមារីនោះទៅជីកដម្លូងលើដំបូកនោះ របូតផ្លែចបជ្រុះធ្លាក់ទៅអន្លុង

នោះ នាងនោះមិនដឹងធ្វើដូចម្ដេចក៏ស្រែកប្រកាសថា លោកណា
អ្នកណាអើយជួយយកផ្លែបបខ្ញុំបាន ខ្ញុំនឹងសងគុណលោកស្រែក
តែប៉ុណ្ណោះ មានសត្វខ្លាមួយចាស់ហើយមានដំបៅក្បាលរុយ
បែងដង្កូវបុះកគ្រិចបេញមកពីក្នុងព្រៃហើយប្រាប់ទៅនាងនោះថា
នាងតាយកឲ្យបានផ្លែបបនោះ តែបើតាយកបានតាឲ្យឯងរកបៃ
ឲ្យតាបានហើយ តាមិនបាច់យកគុណស្រែពីហៅទេ នាងឮខ្លា
ថាដូច្នោះហើយក៏និយាយទៅថា ឱលោកតាអើយឲ្យតែលោកតា
ជួយយកឲ្យបានបុះ ខ្លានោះយកផ្លែបបានពីក្នុងអន្លង់ឲ្យទៅ
នាងនោះហើយឲ្យនាងនោះរកបៃឲ្យ នាងនោះតាំងយកបន្លាមក
ឆ្កឹសដង្កូវនៅដំបៅក្បាលខ្លានោះ ខ្លានោះបេះតែសួរនាងថា នាង
ដំបៅតាស្អុយឬក្រអូប ដំបៅនោះស្អុយណាស់ ប៉ុន្តែនាងនោះ
ឆ្លើយទៅវិញថា ក្រអូបណាស់លោកតា ខ្លានោះបេះតែសួរនាង
នោះៗបេះតែថាក្រអូប លុះឆ្កឹសដង្កូវនោះអស់ទៅ ខ្លានោះបាត់
ឈឺរមាស់ទៅ ហើយនិយាយប្រាប់នាងនោះថា នាងៗយក
ជាលមួយមកតានឹងដាក់ដម្លង់ឲ្យ នាងនោះយកជាលមួយមកឲ្យ
ទៅខ្លានោះៗដាក់សុទ្ធតែមាសប្រាក់ពេញជាលនោះ រួចបងមាត់

ជាលជាប់ រួចឲ្យទៅនាងនោះ រួចប្រាប់នាងនោះថា នាងៗ
យកជាលនេះទៅផ្ទះ ហៅបង-ប្អូននាងមកជុំរួចបិទទ្វារឲ្យជិតសុំ
បើក នាងនោះលាខ្លារួចដើរទៅដល់ផ្ទះតាំងហៅបង-ប្អូនមកជុំ
រួចតាំងបើកជាលនោះ ដល់បើករួចទៅបានសុទ្ធតែមាសនឹង
ប្រាក់ចែកគ្នារួចទៅ លុះយូរបន្តិចទៅ ដឹងទៅដល់ផ្ទះមនុស្ស
ស្រីឯទៀតមានកូនក្រមុំតាំងបញ្ជោកូនក្រមុំថា ហងឯងមើល
កូនគេៗទៅដឹកដម្លូងបានមាសប្រាក់ យកមកចែកបង-ប្អូនគេ
ហងឯងទៅដឹកដម្លូងបានតែដម្លូងគ្មានបានខ្មោចអ្វីទេ លុះថ្ងៃ
ក្រោយឲ្យកូនទៅដឹកដម្លូងដូចនាងនោះទៀត លុះទៅក៏បានប្រ-
ទះនឹងខ្លាមុននោះទៀត ហើយធ្វើជាជ្រុះបបដូចនាងមុននោះ
ហើយថា លោកណាយកបបខ្ញុំបានខ្ញុំនឹងសងគុណលោក ខ្លា
នោះឮហើយក៏មកយកឲ្យរួចឲ្យនាងនោះចាប់ដង្កូវឲ្យ ខ្លាសួរ
ដូចពីមុនថា នាងដំបៅតាស្អុយឬក្រអូប នាងនោះឆ្លើយឡើង
ថា ស្អុយណាស់ ខ្លាឮដូច្នោះថា នាងយកជាលមួយមកតានឹង
ដាក់មាស-ប្រាក់ឲ្យ នាងបានជាលឲ្យខ្លានោះៗតាំងចាប់សុទ្ធ
តែពស់វែកដាក់ពេញជាលហើយឲ្យទៅនាងនោះប្រាប់ថា នាង

យកទៅផ្ទះហៅបងប្អូនមកជុំបិទទ្វារឲ្យជិតសុំបើក នាងនោះទៅ
ដល់ផ្ទះហើយប្រាប់ម្ដាយៗអរណាស់ ឲ្យហៅបងប្អូនមកជុំតាំង
បិទទ្វាររួច បើកដាលនោះសុទ្ធតែពស់វែកចេញមកចឹកមនុស្ស
នោះស្លាប់អស់ទៅ ហេតុនេះមនុស្សយើងមិនត្រូវលោភទេ ហើយ
មួយទៀតកុំឃើញគេធ្វើដូចម្ដេចធ្វើតាមគេនោះ នឹងនាំឲ្យវិនាស
ខ្លួន ។

### ២ — អំពីស្រុកកំពង់ធំពីដើម

ស្រុកកំពង់ធំពីដើមជាស្រុកមួយតូចមានផ្ទះចំនួនប្រហែល
១០ ឬ ១៥ ហើយផ្តុំគ្នានៅតាមមាត់ស្ទឹងខាងអាយ (មុខផ្ទះបង់កា
ឡូបារាំងសព្វថ្ងៃនេះ) រហូតទាល់មកត្រឹមដើមពោធិធំ មុខផ្ទះ
លោកចាងហ្វាងសព្វថ្ងៃនេះ កាលណោះនៅក្នុងបុណ្យលោកតេ
ជោ ត- បំណែកវាលខាងត្បូងសព្វថ្ងៃនេះ គឺសុទ្ធតែព្រៃខ្ពស់
ហើយស្តុកសឹងមានសត្វសាហាវនៅព្រៃ គឺខ្លាដំរីជាដើម ហើយ
នឹងសត្វរមាំងក្តាន់ប្រើសឯទៀតជាច្រើន មនុស្សទាំងពួងមិន
អាចហ៊ានដើរកាត់ព្រៃនេះឡើយចំនួន ២ នាក់ ឬ ៣ នាក់ កាល
ណោះមិនទាន់មានផ្ទះបារាំងផ្សារលក់ទំនិញនៅឡើយទេ មាន

តែបិនមួយនាក់ពីរនាក់ គ្រាន់តែលក់ទំនិញបន្តិចបន្តួចនៅតែក្នុងផ្ទះ តែអំពីព្រះវិហារសព្វថ្ងៃនេះគឺមានមកយូរណាស់មកហើយ មិនដឹងជាប៉ុន្មានឆ្នាំមកទេ ហើយមានថ្មីល់ខ្លីបន្តិចពីខាងក្រោយវត្តនេះមកដល់ត្រឹមស្ទឹង ថ្នល់នេះលោកតេជោ ត លោកឲ្យលើកវត្តនេះសន្មតហៅថាវត្ត (សាំងសាមី) លុះដល់មកបុណ្យលោកតេជោ (រស់) លោកឲ្យស្អាងព្រះវិហារមួយទៀត តែទើបនឹងលើកដីឡើង ស្រុកកើតភាន់ប្រែក៏ខានស្អាងព្រះវិហារនោះទៅនេះគឺដីខ្ពស់ត្រង់រោងល្ខោនសព្វថ្ងៃនេះ អំពីគ្រឿងប្រដាប់ដែលបម្រុងនឹងសង់ព្រះវិហារនោះ លោកគ្រូវត្តកំពង់ធំព្រះនាមលោក (វត្ត) លោកយកទៅសង់ព្រះវិហារឯកំពង់ល្ហងហៅថា វត្តប្រាំបីជោម នៅសព្វថ្ងៃនេះ ក្នុងបុណ្យលោកតេជោរស់នោះ ស្រុកមិនសប្បាយទេ ព្រោះមានបាស់បោបប្លាំងគ្នាជាច្រើន ។

៣ — រឿងអាខ្វាក់នឹងអាខ្វិន

មានបុរសពីរនាក់ ម្នាក់ខ្វាក់ម្នាក់ទៀតខ្វិន អាទាំងពីរនាក់យកគ្នាធ្វើខ្ទើ អាខ្វាក់បានខាងជើង អាខ្វិនបានខាងភ្នែក អា

ខ្វិនជិះកអាខ្វាក់ហើយនាំគ្នាទៅៗតាមផ្លូវ អាទាំងពីរនាក់គិតគ្នានឹងទៅលួចរបស់ទ្រព្យគេ គិតដូច្នោះក៏ព្រមតាមគ្នា លុះយប់ចូលទៅលួចបានរបស់ទ្រព្យគេ ដល់ព្រឹកឡើងយករបស់ទ្រព្យនោះទៅចែកគ្នាក្រោមដើមក្រសាំង អាខ្វិនជាអ្នកមេចំណែក តាំងចែកដាក់ខាងមុខអាខ្វាក់នោះតិច ដាក់ខាងមុខខ្លួនច្រើន ហើយសួរទៅអាខ្វាក់ថា អាឯងយកខាងណា អាខ្វាក់ឆ្លើយមកវិញថា អញយកខាងមុខអាឯង អាខ្វិនតាំងពីចែកម្តងទៀត ក្រោយនេះដាក់ខាងមុខអាខ្វាក់ច្រើន ហើយដាក់ខាងមុខឯងតិច ហើយសួរទៅអាខ្វាក់ថា អាឯងយកខាងណា អាខ្វាក់ឆ្លើយថា អញយកខាងមុខអញ ទើបតែថាប៉ុណ្ណោះផ្លែក្រសាំងមួយជ្រុះមកត្រូវក្បាលអាខ្វាក់ៗ ខឹងណាស់ ក៏ធាក់ទៅអាខ្វិនត្រូវត្រង់ជើងដែលខ្វិនខ្វង់ ក៏ជាជើងនោះទៅ អាខ្វិនតាំងដាល់ទៅអាខ្វាក់ត្រូវភ្នែក ក៏ជាបាត់ខ្វាក់ទៅ អាទាំងពីរនាក់បានជាជម្ងឺតែរៀងខ្លួន ហើយតាំងចែករបស់ទ្រព្យហើយដើរទៅ ។ ៚

(ចប់)

# បញ្ជីរឿង

១ – អំពីទស្សនាការកន្លែងផែនទីក្រុមសុរិយោដី ក្រុងភ្នំពេញ . . . . . . . . . ១២១

២ – បាឋកថា លោក វិកទ័រគោលូបែវ អំពីការស្រាវជ្រាវជាន់ក្រោយនៅទីអង្គរ ក្រម្ការ ដុំ-មៅ ស្រង់សេចក្ដីហើយប្រែជាភាសាខ្មែរ . . . . . . . . . . ១៣៣

៣ – និធិកណ្ឌសូត្រ ក្នុងខុទ្ទកបាឋ, ឧកញ៉ាភក្ដីដេយ៉ាង អាចារ្យបង្រៀនសាលាបាលីជាន់ខ្ពស់ ប្រែចេញពីបាលីមកជាភាសាខ្មែរ . . . . . . . . . . . ១៥៤

៤ – សាសនប្រវត្តិ, ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ រៀបរៀង (ត) . . . . . . . . . . . . . . . . . . . . . ១៥៩

៥ – រឿងព្រេងខ្មែរដែលមិនទាន់បោះពុម្ពផ្សាយ៖

១ – រឿងមនុស្សពីរនាក់ ម្នាក់ខ្ទើមអាចម៍ ម្នាក់ខ្ទើមក្ដី . . . . . . . . . ១៧១

២ – រឿងដែលបង្កើតមានហៅថាតេជោ ចៅហ្វាយខែត្រកំពង់ស្វាយ . . . . ១៧៤

៣ – រឿងអាឡេវ . . . . . . . . . . . . . . . . . . . . . ១៧៩

# រូបថត

១ – ផែនទីក្រុងភ្នំពេញ ថតដោយអាកាសយាន ឃើញព្រះរាជបណ្ណាល័យ, សាលាបាលី, សាលាក្រុមការ, សាលាយុត្តិធម៌ខ្មែរ, វត្តព្រះកែវ, ព្រះបរមរាជវាំង នឹងឃើញទន្លេ ១ ភាគ . . . . . . . . . . . . . . . . . . . . ១១៧

២ – ផែនទីខែត្រព្រៃវែង ឃើញស្រែនឹងផ្លូវ . . . . . . . . . . . . . . ១២៣

៣ – កំពូលប្រាសាទ ១ ក្នុងប្រាសាទតាសោម . . . . . . . . . . . . . . ១២៩

៤ – " " . . . . . . . . . . . . . . . ១៣១

# TABLE DES MATIÈRES

I. Une visite à l'atelier des services du Cadastre à Phnôm-Penh........ 121

II. Conférences de M. Victor Goloubew sur les récentes fouilles d'Angkor, faites au musée Louis Finot à Hanoï le 16 Avril 1934........ 133

III. Nidhikanda Sūtra, tiré de Suttajātaka Nidānānisansa et traduit du Pāli en Cambodgien par feu Oknha PhéaKdey Réachéa Yaing, professeur à l'École Supérieure de Pāli........ 155

IV. Sāsanapravatti ou Histoire des religions, par Préas Maha Pitou Krasém, pandit à la Bibliothèque Royale (suite)........ 159

V. Contes populaires Cambodgiens inédits:

I° Contes des deux hommes, l'un a l'horreur de la saleté et l'autre a l'horreur des procès........ 171

II° Légende relative au titre Décho que porte le Gouverneur de Kompong Svai........ 175

III° L'histoire d'A-Léo........ 179

## ILLUSTRATIONS:

I. Plan de la ville de Phnôm-Penh pris par avion, avec la Bibliothèque Royale, l'École Supérieure de Pāli, l'École des Kromokars, le Palais de la Justice Cambodgienne, la Pagode d'Argent, le Palais Royal et une partie du fleuve........ 117

II. Plan de Preyvèng, les rizières et la route........ 123

III. Ta-Som — Angle Nord-Est de la tour du Gopura Ouest. 129

IV. Ta-Som — Angle Nord-Ouest du Gopura Ouest. . 131

ក្រុំដក្តិពេញ

# យើញព្រះរាជបណ្ណាល័យ សាលាបាឡី នឹងព្រះបរមរាជវាំង

យើញទន្លេ ១ កន្លែង



ផែនទីក្រុងភ្នំពេញ ថតដោយអាកាសយាន

# អំពីទស្សនាការកាន់ផែនទីក្រុមសុរិយោដី ក្រុងភ្នំពេញ

កាលពីថ្ងៃ ២០ ខែឧសភា ឆ្នាំ ១៩៣៤ លោកអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ បាននាំគេនដំណើរដល់ពួកព្រះសង្ឃ ជាអាចារ្យក្នុងសាលាបាលីជាន់ខ្ពស់ ព្រមទាំងសិស្សក្នុងសាលាទាំងអស់ នឹងពួកព្រះសង្ឃជាក្រុមជំនុំប្រែព្រះត្រៃបិដក នឹងពួកព្រះសង្ឃជាសិស្ស មកពីស្រុកលាវ នឹងស្រុកកូសាំងស៊ីន ឲ្យនិមន្តទៅមើលប្រដាប់ធ្វើការនៅកន្លែងផែនទី នឹង ស្តាប់សេចក្តីពន្យល់អំពីកិច្ចការក្នុងក្រសួងនោះ ដោយមានសេចក្តីអនុញ្ញាតអំពីរដ្ឋការ ។

នៅវេលារសៀលម៉ោង ៤ ក្នុងថ្ងៃនោះ ព្រះសង្ឃទាំងអស់បាននិមន្តទៅជួបជុំនៅកន្លែង ផែនទីនោះ លោកអគ្គលេខាធិការក៏អញ្ជើញទៅដែរ ទើបលោកចាងហ្វាងក្នុងក្រសួងផែន ទីនោះ បានបាត់ការឡុតពន្យល់ពីរបៀបធ្វើផែនទីដល់ព្រះសង្ឃគ្រប់អង្គថា:

ដែលហៅថាផែនទី ឬហាត់ដោ គឺរបស់ដែលជាតំណាងភូមិស្ថាន ១ កន្លែង ៗ ដែលគេ ចង់ដឹងចង់ស្គាល់ ។

ក្នុងសម័យសព្វថ្ងៃនេះ ដែលនឹងគូរផែនទីដី មុនដំបូងគេតាំងថតទីដីដោយប្រដាប់ថតនឹង អាកាសយាន (យន្តហោះ) ប៉ុន្តែរូបថតដែលថតដោយអាកាសយាននោះ ឃើញភាពភូមិស្ថាន មិនច្បាស់លាស់ល្អឡើយ ព្រោះអាកាសយានដែលនៅលើអាកាសនោះនៅមិននឹង ។ ដោយ ហេតុដូច្នេះដែលគេនឹងយករូបថតដោយអាកាសយានមកប្រើការឲ្យបានត្រឹមត្រូវល្អនោះ គេត្រូវ យករូបថតនោះ មកថតជាថ្មីម្តងទៀតដោយប្រដាប់ថតដែលរៀបចំតាមក្បួនវិទ្យាសាស្ត្រ គឺប្រដាប់ ថតនេះអាចផ្លាស់ប្រែផ្ទៀងផ្ទាត់នូវរូបភាពរបស់រូបថតដែលប្រែប្រួលមិនទៀងទាត់មិនត្រឹមត្រូវល្អ ដោយហេតុដែលអាកាសយាននៅមិននឹងនោះ ឲ្យត្រឡប់ទៅជាទៀងទាត់ត្រឹមត្រូវល្អឡើងវិញ ។ លុះធ្វើដូច្នេះហើយក៏បានទៅជារូបថតតួច ១ យ៉ាងត្រឹមត្រូវពិតប្រាកដតាមបែបស្ថានដីដែលគេ បានវាស់ផ្ទៀងផ្ទាត់មើល ។ លុះដល់បានជាផែនទីដីយ៉ាងច្បាស់លាស់ដែលគេបោះពុម្ពដោយ ក្រដាសសម្រាប់ថតស្រេចហើយ ទើបបាត់ឲ្យភ្នាក់ងារចេញទៅផ្ទៀងផ្ទាត់ពិនិត្យដល់កន្លែងដី ទៀត ហើយបញ្ជូនរូបថតនោះត្រឡប់មកក្រសួងផែនទីនៅក្រុងភ្នំពេញវិញ លុះឃើញថាត្រឹម ត្រូវពិតប្រាកដហើយ ទើបចាងហ្វាងក្រសួងបាត់ឲ្យជាងគំនូរគូរផែនទីនោះ ដោយក្រដាសភ្លឺមើល ធ្លុះឃើញទៅម្ខាង ព្រោះក្រដាសសម្រាប់ថតនោះមិនជាប់ល្អហើយទុកមិនបានយូរ ឯក្រដាស ភ្លឺនោះជាប់ហើយទុកក៏បានយូរ ហើយគេអាចនឹងចម្លងតទៅទៀតជាប៉ុន្មានសន្លឹកក៏បាន តាម សេចក្តីប្រាថ្នា ។



ដែលឃើញជាក្រឡា ៗ គឺស្រែនីមួយ ៗ

នៅខាងឆ្វេង ឃើញផ្លូវបររថយន្ត




ផែនទីវត្តព្រៃវែង ឃើញស្រែនិងផ្លូវ

ប្រយោជន៍របស់ការនេះ គឺថាកាលណាដែនទីស្រែមួយ ៗ គេបានគូររួចស្រេចហើយ ក៏នឹងបានជាសំអាងដល់ម្ចាស់ស្រែយ៉ាងមាំមួន ហើយតទៅមុខ គ្មានអ្នកឯណានឹងអាចបន្លំបាត់យកដីខ្លះទៅបានឡើយ ។

លំដាប់អំពីនេះទៅទៀត លោកបាងហ្សាំងបានចាត់ឲ្យនាំព្រះសង្ឃទៅមើលគ្រឿងប្រដាប់ផ្សេង ៗ មានប្រដាប់សម្រាប់ថត, ប្រដាប់សម្រាប់ព្រិតរូបថត នឹងប្រដាប់គូរដែនទីស្រែជាដើម គ្រឿងប្រដាប់ទាំងនោះសុទ្ធតែប្រើដោយកំឡាំងភ្លើងអគ្គិស្សនីទាំងអស់ ។

យើងដែលបានទៅឃើញច្បាស់នឹងភ្នែក អំពីកិច្ចការដែលធ្វើក្នុងក្រសួងដែនទីនោះ សឹងមានសេចក្ដីស្ងើចអស្ចារ្យក្នុងចិត្តដោយក្រៃលែង ព្រោះពុំធ្លាប់ដែលបានឃើញសោះឡើយ វេលាដែលបានឃើញហើយនាំចណ្ដាលឲ្យកើតមានជំនឿក្នុងចិត្តថា ការនេះសំដែងឲ្យឃើញច្បាស់លាស់ត្រឹមត្រូវល្អ តទៅមុខទៅ នឹងនាំឲ្យមានប្រយោជន៍ដល់អ្នកជាម្ចាស់ទីដី គឺថាឥតមានអ្នកណានឹងក្លែងបន្លំយកទីដីបានឡើយ ។ ទាំងការឈ្លោះប្រកែកកើតក្ដីក្ដាំ អំពីដណ្ដើមដីធ្លី ក៏នឹងស្ងប់រម្ងាប់ទៅបាន ។



កំពូលប្រាសាទគោបុរ ១ នៅជ្រុងឦសាណ សិងនៅក្នុងចំណោមប្រាសាទតាសោម ខាងទិស
ឯលិច ។



កំពូលប្រាសាទគោបុរ ១ នៅជ្រុងពាយ័ព្យ សិងនៅក្នុងចំណោមប្រាសាទតាសោម ខាងទិស
ឯលិច ។

ទស្សនាវដ្ដីនេះមានបំណងម្យ៉ាងដោយឡែកទៀត នឹងធ្វើឲ្យអ្នកមើលបានដឹងកិច្ចការផ្សេងៗ ដែលមានប្រយោជន៍ដល់ព្រះពុទ្ធសាសនា ឬដល់ពង្សាវតារ ក្នុងស្រុកខ្មែរ ។ ដោយហេតុនេះបានជាយើងស្រង់យកសេចក្ដីផ្សាយជូន អំពីបាឋកថា របស់លោកវិកទ័រគោលូបែហ្វ ជាអ្នកស្រាវជ្រាវប្រាសាទបុរាណដែលបានធ្វើការស្រាវជ្រាវជាច្រើនឆ្នាំ នៅទីប្រាសាទអង្គរ ហើយទើបនឹងរកឃើញទីក្រុងធំដំបូង របស់មហានគរដែលផ្សេងអំពីដែលធ្លាប់ជាប់ជឿរហូតមកដល់សព្វថ្ងៃថា នៅអង្គរធំមានប្រាសាទបាយ័ននៅជាកណ្ដាលនោះឡើយ គឺជាទីជុំវិញភ្នំបាខែងដូចសេចក្ដីដែលយើញនឹងឃើញតទៅនេះ ។

ស. ត.

បាឋកថាវិកទ័រគោលូបែហ្វ អំពីការស្រាវជ្រាវជាន់ក្រោយនៅទីអង្គរក្រម្ការ ជុំ-មៅ ស្រង់សេចក្ដីហើយប្រែជាភាសាខ្មែរ ។

គេបានជឿជាយូរឆ្នាំណាស់មកហើយថា ទីក្រុងអង្គរធំសព្វថ្ងៃព្រមទាំងកំផែងនឹងគូជុំវិញ នោះជាទីក្រុងដែលព្រះបាទ

យសោវរម័នទី ១ ទ្រង់កសាង ក្នុងពុទ្ធសករាជ ១៤០០ ឆ្នាំ (ចុងឆ្នាំ៩០០) ។ ការដែលបានពិនិត្យឃើញនូវប្រាសាទបាយ័ន មានក្បាច់របនាជាបែបព្រះពុទ្ធសាសនា ហើយនៅហោជាងមានរបនាជារូបលោកេស្វរពោធិសត្វនោះ នាំឱ្យកើតមានសេចក្តីសង្ស័យជាះច្រើន អំពីប្រាសាទនេះ មិនដឹងជាគេសាងឧទ្ទិស្សដល់សាសនាណា ព្រោះធ្លាប់បាននាំគ្នាជឿរហូតមកថា ជាប្រាសាទឧទ្ទិស្សថ្វាយព្រះឥស្វរ ហើយគេសន្និដ្ឋានថា គឺជាភ្នំកណ្តាល ដែលមានពោលក្នុងចារិកបូរាណ ។

ដែលគួរដំរូវថា ជាការបំរើនរបស់របនាខ្មែរ ឬរបនារបស់អង្គរនោះ ប្រាសាទបាយ័នព្រមទាំងទីឧបោសថតូច ៗ ដែលមានមុខមនុស្សនឹងបែរទៅខាត់ខ្វែងព្រមទាំងដណ្តើរក្នុងទីងងឹត ជាដំណាងនៃសម័យដែលជាហើនការ ។ ប្រាសាទនេះមិនត្រូវលើកទុកដាក់ថា ជាប្រាសាទសម្រាប់ទេវរាជ ដែលព្រះបាទយសោវរម័នទី ១ ទ្រង់កសាងជាកណ្តាលព្រះនគរនោះឡើយ ។ តើហេតុភេទនេះមានប្រការដូចម្តេចទៅ? ឯហេតុភេទនោះ គឺថាបើប្រាសាទបាយ័ន មិនមែនជាភ្នំកណ្តាលរបស់ស្តេច

យសោវរម័នទេ ការដែលទុកដាក់ក្រុងអង្គរធំ ជាក្រុងយសោ-ធរបុរីរបស់មហាក្សត្រនេះក៏គ្មានភស្តុតាងជាម៉ាំមួនដែរ ។ ក្នុងស្ថាននេះគួរគប្បីតែពិចារណារិះរកនូវបំណោទ្យថ្មី ១ ទៀត គឺបំណោទ្យយ៉ាងចាប់ចិត្តជាងរឿងរ៉ាវដទៃ ដែលពង្សាវតារខ្មែរ នឹងរឿងរ៉ាវក្សត្រខ្មែរ ពោទ្យមកដល់យើង គឺថាត្រូវរកឲ្យឃើញតើក្រុងអង្គរជាដំបូងដែលកសាងក្នុងសម័យចុងឆ្នាំ ៩០០ នោះនៅ ៗ ទីណា? ។

ភ្នំបាខែង៖ អស់លោកអស់អ្នកជាច្រើន ទំនងជានឹកឃើញនូវភ្នំតូច ១ នៅពីខាងត្បូងអង្គរធំ ដែលខ្លះបានឡើងជំរាលភ្នំនោះ ខ្លះឡើងដោយជើង ខ្លះឡើងដោយជិះដំរី, ហើយលុះឡើងទៅដល់កំពូលលើ ក្រឡេកមកក្រោមឃើញភាពភូមិឋានយ៉ាងល្អជាទីសប្បាយភ្នែកត្រង់វាលអង្គរ នឹងទន្លេសាប ។ គេអាចនឹងនិយាយបានថា ភាពភូមិឋាននេះបើទុកជាមិនមែនជាកន្លែងយ៉ាងសំខាន់តែ ១ សម្រាប់សប្បាយភ្នែករបស់ប្រាសាទបាខែង ក៏គង់ជាកន្លែងដែលសំខាន់ជាងទីឯទៀត ៗ ដែរ ។ នៅវេលាពេលថ្ងៃអស្ដង្គត គេតែងឡើងទៅលើភ្នំនោះ

ដើម្បីមើលវែរះលើប្រាសាទនគរវត្ត ហើយបំណែកប៉ែកខាងថ្ងៃលិចនោះ ឃើញរន្ទះពន្លឺចេញពីក្នុងទឹកបារាយខាងលិច ចេញពណ៌មាសក្រហមឆ្អៅ ។ គេសំឡឹងមើលនូវផ្ទៃមេឃពណ៌ខៀវដែលនៅជុំវិញដោយសប្បាយភ្នែក ហើយគេមានសេចក្តីត្រេកអរក្នុងចិត្តដោយមើលទៅស្គាល់ជួរភ្នំដងរែកពីចំងាយ ហើយក៏ឃើញនូវប្រាសាទបូរាណ ផុលផុសដេរដាសពាសពេញក្នុងព្រៃព្រឹក្សា ។

បំណែកឯទេវស្ថានដែលបាក់បែក ហើយដែលពួននៅពីខាងក្រោយស្មៅខ្ពស់ ៗ នៃភ្នំបាខែងនោះ ឃើញថា កាលពីដើមមិនជាមានប្រយោជន៍ប៉ុន្មានឡើយ បំពោះនឹងភ្នែកអ្នកដែលដើរមើល ។ បើយ៉ាងអើពើនឹងប្រាសាទនេះណាស់ក៏គ្រាន់តែពិនិត្យ ១ ស្របក់នូវចេតិយស្ថានដែលមានថ្នាក់ ដែលមានជណ្តើរចង្អៀតហើយចោត នៅជាកណ្តាលទេវស្ថានទាំងនេះ ចេតិយនេះនៅក្រោមម្លប់ឈើធំ ៗ ហើយកំពូលខាងលើកប់បាត់ទៅក្នុងគំនរថ្មភក់ដែលគរពូនកំពូលខាងលើឥតសណ្តាប់ធ្នាប់ ។ តើប្រាសាទដែលមានគំនរថ្មគរគ្របសង្កត់ ១ ភាគនេះ ជាប្រា-

សាទអ៊ីកាលដាក់ដើម៖ សេចក្ដីនេះគ្មានអ្នកណាមួយដឹងជាប្រា-កដឡើយ ប៉ុន្តែហាក់ដូចជាច្បាស់សេចក្ដីថា ប្រាសាទនេះសាងសម្រាប់ដំកល់លិង្គ ដែលព្រះបាទយសោវរម័នបានសាងឡើង ព្រោះមានភស្តុតាងបញ្ជាក់ដោយអក្សរចារិកឆ្លាក់ភ្ជាប់នៅលើទ្វារ ១ របស់ប្រាសាទនោះ ។

កាលពីឆ្នាំ ១៩២៣ នៅវេលាដែលបានធ្វើការជញ្ជូនដុំថ្មចេញនោះ គេឃើញលេចនូវទីអាសនៈ៥ ឡើងលើចេតិយ-ស្ថាន ទីអាសនៈនោះធ្វើដោយថ្មភក់រៀបរៀងគ្នាជា ៥ មុម ១ កណ្ដាល ៤ សងខាងជុំវិញ មានសណ្ឋានដូចគ្នានឹងប្រាសាទតាកែវ នឹងប្រាសាទប្រែរូប ។ គឺជាការរកឃើញយ៉ាងសំខាន់ ។ ក្បាច់ចំឡាក់យ៉ាងល្អិតផ្ចិតផ្ចង់ដែលជាប់នៅហោជាង នៅសុំទ្វារនឹងនៅជញ្ជាំង នាំឲ្យយល់ឃើញនូវជំនឿយ៉ាងខ្ពស់របស់ប្រាសាទនេះក្នុងក្បួនរបនា ហើយនាំឲ្យយល់ម្យ៉ាងទៀត ដោយមានចារិកបញ្ជាក់បន្ថែមថា ជាប្រាសាទដែលកសាងឡើងក្នុងរជ្ជកាលព្រះបាទយសោវរម័នទី ១ ដែលជាអ្នកកសាងក្រុងអង្គរ។

ដែលផញ្ញូនគាស់កកាយជាថ្មី កាលពីឆ្នាំ ១៩២៩ នោះឡើយ មានជាសំអាងយ៉ាងមាំដល់អ្នកស្រាវជ្រាវប្រាសាទបុរាណ ដែលបានទាមទារកន្លែងទីយ៉ាងខ្ពស់ ១ ឲ្យភ្នំបាខែង ព្រោះប្រាសាទនេះគេបានបញ្ចូលក្នុងថ្នាក់យ៉ាងទាប ក្នុងបណ្តាប្រាសាទបុរាណទាំងប៉ុន្មាន ។ ក្រៅអំពីស្នាមជានទ្វារប្រាសាទទាំង ៤ ទិសនៅលើកំពូលភ្នំនោះ លោកហង់រីមារឡាល់ បានរកឃើញជណ្តើរ ១ យ៉ាងល្អធ្វើដោយថ្មបាយក្រៀមនៅទីជំរាលភ្នំខាងជើង ដែលនៅល្អស្រួលបួលឥតបាក់បែក ហើយឯជណ្តើរសំរាប់ចេញទៅនោះមានរបនាជារូបរាជសីហ៍២ធំៗមានរូបភាពដូចគ្នានឹងដែលយើងតែងបានឃើញមកហើយនោះ ឈរចាំនៅទិសខាងកើតនៅជើងភ្នំនោះ ។

ប៉ុន្តែឃើញនៅមានច្រើន ហើយសំខាន់ជាងដែលបានឃើញហើយទៅទៀត ព្រោះការស្រាវជ្រាវគាស់កកាយរំលើងព្រឹក្សាលតាវល្លិចេញនាំឲ្យប្រទះឃើញ នៅក្បែរភ្នំបាខែងមានប្រាសាទតូច ៗ ជាច្រើនដែលធ្វើដោយឥដ្ឋ ក្នុងបណ្តាប្រាសាទទាំងនេះមានខ្លះឃើញមានលិង្គនៅឡើយ ប្រាសាទទាំងនេះរៀង

វាយជុំវិញតួភ្នំ ហើយមានទំនងបែបកសាងក្នុងសម័យជាមួយគ្នា នឹងតួប្រាសាទធំដែរ ។ សំអាងដែលមានឡើងដោយប្រាសាទតូចៗ ទាំងនេះ ជាការសំខាន់ល្អណាស់ ព្រោះនាំឲ្យបញ្ជាក់បានជាប្រាសាទភ្នំបាខែងនេះ កាលជាន់ស្ដេចដំបូងក្នុងក្រុងអង្គរ មិនមែនជាអាស្រមធម្មតា ដែលមានសភាពជាទេវស្ថានបន្ទាប់បន្សំអំពីទេវស្ថានសម្រាប់សាសនាក្នុងមហាបុរីឡើយ គឺបាខែងនេះជាតួទីក្រុងធំ ១ យ៉ាងស្ដុកស្ដម្ភ ។ ក្នុងវេលានេះឥតមានសេចក្ដីសង្ស័យអ្វីដូចកាលពីដើមឡើយ អំពីឈ្មោះ "ភ្នំកណ្ដាល" ដែលគេបានទុកដាក់ថាជាប្រាសាទបាយ័ននោះ ហើយតមកថាប្រាសាទវិមានអាកាស ។ ឯភ្នំកណ្ដាលនេះឯងច្បាស់ជាភ្នំបាខែងដោយពិតឥតសង្ស័យ ។

ជាដើមគឺទីក្រុងរបស់ព្រះបាទយសោវរម័ន បានចាប់កសាងក្នុងសម័យដែលស្រុកទេសកំពុងសំបូរ ហើយកិច្ចការខាងរដ្ឋប្រសាសនោបាយក៏ទូលាយស្រួល ដូចមានបញ្ជាក់ក្នុងសិលាចារិកពីឆ្នាំ ៩៤៧ ព.ស. ១៤៩១ ស្រាប់ ថាជាទីក្រុងរបស់

ប្រទេសដ៏ខ្លាំងពូកែ ១ ដែលមានព្រំប្រទល់ គឺស្រុកមន ស្រុកចិន នឹងស្រុកចម្ប៉ា ។

គ្មានអ្វីនាំមិនឲ្យជឿថា ចំនួនអ្នកស្រុកក្នុងក្រុងក្នុងជាន់នោះ មានដល់ ១ សែននាក់ ឬលើសពីនេះទៅទៀតឡើយ ។ ម្យ៉ាងវិញទៀតគួរតែយកចិត្តទុកដាក់ជឿថា ទីក្រុងក្នុងប្រទេសអាស៊ី តែងតែមានទំលាប់តាំងលើផ្ទៃដីយ៉ាងធំទូលាយ ។ តាមយោបល់របស់ខ្ញុំថា ទីក្រុងរបស់ព្រះបាទយសោវរម័ន នោះមិនមែននៅក្នុងទីណាក្រៅពីទីភូមិឋានយ៉ាងធំ ដែលនៅជុំវិញទីដីស្រែនោះឡើយ គឺជាផ្ទះសំបែងដែលធ្វើដោយគ្រឿងប្រដាប់ស្រាលៗ មានបែបលំនាំដូចជាផ្ទះសំបែងអ្នកសៀមរាប សព្វថ្ងៃនឹងក្នុងភូមិខ្មែរនៅក្រុងភ្នំពេញដូច្នោះឯង ។

ឯភស្តុតាងជាទីសំគាល់ថា ជាទីក្រុងសម្រាប់ស្តេចនោះ ខ្ញុំឃើញមានតែភាពផ្លូវថ្នល់ដែលមានបែកជាបួនមុខយ៉ាងធំចេញទៅគ្រប់ទិសទាំង ៤ ពីជើងភ្នំដែលជាទីប្រាសាទទេវរាជទៅ ។ ខ្ញុំបានទៅស្ទង់មើលបែបភាពផ្លូវទាំង ៤ នោះជាដំបូងហើយពិចារណាវាយសេចក្តីរកមើលផ្លូវដែលពីតកាលកសាងហើយនោះ ។

កាលពីឆ្នាំ ១៩៣១ ក្នុងពេលដែលខ្ញុំបានមកនៅក្នុងស្រុកខ្មែរបន្តិចនោះ ខ្ញុំបានយកសេចក្តីយល់ឃើញរបស់ខ្ញុំទៅស្ទង់មើលដល់ទីកន្លែង ហើយក៏បានគូរជាហាត់ដោរបស់ទីក្រុងចាស់នោះជាមួយនឹងលោកហង់រីមារហ្សាល់ជាអ្នកគ្រប់គ្រងប្រាសាទអង្គរ ។

ការថតដោយអាកាសយាន នាំឲ្យខ្ញុំពិនិត្យឃើញថាភ្នំបា-ខែងនោះមានស្រះនៅជុំវិញដោយច្រើនកន្លែង ដែលបាំងបាត់ដោយកន្លែងៗក្នុងព្រៃ ដោយហេតុនេះហើយបានជាបាត់ដានផ្លូវដែលចេញពីភ្នំទៅគ្រប់ទិសទាំង ៤ ។ ក្នុងស្ថាននេះឃើញថាសេចក្តីយល់ឃើញរបស់ខ្ញុំនោះ មានភស្តុតាងបញ្ជាក់ដោយជាក់លាក់ជាមុនដែលចាប់ផ្តើមការគាស់កកាយកាប់ឆ្ការព្រៃជុំវិញភ្នំនោះទៅទៀត ។ ក្នុងពេលធ្វើការជាដំបូងនោះមានរូបថតដោយអាកាសយានជួយការខ្ញុំជាយ៉ាងសំខាន់ណាស់ ។

ដោយមានពេលតិចណាស់ ក្នុងថ្ងៃនេះ ខ្ញុំមិនអាចនឹងអធិប្បាយជូនអស់លោកដោយល្អិតល្អន់ អំពីការដែលខ្ញុំគាស់កកាយកាប់ឆ្ការតាមសេចក្តីសំគាល់ក្នុងរូបថត ដោយអាកាស-

យាន ហើយដែលយកត្រីវស័យមកជាប្រធានរបស់ការនោះ ។ មានកន្លែងខ្លះព្រៃស្បាតពន់ពេកនោះធ្វើការយឺតពេកណាស់ ដោយចាត់ការកាប់ព្រៃនឹងកាត់វល្លិដែលនៅខាំងផ្លូវ ដើរទៅមិនរួច ជួនកាលត្រូវយកដំរីមកជួយបើកផ្លូវទៀតទើបបាន ។ បានចាប់កាប់ឆ្ការផ្លូវចំណែកខាងកើតជាមុន ហើយយើងដើរតាមគន្លងលំអាននោះរហូតលុះដល់មកមាត់ស្ទឹងសៀមរាប ក្នុងទីនោះយើងបានប្រទះប្រាសាទបូរាណ ១ ពួកទៀតនៅលើត្រើយខាងស្តាំនៃស្ទឹង ។ ក្នុងបណ្តាប្រាសាទបាក់បែកទាំងនោះ មានសល់ឃើញទេវស្ថានតូច ១ ដែលកសាងក្នុងសម័យជាមួយគ្នានឹងប្រាសាទបាខែង ហើយទេវរូបសម្រាប់គោរពនមស្សការក្នុងទីនោះ គឺជារូបទេវធីតា ១ ដែលមានបែបភាពសក្តិសមល្អ ។ រួចពីនោះទើបចាប់ចាត់ការកាប់ឆ្ការផ្លូវខាងទិសខាងលិច ខាងត្បូងនឹងខាងជើង ។ ក្នុងដើមខែឧកត្តូប ការរបស់យើងបានឈ្មោះថាជាស្រេចហើយ ។ គេបានឃើញស្គាល់ច្បាស់នៅផ្លូវធំ ៤ ទិសរបស់ទីក្រុងដំបូងនៃមហានគរ ហើយគេបានស្ទង់ថាក្នុងទីអង្គរធំនៅផ្លូវបន្ទាត់ពីបាខែងទៅពិមានអាកាស មានការងារ

ម្យ៉ាងដែលធ្វើដោយបូកបាយអរ ធ្វើឲ្យឃើញដោយជាក់ច្បាស់នូវគោលជាកន្លែងដែលផ្លូវខាងជើង ឆ្លងកាត់ប្រឡាយទឹកយ៉ាងតូប ១ ដែលមានរៀបថ្នាក់ជណ្ដើរដោយថ្មបាយក្រៀម ។

ការស្រាវជ្រាវដែលបានធ្វើក្នុងដំបន់ជិតខាងជាប់នឹងភ្នំបាខែងនោះក៏បានការជាយ៉ាងសំខាន់ណាស់ដែរ គឺថាក្រៅពីឃើញអ្វីៗឯទៀត នោះយើងថែមបានឃើញនៅជុំវិញភ្នំមានកំផែង ៤ ជ្រុងដែលមានសណ្ឋានជាលើកដីឲ្យខ្ពស់ឡើងហើយនៅទីបណ្ដោយតាមកំផែងនេះទៅឃើញមានស្រះនឹងគូជាច្រើន ។ ម្យ៉ាងវិញទៀតនៅប៉ែកជ្រុងខាងកើតវេលាដែលខ្ញុំបានស្រាវជ្រាវលើទីទួល ១ ជាមួយនឹងលោកមារក្ខាល់ជាមិត្រនឹងខ្ញុំនោះបានប្រទះឃើញប្រាសាទ ១ យ៉ាងសំខាន់ធ្វើដោយថ្មបាយក្រៀម នៅៗជ្រុងផ្លូវចាស់ដែលយើងបានដើរតាមជានដរាបដល់ស្ទឹងសៀមរាបកាលគ្រាមុននេះ ។ ក្នុងទីបំផុតខ្ញុំបានប្រទះឃើញរូបគោទិព្វ ៣ ដែលឈ្មោះថា នន្ទិន នៅលើកំពូលភ្នំបាខែងតាជើងប្រាសាទនោះឯង គោនេះបាក់បែកគ្រាំគ្រាណាស់ទៅហើយ តែនៅស្គាល់បានដោយច្បាស់លាស់ ។

ឯគោទាំង ៣ នេះ ត្រូវមានគោទី ៤ មួយទៀតយកមកបញ្ចូលផងទើបបានគ្រប់ ប៉ុន្តែជាអកុសលអ្វីខ្ញុំរកស្នាមជាន់គោទី ៤ នោះមិនឃើញសោះ ។ ឯគោទាំង ៤ ត្រូវឈមមុខទៅទិសទាំង ៤ ទិស ១ ម្នាក់ ៗ តាមជណ្តើរទាំង ៤ ដែលឡើងឆ្ពោះទៅប្រាសាទលិង្គរបស់ស្តេច ។ រឿងដែលគេធ្វើដំណាងនេះជាការងាយយល់ច្បាស់ណាស់ដោយគេដឹងថា គោនន្ទិនេះជាពាហណរបស់ព្រះសិវ ហើយឯទីអាសន៍កណ្តាលនោះមានទ្វារចេញទាំង ៤ ទិស ហើយព្រះដែលគង់នៅលើភ្នំបាខែងនោះ ត្រូវការគោជំនិះមិនតិចពី ៤ រូបឡើយ គឺក្នុង ១ ទិសពាហណ ១ ដើម្បីនឹងបានផ្សាយសេចក្តីឧបត្ថម្ភរបស់ព្រះអង្គទៅក្នុងគ្រប់ទិសឲ្យស្មើគ្នាក្នុងលោកដែលព្រះអង្គជាម្ចាស់លើ ។

ឯសេចក្តីអធិប្បាយដែលមានសំអាង អំពីភ្នំបាខែងនេះមិនអាចនឹងធ្វើឲ្យម្តេចឲ្យជាងនេះទៅទៀតឡើយ ឯភ្នំបាខែងនេះហើយជាភ្នំកណ្តាលដែលជាលំនៅជានិច្ចរបស់ព្រះម្ចាស់លោក ។

កាលពីឆ្នាំ ១៩៣៣ សេចក្តីព្យាយាមរបស់យើងបានឆ្ពោះទៅលើជាន់ដំណែលប្រាសាទបូរាណដែលនៅ ៗ ជើងភ្នំបា-

ខែង ។ ក្នុងវេលានោះយើងបានកត់សំគាល់ទុកនូវគ្រឿងផ្សេងៗ ដែលជាកំផែង ៤ ជ្រុងតាំងឡើងដោយលើកដីឲ្យខ្ពស់ ហើយ តាមបណ្ដោយកំផែងនោះ មានស្រះនឹងគូតាំងនៅដែលមានឈើ ស្មៅដុះគ្របសង្កត់ ។ ក្នុងវេលានេះត្រូវចាត់រកនូវគោបុរ ឬ ប្រាសាទក្លោងទ្វារ ប្រាសាទនេះត្រូវមាន៤ ហើយទីកន្លែងនោះ មានខ្សែកាត់ត្នុភ្នំបាខែងបង្អុលឲ្យឃើញស្រាប់ ។ បំណែកខាង ជ្រុងឯកើត បំណោទ្យនេះហាក់ដូចជាបានរកពើញហើយ ព្រោះកាលពីឆ្នាំទៅមិញ យើងបានគាស់កកាយឃើញបែបជាទី លានឬប៉មធ្វើដោយថ្មបាយក្រៀម ១ ដែលប្រហែលជាគេធ្វើជា ជឿនរបស់គោបុរដែលធ្វើដោយវត្ថុស្រាល ៗ ។

បំណែកខាងជ្រុងឯលិចនោះការស្ទង់របស់យើង ដែលបាន ធ្វើពីក្នុងខែសិបតម ១៩៣២ នាំឲ្យយើងដឹងថាមានដុំថ្មនៅក្នុង ដំបូក ១ ហើយដែលជាទីសំគាល់នូវផ្លូវធំទិសខាងលិច ។ ក្នុង ទីនោះហើយដែលជាទីត្រូវគាស់កកាយរក វេលានេះខ្ញុំទុកឲ្យ អស់លោកនឹកមើល អំពីសេចក្ដីត្រេកអររបស់អ្នករកប្រាសាទ បូរាណ ជាយ៉ាងដូចម្ដេច នៅវេលាដែលបានឃើញនូវស្នាម

ដានប្រាសាទលេចចេញមកពីក្នុងគន្លងចបកាប់ ។ តាមការពិតនោះប្រាសាទដែលលេចឡើងពីក្នុងឫសឈើនេះ មិនជាធំដុំនាំឲ្យផ្អើមផ្អើលនឹងក្លោងទ្វារនគរធំឡើយ ។ ប៉ុន្តែដែលជាសំខាន់នោះគឺថាជាតួគោបុរដោយពិតប្រាកដ ហើយគោបុរនោះត្រូវនៅលើទីកន្លែងនោះដោយពិតប្រាកដមែន ។

ក្នុងវេលានេះត្រូវពិនិត្យរកកន្លែងទ្វារពីរទៀត គឺទ្វារខាងត្បូងនិងទ្វារខាងជើង ។ ឯទ្វារខាងត្បូងនោះមិនយូរប៉ុន្មានក៏លេចចេញឡើងពីក្នុងដីដែលជាទួលទាប ៗ ដែលផ្សៀងផ្លាត់ដោយត្រីវិស័យ ហើយគាស់កកាយដោយការស្ទង់, ឯចំណែកទ្វារខាងជើងវិញ ការស្រាវជ្រាវរបស់យើងដរាបមកដល់ក្នុងពេលនេះជាការឥតផលឥតប្រយោជន៍នោះ ពិតមែនតែបានពិ-ចារណារិះគិតថា ទ្វារនេះប្រហែលជាគ្មានតាំងពីដើមមក ។ គេអាចនឹងសន្និដ្ឋានបានថា ទ្វារនេះធ្វើដោយឈើទាំងអស់ បានជាបាត់រកមិនឃើញទាំងមូល ហើយគេនឹងយល់បានម្យ៉ាងទៀតថា ថ្មដែលធ្វើជាគ្រឹះក្រោមទាំងប៉ុន្មាននោះពួកជាងដែលកសាងប្រាសាទព្រះបាទជយវរម័នទី ៧ បានជញ្ជូនយកទៅប្រើការក្នុង

ការកសាងនគរធំ ។ សេចក្ដីយល់ឃើញខាងក្រោយនេះហាក់ដូចជាពិតរបស់ខ្ញុំ ។ តែទោះដូចម្ដេចក៏ដោយ ការដែលបាត់រកមិនឃើញនូវគោបុរខាងជើងនៃភ្នំបាខែងក៏ដូចជាការបាត់ជណ្ដើរថ្មបាយក្រៀមនៅទិសខាងត្បូងដូច្នោះដែរ គឺឥតនាំឲ្យអាក់អ្វីដល់ការស្រាវជ្រាវរបស់យើងទេ ហើយគេអាចនឹងទុកដាក់បានជាពិតប្រាកដថា ភ្នំបាខែងកាលពីដើមមានកំផែងព័ទ្ធដោយជុំវិញ មានទ្វារមានដីលើកជាទំនប់ខ្ពស់ឡើង, មានគូនឹងមានស្រះ ។ កំផែងនេះមានប្រវែង ៦៥០ ម៉ែត្រពីខាងកើតទៅខាងលិច, ៤៤០ ម៉ែត្រពីខាងជើងទៅខាងត្បូង ។ កំផែងនេះទំនងជាធ្វើតាមបែបកំផែងក្នុងស្រុកឥណ្ឌៀ គឺថាមានរបងព័ទ្ធជុំវិញនឹងប្រាសាទតូច ៗ ធ្វើដោយឈើគ្រាំពាផង ។

បែបភាពរបស់ទីក្រុងចាស់នេះហាក់ដូចជារកឃើញហើយនៅមានការត្រិះរិះគិតអំពីបង្គងដែលតាំងនៅក្នុងអង្គរធំបណ្ដោយតាមផ្លូវថ្នល់ពីប្រាសាទបាយ័នទៅទ្វារខាងលិច ។ កាលពីឆ្នាំ ១៩៣២ ខ្ញុំបានកត់សំគាល់នូវប្រឡាយមានទឿនថ្នាក់ធ្វើដោយថ្មបាយក្រៀមដែលនៅ ៗ ជិតក្បែរផ្លូវថ្នល់ ហើយមានសណ្ឋាន

បណ្ដោយគ្នានឹងថ្លានេះទៅ ។ ការស្រាវជ្រាវរឿងរ៉ាវនេះមិនទាន់ស្រេចនៅឡើយទេ ប៉ុន្តែឯប្រទ្បាយនេះខំតាំងចិត្តទុកជាមុនថា កាលណាគាស់កកាយឲ្យលេចច្បាស់សព្វគ្រប់ឡើងនឹងធ្វើឲ្យយើងបានដឹងសេចក្ដីដោយជាក់លាក់អំពីទីក្រុងដែលហាក់ដូចជាបានតាំងព្រៃខាងជើងមិនរវល់ត្រូវការដល់គូខាងក្រៅឡើយ ។ យើងបានពិនិត្យឃើញថា ក្នុងក្រុងនគរធំមានផ្លូវថ្លាចាស់ៗមានផ្ទៃសំគាល់បានថាទាបជាងផ្ទៃប្រាសាទបាយ័ន ។ ផ្លូវទាំង ២ នេះ ១ ធំជាងហើយមានប្រយោជន៍ជាងផ្លូវធំនេះនៅបំត្រង់ខ្សែបន្ទាត់ភ្នំបាខែងពីខាងជើងទៅខាងត្បូង ។ នៅជិតក្បែរផ្លូវនេះហើយដែលគេយកបានត្បូងកណ្ដៀងស្រួកក្លែងយ៉ាងល្អ ១ គ្រាប់ទំងន់ ៤៩ ក្រាត់ កប់នៅក្នុងដីយ៉ាងជ្រៅ ត្បូងនេះមានស្នាមបរណៃយ៉ាងថ្លិតថ្លង់ ។

មានប្រយោជន៍យ៉ាងធំ ១ ទៀត ក្នុងការដែលបានរកឃើញស្ពាន ១ នៅខាងក្រោមផ្លូវថ្លាប្រាសាទបាយ័ន (ទ្វារខាងលិច) ។ ប៉ុន្តែក្នុងវេលានេះ យើងមិនទាន់ដឹងរូបមុខក្រសួងរបស់ស្ពាននេះក្នុងការស្រាវជ្រាវជាន់ក្រោយរបស់យើងទេ ព្រោះការ

ទើបតែនឹងបានចាប់ផ្ដើមធ្វើ ។ ដីផ្ទៃខាងក្រោមនគរធំនោះនៅមិនទាន់បានគាស់កកាយនៅឡើយ ការនេះត្រូវឲ្យមានសេចក្ដីព្យាយាមជាច្រើនឆ្នាំទើបអាចនឹងរើឡើងឲ្យឃើញបានសព្វគ្រប់ល្អ ។

ដែលនាំឲ្យសំគាល់ឃើញបានក្នុងវេលាដែលក្រឡេកមើលទៅនោះ គឺឃើញមានចំនួនស្រះនឹងត្រពាំងជាច្រើន ជួនកាលរៀបរៀងមានបែបត្រឹមត្រូវ, ជួនកាលរៀបរៀងត ៗ គ្នាជាជួរបណ្ដោយតាមផ្លូវធំ ៗ ដែលជាផ្លូវរបស់ទីក្រុងដែលបាត់បង់ទៅ ។ ចំនួនស្រះនឹងត្រពាំងទាំងអស់ជាង ៨០០ តែមានកន្លែងខ្លះស្រះនឹងត្រពាំងមានទំនងនាំឲ្យគិតឃើញថា ជាផ្លូវដែលជីកដោយខ្សែបន្ទាត់ ហើយសេចក្ដីដែលគិតឃើញនេះមានសំអាងដោយបែបភាពវត្ថុផ្សេង ៗ ដែលកប់នៅក្នុងស្មៅព្រៃជុំវិញដែលជាស្មៅព្រៃយ៉ាងអាក្រក់ញាតស្បាតប្រកបដោយបន្លា ហើយមានស្រមោចភ្លើងនៅការពារមិនឲ្យចូលទៅបាន ។ ក្នុងបណ្ដាវត្ថុទាំងនេះ ឃើញមានបំណែកជានក្បានបិននឹងខ្មែរ, មានក្បឿង, ត្បាល់ថ្មសម្រាប់កិន, គ្រឿងសម្រិទ្ធ, កែវបរណៃ, គ្រឿង

ដៃអាកៀម, ដុំដែកប្រែសចាប់ ដែលពុកផុយរលួយ ។ នៅកន្លែងខ្លះការស្ទង់ដីយ៉ាងប្រញាប់ ៗ ក្នុងជំរៅរវាង ១ ម.៥០ នាំឲ្យប្រទះឃើញផេះនឹងកំទេចធ្យូងតូច ៗ ជារបស់ដែលសល់នៅពីផ្ទះសម្បែងពីដើមដែលគេនៅក្នុងទីនោះ។ បើទុកជាឃើញវត្ថុបន្តិចបន្តួចដូច្នេះក្តី អ្នកស្រាវជ្រាវប្រាសាទបូរាណក៏យកចិត្តទុកដាក់, ឥតមានធ្វេសប្រហែសឡើយ ។ អំពីភ្លឺទាំងប៉ុន្មាន ដែលមានទំនងមិនសមគួរជាភ្លឺសម្រាប់ទីក្រុងរបស់ព្រះបាទយសោវរម័ន នោះ មានភ្លឺ ១ ដែលគួរឲ្យយើងពិនិត្យផ្ចិតផ្ចង់ ភ្លឺនោះតាំងចេញពីទីខាងកើតនគរវត្តជិតស្រះអមក្រុង ឆ្ពោះទៅខាងជើង ហើយកោងយ៉ាងស្រួលបន្តិចទៅរកផ្លូវដែលចេញពីភ្នំបាខែងទៅស្ទឹងសៀមរាប ។ ខ្ញុំមានសេចក្តីសង្ស័យថា ភ្លឺនេះប្រហែលជាកាលពីដើមជាព្រំខាងកើតនៃ «ក្រុងអង្គរធំដំបូង» នោះឯង ។

ប្រសិនបើការដែលពិនិត្យដល់ទីកន្លែងនេះញាំងខ្ញុំកុំឲ្យបោះបង់បង់ការស្រាវជ្រាវដែលចាប់ធ្វើហើយនេះ ខ្ញុំក៏គ្មានភ័ព្វនឹងបានរកឃើញនូវសិលាចារិក ១ កន្លែងឡើយ ។ ក្នុងវេលា

នេះ ខ្ញុំគ្រាន់តែមានសំអាងរបស់សិលាចារិកពីរច្បាប់ដែលលោក សឺដេស បានបេញផ្សាយក្នុង ប៊ុល្លឺតាំងរបស់សាលាបារាំង សែសនៅចុងបូពាប្រទេស ។

សិលាចារិកទី ១ មានរាយឈ្មោះមនុស្សដែលនៅធ្វើការ គោរពនូវព្រះស្រីយសោធរេស្វរ គឺលិង្គដែលព្រះបាទយសោវរម័ន កសាងនៅលើភ្នំបាខែងនោះ ។ ឯសិលាចារិក ១ ច្បាប់ ទៀតរៀបរាប់នូវកំណែនដែលជាប់បំពាក់ដល់ កម្រតេងជគត ភ្នំកណ្ដាល គឺព្រះដែលស្ថិតលើភ្នំកណ្ដាល ។

លោកសឺដេស បានសំគាល់ឃើញថាដូច្នេះ "លើភ្នំបា-ខែងនេះជាទីកណ្ដាលរបស់ក្រុងយសោធរបុរ ដែលព្រះបាទយ-សោវរម័នបានកសាងនៅចុងឆ្នាំ៩០០នោះគេយល់បានថាដូច្នេះ ហើយបានជាប្រាសាទដែលសាងនៅលើកំពូលភ្នំ មានឈ្មោះ ថា យសោធរេស្វរ ។

លោកសឺដេសបានអធិប្បាយរួចជាស្រេចហើយ អំពីរឿង ឈ្មោះប្រាសាទនេះ ដែលមានបែបដូចគ្នានឹងប្រាសាទឥន្ទ្រេស្វរ ដូច្នោះដែរ គឺជាឈ្មោះរបស់លិង្គស្ដេច ដែលព្រះបាទឥន្ទ្រវរម័ន

បានសាងឡើងក្នុងក្នុងរវាងពាក់កណ្ដាលឆ្នាំ ៩០០ នៅលើភ្នំដែលធ្វើឡើង ឈ្មោះថាបាក្ង នៅក្នុងដំបន់រលួសជិតក្រុងសៀមរាប ។ ម្យ៉ាងវិញទៀតអំពីបែបហាត់ដោដែលកសាងរបស់ប្រាសាទនេះ មានសណ្ឋានដូចគ្នាឥតប្រើលិះអំពីហាត់ដោប្រាសាទភ្នំបាខែង ។ តើនឹងត្រូវវិនិច្ឆ័យសេចក្ដីដូចម្ដេចអំពីបែបភាពប្រាសាទទាំង ២ ដែលដូចគ្នានេះ តាមយោបល់ខ្ញុំ ៗ ត្រូវវិនិច្ឆ័យថាប្រាសាទទាំង ២ នេះដំកល់នូវព្រះ ២ អង្គដែលមានសក្ដិស្មើគ្នាហើយដែលគេគោរពបូជាដូចគ្នាដែរ? គេអាចនឹងទុកដាក់ដូចជាពិតបានថា លិង្គជាទីគោរពនៅលើប្រាសាទបាក្ងនោះមិនមែនអ្វីក្រៅអំពីព្រះយ៉ាងធំបំផុតក្នុងទីក្រុងខ្មែរឡើយ គឺជាព្រះទេវរាជនោះឯង ។ គេអាចនឹងឧបមាបានដោយឥតខ្លាចខុសថា ព្រះដែលស្ថិតនៅលើភ្នំបាខែង នោះក៏ជាព្រះដែលធំបំផុតក្នុងបណ្ដាព្រះទាំងប៉ុន្មាន ដែលគេគោរពក្នុងនគរបស់ព្រះបាទយសោវរម៉ន ។ បើនឹងថាតាមពាក្យផ្សេងទៀត គឺជាព្រះទេវរាជ "ព្រះម្ចាស់លោក" នោះឯង ។

ដែលកសាងប្រាសាទថ្វាយព្រះនៅលើភ្នំនេះ  គឺព្រះបាទយសោវរ្ម័ន ទ្រង់ចាត់ការធ្វើដោយប្រាប់តាមទំនៀមបុរាណក្នុងស្រុកខ្មែរដូច្នោះ ព្រោះក្សត្រខ្មែរទាំងឡាយ តែងមានជំនឿដូចជាក្សត្របុរាណក្នុងក្រុងហ្វូណ័នដែរ ថាតាំងទីក្រុងនៅក្បែរជើងភ្នំជាការមានសួស្តីល្អ ។ ដោយហេតុនេះបានជាក្នុងគំនិតជាផ្លូវសាសនារបស់បណ្តាជាតិខ្មែរ  ថាភ្នំរបស់ព្រះបាទយសោវរ្ម័ន គឺយសោធរគិរីនោះ ជាដំណរមកអំពីភ្នំវត្តភូក្នុងស្រុកលាវ ហើយភ្នំវត្តភូនេះ  ជាដំណាមកអំពីបាភ្នំដែលជាវិមានរបស់ព្រះសិវគិរី តពីវេលាវិនាសក្រុងហ្វូណ័នមក ។

វិកទ័រគោលូបែហ្វ

# និធិកណ្ឌសូត្រ ក្នុងខុទ្ទកបាឋ

ឧកញ៉ាភក្តីរាជាយ៉ាំង ប្រែចេញពីបាឡីមកជាភាសាខ្មែរ

សេចក្ដីថា អនុមោទនាទាំងឡាយឯណាគឺព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា អនុមោទនាទាំងឡាយមាន ៣ ប្រការ គឺអនុមោទនាក្នុងសូត្រមាននិធិកណ្ឌសូត្រដ៏ប្រកបបំពោះដោយទានាទិសង្ឃជាដើម ក្នុងភត្តទាំងឡាយមានសង្ឃភត្តជាដើម ១ គឺអនុមោទនាក្នុងសូត្រមានមង្គលសូត្រជាដើម ក្នុងមង្គលទាំងឡាយមានគេហប្បវេសនមង្គលជាដើម ១ គឺអនុមោទនាក្នុងសូត្រមានតិរោកុឌ្ឌសូត្រជាដើម ក្នុងភត្តទាំងឡាយមានមតកភត្តជាដើម ១ ឯអនុមោទនាទាំងឡាយនោះ គឺបណ្ឌិតគប្បីដឹងដោយប្រការដូច្នេះថា បុរសកប់ទុកនូវកំណប់ទ្រព្យក្នុងទីទឹកជ្រៅដោយគិតថា នាកាលប្រយោជន៍កិច្ចកើតឡើងព្រមហើយ ទ្រព្យនេះនឹងមានដើម្បីប្រយោជន៍ដល់អញ ទ្រព្យនេះនឹងមានដើម្បីដោះនូវពាក្យអាក្រក់អំពីស្ដេចផង នូវសេចក្ដីបៀតបៀនអំពីចោរផង នូវបំណុលផង ក្នុងកាលមានបាយក្រផង ក្នុងសេចក្ដីអន្តរាយទាំងឡាយផង រីកំណប់នេះឃ្លាតអំពីទីកន្លែង

ទៅក៏មាន សេចក្តីបំណាំរបស់បុរសនោះវង្វេងភ្លេចទៅក៏មាន នាគទាំងឡាយប្រានបេញទៅក៏មាន យក្ខទាំងឡាយលួចយកនូវកំណប់នោះទៅក៏មាន ម្យ៉ាងវិញទៀត ញាតិទាំងឡាយសំអប់ស្រែងយកទៅក៏មាន បុគ្គលអ្នកខ្វល់ខ្វាយតិបអស់បុណ្យទៅក្នុងកាលឯណា ទ្រព្យទាំងពួងនេះក៏នឹងវិនាសទៅក្នុងកាលណោះឯង រីកំណប់គឺស្រ្តីក្តីគឺបុរសក្តីបានកប់ទុកដោយទានសីលសង្រ្គម ទូន្មាននូវឥន្ទ្រិយទើបឈ្មោះថាជាកំណប់ល្អ ម្យ៉ាងទៀតបានកប់ទុកក្នុងព្រះចេតិយ ឬក្នុងព្រះសង្ឃក្តីបុគ្គលក្តីក្នុងភ្ញៀវមាតាបិតា បងប្រុសស្រីក្តី ទើបឈ្មោះថាកំណប់ល្អប្រពៃណាស់ ឯកំណប់គឺបុណ្យនេះ បើបុគ្គលបានកប់ទុកល្អហើយ ឈ្មោះថាអជេយ្យោ រកបុគ្គលដទៃផ្ចាញ់មិនបាន អនុគាមិកោ តែងប្រព្រឹត្តជាប់តាមបុគ្គលជាម្ចាស់ ៗ តែងកាន់យកនូវកំណប់គឺបុណ្យនោះ ទៅក្នុងទីគឺខ្លួនលះបង់នូវរាងកាយហើយគប្បីទៅទាំងឡាយ កំណប់គឺបុណ្យនេះ អាចឲ្យនូវសេចក្តីប្រាថ្នាទាំងពួងដល់ទេវតានឹងមនុស្សទាំងឡាយ ទេវតានឹងមនុស្សទាំងឡាយប្រាថ្នាក្រៃពេកនូវផលឯណា ផលនោះ ៗ ទាំងពួងគឺទេវតានឹង

មនុស្សតែងបានដោយកំណាប់គឺបុណ្យនេះឯង   សភាពបុគ្គល មានសម្បុរល្អក្តី   មានសំឡេងពីរោះក្តី   មានទ្រង់ទ្រាយល្អក្តី មានរូបឆោមល្អក្តី   ភាវនៃបុគ្គលជាធំក្តី   ភាវបុគ្គលមាន បរិវារក្តី   គុណសម្បត្តិទាំងពួងមានសម្បុរល្អជាដើម   គឺទេវតា នឹងមនុស្សតែងបានដោយបុញ្ញនិធិកំណាប់គឺបុណ្យនេះ   ភាវនៃ បុគ្គលជាស្តេចក្នុងប្រទេសក្តី   ភាវនៃបុគ្គលជាស្តេចចក្រពត្តិក្នុង ទ្វីប ១ ក្តី   ភាវនៃបុគ្គលជាស្តេចចក្រពត្តិក្នុងទ្វីបទាំង ៤ ជាសុខ ជាទីសំឡាញ់ក្តី   ភាវនៃបុគ្គលជាស្តេចនៃទេវតាក្នុងស្ថានទិព្វ ទាំងឡាយក្តី គុណសម្បត្តិមានស្តេចប្រទេសរាជជាដើមទាំងពួង គឺទេវតានឹងមនុស្សតែងបានដោយបុញ្ញនិធិ កំណាប់គឺបុណ្យនេះ សម្បត្តិជារបស់នៃមនុស្សឯណាក្តី   សេចក្តីដំរេកក្នុងទេវលោក ឯណាក្តី   សម្បត្តិគឺព្រះនិព្វានឯណាក្តី   គុណសម្បត្តិទាំងពួង នោះគឺទេវតានឹងមនុស្សតែងបានដោយបុញ្ញនិធិ   កំណាប់គឺ បុណ្យនេះ   ភាវនៃព្រះយោគាវចរកុលបុត្តកាលព្យាយាមដោយ យោនិសោមនសិការបំពេញនូវសមថកម្មដ្ឋាន   នឹងវិបស្សនាកម្មដ្ឋានបានស្មាត់ក្នុងវិជ្ជានឹងវិមុត្តិ ព្រោះអាស្រ័យនូវមិត្តសម្បទា គឺ

(កល្យាណមិត្ត) សេចក្តីស្អាតក្នុងវិជ្ជានឹងវិមុត្តិទាំងពួងនោះ គឺទេវតានឹងមនុស្សតែងបានដោយបុញ្ញនិធិ កំណាប់គឺបុណ្យនេះ បដិសម្ភិទា ៤ ឯណាក្តី វិមោក្ខ ៨ ឯណាក្តី សាវកបារមីក្តី បច្ចេកពោធិភូមិក្តី ពុទ្ធភូមិក្តី គុណសម្បត្តិទាំងពួងនេះគឺទេវតានឹងមនុស្សតែងបានដោយបុញ្ញនិធិកំណាប់គឺបុណ្យនេះឯង ។

បុញ្ញសម្បទាឯណា បុញ្ញសម្បទានេះ មានឫទ្ធិធំដូច្នេះ ហេតុដូច្នោះ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម ទ្រទ្រង់នូវព្យាយាមតែងពោលសរសើរនូវបុគ្គលអ្នកមានបុណ្យ បានធ្វើហើយក្នុងកាលមុន (គឺក្នុងជាតិដែលកន្លងមកហើយ) សេចក្តីក្នុងនិធិកណ្ឌសូត្រ ចប់បរិបូណ៌តែប៉ុណ្ណោះ ។

# សាសនប្រវត្តិ

ព្រះមហាពិទូរ ក្រសេម គន្ថរចនបណ្ឌិតនៅព្រះរាជបណ្ណាល័យ

រៀបរៀង

(ត)

## ព្រះចន្ទ្រ

ចន្ទ្រជាឈ្មោះនៃទេវបុត្រ ១ អង្គ ស្ថិតនៅឯចន្ទ្រលោក មានវិមានអណ្តែត ឬមានរថប្រាក់ទិមរសេះគូ មានពន្លឺរស្មីយ៉ាងស្រទន់ តែងរង្គាត់ទៅតាមចក្ររាសី ដើម្បីបំភ្លឺលោកក្នុងវេលារាត្រី មានគតិប្រហែលគ្នានឹងព្រះអាទិត្យ ។ ក្នុងរឿងមហាភារតនឹងរឿងរាមាយណថា ព្រះចន្ទ្រកើតអំពីសមុទ្រទឹកដោះ ក្នុងកាលដែលទេវតានឹងអសុរក្បូរសមុទ្រនោះយកថ្នាំទិព្វ គឺក្នុង ១ណដែលទេវតានឹងអសុរក្បូរទឹកសមុទ្រនោះទៅកើតបានជារបស់ផ្សេង ៗ គឺមេគោទិព្វ ១ ព្រះចន្ទ្រ ១ ទឹកពិសកាឡកូដ ១ ថ្នាំអមឫត ១ ។ មេគោទិព្វនោះអ្នកណាចង់បានអ្វី រឹតដោះវាទៅ នឹងបានរបស់នោះដូចប្រាថ្នា ពួកទេវតានាំយកទៅទុកឯឋានសួគ៌, ព្រះចន្ទ្របានជាម្ចាស់លោក ១, ពិសកាឡកូដ សត្វផ្សេង ៗ មាននាគ ពស់ ខ្ទួយ ក្អែបជាដើមក្រេបផឹកអស់ទៅ ហេតុនោះសត្វទាំងនេះទើបមានពិស្មខ្លាំង, ថ្នាំអមឫតពួកទេវតានាំគ្នាផឹករាល់ ៗ គ្នាទៅ ហេតុនោះទេវតាទើបមានអាយុវែងសល់អំពីនោះទេវតានាំយកទៅទុកឯព្រះចន្ទ្រ ហេតុនោះព្រះចន្ទ្រ

ទីបមានរស្មីត្រជាក់ស្រទន់ ។ អ្នកចង់ជ្រាបសេចក្ដីពិស្ដារបួរមើលក្នុងរឿងកុមារីតារ ។

បំណែកឯក្នុងគម្ពីរខាងពុទ្ធសាសនាថា ព្រះអាទិត្យ ១ ព្រះចន្ទ្រ ១ ព្រះរាហូ កាលដើមកើតជាមនុស្សនៅក្នុងមនុស្សលោកនេះជាបងប្អូនរួមឧទរជាមួយគ្នា បានធ្វើបុណ្យឲ្យទានមានប្រការផ្សេង ៗ ជាមួយគ្នា លុះស្លាប់អំពីមនុស្សលោកនេះទៅបងបង្អស់បានទៅកើតជាសុរិយទេវបុត្រ ប្អូនបន្ទាប់បានទៅកើតជាចន្ទ្រទេវបុត្រ ប្អូនបំផុតបានទៅកើតជារាហុអសុរិន្ទ្រ ដូច្នេះឃើញសេចក្ដីផ្សេងគ្នាឆ្ងាយ ។

ព្រះវរុណ

ព្រះវរុណ ខ្លះហៅព្រះពិរុណ ជាស្ដេចធំ ១ ជាអធិបតីលើនាគទាំងឡាយ មានះនាគជាពាហណៈ (តែក្នុងអាជានាជិយបរិត្តថា ព្រះវិរូបក្ខជាអធិបតីលើនាគទាំងឡាយ) ជាអ្នកទ្រង់នូវមហិទ្ធិឫទ្ធិដ៏មោះហិមាតែងបណ្ដាលឲ្យភ្លៀងធ្លាក់ចុះមកក្នុងមនុស្សលោករហូតចក្រវាឡ ដើម្បីស្រោចស្រង់សត្វលោកព្រមទាំងព្រឹក្សាលតាជាតិទាំងពួង ។

ព្រះកុវេរ

ក្នុងមហារាជ ៤, ព្រះកុវេរជាស្តេចធំ ១ អង្គ មាននាមដទៃទៀតថា ធនេស្វរ, ធនាធិប ព្រោះជាធំលើសម្បត្តិទាំងឡាយ ស្ថិតនៅឰដ៏ភ្នំព្រះសុមេរុរាជទិសខាងជើង ជាអធិបតីគ្រប់គ្រងពពួកយក្ខទាំងឡាយ នៅមានមហារាជ ៣ អង្គទៀត គឺព្រះធ-តរដ្ឋ ជាធំលើយក្ខទាំងឡាយ គ្រប់គ្រងភ្នំព្រះសុមេរុរាជទិសខាងកើត, ព្រះវិរុឡ្ហកជាធំលើកុម្ភណ្ឌទាំងឡាយ គ្រប់គ្រងភ្នំព្រះសុមេរុរាជទិសខាងត្បូង, ព្រះវិរូបក្ខ ជាធំលើនាគទាំងឡាយ គ្រប់គ្រងភ្នំព្រះសុមេរុរាជទិសខាងលិច ទាំង ៤ អង្គនេះសុទ្ធតែជាអ្នកទ្រង់នូវអានុភាពដ៏ពន្លឹក អាចនឹងប្រសិទ្ធពរឬនឹងដាក់បណ្តាសាឲ្យអ្នកឯណានីមួយក៏បាន ក្នុងមួយអង្គៗមានបុត្រច្រើនៗតែឈ្មោះឥន្ទ្រៗ ដូចគ្នាទាំងអស់ ទាំង ៤ អង្គ ។ មហារាជ ៣ អង្គ ខាងក្រោយមិនឃើញរាប់ចូលក្នុងគណទេវជំនុំផងដោយហេតុអ្វីមិនអាចដឹង ។

## ព្រះយម

ព្រះយម ឬព្រះយមរាជា ឬហៅព្រះធម្មរាជា ជាស្តេចនៃសេចក្តីស្លាប់ ជាបុត្រព្រះវិវស្វត (គឺព្រះអាទិត្យ) នឹងនាងសរន្យុ។ លក្ខណៈរាងរូបសំបើមមុខគួរខ្លាច គឺខ្លួនខៀវស្រងាត់ ភ្នែកឆេះជាភ្លើងពព្លាម ស្លៀកពាក់ពណ៌ក្រហមដូចឈាម មានគោជាពាហណា មានដំបងឈ្មោះយមទណ្ឌជាអាវុធ នឹងខ្សែអន្ទាក់សម្រាប់ទាក់វិញ្ញាណអ្នកដែលស្លាប់ យកទៅសួរយកចម្លើយ មានដំណែងជាតុលាការពិភាក្សាសួរយកចម្លើយនឹងធ្វើទោសទណ្ឌកម្មដល់ខ្មោចទាំងឡាយ ទើបមាននាមថា ព្រះធម្មរាជា គឺមនុស្សអ្នកដែលស្លាប់ហើយ នឹងទៅកើតជាអ្វីភ្លាមមិនបាន តោងទៅជាខ្មោចរួមនៅក្នុងយមលោកជាមុនសិន ព្រោះឈ្មោះនឹងអំពើកម្មល្អឬអាក្រក់ដែលខ្លួនបានធ្វើហើយ យមបាលបានត្រាទុកក្នុងបញ្ជីឈ្មោះអគ្រិសំធានា កាលទៅដល់យមលោកហើយ មានយមបាលម្នាក់ជាស្មេរ ឈ្មោះចិត្តគុប្ត ជាអ្នកកាន់បញ្ជីនេះនាំយកទៅសូត្រាយការៈ ស្មេរព្រះយមរាជ ខ្មោចឯណាបានធ្វើសេចក្តីល្អទុក ក៏

បញ្ជូនឲ្យទៅកើតឯឋានសួគ៌ ខ្មោចឯណាបានធ្វើសេចក្ដីអាក្រក់ទុក ក៏បញ្ជូនឲ្យទៅទទួលទោសឯឋាននរក ។ ន័យថា យមលោកនៅទិសក្រោម ព្រះយមជាយមលោកបាល គ្រប់គ្រងយមលោកនោះ មានផ្ទៃមួយគូ ក្នុងផ្ទៃមួយមានភ្នែក ៤ ប្រមុះត្រប៉ែតដូចគ្នាទាំងគូ សម្រាប់នៅចាំយមលោកនោះ ។ រឿងភាពយមលោកមានឆ្លាក់ទុកនៅប្រាសាទនគរវត្តនាព្រះរបៀងទី ១ ជាន់ខាងត្បូង ភាគខាងកើត មានរូបព្រះយមនឹងរណ្ដៅនរកឈ្មោះផ្សេង ៗ អ្នកប្រាថ្នាចង់ឃើញ ក៏ចូរទៅមើលនៅទីនោះចុះ ។

## ព្រះស្កន្ទ

ព្រះស្កន្ទនេះមាននាមសម្រាប់ហៅយ៉ាងដទៃទៀត គឺខន្ទកុមារ ស្វាមីកុមារ, កត្តិកេយ, ជាឱរសព្រះឥសូរ មានដំណែងជាមេទ័ពរបស់ទេវតា ជាអ្នកទ្រង់នូវអានុភាពដ៏មោះហិមា អ្នកណាធ្វើសេចក្ដីភក្ដីនឹងបំពេញតបៈឲ្យជាទីពេញព្រះហឫទ័យហើយ ក៏អាចនឹងប្រសិទ្ធិពរឲ្យតាមដែលត្រូវការ ។ ន័យ ១ ទៀតថា

ជាស្ដេចចោរកម្ម ឆ្លាសក្នុងវិធីធ្វើចោរកម្មយ៉ាងបំណាប់ បានសំ-ដែងគំរាឈ្មោះ "ចោរវិទ្យា" ដល់បុរសម្នាក់ឈ្មោះ យុគាចារ្យ ១ ពួកអ្នករកស៊ីលបលួច ប្រហែលជាបានបំណែះអំពីព្រះស្កន្ធនេះជាគ្រូដើមទេដឹង ? ។

ឱរសព្រះឥស្សូរនៅមាន ១ អង្គទៀតឈ្មោះ វិឃនេស (ដែលខ្មែរយើងហៅព្រះភក្ដ្រនេស) មានលក្ខណរូបកាយប្លែកអំពីទេវតាទាំងឡាយ គឺក្បាលជាក្បាលដំរី មានភ្លុកប្រមោយដូចដំរីសុទ្ធវិស័យ អវយវពីត្រឹមស្មាចុះក្រោមជាមនុស្ស ហេតុអ្វីបានជាមានអវយវបំប្លែកដូច្នេះ មានរឿងថា "កាលព្រះវិឃនេសនេះនៅកុមារ ព្រះបិតាត្រាស់ឲ្យរៀបពិធីសោកន្ដ (កោរសក់) និងត្រាស់ឲ្យអញ្ជើញពួកទេវតាទៅប្រជុំក្នុងពិធីនោះជាច្រើន បានបាត់ទេវទូត ១ ឲ្យទៅអញ្ជើញព្រះវិស្ណុ ខណៈនោះព្រះវិស្ណុកំពុងផ្ទំស្កល់ ទេវទូតចូលទៅផ្ទំស័ង្វដះ ដើម្បីនឹងបានទូលអញ្ជើញតាមដំណើរ ព្រះវិស្ណុតើនឡើងក៏ខ្ញាល់តឹង លាន់ព្រះឱង្ការថា កោរសក់អាកូនកំបុតក្បាលនោះឬ(១) គ្រានោះក្បាលព្រះវិឃនេសក៏កំបុតបាត់ទៅមែនតាមទិវាង្គារ ព្រះឥស្សូរត្រាស់ឲ្យរកក្បាលមក

តជាថ្មីក៏រកមិនបាន ទៅឃើញខ្មោចដំរីងាប់ ក៏កាត់យកមកត នឹងខ្លួនព្រះវិឃនេស ក៏ជាប់ហើយរស់ឡើងវិញ ព្រះវិឃនេស ទើបមានក្បាលជាក្បាលដំរី ខ្លួនជាទេវតាដូចរូបភាពដែលគេ សាងទុកនោះ លោកនេះក្នុងដំណាលសរសើរថា ជាអ្នកមាន ឫទ្ធានុភាពណាស់ដែរ គឺអាចនឹងលូកប្រមោយទៅបោសផ្កាយ លើផ្ទៃមេឃទម្លាក់ចុះមកដីទាំងអស់ក៏បាន អាចនឹងប្រសិទ្ធពរឲ្យ អ្នកឯណានីមួយឲ្យទៅជាអ្នកវិសេសដូចម្ដេចក៏បាន ហេតុនោះ ពួកអ្នកកាន់សាសនាព្រាហ្មណ ទើបចូលចិត្តសាងរូបលោកនេះ ទុកជាអនុស្សាវរីយ៍ច្រើនណាស់ តែគេមិនរាប់បញ្ចូលក្នុងគណ ទេពជុំនុំ ។ ឯរូបគណទេពជុំនុំនោះគេធ្វើជា ១ បែប គឺមួយយ៉ាង ធ្វើជារូបអង្គុយរៀងគ្នាទាំង ៩ អង្គ មួយយ៉ាងទៀតធ្វើជារូបគង់ លើពាហណផ្សេងគ្នាទាំង ៩ អង្គ អ្នកទៅមើលប្រាសាទបូរាណ បើគន់មើលនឹងឃើញរូបទេពជុំនុំនេះជាច្រើន ។

ទេវតាប្រចាំធាតុទាំង ៤

ទេវតាប្រចាំធាតុនោះក្នុងគំរាព្រាហ្មណ រាប់យកទេវតា ក្នុងគណទេពជុំនុំនោះខ្លះ បញ្ចូលថ្មីខ្លះ ដូចមានតទៅនេះ

ទេវតាប្រចាំធាតុទឹក

ព្រះមាឃវាន គឺព្រះឥន្រ្ទ ១ ព្រះវរុណ ឬព្រះពរុណ ១ ។

ទេវតាប្រចាំធាតុភ្លើង

ព្រះអគ្គិនី ១ ព្រះអាទិត្យ ១ ព្រះចន្រ្ទ ១ ។

ទេវតាប្រចាំធាតុខ្យល់

ព្រះវាយុ ឬព្រះពាយុ ១ ព្រះមារុត ១ ។

ទេវតាប្រចាំធាតុដី

ព្រះយម ១ ព្រះកាល ១ ។

បណ្តាទេវតាប្រចាំធាតុអំបាលនេះ ព្រះមាឃវានប្រសើរជាងគេទាំងអស់ ព្រោះជាអ្នកតែងជួយរំលត់សេចក្តីក្តៅក្រហាយ ឲ្យសេចក្តីត្រជាក់ដល់សត្វលោកទូទៅ ជាព្រះគុណាមួយយ៉ាង គ្មានឲ្យទោសដល់អ្នកណាសោះ ដូចមានប្រាកដក្នុងរឿងផ្សេងៗ សូម្បីខាងព្រះពុទ្ធសាសនាថា អ្នកណាមួយមានព្យាយាម ប្រព្រឹត្តសុចរិតយុត្តិធម៌ដោយមុតមាំ កាលដល់នូវក្តីទុក្ខក្រលំបាក ឬបាននូវក្តីក្តៅក្រហាយដោយ

ហេតុឯណានីមួយ រមែងក្តៅដល់ព្រះឥន្ទ្រ ។ តោងមកជួយសង្គ្រោះជាដរាប ។ ទេវតាក្រៅអំពីនេះឲ្យទាំងគុណទាំងទោស ដូចយ៉ាងព្រះអាទិត្យ ព្រះអគ្និ ជាអ្នកមានពន្លឺរស្មីក្តៅក្តាត់ អាចនឹងឆេះលំអិតលោកឲ្យវិនាសទៅក៏បាន តែព្រះមាយាវាន គឺមហាមេឃអ្នកទ្រទ្រង់នូវភ្លៀង អាចការពារទុកមិនឲ្យឆេះឡើងបាន. ព្រះវរុណក៏អាចនឹងបង្ហូរទឹកភ្លៀងឲ្យធ្លាក់ចុះមកលិចលង់លោកវិនាសទៅក៏បាន តែព្រះមាយាវានពោលគឺមហាមេឃទ្រង់ខាំងទឹកភ្លៀងទុក បែងឲ្យធ្លាក់ចុះមកតែល្មម លោកទើបមិនអន្តរាយ. ព្រះពាយុក៏អាចបក់ផាត់លោកឲ្យខ្ទេចខ្ទីទៅក៏បាន តែព្រះមាយាវានជាមហាមេឃទប់ទុកបាន ហេតុនោះព្រះមាយាវានទើបមាននាមថា សក្តោអ្នកអាចគ្រប់យ៉ាង ។

ពណ៌នាមកក្នុងគុណសម្បត្តិនៃទេវតាផ្សេង ៗ ក្នុងលទ្ធិព្រហ្មញ្ញក៏សម្មតិថាជាចប់តែប៉ុណ្ណោះ ។

# រឿងព្រេងខ្មែរ

## ១— រឿងមនុស្សពីរនាក់ ម្នាក់ខ្ពើមអាចម៍ជិះដំរី ម្នាក់ទៀតខ្ពើមក្ដីឡើងចុងត្នោត

អាម្នាក់ខ្ពើមក្ដីតាំងតែឡើងចុងត្នោត ហើយយកស្លឹកត្នោតចាក់ស្នុគ្រចាក់ធ្វើរូបគ្រប់សត្វទាំងអស់ ហើយគិតថា អញលក់ស្នុគ្រទាំងអស់នេះយកប្រាក់ទៅទិញសំលៀកបំពាក់នឹងទិញក្របីធ្វើស្រែ ហើយនឹងលោះខ្ញុំប្រើ បើកាលណាអញប្រើវាមិនបានអញនឹងវាយធាក់វា ថាតែប៉ុណ្ណោះក៏យកជើងធាក់ស្នុគ្រនោះ ធាក់មិនតិចតួចទាល់តែភ្លាត់ជើងធ្លាក់ពីលើចុងត្នោត តែបុរសនោះប្រវាចាប់ចុងត្នោតជាប់ ហើយដូចជាគេចងព្យួរនៅចុងត្នោតនោះ បុរសនោះភ័យណាស់មិនដឹងបើធ្វើឯណាអ្វីឡើយ ។

ក្នុងសម័យនោះ អាម្នាក់ទៀតដែលខ្ពើមអាចម៍ តាំងតែជិះនៅលើខ្នងដំរី ហើយក៏បរដំរីនោះទៅ លុះដល់ក្រោមដើមត្នោត អាខ្ពើមក្ដីក្រឡេកឃើញក៏ស្រែកហៅថា អើអ្នកជិះដំរីមេត្តាយកអាយុខ្ញុំផង អាជិះដំរីក្រឡេកទៅឃើញអាខ្ពើមក្ដីតោងជាងត្នោតព្យួរខ្លួននៅនោះហើយឆ្លើយតបទៅវិញថា មិនដឹងជួយដូចម្ដេចទេ អានៅលើចុងត្នោតថា អ្នកឯងបរដំរីមកពី

ខាងក្រោម ហើយអ្នកឯងឈរឡើងទាញជើងខ្ញុំ អាជិះដំរីឮ ហើយក៏បរដំរីទៅពីខាងក្រោម រួចតាំងក្រោកឈរលើខ្នងដំរី ឡើងដៃប្រវាចាប់ជើង កំពុងតែចាប់ជើង ដំរីនោះវាដួចជាគេអន្ទោកដេញវាៗដើរទៅ បុរសពីរនាក់ក៏នៅព្យួរតែកតោកនៅនោះ អាពីរខាងលើភ័យណាស់ពេក វាកអាចម៍ដាក់ក្បាលអាក្រោម អាទាំងពីរនាក់ភ័យណាស់មិនដឹងគិតធ្វើដូចម្តេច ក្នុងវេលានោះមានអាទំពែកទាំង ៤ នាក់ដើររកស៊ីកាន់ក្តី លុះដើរទៅដល់កន្លែងនោះ បុរសពីរនាក់ដែលកៅជាប់នៅឆាងត្នោតនោះស្រែកថា នែលោកទាំង ៤ នាក់ដែលដើរនោះមេត្តាយកអាយុខ្ញុំផង សុំខ្ញុំទៅនៅបម្រើធ្វើជាខ្ញុំ អាទំពែកទាំង ៤ ឮហើយក៏ងើបមើលទៅឃើញអាពីរនាក់នោះ ក៏ជំនុំគ្នាថា យើងទាំង ៤ នាក់តាំងពីដើររកស៊ីកាន់ក្តីប្លៃណាមិនដែលបានខ្ញុំប្រើសោះ ឥឡូវយើងគិតយកអាពីរនាក់នេះធ្វើជាខ្ញុំយើង គិតដូច្នោះហើយបុរសទាំង ៤ នាក់ដើរចូលទៅក្រោមដើមត្នោតក៏និយាយថា យើងមិនដឹងធ្វើម្តេចទេ អាពីរនាក់ថា ឱលោកអើយលោកយកសំពត់លោកនោះបងនឹងកលោក ម្នាក់ ១ ជ្រុងហើយឈរទាញឲ្យតឹងពីក្រោម

ទុំ ៗ នឹងទំលាក់ខ្លួនទុំទៅលើសំពត់នោះ បុរស ៤ នាក់ស្លាប់ ហើយក៏ធ្វើតាមពាក្យអាពីរនាក់នោះស្រេចហើយ អាពីរនាក់ទំ-លាក់ខ្លួនមកបំសំពត់នោះ ទើបឯអាទំពែកទាំង ៤ ទង្គិចក្បាលគ្នាស្លាប់អស់ទៅ បុរសពីរនាក់ដឹងជាអា ៤ នាក់ស្លាប់ហើយ ភ័យណាស់ លុះយប់មានផ្ទះយាយចាស់ម្នាក់ប្ដីគាត់មិននៅទៅធ្វើបម្ការបាត់ អាបុរសពីរនាក់នាំគ្នាសែងខ្មោចអាទំពែកទាំង ៤ យកទៅដាក់នៅរានហាលផ្ទះនោះហើយនាំគ្នារត់បាត់ទៅ លុះព្រឹកឡើងយាយចាស់នោះភ្ញាក់ពីដេកឡើង ចេញទៅលុបមុខខាងក្រៅឃើញខ្មោចនោះហើយភ្ញាក់ព្រើតថា យើខ្មោចអ្វីមកស្លាប់នៅនេះ ថាហើយក៏អូសខ្មោចនោះមួយម្ដង ៗ យកទៅដាក់ក្នុងផ្ទះហើយយកខ្មោចនោះមករុំសំពត់ស រួចយកមកដាក់ខាងក្រៅ ហើយយំទួញថាប្ដីស្លាប់ដើរទៅរកអ្នកស្រុកឲ្យគេជួយយកទៅកប់ អ្នកស្រុកគេមកជួយយកខ្មោចនោះទៅកប់ ហើយត្រឡប់មកផ្ទះវិញ លុះស្អែកឡើងធ្វើដូចមុនទៀត ហើយប្រាប់គេថា ប្ដីខ្លួនត្រឡប់មកវិញ អ្នកស្រុកគេក៏ជួយទៀត លុះខានស្អែកទៀត

ធ្វើយ៉ាងនេះទៀត ទាល់តែគ្រប់ខ្មោចទាំង ៤ អ្នកស្រុកតាំងគិតគ្នាថា យើងទៅវាយខ្មោចនេះក្រែងមកទៀត គិតរួចហើយក៏នាំគ្នាទៅចាំនៅផ្លូវដែលយកខ្មោចនោះទៅកប់ លុះពេលព្រលប់តាប្ដីយាយនោះអស់អង្ករស៊ី ត្រឡប់មកពីបំការមកយកអង្ករស៊ីលីទាំងដឹងមួយផង មកដល់ប្រទះនឹងពួកអ្នកស្រុកដែលគេចាំនោះគេស្រែកថា កនយើងមកទៀតហើយ គេនាំគ្នាដេញវាយស្រែកថា ខ្ញុំទេ ខ្ញុំមកពីបំការទេ គេថា អាឯងស្លាប់ទៅហើយមកវិញ ៤-៥-ដង ឲ្យតែគេពិបាក គេវាយតានោះទាល់តែស្លាប់ទៅ ។

(ចប់)

## ២ — អំពីរឿងដែលបង្កើតមានហៅថាគេដោះចៅហ្វាយខេត្តកំពង់ស្វាយ

## ពីដើមឡើយគ្មានទេ គឺមានហៅតែចៅហ្វាយស្រុកទេ

កាលណោះមានមនុស្សម្នាក់តាំងសិល្ប នៅស្រុកកំពង់ធំ លុះតាំងសិល្បនៅយូរទៅពូកែណាស់ គ្មានអ្នកណានឹងច្បាំងឈ្នះសោះ ក៏តាំងខ្លួនធ្វើជាស្ដេចនៅកំពង់ស្វាយ ព្រះករុណាជាអម្ចាស់ទ្រង់មានព្រះបន្ទូលថា បើឈ្មោះណាចាប់អ្នកសិល្បនេះបាននឹងឲ្យធ្វើជាចៅហ្វាយស្រុកកំពង់ស្វាយ អ្នកណាក៏មិនហ៊ាននឹងមកចាប់អ្នកសិល្បនេះទេ ព្រោះសិល្បនេះពូកែណាស់ នោះមានតែមនុស្សម្នាក់ចូលទៅថ្វាយបង្គំទូល ព្រះករុណាជាអម្ចាស់សុំខ្លួនទៅចាប់អ្នកសិល្បនោះ ព្រះករុណាទ្រង់ព្រមហើយឲ្យមនុស្សនោះមកចាប់ មនុស្សនោះមានប្រាជ្ញាណាស់ ហើយមកដល់កំពង់ធំ យកកូនក្រមុំម្នាក់ស្អាតទៅជូនអ្នកសិល្បនោះធ្វើជាប្រពន្ធអ្នកសិល្បនោះអរណាស់ ហើយទទួលនាងនោះយកធ្វើជាប្រពន្ធទៅលុះយូរប្រហែលមួយឆ្នាំ មនុស្សនោះហៅកូនដែលឲ្យទៅអ្នកសិល្បនោះធ្វើប្រពន្ធមកប្រាប់ថា កូនឯងសួរប្ដីឯងតើតមត្រណមអ្វីខ្លះកូននោះឮដូច្នោះហើយទៅវិញ លុះពេលយប់តាំង

សួរសិល្បប្ដីថា លោកតមត្រណមអ្វីខ្លះ ប្ដីក៏មិនព្រមប្រាប់សោះ ប្រពន្ធនោះចេះតែសួររាល់ពេលប្ដីនោះក៏មិនព្រមប្រាប់ ប្រពន្ធក៏ថា បើលោកមិនប្រាប់ធ្វើម្ដេចនឹងដឹងថាលោកតមអ្វីខ្លះក្រែងលោខ្ញុំធ្វើអ្វីទៅមិនដឹងខុសត្រណមលោក អ្នកសិល្បដែលពូកែក៏ប្រាប់ទៅប្រពន្ធថា ត្រណមដែលតមនោះគឺតមកុំឲ្យតែវាយដែក ប្រពន្ធស្ដាប់ហើយក៏នៅស្ងៀមទៅ លុះយូរទៅអាពុកនោះសួរថា ប្ដីឯងតមដូចម្ដេចខ្លះ នាងនោះប្រាប់ថា តមតែកុំឲ្យវាយដែកអា-ពុកឮហើយនៅស្ងៀម លុះយូរបន្តិចទៅក៏ទៅសុំអ្នកសិល្បកូនប្រសានោះធ្វើរោងដំដែកថា ខ្ញុនក្រលំបាកគិតនឹងធ្វើរោងដំដែកមួយ អ្នកសិល្បនោះឮក៏ព្រមឲ្យអាពុកក្មេកនោះធ្វើរោងដំដែក អាពុកក្មេកនោះទៅតាំងរោងដំដែកមួយនៅភូមិស្លាកែតនៅខាងលិចវត្តកំពង់ធំសព្វថ្ងៃនេះ តាំងតែដំដែកនោះធ្វើជាប្រដាប់គ្រប់យ៉ាងមានកូនជាងនោះប្រហែល២០នាក់ លុះយូរៗទៅគាត់មកលេងនឹងកូនគាត់ហើយធ្វើជានិយាយថា ឯងមិននាំប្ដីឯងទៅលេងមើលអញដំដែកម្ដង កូននោះឮហើយក៏បបួលអ្នកសិល្បនោះៗក៏មិនព្រមទៅ ព្រោះខ្លួនតមមិនឲ្យវាយដែកនឹងដំដែក ប្រ-

ពន្ធបេះតែបប្ចូលប្រើនជងពេកក៏ព្រមទៅ ដល់ទៅដល់រោងជាំ ដែកនោះ អាពុកក្មេកឃើញកូនប្រសានោះមក ឲ្យកូនជាងដុត ភ្លើងគ្រប់កន្លែងស្នប់ទាំងអស់ ហើយត្រង់កន្លែងស្នប់ដែលគាត់ ធ្វើនោះគាត់ដាក់គ្រែ១ជិតនោះ ហើយនៅលើគ្រែគាត់ដាក់សុទ្ធ តែញញួដីដែក ហើយគាត់ហៅទៅកូនប្រសានោះថា លោក អញ្ជើញអង្គុយលើគ្រែខាងនេះ ក៏ទៅអង្គុយលើគ្រែតាមពាក្យ ដែលអាពុកក្មេកអញ្ជើញ អាពុកក្មេកតាំងតែដុតដែកនោះឲ្យ ឆេះក្រហម ហើយមើលទៅថាល្មមអ្នកសិល្បនោះភ្លេចខ្លួនហើយ តាំងយកដង្កាប់ចាប់ដែកនោះមក រួបរុញទៅខាងមុខអ្នកសិល្ប នោះគាត់ធ្វើជាស្រែកហៅលោកជួយផង អ្នកសិល្បនោះភ្លេច ខ្លួនក៏កញ្ចក់ញញួមកតាំងសំពងដែកនោះបាន១ម៉ាំង ទើបនឹក ឃើញថា អញខុសត្រូវណាមតើ រួបតាំប្រែពន្ធមកផ្ទះវិញ លុះ យូរទៅអាពុកនោះទៅសួរកូនថា ឥឡូវប្ដីឯងភេទដូចពីដើម ឬ ដូចម្ដេច កូនប្រាប់ថា ឥឡូវមិនដូចពីដើមទេ អាពុកស្ដាប់ហើយ ដឹងថា កូនប្រសាអស់ពូកែហើយ លុះយប់តាំងចូលទៅចាប់ អ្នកសិល្បកូនប្រសានោះចងជាប់ តាំយកទៅថ្វាយព្រះករុណា

ជាអំម្ចាស់ៗ ឲ្យយកទៅសម្លាប់ ហើយតាំងគាត់នោះឲ្យធ្វើជាចៅហ្វាយស្រុកកំពង់ស្វាយ តាំងងារជាឧកញ៉ាតេជោមិនមែនដាក់(ដៃជោ)នេះទេ គឺដាក់អក្សរ(តេជោ)បានជាដាក់យ៉ាងនេះ ព្រោះថាកើតពីដែកភ្លើងឆេះ គឺតាំងពីនោះមកបានជាមានហៅថា ឧកញ៉ាតេជោ ។ តែយូរឆ្នាំណាស់មកហើយ ។

### ៣ – រឿងអាឡេវ

មានមួយថ្ងៃនោះអាឡេវទៅចាំចម្ការជាមួយនឹងអាពុកវា លុះនៅយូរទៅអាឡេវនឹកចង់ស៊ីអន្សម ហើយក៏លាអាពុកទៅផ្ទះវិញ មកតាមផ្លូវអាឡេវទៅរកគេឲ្យកោរសក់អស់បេញ ហើយមកប្រាប់ម្ដាយវាថា ម៉ែ ឪគាត់ស្លាប់ទៅហើយតែអញបានរៀបធ្វើបុណ្យគាត់រួចទៅហើយ ដូច្នេះម៉ែឯងរៀបអន្សមឲ្យមកអញយកទៅប្រគេនលោកដើម្បីឲ្យបានមគ្គផលទៅដល់គាត់ ម្ដាយស្ដាប់ហើយក៏តាំងរៀបអន្សមជ្រូកដាក់ស្ងោរឆ្អិនយកទៅឲ្យអាឡេវ ៗ យកអន្សមនោះទៅបែកអាពុកវាស៊ីហើយនិយាយប្រាប់ទៅថា ម៉ែគាត់ស្លាប់ហើយ អញបានបួសមុខភ្លើងធ្វើបុណ្យគាត់រួចស្រេចបានត្រឡប់មកនេះ អាពុកក៏ជឿណាស់ហើយយំសោកកើតទុក្ខ កំពុងតែកើតទុក្ខអាឡេវនិយាយថា ឪកុំកើតទុក្ខអ្វីខ្ញុំមកឃើញមានក្រមុំម្នាក់ល្អស្អាត សុំខ្ញុំទៅដណ្ដឹងឲ្យ អាពុកស្ដាប់ហើយនឹកអរ ហើយបាត់កើតទុក្ខទៅរួចអំពីនោះអាឡេវតាំងទៅប្រាប់ម្ដាយទៀតថា ម៉ែកុំកើតទុក្ខឥខ្ញុំមកឃើញកំឡោះម្នាក់ស្អាតបាតចាំខ្ញុំទៅដណ្ដឹងឲ្យ ម្ដាយស្ដាប់ហើយនឹកអរ

ហើយបាត់កើតទុក្ខទៅ អាឡេវវ៉ាបញ្ឆោតអាពុកម្ដាយវ៉ាឲ្យយកគ្នា ហើយវ៉ាទៅប្រាប់អាពុកវ៉ាថា វ៉ាដណ្ដឹងបានហើយតែគេឲ្យការយប់ រួចវ៉ាទៅប្រាប់ម្ដាយវ៉ាវិញថា បានហើយតែគេឲ្យការយប់ លុះដល់យប់ម្ដាយនោះតាំងរៀបខ្លួនស្លៀកពាក់គ្រឿងប្រដាប់ ហើយវ៉ាទៅនាំអាពុកវ៉ាមក តែការនោះវ៉ាមិនឲ្យអុចភ្លើងទេ ឲ្យពន្លត់បង្កៀងទាំងអស់ វ៉ានាំអាពុកវ៉ាទៅដល់ហើយវ៉ាឲ្យចូលទៅក្នុងរួចវ៉ារត់បាត់ទៅ ប្ដីប្រពន្ធនោះតាំងនិយាយគ្នាប្រពន្ធនិយាយទៅនឹងប្ដីៗឮសំឡេងហើយនឹកសង្ស័យដូចជាសំ-ឡេងប្រពន្ធពីដើម ប្ដីនិយាយទៅប្រពន្ធវិញប្រពន្ធក៏នឹកសង្ស័យហើយប្ដីសួរទៅប្រពន្ធថា សំឡេងនេះដូចជាសំឡេងម៉ែអាឡេវប្រពន្ធឆ្លើយឡើងវិញថា ម៉ែអាឡេវថាមិនម៉ែអាឡេវ ប្រពន្ធសួរទៅប្ដីថា សំឡេងនេះដូចជាសំឡេងឪអាឡេវ ប្ដីឆ្លើយឡើងថាឪអាឡេវថាមិនឪអាឡេវ តាំងនាំគ្នាអុចបង្កៀងឡើងមើលទៅឃើញតែប្ដីប្រពន្ធឯងពីដើមវិញសោះ ហើយថា អាឡេវនេះបានហៅចំជាអាឡេវ រកអាឡេវអាឡេវរត់ទៅបាត់ ហេតុនេះបានជា

ពាក្យចាស់លោកថា កុំធ្វើគំនិតដូចអាឡេវ ព្រោះដូចនិទាន
មកនេះស្រាប់ ។

(មានពាក្យចាស់លោកនិទានថា)

ម៉ែនឹងបេះឲ្យគេកោត ម៉ែនឹងដោតឲ្យគេអាណិត ម៉ែនឹង
ហាំឲ្យមានបិត្ត ម៉ែនឹងគិតឲ្យបានការ ។ ម៉ែនឹងកាបឲ្យពេញ
វង្ស ម៉ែនឹងល្ងង់ឲ្យផុតថា ម៉ែនឹងប្រាជ្ញឲ្យបានការ ម៉ែនឹងគេថាឲ្យ
បានខ្នាត ។ ឲ្យរៀនអត់ឱនពាក្យដូនតា ឲ្យរៀនវិជ្ជាការនូវ
សិល្បសាស្ត្រ ឲ្យរៀនបិត្តល្អកុំប្រមាទ ឲ្យខំសង្វាតរកទ្រព្យធន ។

# បញ្ជីសៀវភៅដែលព្រះរាជបណ្ណាល័យបោះពុម្ពផ្សាយ

| | | |
|---|---|---|
| ព្រះត្រៃបិដក (បាឡីនិងប្រែ) ១ ចប់ចំនួន ១០០ សៀវភៅ. . . . | ថ្លៃ | ២៥០៛,១០ |
| ទស្សនាវដ្ដី. . . . . . . . . . . . . . . . . . . . . . . | — | ៤, ០០ |
| សាសនកិច្ចានុក្រម ១២ ខ្សែ . . . . . . . . . . . . . . . . | — | ០, ៥០ |
| ដំណាលពុទ្ធចេតិយ. . . . . . . . . . . . . . . . . . . . | ១ សៀវភៅ ថ្លៃ | ១, ៨០ |
| អំពីព្រះពុទ្ធសាសនា. . . . . . . . . . . . . . . . . . . | — | ១, ៥០ |
| កច្ចាយនូបត្ថម្ភកខ្សែ ១. . . . . . . . . . . . . . . . . | — | ១, ៣០ |
| " " ខ្សែ ២. . . . . . . . . . . . . . . . . . | — | ១, ៤០ |
| អភិធម្មត្ថសង្គហ. . . . . . . . . . . . . . . . . . . . | — | ០, ៩០ |
| មិលិន្ទបញ្ហាខ្សែ ១. . . . . . . . . . . . . . . . . . . | — | ០, ៩១ |
| " " ខ្សែ ២. . . . . . . . . . . . . . . . . . | — | ០, ៧០ |
| អរិយសច្ចកថា. . . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| វុត្តោទយ. . . . . . . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| ធម្មបទដ្ឋកថា. . . . . . . . . . . . . . . . . . . . . | — | ០, ៦៥ |
| សុរិយាត្រឡើងស័ក. . . . . . . . . . . . . . . . . . . | — | ០, ៦០ |
| សតិបដ្ឋានសុត្ត. . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| មរណានុស្សតិ. . . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| បញ្ញាសជាតក. . . . . . . . . . . . . . . . . . . . . | — | ០, ៥០ |
| គិហិបដិបត្តិ. . . . . . . . . . . . . . . . . . . . . | — | ០, ៤៥ |
| អំពីប្រាសាទនៅអង្គរ. . . . . . . . . . . . . . . . . . | — | ០, ៣៥ |
| មាតាបិតុឧបដ្ឋាន. . . . . . . . . . . . . . . . . . . | — | ០, ៣៥ |
| សិង្គាលោវាទសុត្ត. . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| ទេសចារិកថា. . . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សាមណេរវិន័យ. . . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| ជាតិមោក្ខសង្ខេប. . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| សេកសោមបណ្ឌិត. . . . . . . . . . . . . . . . . . . | — | ០, ៣០ |
| អំពីព្រះនិព្វាន. . . . . . . . . . . . . . . . . . . . | — | ០, ៦០ |
| ១០០ គាថា. . . . . . . . . . . . . . . . . . . . . . | — | ០, ២១ |

| | | |
|---|---|---|
| មនោបុព្វកថា. . . . . . . . . . . . . . . . . . . . . . . | ១ សៀវភៅថ្លៃ | ០, ១៥ |
| ពុទ្ធាភិទានុសាសនី. . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| កាលាមសុត្តនឹងបរាភវសុត្ត. . . . . . . . . . . . . . . . | — | ០, ១៥ |
| គតិលោកវៀ ១. . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ច្បាប់ថ្មី. . . . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ពាក្យសក្រិភ ទី ១. . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| " " ២. . . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| " " ៣. . . . . . . . . . . . . . . . . . . . . . . | — | ០, ១៥ |
| ញាណកថា. . . . . . . . . . . . . . . . . . . . . . . | - | ០, ១២ |
| សំវេជនិយធម៌. . . . . . . . . . . . . . . . . . . . . | — | ០, ១២ |
| សីមាវិនិច្ឆ័យ. . . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| អនត្តលក្ខណសុត្ត. . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| នាគោបមាទិកថា. . . . . . . . . . . . . . . . . . . . | — | ០, ០៨ |
| សេចក្តីដាស់តឿន. . . . . . . . . . . . . . . . . . . . | — | ០, ០៦ |
| សុភទោសកថា. . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| អក្កោសកថា. . . . . . . . . . . . . . . . . . . . . . | - | ០, ០៥ |
| ព្រះបង្គមកែវ. . . . . . . . . . . . . . . . . . . . . | — | ០, ១០ |
| ពុទ្ធប្រវត្តិ . . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| រឿង ៩ ពាន់ ១ យប់. . . . . . . . . . . . . . . . . . | — | ០, ០៤ |
| បាយាសិរាជញ្ញសុត្ត. . . . . . . . . . . . . . . . . . . | — | ០, ០៤ |
| គិរិមានន្ទសុត្ត. . . . . . . . . . . . . . . . . . . . . | — | ០, ០៧ |
| ពាក្យកាព្យក្រមអ្វី. . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| សប្បុរិសធម៌. . . . . . . . . . . . . . . . . . . . . . | — | ០, ០៥ |
| សារទេសនា. . . . . . . . . . . . . . . . . . . . . . | — | ០, ០៣ |
| អនុត្តរិយសុត្ត. . . . . . . . . . . . . . . . . . . . . | — | ០, ០២ |
| បុណ្ណោវាទសុត្ត. . . . . . . . . . . . . . . . . . . . | — | ០, ០២ |
| សត្តបរិត្តនឹងទ្វាទសបរិត្ត. . . . . . . . . . . . . . . . | — | ០, ៣៥ |
| ធម្មបទីប . . . . . . . . . . . . . . . . . . . . . . . | — | ០, ៤០ |
| ល្បើកទូន្មានកូនចៅចិន . . . . . . . . . . . . . . . . . | — | ០, ១៥ |

| | | |
|---|---|---|
| ជយវរម័ន ទី ៧ (អក្សរខ្មែរ) . . . . . . . . . . . . | ថ្លៃ | ០រ ២៥ |
| ជយវរម័ន ទី ៧ (អក្សរបារាំង) . . . . . . . . . . . . | — | ០, ៤៥ |
| អត្ថានុសាសនី . . . . . . . . . . . . . . . . . | — | ០, ១០ |
| វិជ្ជាចរណកថា . . . . . . . . . . . . . . . . . | — | ០, ៣៥ |

## រូបផ្តិតពុម្ពផ្សេង ៗ

| | | |
|---|---|---|
| រូបព្រះបាទសម្តេច ព្រះស៊ីសុវត្ថិមុនីវង្ស ក្រដាសរឹង . . . . . . . | ថ្លៃ | ០រ ២៥ |
| " " ក្រដាសទន់ . . . . . . . | — | ០, ០៦ |
| " ព្រះស៊ីសុវត្ថិ . . . . . . . . . . . . . . . . | — | ០, ២០ |
| " ព្រះចៅក្រុងកម្ពុជា ៤ ព្រះអង្គ . . . . . . . . . | — | ០, ១០ |
| រូបសម្តេចព្រះវររាជជននី . . . . . . . . . . . . . . . | — | ០, ០២ |
| ព្រះពុទ្ធរូបមានអគ្គសាវកអម (របនាពណ៌) . . . . . . . . . . | — | ០, ០៥ |
| ព្រះពុទ្ធរូប និព្វាន . . . . . . . . . . . . . . . . | — | ០, ១៥ |
| " ៣ ព្រះអង្គ . . . . . . . . . . . . . . . . . | — | ០, ០៥ |
| " ១ ព្រះអង្គ . . . . . . . . . . . . . . . . . | — | ០, ១៥ |
| រូបវេស្សន្តរជាតក ១៣ សន្លឹក ៗ សន្លឹក . . . . . . . . . . . . | — | ០, ១៦ |
| រូបព្រះពុទ្ធបាទ ១ សន្លឹក . . . . . . . . . . . . . . . | — | ០, ០៣ |
| រូបព្រះឥន្ទ្រហែសំពត់រឿងពុទ្ធបរិវត្តន៍ . . . . . . . . . . | — | ០, ០៣ |
| ព្រះរូបសម្តេចព្រះមហាសង្ឃរាជ (ទៀង) . . . . . . . . . . . | — | ០, ០៣ |
| ព្រះពុទ្ធរូបបាយ័ន ១៣ សន្លឹក ១ សន្លឹក . . . . . . . . . . . | - | ០, ០២ |
| រូបគំនូរ តេមិយជាតក ១៣ សន្លឹក . . . . . . . . . . . . . | — | ០, ១៥ |
| " មហាជនកជាតក ១៣ សន្លឹក . . . . . . . . . . . | — | ០, ១៥ |
| " សុវណ្ណសាមជាតក ១៣ " . . . . . . . . . . . | -- | ០, ១៥ |
| ប្រតិទិនឆ្នាំថ្មី . . . . . . . . . . . . . . . . . . | -- | ០, ១៥ |
| ព្រះពុទ្ធរូបមានព្រះឥន្ទ្រនិងព្រះព្រហ្មឈរអម . . . . . . . . . . | — | ០, ០៥ |

ÉCOLE FRANÇAISE
BIBLIOTHÈQUE